វិទ្យាស្ថានបណ្តុះបណ្តាល និង ស្រាវជ្រាវ
ដើម្បីអភិវឌ្ឍន៍កម្ពុជា (វបសអ)

# សង្ខេប
# របាយការណ៍អភិវឌ្ឍន៍
# ប្រចាំឆ្នាំ២០១០-១១



ការបោះពុម្ពផ្សាយរបស់វិទ្យាស្ថាន វបសអ

វិទ្យាស្ថានបណ្តុះបណ្តាល និង ស្រាវជ្រាវ
ដើម្បីអភិវឌ្ឍន៍កម្ពុជា (វបសអ)

# សង្ខេប
# របាយការណ៍អភិវឌ្ឍន៍
# ប្រចាំឆ្នាំ២០១០-១១

*Annual Development Review*
*2010 - 2011*

ភ្នំពេញ ខែមីនា ឆ្នាំ២០១១

ក្នុងលក្ខណៈជាវិទ្យាស្ថានឯករាជ្យមួយរបស់កម្ពុជាខាងការស្រាវជ្រាវពីគោលនយោបាយអភិវឌ្ឍន៍ CDRI មានបេសកកម្មចូលរួមចំណែកដល់ការអភិវឌ្ឍន៍ ប្រទេសកម្ពុជាប្រកបដោយចីរភាព និងការលើកកម្ពស់សុខុមាលភាពរបស់ប្រជាពលរដ្ឋកម្ពុជា តាមរយៈការស្រាវជ្រាវមានគុណភាពខ្ពស់ពីគោលនយោបាយអភិវឌ្ឍន៍ ការផ្សព្វផ្សាយ ចំណេះដឹង និងការកសាងសមត្ថភាព ។

CDRI ប្រឹងប្រែងបំពេញបេសកកម្មនេះ ដោយធ្វើការងារជាដៃគូជាមួយស្ថាប័នសាធារណៈ និងសង្គមស៊ីវិលកម្ពុជា ស្ថាប័នអភិវឌ្ឍន៍ក្នុងតំបន់ និងពិភពលោក និងដោយគោរពដល់សមត្ថភាពរបស់ប្រជាពលរដ្ឋ និងស្ថាប័នកម្ពុជា ចំណេះដឹង និងបទពិសោធន៍ក្នុងស្រុក ព្រមទាំងប្រវត្តិសាស្ត្រ និងវប្បធម៌របស់ប្រទេសកម្ពុជា ។

**© រក្សាសិទ្ធិឆ្នាំ២០១១ វិទ្យាស្ថានបណ្តុះបណ្តាល និង ស្រាវជ្រាវដើម្បីអភិវឌ្ឍន៍កម្ពុជា**

រក្សាសិទ្ធិគ្រប់យ៉ាង - គ្មានផ្នែកណាមួយនៃឯកសារនេះ ត្រូវបានចម្លងទុក ឬផ្សព្វផ្សាយតាមទម្រង់ និង តាមមធ្យោបាយផ្សេងៗ ដូចជា អេឡិចត្រូនិក យន្តកម្ម ថតចម្លង... ។ល។ ដោយគ្មានការអនុញ្ញាតជាលាយល័ក្ខណ៍អក្សរពីវិទ្យាស្ថានបណ្តុះបណ្តាល និង ស្រាវជ្រាវដើម្បីអភិវឌ្ឍន៍កម្ពុជាឡើយ ។

ISBN 978—99950—52-41-6

**សង្ខេបរបាយការណ៍អភិវឌ្ឍន៍ប្រចាំឆ្នាំ២០១០-២០១១**

*Annual Development Review 2010-11*

ភ្នំពេញ ខែមីនា ឆ្នាំ២០១១

**វិទ្យាស្ថានបណ្តុះបណ្តាល និង ស្រាវជ្រាវដើម្បីអភិវឌ្ឍន៍កម្ពុជា**

☞ អគារលេខ ៥៦ ផ្លូវលេខ ៣១៥ ខណ្ឌទួលគោក ភ្នំពេញ កម្ពុជា

✉ ប្រអប់សំបុត្រលេខ ៦២២ ភ្នំពេញ កម្ពុជា

☏ ទូរស័ព្ទ៖ (៨៥៥-២៣) ៨៨១-៣៨៤, ៨៨១-៧០១, ៨៨១-៩១៦, ៨៨៣-៦០៣

🖷 ទូរសារ៖ (៨៥៥-២៣) ៨៨០-៧៣៤

អ៊ីមែល៖ cdri@wicam.com.kh

គេហទំព័រ៖ http://www.cdri.org.kh

កែសម្រួល និងរចនាដោយ៖ ម៉េន-ច័ន្ទធីតា អ៊ុំ-ចាន់ថា និង យូ សិទ្ធីរិទ្ធ
បកប្រែដោយ៖ ខេង-សេង
បោះពុម្ពនៅប្រទេសកម្ពុជា ដោយរោងពុម្ព ស្រ៊ុន ហ៊ាង ភ្នំពេញ

# មាតិកា


បញ្ជីក្រាហ្វិក និងតារាង .................... 9
បញ្ជីអក្សរកាត់ .................... 11
សេចក្តីផ្តើម .................... 15

**ផ្នែកទី ១. សេដ្ឋកិច្ច ពាណិជ្ជកម្ម និង សហប្រតិបត្តិការក្នុងតំបន់** .................... 19

I. *ការពិនិត្យពីគោលនយោបាយឧស្សាហកម្មកម្ពុជា* .................... 21
១. រចនាសម្ព័ន្ធឧស្សាហកម្ម .................... 21
២. ស្ថានភាពបច្ចុប្បន្ននៃវិស័យឧស្សាហកម្ម .................... 23
២.១. កាត់ដេរ និងវាយនភ័ណ្ឌ .................... 23
២.២. សំណង់ និង រ៉ែ .................... 26
៣. ក្របខ័ណ្ឌគោលនយោបាយឧស្សាហកម្ម .................... 27
៣.១. គោលនយោបាយឧស្សាហកម្មទូទៅ .................... 27
៤. សេចក្តីសន្និដ្ឋាន .................... 32
ឯកសារយោង .................... 32

II. *ការវាយតម្លៃផលប៉ះពាល់នៃប្រទេសចិនលើការកាត់បន្ថយភាពក្រីក្រក្នុងមហាអនុតំបន់មេគង្គ៖ ករណីសិក្សានៅកម្ពុជា* .................... 35
១. សេចក្តីផ្តើម .................... 35
២. ទិដ្ឋភាពទូទៅនៃទំនាក់ទំនងវិនិយោគ
៣. របកគំហើញការសិក្សា .................... 38
៤. ...អនុសាសន៍គោលនយោបាយ .................... 40
ឯកសារយោង .................... 42

III. *ប្រើប្រាស់វិធីសាស្ត្រប៉ាន់ស្មានឥទ្ធិពលប្រព្រឹត្តិកម្ម (PSM) ដើម្បីទទួលបានក្រុមប្រៀបធៀប ២ ក្នុងអង្កេតមូលដ្ឋាន៖ ករណីគម្រោងបញ្ជូនចរន្តអគ្គិសនីនៅមហាអនុតំបន់មេគង្គ* .................... 45
១. សេចក្តីផ្តើម .................... 45
២. វិធីសាស្ត្រ .................... 45
៣. សូចនាករសេដ្ឋកិច្ច-សង្គមកិច្ចសំខាន់ៗ .................... 46
៤. ការផ្គូផ្គងគ្រួសារក្នុងក្រុមក្នុងគម្រោង និងក្រុ 48
៤.១. ជំហានក្នុងការប៉ាន់ស្មាន .................... 48
៤.២. ទិន្នន័យ និងការកំណត់គំរូ .................... 48
៤.៣. លទ្ធផលជាក់ស្តែង .................... 49
៥. សេចក្តីសន្និដ្ឋាន .................... 51
ឯកសារយោង .................... 52

IV. *ក្របខ័ណ្ឌគោលនយោបាយ និងស្ថានភាព ទេសន្តរប្រវេសន៍ពលកម្មនៅកម្ពុជា*.... 53

១. សេចក្តីផ្តើម.................................................................................. 53

២. ស្ថានភាពទេសន្តរប្រវេសន៍ពលកម្មនៅកម្ពុជា 53

៣. គោលនយោបាយទេសន្តរប្រវេសន៍ពលកម្ម 55

៤. ក្របខ័ណ្ឌច្បាប់គ្រប់គ្រងលើទេសន្តរប្រវេសន៍ពលកម្ម 55

៥. ការវាយតម្លៃរួមនៃគោលនយោបាយ 56

៦. សេចក្តីសន្និដ្ឋាន.................................................................................. 58

ឯកសារយោង.................................................................................. 59

**ផ្នែកទី ២. ភាពក្រីក្រ កសិកម្ម និង អភិវឌ្ឍន៍ជនបទ**..............................................61

V. *ជម្រើសគោលនយោបាយសម្រាប់ក្រុមជនងាយរងគ្រោះ៖ កំណើនប្រាក់ចំណូល និងការគាំពារសង្គម*.................................................................................. 63

១. សេចក្តីផ្តើម.................................................................................. 63

២. ទំនាក់ទំនងរវាងកំណើនសេដ្ឋកិច្ច ភាពក្រី 63

៣. អ្នកណាខ្លះជាជនងាយរងគ្រោះ ? ហេតុអ្វីបា 65

៣.១. ប្រជាជនជាង ២៥% រស់នៅក្រោមបន្ទាត់ភាពក្រីក្រ .................................... 65

៣.២. កិច្ចគាំពារសង្គមកិច្ច និងការកាត់បន្ថយភាពងាយរងគ្រោះ ............................ 67

៤. សេចក្តីសន្និដ្ឋាន ជម្រើសរ

សម្រាប់ការគាំពារសង្គមកិច្ចប្រកបដោយប្រសិទ្ធភាព............................................ 68

ឯកសារយោង.................................................................................. 69

VI. *និន្នាការប្រែប្រួលភាពក្រីក្ររយៈពេលបួនឆ្នាំក្នុង ៩ ភូមិនៅកម្ពុជា វិធីសាស្ត្រគិតលើទ្រព្យសម្បត្តិ*..................................................................................71

សេចក្តីសង្ខេប..................................................................................71

១. សេចក្តីផ្តើម..................................................................................71

២. ការសិក្សាពីមុនមក.................................................................................. 73

៣. ទិន្នន័យ និងវិធីសាស្ត្រ.................................................................................. 74

៤. លទ្ធផលខាងសេដ្ឋកិច្ចមាត្រសាស្ត្រ..................................................................................81

៥. សេចក្តីសន្និដ្ឋាន.................................................................................. 82

ឯកសារយោង.................................................................................. 84

VII. *សិទ្ធិកាន់កាប់ដីធ្លី និងផលិតភាពស្រូ* 87

១. សេចក្តីផ្តើម.................................................................................. 87

២. ការសិក្សាលើឯកសារពាក់ព័ន្ធ.................................................................................. 88

៣. ក្របខ័ណ្ឌជាក់ស្តែង និងទស្សនទាន.................................................................................. 89

៤. ទិន្នន័យ និងលទ្ធផលជាក់ស្តែង..................................................................................91

៥. សេចក្តីសន្និដ្ឋាន និងការពិភាក្សាគោលនយោបាយ 96

ឯកសារយោង .................................................................................. 98

**ផ្នែកទី ៣. ធនធានធម្មជាតិ និងបរិស្ថាន** ....................101

VIII. *ការសិក្សាប្រកបដោយការចូលរួម និងការស្រាវជ្រាវសកម្ម ដើម្បីពង្រឹងការគ្រប់គ្រងប្រព័ន្ធធារាសាស្ត្រ ក្នុងបរិបទនៃការគ្រប់គ្រងអាងស្ទឹង* ....................103
សេចក្ដីសង្ខេប....................103
១. កម្មវិធីអភិវឌ្ឍន៍សមត្ថភាពស្រាវជ្រាវ និងគ្រប់គ្រងធនធានទឹក ....................104
២. សមាសភាគធារាសាស្ត្ររូបវ័ន្ត....................104
២.១. បញ្ហាប្រឈម ....................104
២.២. សំណួរស្រាវជ្រាវ....................106
២.៣. គោលបំណង....................106
៣. ប្រវត្តិនៃការគ្រប់គ្រងធនធានទឹក....................106
៤. ច្បាប់ និងគោលនយោបាយស្ដីពីការគ្រប់គ្រងធនធានទឹក ....................108
៥. តម្លៃនៃចំណេះដឹងជលសាស្ត្រ ក្នុងការគ្រប់គ្រងអាងស្ទឹង ឬអាងទន្លេ ....................108
៦. វិធីសាស្ត្រថ្មី ដើម្បីគ្រប់គ្រងធនធានទឹក ក្នុងបរិបទនៃការកែលម្អធារាសាស្ត្ររូបវ័ន្ត និងសង្គម....................109
៧. វិធីសាស្ត្រសិក្សាស្រាវជ្រាវ....................110
៨. ករណីសិក្សា ....................110
៩ លទ្ធផលសំខាន់ៗ....................111
១០. សរុបសេចក្ដី និងអនុសាសន៍....................113
១០.១. សរុបសេចក្ដី....................113
១០.២. អនុសាសន៍....................114
ឯកសារយោង....................116

**ផ្នែកទី ៤. អភិបាលកិច្ចបែបប្រជាធិបតេយ្យ និងកំណែទម្រង់សាធារណៈ**....................119

IX. *គណនេយ្យភាពក្នុងប្រព័ន្ធគ្រប់គ្រងចំណាយសាធារណៈនៅថ្នាក់ក្រោមជាតិកម្ពុជា*....................121
១. អត្ថន័យនៃពាក្យគណនេយ្យភា
នៅថ្នាក់ក្រោមជាតិ ....................121
២. ប្រព័ន្ធគ្រប់គ្រងចំណាយសាធារណៈនៅ 122
២.១. ប្រព័ន្ធទូទៅរបស់ជាតិ....................122
២.២. ប្រព័ន្ធគ្រប់គ្រងចំណាយក្នុងក្របខ័ណ្ឌរបស់ គ.ជ.អ.ប ....................123
២.៣. ប្រព័ន្ធគម្រោងរបស់ដៃគូអភិវឌ្ឍន៍....................124
៣. គណនេយ្យភាព និងបរិវារកិច្ច....................125
៤. សេចក្ដីសង្ខេប....................126
ឯកសារយោង....................127

X. *ការសិក្សាវាយតម្លៃលើគម្រោងសាកល្បង ការិយាល័យច្រកចេញចូលតែមួយ និងការិយាល័យ ប្រជាពលរដ្ឋ* ....... 129
១. ការផ្តល់សេវានៅមូលដ្ឋានតាមប្រព័ន្ធដែលមានស្រាប់ ....... 129
២. ការិយាល័យច្រកចេញចូលតែមួយ ....... 130
៣. ការិយាល័យប្រជាពលរដ្ឋ ....... 132
៤. សេចក្តីសន្និដ្ឋាន និងអនុសាសន៍ ....... 133
ឯកសារយោង ....... 135

**ផ្នែកទី ៥. អភិវឌ្ឍន៍សង្គម** ....... 137

XI. *គ្រឿងលើកទឹកចិត្ត និង ការរក្សាបុគ្គលិកសុខាភិបាល នៅតំបន់ជនបទ និងតំបន់ជួបការលំបាកនៅកម្ពុជា* ....... 139
១. សេចក្តីផ្តើម ....... 139
២. វិធីសាស្ត្រ ....... 139
៣. លទ្ធផល ....... 142
៥. សេចក្តីសន្និដ្ឋាន ....... 146
ឯកសារយោង ....... 147

XII. *ការធ្វើអង្កេតចំណាយមហន្តរាយលើការថែទាំសុខភាពគ្រួសារ៖ លទ្ធផលពីអង្កេតសេដ្ឋកិច្ចសង្គមកិច្ចកម្ពុជាឆ្នាំ២០០៧* ....... 151
១. សេចក្តីផ្តើម ....... 151
២. ទស្សនទាន ....... 152
២.១. និយមន័យ ....... 152
២.២. ការវាស់វែងពីអត្រា និងភាពធ្ងន់ធ្ងរនៃការចំណាយមហន្តរាយ ....... 152
២.៣. របាយ - រង្វាស់កម្រិតបម្រែបម្រួល ....... 152
៤. លទ្ធផល ....... 153
៥. ការពិភាក្សា ....... 154
៦. សេចក្តីសន្និដ្ឋាន ....... 155
ឯកសារយោង ....... 156

*បញ្ជីឯកសារបោះពុម្ពផ្សាយរបស់វិទ្យាស្ថាន* CDRI ....... 159

# បញ្ជីក្រាហ្វិក និង តារាង


**I**

ក្រាហ្វិក ១៖ រចនាសម្ព័ន្ធនៃវិស័យកម្មន្តសាលកម្ម............. 22
ក្រាហ្វិក ២៖ ម្ចាស់កម្មសិទ្ធិរោងចក្រកាត់ដេរ គិតតាមប្រទេស 24
ក្រាហ្វិក ៣៖ ការនាំចេញទំនិញកម្ពុជា............................................ 25
ក្រាហ្វិក ៤៖ គោលដៅនាំចេញវាយនភ័ណ្ឌកម្ពុជា............. 26
ក្រាហ្វិក ៥៖ យុទ្ធសាស្ត្រចតុកោណ............................................... 28

តារាង ១៖ រចនាសម្ព័ន្ធឧស្សាហកម្មកម្ពុជា............................21
តារាង ២៖ រោងចក្រកាត់ដេរកម្ពុជា............................................... 24
តារាង ៣៖ គ្រឿងលើកទឹកចិត្តសម្រាប់អ្នកអភិវឌ្ឍ 29
តារាង ៤៖ ការវិវត្តគោលនយោបាយពាណិជ្ជកម្ម........... 30
តារាង ៥៖ ការប្រៀបធៀបច្បាប់វិនិយោគបរទេសក្នុងតំបន់ 31

**III**

តារាង ១៖ Probit Regression នៃគំរូតាងមួយមាន ៧ 49
តារាង ២៖ ការប្រៀបធៀបពីអថេរ 50
តារាង ៣៖ សង្ខេបចំនួនគ្រួសារដែលត្រូវរក្សាទុក និងជ 51

**IV**

ក្រាហ្វិក ១៖ ពលករចំណាកស្រុកកម្ពុជាត្រូ 64
ក្រាហ្វិក ២៖ ពលករចំណាកស្រុកកម្ពុជាត្រូ 64

**V**

ក្រាហ្វិក ១៖ កំណើន ផសស.............................................................. 64
ក្រាហ្វិក ២៖ ប្រភពកំណើនតាមវិស័យ............................................. 64
ក្រាហ្វិក ៣៖ របាយអត្រាគ្រួសារក្រីក្រ (គិតជា 66
ក្រាហ្វិក ៤៖ តំបន់អសន្តិសុខស្បៀង............................................... 66
ក្រាហ្វិក ៥៖ ចំណាយរដ្ឋាភិបាលលើការគាំពារសង្គមតាម 67

**VI**

តារាង ១៖ សន្ទស្សន៍ចំនួនជនក្រីក្រតាមតំបន់ ឆ្ន 75
តារាង ២៖ ស្ថិតិពិពណ៌នា.......................................................................... 76
តារាង ៣៖ សមាសភាគសំខាន់ៗ និង 77
តារាង ៤៖ វត្តមានភាពក្រីក្រ.................................................................. 78
តារាង ៥៖ ស្ថានភាពក្រីក្ររបស់គ្រួសារបែងចែកតា 79
តារាង ៦៖ ប្រជាសាស្ត្រ និងស្ថានភាពក្រីក្រនៃគ្រួសារ 80

តារាង ៧៖ ការប៉ាន់ស្មានដោយប្រើ Multin
និងមួយគ្រាៗ........................................................................................81
ឧបសម្ព័ន្ធ១៖ (មេគុណ)សំខាន់ៗនៃភូមិធ្វើអង្កេត.................... 83

VII
ក្រាហ្វិក ១៖ ក្របខ័ណ្ឌទស្សទាន
ប្រសិទ្ធភាពសេដ្ឋកិច្ច........................................................................................90

តារាង ១៖ ស្ថិតិអំពីក្បាលដី (តួលេខមធ្យម លើកលែង
តារាង ២៖ ស្ថិតិអំពីក្រុមគ្រួសារ........................................................ 93
តារាង ៣៖ ស្ថិតិអំពីភូមិ........................................................................ 94
តារាង ៤៖ ឯកសារបញ្ជាក់កម្មសិទ្ធិដី និងផលិតភាពស្រូវ
ឧបសម្ព័ន្ធ ១៖ ឯកសារបញ្ជាក់កម្មសិទ្ធិដី និងផលិតភាពស្រូវ

VII
ក្រាហ្វិក ១៖ អាងស្ទឹងជ្រៃបាក់ ក្នុងខេត្តកំពង់ឆ្នាំង................................................................ 111
ក្រាហ្វិក ២៖ អ៊ីដ្រូក្រាហ្វធារទឹកមធ្យមប្រចាំខែ នៃឆ្នាំ២០០៧ និង២០០៨................................112

VIII
តារាង ១៖ ស្ថាប័ន និងការទទួលខុសត្រូវ..............................113

XI
ក្រាហ្វិក ១៖ ការទស្សទាយពីការ
ង្កើតសេណារីយ៉ូពិសោធន៍គ្រាប់ផ្សេងៗ ........................................................144
ក្រាហ្វិក ២៖ ការទស្សទាយពីកា
រីយ៉ូពិសោធន៍គ្រាប់ផ្សេងៗ ..........................................................................145
ក្រាហ្វិក ៣៖ ការទស្សទាយពីការជ្រើសយកការងារ
តាមរយៈការបង្កើតសេណារីយ៉ូពិសោធន៍គ្រាប់ផ្សេងៗ .......................................146

តារាង ១៖ ចរិតលក្ខណៈការងារបានកំណត់សម្រាប់ គិលានុបដ្ឋាក និងឆ្មប ..............................140
តារាង ២៖ ចរិតលក្ខណៈការងារបានកំណត់សម្រាប់វេជ្ជបណ្ឌិត.............................................141

# បញ្ជីអក្សរកាត់

| | |
|---|---|
| ផសស | ផលិតផលក្នុងស្រុកសរុប |
| សបកទ | សហគមន៍កសិករប្រើប្រាស់ទឹក |
| កិច្ចព្រមព្រៀង Multi-Fibre | កិច្ចព្រមព្រៀងសាច់ក្រណាត់គ្រប់មុខ (Multi-Fibre Agreement) |
| គ.ជ.អ.ប-NCDD | គណៈកម្មាធិការជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ (The National Committee for Sub-National Democratic Development) |
| ACFTA | តំបន់ពាណិជ្ជកម្មសេរីអាស៊ាន-ចិន (ASEAN-China Free Trade Area) |
| ADB | ធនាគារអភិវឌ្ឍន៍អាស៊ី (Asian Development Bank) |
| AFTA | តំបន់ពាណិជ្ជកម្មសេរីអាស៊ាន (ASEAN Free Trade Area) |
| APO | អង្គការផលិតភាពអាស៊ី (Asian Productivity Organisation) |
| ASEAN | សមាគមប្រជាជាតិអាស៊ីអាគ្នេយ៍ (Association of Southeast Asian Nations) |
| ASYCUDA | ប្រព័ន្ធស្វ័យប្រវត្តិគ្រប់គ្រងទិន្នន័យគយ (Automated SYstem for CUstoms Data) |
| CDC | ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា (Council for the Development of Cambodia) |
| CDRI | វិទ្យាស្ថានបណ្តុះបណ្តាល និង ស្រាវជ្រាវដើម្បីអភិវឌ្ឍន៍កម្ពុជា (Cambodia Development Resource Institute) |
| CMDGs | គោលដៅអភិវឌ្ឍន៍សហស្សវត្សរ៍កម្ពុជា (Cambodia Millennium Development Goals) |
| CSES | អង្កេតសេដ្ឋកិច្ច-សង្គមកិច្ចកម្ពុជា (Cambodia Socio-Economic Survey) |
| DCE | ការពិសោធរកមើលជម្រើសផ្ទាល់ (Discrete Choice Experiment) |
| DIF | មូលនិធិសម្រាប់ក្រុង ស្រុក/ក្រុង (District Initiative Fund) |
| DO | ការិយាល័យប្រជាពលរដ្ឋ (District Ombudsmen) |
| EDC | អគ្គិសនីកម្ពុជា (Electricite du Cambodge) |
| EHP | កម្មវិធីប្រមូលផលដើមដៃ (Early Harvest Programme) |
| EIC | វិទ្យាស្ថានសេដ្ឋកិច្ចកម្ពុជា (Economic Institute of Cambodia) |
| FAO | អង្គការស្បៀងអាហារ និង កសិកម្ម |
| FDI | វិនិយោគផ្ទាល់ពីបរទេស (Foreign Direst Investment) |
| FGDs | ការពិភាក្សាតាមក្រុមស្នូល (Focus Group Discussions) |
| GHI | សន្ទស្សន៍ភាពអត់ឃ្លានសាកល (Global Hunger Index) |
| GMAC | សមាគមរោងចក្រកាត់ដេរនៅកម្ពុជា (Garment Manufacturers Association of Cambodia) |
| GMS | មហាអនុតំបន់មេគង្គ (Greater Mekong Sub-region) |

| | |
|---|---|
| GSP | ប្រព័ន្ធអនុគ្រោះទូទៅ (Generalized System of Preferences) |
| ICT | បច្ចេកវិទ្យាព័ត៌មាន និងទូរគមនាគមន៍ (Information and Communication Technology) |
| ID-Poor | កម្មវិធីអត្តសញ្ញាណកម្មគ្រួសារក្រីក្រ (Identification of Poor Households Programme) |
| IMF | មូលនិធិរូបិយវត្ថុអន្តរជាតិ (International Monetary Fund) |
| IOM | អង្គការអន្តរជាតិសម្រាប់ទេសន្តរប្រវេសន៍ (International Organisation for Migration) |
| IWRM | វិធីសាស្ត្រគ្រប់គ្រងធនធានទឹកចម្រុះ (Integrated Water Resources Management approach) |
| LMAP | គម្រោងរៀបចំដែនដី និងរដ្ឋបាលដីធ្លី (Land Management and Administration Project) |
| MAFF | ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ (Ministry of Agriculture, Forestry and Fisheries) |
| MDG | គោលដៅអភិវឌ្ឍន៍សហស្សវត្សរ៍ (Millennium Development Goal) |
| MEF | ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ (Ministry of Economics and Finance) |
| MFN | លក្ខខណ្ឌអនុគ្រោះបំផុតផ្នែកពាណិជ្ជកម្ម (Most Favoured Nation) |
| MoLVT | ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ (Ministry of Labour and Vocational Training) |
| MOPS | ការចាកផុតពីភាពក្រីក្រ (Moving Out of Poverty Study) |
| MoSALVY | ក្រសួងសង្គមកិច្ច ការងារ បណ្តុះបណ្តាលវិជ្ជាជីវៈ និងយុវនីតិសម្បទា (Ministry of Social Affairs, Labour, Vocational Training and Youth Rehabilitation) |
| MOWRAM | ក្រសួងធនធានទឹក និងឧតុនិយម (Ministry of Water Resources and Meteorology) |
| MPI | សន្ទស្សន៍ភាពក្រីក្រពហុវិស័យ (Multidimensional Poverty Index) |
| NGOs | អង្គការមិនមែនរដ្ឋាភិបាល (Non-government Organisations) |
| NSDP | ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ (National Strategic Development Plan) |
| NSPS | យុទ្ធសាស្ត្រជាតិលើការគាំពារសង្គម (National Social Protection Strategy) |
| ODA | ជំនួយអភិវឌ្ឍន៍ផ្លូវការ (Official Development Assistant) |
| OWSO | ការិយាល័យច្រកចេញចូលតែមួយ (One Window Service Office) |
| PCA | ការវិភាគសមាសភាគគោល (Principal Component Analysis) |
| PDS | ការសិក្សាពីឌីណាមិកភាពក្រីក្រ (Poverty Dynamics Study) |
| PICM | វិធីសាស្ត្រគ្រប់គ្រងអាងស្តឹង (ឬអាងទន្លេ) ចម្រុះប្រកបដោយការចូលរួម (Participatory Integrated Catchment Management) |

| | |
|---|---|
| PIF | មូលនិធិវិនិយោគសម្រាប់រាជធានី/ខេត្ត (Provincial Investment Fund) |
| PRDC/ExCom | គណៈកម្មាធិការអភិវឌ្ឍន៍ជនបទ និង គណៈកម្មាធិការប្រតិបត្តិរាជធានី និងខេត្ត (Provincial/Municipal Rural Development committee-PRDC and its executive committee-ExCom) |
| PSM | វិធីសាស្រ្តប៉ាន់ស្មានឥទ្ធិពលប្រព្រឹត្តិកម្ម (Propensity Score Matching) |
| RGC | រាជរដ្ឋាភិបាលកម្ពុជា (Royal Government of Cambodia) |
| SEZ | តំបន់សេដ្ឋកិច្ចពិសេស (Special Economic Zones) |
| SITC | ចំណាត់ថ្នាក់ស្តង់ដារពាណិជ្ជកម្មអន្តរជាតិ (Standard International Trade Classification) |
| SME | សហគ្រាសធុនតូច និងមធ្យម (Small and Medium Enterprise) |
| SPACE | ការពង្រឹងសកម្មភាព គណនេយ្យភាព និងការចូលរួមរបស់ប្រជាពលរដ្ឋ (ឈ្មោះគម្រោង) (Strengthening Performance, Accountability and Civic Engagement) |
| TWGAW | ក្រុមការងារបច្ចេកទេស កសិកម្ម និងទឹក (Technical Working Group on Agriculture and Water) |
| UNDP | កម្មវិធីអភិវឌ្ឍន៍អង្គការសហប្រជាជាតិ (United Nations Development Programme) |
| USAID | ទីភ្នាក់ងារសហរដ្ឋអាមេរិកសម្រាប់ការអភិវឌ្ឍអន្តរជាតិ (United States Agency for International Development) |
| VAT | អាករលើតម្លៃបន្ថែម (Value Added Tax) |
| WB | ធនាគារពិភពលោក (World Bank) |
| WTO | អង្គការពាណិជ្ជកម្មពិភពលោក (World Trade Organisation) |

# សេចក្ដីផ្ដើម

របាយការណ៍អភិវឌ្ឍន៍ប្រចាំឆ្នាំលេខថ្មី សម្រាប់ឆ្នាំ២០១០-១១ នេះ វិទ្យាស្ថានបណ្ដុះបណ្ដាល និងស្រាវជ្រាវដើម្បីអភិវឌ្ឍន៍កម្ពុជា (CDRI) បានផ្សព្វផ្សាយចេញ នាឱកាសសន្និសីទចក្ខុវិស័យប្រទេសកម្ពុជាប្រចាំឆ្នាំលើកទី៥ ។ សន្និសីទនេះ បានរៀបចំឡើងក្នុងកិច្ចសហការជាដៃគូរវាងវិទ្យាស្ថាន CDRI និង ធនាគារ ANZ Royal នៅសណ្ឋាគារភ្នំពេញ នាថ្ងៃទី១៦ មីនា ២០១១ ។ ស្របតាមប្រធានបទ "ជំរុញកំណើនសេដ្ឋកិច្ចខ្ពស់ និងការអភិវឌ្ឍប្រកបដោយចីរភាពនៅប្រទេសកម្ពុជា៖ កាលានុវត្តភាព និង បញ្ហាប្រឈម" សន្និសីទចក្ខុវិស័យឆ្នាំ២០១១ មានរួមប្រជុំថ្នាក់ដឹកនាំមកពីខាងរដ្ឋាភិបាល វិស័យឯកជន ស្ថាប័នស្រាវជ្រាវ អង្គការសង្គមស៊ីវិល និង សហគមន៍អភិវឌ្ឍន៍អន្តរជាតិ ដើម្បីពិចារណាពីសមិទ្ធផលដែលប្រទេសកម្ពុជាសម្រេចបាន និងការងារទៅអនាគត ។ ដូចគ្នានឹងសន្និសីទចក្ខុវិស័យលើកមុនៗដែរ សន្និសីទចក្ខុវិស័យប្រទេសកម្ពុជាលើកទី៥ បានទទួលកិត្តិយសដ៏វិសេសដោយ សម្ដេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា អញ្ជើញចូលរួមជាអធិបតី និងថ្លែងសុន្ទរកថាគន្លឹះបើកសន្និសីទ ។

សន្និសីទចក្ខុវិស័យលើកទី៥ និងរបាយការណ៍អភិវឌ្ឍន៍ប្រចាំឆ្នាំថ្មីនេះ កើតមានឡើងនៅក្រោយពេលប្រទេសកម្ពុជាបានឆ្លងផុត ផលប៉ះពាល់យ៉ាងធ្ងន់ធ្ងរនៃវិបត្តិសេដ្ឋកិច្ច និងហិរញ្ញវត្ថុសាកលនៅឆ្នាំ២០០៨-២០០៩ ហើយនិងវិធានការទប់ទល់ដែលបានដាក់អនុវត្តប្រកបដោយជោគជ័យ ទោះបីមានបទពិសោធន៍ឈឺចាប់ខ្លះតែមានប្រយោជន៍ក្ដី ។ នៅឆ្នាំ២០១០-១១ ការរើបសេដ្ឋកិច្ចឡើងវិញ កំពុងជឿនលឿនទៅមុខ ដោយមានកំណើនខ្លាំងនៃវិស័យទេសចរណ៍ និងការនាំចេញសម្លៀកបំពាក់ កំណើនវិស័យកសិកម្ម ជាពិសេសផលិតកម្មស្រូវ ឧស្សាហកម្មកិនស្រូវ និងការនាំចេញអង្ករ និងកំណើនផលិតកម្មកៅស៊ូ ប៉ុន្តែវិស័យសំណង់មិនមានកំណើនទេ ។ ពាណិជ្ជកម្មក៏មាននិន្នាការជាទូទៅល្អប្រសើរដែរ ក្នុងនោះ ពាណិជ្ជកម្មរវាងកម្ពុជា ជាមួយចិន និងកូរ៉េខាងត្បូង បានកើនឡើងយ៉ាងខ្លាំងក្នុងឆ្នាំ២០១០ (៤២% និង ៣០% រៀងៗគ្នា) បន្ទាប់ពីការចាប់អនុវត្តតំបន់ពាណិជ្ជកម្មសេរីចិន-អាស៊ាន និងតំបន់ពាណិជ្ជកម្មសេរីកូរ៉េខាងត្បូង-អាស៊ាន និងការកាត់បន្ថយអត្រាពន្ធគយជាប់ទាក់ទិន ។

ស្ថានភាពម៉ាក្រូសេដ្ឋកិច្ចកម្ពុជា ក៏ល្អដែរ ដោយ ផសស កើន ៥,៥% នៅឆ្នាំ២០១០ ហើយក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុកម្ពុជា ធនាគារពិភពលោក និង ធនាគារអភិវឌ្ឍន៍អាស៊ី បានព្យាករណ៍ថា ផសស កម្ពុជា នឹងកើន ៦% នៅឆ្នាំ២០១១ រីឯ អង្គការមូលនិធិរូបិយវត្ថុអន្តរជាតិ ព្យាករណ៍ថា វានឹងកើន ៦,៨% ។ អតិផរណានៅកម្ពុជា មានកម្រិតប្រមាណ ៤% ហើយធនបំរុងអន្តរជាតិបានកើនឡើងបន្តិច និងនៅមានទំហំធំដដែល ។ កំណើនឥណទាន បានរើបឡើងវិញដល់ជាង ២០% នៅចុងឆ្នាំ២០១០ ធៀបនឹង ៦,៥% នៅចុងឆ្នាំ២០០៩ ។ ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ព្យាករណ៍ថា នៅឆ្នាំ២០១១ កម្ពុជានឹងសម្រេចបានកំណើនវិស័យកសិកម្ម ៤,៧% ឧស្សាហកម្ម ៨,៣% និង សេវាកម្ម ៦,១% កំណើនចំណូលក្នុងស្រុក ដល់ ១៣,៥% នៃ ផសស និងកំណើនចំណាយសរុប ដល់ ១៨,៩% នៃ ផសស ។ បច្ចុប្បន្ន រដ្ឋាភិបាលកម្ពុជា កំពុងផ្ដោតការយកចិត្តទុកដាក់លើយុទ្ធសាស្ត្រពិពិធកម្មសេដ្ឋកិច្ច ដែលរួមមាន ការបង្កើនអង្ករ និងកៅស៊ូនាំចេញ ការបង្កើតវិស័យឧស្សាហកម្មថ្មីៗ ដូចជា ផ្នែកដំឡើងយានយន្ត បរិក្ខារអគ្គីសនី និងឧស្សាហកម្មធុនស្រាលដទៃទៀត ព្រមទាំង វិធានការកែទម្រង់ផ្សេងៗដើម្បីលើកកម្ពស់ការសម្របសម្រួលពាណិជ្ជកម្ម និងបរិយាកាសវិនិយោគ ។

ពិតហើយ ផសស មានកំណើនខ្ពស់ជាងមុន ហើយការកាត់បន្ថយភាពក្រីក្រក៏ឿនលឿន ទៅមុខដែរ ប៉ុន្តែភាពក្រីក្រនៅតែមានកម្រិតខ្ពស់ ហើយវិសមភាពក្នុងជីវភាពក៏កើនឡើងដែរ ។ ដោយសារឧបសគ្គនៃវិបត្តិសាកល ភាពក្រីក្រមានកម្រិតប្រហែល ២៧% ឬខ្ពស់ជាងនេះទៀតនៅតាមតំបន់ខ្លះនៃប្រទេសកម្ពុជា ។ ដំណើរការឆ្ពោះទៅសម្រេចគោលដៅអភិវឌ្ឍន៍សហស្សវត្សរ៍កម្ពុជា (CMDGs) ក៏មិនបានស្មើគ្នាល្អដែរ ក្នុងនេះ ការកាត់បន្ថយភាពក្រីក្រដើរទាន់ផែនការតែដោយផ្នែក ការកាត់បន្ថយអត្រាមរណភាពកុមារ ព្រមទាំងការកាត់បន្ថយអត្រាកើតជម្ងឺអេដស៍ គ្រុនចាញ់ គ្រុនឈាម និងរបេង សម្រេចតាមផែនការ ខាងជំនួយអភិវឌ្ឍន៍ផ្លូវការ (ODA) និង បច្ចេកវិទ្យាព័ត៌មាន និងទូរគមនាគមន៍ (ICT) មានលទ្ធផលល្អ ខាងការអប់រំនៅបឋមសិក្សា អក្ខរកម្ម និងសមភាពយេនឌ័រ ដើរយឺតជាងផែនការ និង ខាងការកាត់បន្ថយអត្រាមរណភាពមាតា ការការពារធនធានធម្មជាតិ និង ការគ្រប់គ្រងដី មានលទ្ធផលទន់ខ្សោយ ។

កម្ពុជារៀនសូត្របានបទពិសោធន៍សំខាន់ៗមួយចំនួនពីវិបត្តិសាកល សម្រាប់កំណើនប្រកបដោយចីរភាព និងការអភិវឌ្ឍ ។ ទី១ កំណើនសេដ្ឋកិច្ចក្នុងទស្សវត្សរ៍កន្លងមក អាចពុំមានចីរភាពទេ បើសិនជាសេដ្ឋកិច្ចមិនប្រែប្រួល ។ ទី២ កម្ពុជា អាចសម្រេចបានកំណើនប្រកបដោយចីរភាព ដោយប្រើយុទ្ធសាស្ត្រកំណើនផ្តោតលើ ការលើកកម្ពស់ការប្រកួតប្រជែង និងពិពិធកម្មសេដ្ឋកិច្ច ។ ទី៣ កម្ពុជាមានស្ថានភាពល្អដើម្បីទាញយកអត្ថប្រយោជន៍ពីកាលានុវត្តភាពបីសំខាន់ៗ គឺការទាញយកប្រយោជន៍ពីសមាហរណកម្មតំបន់ ការគ្រប់គ្រងធនធានធម្មជាតិប្រកបដោយចីរភាព និង ការវិនិយោគកសាងអនាគតរបស់ខ្លួន ដោយផ្តោតលើវិស័យកសិកម្ម ហេដ្ឋារចនាសម្ព័ន្ធ ការអប់រំ និង ការបង្កើនប្រាក់សន្សំ ។

ការស្រាវជ្រាវថ្មីៗរបស់វិទ្យាស្ថាន CDRI បានរកឃើញកត្តាសំខាន់ៗមួយចំនួន ដែលអាចជំរុញកំណើនដោយមានការរាប់បញ្ចូល និងសេណារីយ៉ូអភិវឌ្ឍន៍ប្រកបដោយចីរភាពសម្រាប់ប្រទេសកម្ពុជា ។ កត្តាទាំងនោះ រួមមាន៖

- បរិយាកាសម៉ាក្រូសេដ្ឋកិច្ចមានការគ្រប់គ្រងល្អ និងមានស្ថិរភាព ដែលជំរុញពិពិធកម្មសេដ្ឋកិច្ច សមត្ថភាពប្រកួតប្រជែង ផលិតកម្ម និង ចំណាយប្រើប្រាស់ក្នុងស្រុក ។
- បរិយាកាសកាន់តែអំណោយផលដល់ការអភិវឌ្ឍវិស័យឯកជន និងវិនិយោគ និងមានជាអាទិ៍ វិធានការប្រឆាំងអំពើពុករលួយ និង ការលើកកម្ពស់នីតិរដ្ឋ ដើម្បីផ្តល់ភាពប្រាកដប្រជា សម្រាប់អ្នកវិនិយោគក្នុងស្រុក និងអន្តរជាតិ ព្រមទាំង ការវិនិយោគជាយុទ្ធសាស្ត្រដោយរាជរដ្ឋាភិបាល ដៃគូអភិវឌ្ឍន៍ និងវិស័យឯកជន ក្នុងការអភិវឌ្ឍធនធានមនុស្សជាពិសេស ការអប់រំថ្នាក់ក្រោយឧត្តម និង ការបណ្តុះបណ្តាលវិជ្ជាជីវៈ ដើម្បីបំពេញតម្រូវការទីផ្សារការងារ ។
- ការពង្រឹងវិស័យបម្រើការនាំចេញសំខាន់ៗ ដូចជា កសិកម្ម និងអភិវឌ្ឍន៍ជនបទ ទេសចរណ៍ សំណង់ ថាមពល និងហេដ្ឋារចនាសម្ព័ន្ធ ព្រមទាំង ការសម្រួលពាណិជ្ជកម្ម និង វិនិយោគ ។
- ការអនុវត្តយ៉ាងសក្តិសិទ្ធិនូវគោលនយោបាយរដ្ឋាភិបាលដែលមានចែងក្នុង ផែនការអភិវឌ្ឍន៍យុទ្ធសាស្ត្រជាតិឆ្នាំ២០០៩-១៣ ដើម្បីសម្រេចបានកំណើនផលស្រូវខ្ពស់ប្រកបដោយចីរភាព និង គោលនយោបាយឆ្នាំ២០១០ ស្តីពី ការជម្រុញផលិតកម្ម និងការនាំចេញស្រូវអង្ករ ព្រមទាំងកត្តាសំខាន់ៗដែលនាំឲ្យមានជោគជ័យ ដូចជា ហេដ្ឋារចនាសម្ព័ន្ធជនបទ ផលិតភាពស្រូវ ពិពិធកម្មមុខដំណាំ លទ្ធភាពទទួលបានឥណទាន សេវាផ្សព្វផ្សាយបច្ចេកទេសកសិកម្ម ការអប់រំនិងបណ្តុះបណ្តាលវិជ្ជាជីវៈ ការគ្រប់គ្រងកាន់តែសក្តិសិទ្ធិ

និងមានតម្លាភាពនូវ ដីសម្បទានសេដ្ឋកិច្ច និងសង្គមកិច្ច ដើម្បីជម្រុញការអភិវឌ្ឍសេដ្ឋកិច្ច អំណោយផលដល់អ្នកក្រ និងការប្រើប្រាស់ដីឲ្យមានផលិតភាព ។

- ហេដ្ឋារចនាសម្ព័ន្ធ "រឹង និង ទន់" សម្រាប់ការតភ្ជាប់ក្នុង មហាអនុតំបន់មេគង្គ (GMS) តំបន់អាស៊ាន និង អាស៊ីអាគ្នេយ៍ (អាស៊ាន ចិន កូរ៉េ ជប៉ុន) ហើយសម្រាប់កម្ពុជា គឺមានជាអាទិ៍ ការកសាងផ្លូវដែក ផ្លូវថ្នល់ ការផលិតថាមពល ការពង្រឹងបទបញ្ញត្តិនិងស្ថាប័នឆ្លងកាត់ព្រំដែន និង ការកសាងសមត្ថភាព ។
- សមាហរណកម្មជាយុទ្ធសាស្ត្រនៃសេដ្ឋកិច្ចកម្ពុជា និងទំនាក់ទំនងវិនិយោគ និងពាណិជ្ជកម្មសំខាន់ៗរបស់កម្ពុជា នៅក្នុង មហាអនុតំបន់មេគង្គ អាស៊ាន អាស៊ានធំទូលាយ ទីផ្សារចិន កូរ៉េ និង ជប៉ុន និង ទីផ្សារអន្តរជាតិជាគោលដៅដទៃទៀត ។

សង្ខេបរបាយការណ៍អភិវឌ្ឍន៍ប្រចាំឆ្នាំ២០១០-១១ នេះ ជារបាយការណ៍ប្រចាំឆ្នាំលេខ៦ របស់ CDRI ស្តីពីបញ្ហាអភិវឌ្ឍន៍មួយចំនួននៅកម្ពុជា និងដំណោះស្រាយបញ្ហានានាដែលលើកឡើងខាងលើ ។ របាយការណ៍នេះ ផ្តល់នូវការវិភាគលើ បញ្ហាជាក់លាក់មួយចំនួន និង លទ្ធផលស្រាវជ្រាវរបស់ CDRI ក្នុងអំឡុងពេលមួយឆ្នាំកន្លងទៅ ដែលរួមមាន គោលនយោបាយឧស្សាហកម្មនិងពិពិធកម្មសេដ្ឋកិច្ច ទេសន្តរប្រវេសន៍ពលកម្ម ការវាយតម្លៃពីផលប៉ះពាល់របស់ប្រទេសចិនលើការកាត់បន្ថយភាពក្រីក្រ ភាពក្រីក្រមួយគ្រាៗនិងវ៉ាំរ៉ែ កំណើនប្រាក់ចំណូលនិងការគាំពារសង្គម ការផ្តល់សេវាការិយាល័យច្រកចេញចូលតែមួយនៅក្នុងកំណែទម្រង់អភិបាលកិច្ចថ្នាក់ក្រោមជាតិ គណនេយ្យភាពនិងការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ សិទ្ធិកាន់កាប់ដីធ្លីនិងផលិតភាពស្រូវ ធនធានទឹកនិងការគ្រប់គ្រងប្រព័ន្ធធារាសាស្ត្រនៅមូលដ្ឋាន និង គ្រឿងលើកទឹកចិត្តដើម្បីរក្សាបុគ្គលិកសុខាភិបាលឲ្យធ្វើការនៅជនបទ និង ផលប៉ះពាល់នៃចំណាយមហន្តរាយលើការថែទាំសុខភាព ចំពោះជនក្រីក្រ និងជនងាយរងគ្រោះ ។

វិទ្យាស្ថាន CDRI សង្ឃឹមថា សន្និសីទចក្ខុវិស័យប្រទេសកម្ពុជា ដែលប្រារព្ធធ្វើជារៀងរាល់ឆ្នាំ ព្រមទាំងរបាយការណ៍អភិវឌ្ឍន៍ប្រចាំឆ្នាំ ជាភាសាខ្មែរ និងអង់គ្លេស អាចចូលរួមចំណែកជួយផ្សព្វផ្សាយកាន់តែទូលំទូលាយនូវ លទ្ធផលស្រាវជ្រាវខាងគោលនយោបាយអភិវឌ្ឍន៍ប្រកបដោយគុណភាព ដែលជាប់ទាក់ទងនឹងបញ្ហាសំខាន់ៗសម្រាប់អនាគតប្រទេសកម្ពុជា ព្រមទាំងអាចក្លាយជាធនធានដ៏មានប្រយោជន៍សម្រាប់គោលនយោបាយអភិវឌ្ឍន៍របស់ រាជរដ្ឋាភិបាលកម្ពុជា ដៃគូអភិវឌ្ឍន៍អន្តរជាតិ និង អ្នកពាក់ព័ន្ធកម្ពុជានានា ។ ឯកសារទាំងពីរនេះ ក៏ដូចជា របាយការណ៍ស្តីពីសន្និសីទចក្ខុវិស័យប្រទេសកម្ពុជាឆ្នាំ២០១១ អាចស្វែងរកបានដោយឥតគិតថ្លៃ តាមរយៈគេហទំព័ររបស់វិទ្យាស្ថាន www.cdri.org.kh ។

*ឡារី ស្ត្រេន្ទ*
*នាយកប្រតិបត្តិ CDRI*
*ខែមីនា ឆ្នាំ២០១១*

# ផ្នែកទី ១
# សេដ្ឋកិច្ច ពាណិជ្ជកម្ម និង
# សហប្រតិបត្តិការក្នុងតំបន់

-I-

# ការពិនិត្យពីគោលនយោបាយឧស្សាហកម្មកម្ពុជា

*ដោយលោក តុង គឹមស៊ុន*[១]

## ១. រចនាសម្ព័ន្ធឧស្សាហកម្ម

ឧស្សាហកម្មកម្ពុជាមានកំណើនយ៉ាងខ្លាំងនៅដើមទសវត្សរ៍១៩៦០ ដោយសារមានរោងចក្រទើបសាងសង់ថ្មីជាច្រើន ។ ប៉ុន្តែក្នុងរបបខ្មែរក្រហម (១៩៧៥-៧៩) វិស័យនេះទាំងមូលគ្មានផលិតភាពទេ ពីព្រោះកម្មន្តសាលកម្មភាគច្រើនបានខូចខាតអស់ ហើយប្រជាជនក៏ត្រូវបានជម្លៀសចេញពីទីក្រុង និងបង្ខំឲ្យធ្វើការក្នុងស្រែនៅតំបន់ជនបទ ។ ក្នុងទសវត្សរ៍១៩៨០ កម្មន្តសាលកម្មមួយចំនួន បានដំណើរការឡើងវិញក្រោមការឧបត្ថមពីសហភាពសូវៀត និង ប្រទេសវៀតណាម ។ កាលនោះរដ្ឋគ្រប់គ្រងលើរោងចក្រទាំងអស់ ហើយរបស់ផលិតបាន គឺសម្រាប់តែការប្រើប្រាស់ក្នុងស្រុក ឬធ្វើពាណិជ្ជកម្មជាមួយប្លុកកុម្មុយនិស្ត ។

នៅចុងទសវត្សរ៍១៩៨០ កម្ពុជាចាប់ផ្តើមធ្វើសេរីភាវូបនីយកម្មសេដ្ឋកិច្ច និង បើកចំហពាណិជ្ជកម្មជាមួយប្រទេសឯទៀតក្នុងតំបន់ និង ពិភពលោក ជាពិសេសជាមួយថៃ ។ ការធ្វើសមាហរណកម្មចូលក្នុងតំបន់ និងសហគមន៍អន្តរជាតិ បានក្លាយជាកាតព្វកិច្ចនៅពេលប្រទេសកម្ពុជាចូលជាសមាជិកសមាគមប្រជាជាតិអាស៊ីអាគ្នេយ៍ (ASEAN) ក្នុងឆ្នាំ១៩៩៩ និង អង្គការពាណិជ្ជកម្មពិភពលោក (WTO) ក្នុងឆ្នាំ២០០៣ ។ សមាជិកភាពក្នុងអង្គការពាណិជ្ជកម្មពិភពលោករំពឹងថាជួយផ្តល់ឲ្យកម្ពុជានូវទីផ្សារដ៏ធំ ប៉ុន្តែកម្ពុជាត្រូវតែប្រកួតប្រជែងលើទីផ្សារពិភពលោកជាពិសេស សម្រាប់ទំនិញកម្មន្តសាល ដែលជាបញ្ហាប្រឈមសម្រាប់ឧស្សាហកម្មកម្ពុជា ។

តារាង ១៖ រចនាសម្ព័ន្ធឧស្សាហកម្មកម្ពុជា (ថ្លៃថេរឆ្នាំ២០០០ គិតជាពាន់លានរៀល)

| | 1998 | 1999 | 2000 | 2001 | 2002 | 2003 | 2004 | 2005 | 2006 | 2007 | 2008 | 2009 |
|---|---|---|---|---|---|---|---|---|---|---|---|---|
| រ៉ែ | 20.1 | 26.6 | 33.5 | 37.4 | 47.0 | 55.5 | 68.9 | 87.0 | 100.9 | 108.7 | 125.9 | 151.1 |
| កម្មន្តសាលកម្ម | 1445.5 | 1730.6 | 2254.8 | 2597.5 | 2971.7 | 3337.4 | 3926.7 | 4308.6 | 5059.8 | 5509.3 | 5681.6 | 4799.9 |
| អាហារ ភេសជ្ជៈ & ថ្នាំជក់ | 446.4 | 467.6 | 449.4 | 460.7 | 448.9 | 469.8 | 445.2 | 485.4 | 501.6 | 517.3 | 547.8 | 580.7 |
| វាយនភ័ណ្ឌ សំលៀកបំពាក់ គ្រឿងសម្រាប់បំពាក់នៅជើង | 547.5 | 771.2 | 1297.1 | 1665.7 | 2021.4 | 2360.3 | 2946.8 | 3216.8 | 3873.1 | 4260.8 | 4354.6 | 3962.7 |
| ឈើ ក្រដាស ការបោះពុម្ព | 153.6 | 146.5 | 132.4 | 93.6 | 93.8 | 80.4 | 83.8 | 92.2 | 99.9 | 104.8 | 110.1 | 115.6 |
| ផលិតកម្ម កៅស៊ូ | 54.8 | 62.9 | 69.2 | 69.7 | 69.2 | 62.4 | 57.0 | 51.9 | 53.6 | 58.8 | 64.2 | 70.3 |
| ផលិតកម្ម ផ្សេងទៀត | 243.2 | 282.4 | 306.7 | 307.8 | 338.4 | 364.4 | 393.9 | 462.3 | 531.6 | 567.6 | 604.5 | 651.4 |
| អគ្គិសនី ហ្គាស ទឹក | 50.8 | 54.4 | 58.1 | 69.5 | 75.5 | 82.3 | 91.5 | 103.0 | 135.5 | 151.2 | 164.1 | 178.0 |
| សំណង់ | 419.6 | 534.6 | 731.6 | 718.3 | 912.8 | 1014.4 | 1147.9 | 1401.1 | 1681.2 | 1794.7 | 1898.8 | 1993.7 |
| ឧស្សាហកម្ម | 1936.1 | 2346.2 | 3078.0 | 3422.7 | 4006.9 | 4489.6 | 5235.1 | 5899.7 | 6977.5 | 7563.9 | 7869.8 | 7122.7 |

*ប្រភព៖ MEF 2010*

១ លោក តុង គឹមស៊ុន ជាអ្នកស្រាវជ្រាវ ។ អ្នកនិពន្ធសូមអរគុណ បណ្ឌិត រីបេកា កាតាឡា និង អ្នកកែសម្រួលឯកសារពីផ្នែកខាងក្រៅវិទ្យាស្ថាន ចំពោះការជួយមតិលើអត្ថបទព្រាង ។

ពីឆ្នាំ១៩៩៨ ដល់ ២០០៨ ឧស្សាហកម្មមានកំណើនប្រហែល ១៤,២% ក្នុង១ឆ្នាំ គឺលឿនជាងសេវាកម្ម ( ៩,៩% ) និង កសិកម្ម (៤,២%) ប៉ុន្តែក្នុងទសវត្សរ៍២០០០ វាមានអត្រាកំណើនពីមួយឆ្នាំទៅមួយឆ្នាំ ឡើងចុះជាខ្លាំង និងចុះដល់អវិជ្ជមានក្នុងឆ្នាំ២០០៩ ។ ចំណែកឧស្សាហកម្មនៅក្នុងផលិតផលក្នុងស្រុកសរុប (ផសស) កើនឡើងទ្វេ ពី ១៣,៥% ក្នុងឆ្នាំ១៩៩៨ ដល់ ២៧,៥% ក្នុងឆ្នាំ២០០៨ ។ វិស័យនេះប្រើប្រាស់តែ ៦,៨% នៃកម្លាំងពលកម្មនៅកម្ពុជាទាំងមូល ក្នុងឆ្នាំ១៩៩៥ និង ១៥,៤% ក្នុងឆ្នាំ២០០៧ ។ ឧស្សាហកម្មចំបងៗមានជាអាទិ៍ កម្មន្តសាលកម្ម សំណង់ អគ្គិសនី ហ្គាស និង ទឹក និង ការយករ៉ែ ។ ក្នុងឆ្នាំ២០០៨ កម្មន្តសាលកម្ម មានចំណែក ៧២,៨% នៃផលិតកម្មឧស្សាហកម្ម បន្ទាប់មកគឺសំណង់ (២៣,៧%) អគ្គិសនី ហ្គាស និង ទឹក (២%) និង រ៉ែ (១,៥%) ។

សកម្មភាពកាត់ដេរ មានចំណែកធំបំផុតដល់ ៦៦% នៅក្នុងកម្មន្តសាលកម្ម ក្នុងឆ្នាំ១៩៩៨-២០០៨ (១០,៥% ជាមធ្យមនៃ ផសស កម្ពុជា) និងមានសន្ទុះខ្លាំងជាងគេក្នុងវិស័យឧស្សាហកម្ម ដោយមានអត្រាកំណើនប្រចាំឆ្នាំ ៣៤,៧% និងជាប្រភពការងារ និងចំណូលរូបិយវត្ថុបរទេសដ៏សំខាន់ ។ វាតំណាងឲ្យពី ៧០-៨០% នៃការនាំចេញសរុបប្រចាំឆ្នាំ នៅមុនឆ្នាំ២០០៨ គឺមុនពេលវិបត្តិហិរញ្ញវត្ថុពិភពលោក បានប៉ះពាល់ដល់សហរដ្ឋអាមេរិក ដែលជាគោលដៅសំខាន់បំផុតនៃផលិតផលកាត់ដេរកម្ពុជា ។ វិស័យនេះ ប្រើពលករជាង ៣៥២.០០០នាក់ ភាគច្រើនជានារីមកពីជនបទ ឬប្រហែល ៤% នៃកម្លាំងពលកម្មសរុប និង ៣៨% នៃពលករដែលបម្រើការក្នុងកម្មន្តសាលកម្មក្នុងឆ្នាំ២០០៧ ។ តាមការប៉ាន់ស្មាន មានប្រជាជនប្រហែល ១,៧ លាននាក់ កំពុងពឹងផ្អែកលើផ្នែកកាត់ដេរដោយផ្ទាល់ និងដោយប្រយោល (Tong 2010c) ។

ក្រាហ្វិក ១៖ រចនាសម្ព័ន្ធនៃវិស័យកម្មន្តសាលកម្ម




*ប្រភព៖ MEF 2010*

ការរីកលូតលាស់វិស័យកាត់ដេរនៅកម្ពុជា អាស្រ័យជាសំខាន់លើការទទួលបានលក្ខខណ្ឌអនុគ្រោះនៅទីផ្សារមួយចំនួន ដូចជា អត្រាពន្ធ (៥-៣០%) តាមលក្ខខណ្ឌអនុគ្រោះបំផុតផ្នែក

ពាណិជ្ជកម្ម (MFN) ទទួលបានពីសហភាពអឺរ៉ុប និង អត្រាពន្ធ (១២%) តាមប្រព័ន្ធអនុគ្រោះទូទៅ (GSP) ទទួលបានពីសហរដ្ឋអាមេរិក ។ លក្ខខណ្ឌអនុគ្រោះទាំងនេះ បានទាក់ទាញវិនិយោគិនបរទេសជាច្រើន (Tong 2010a)។ ទោះបីការទទួលបានកូតាអនុគ្រោះតាមរយៈកិច្ចព្រមព្រៀងសាច់ក្រណាត់គ្រប់មុខ (Multi-Fibre Agreement) បានផុតកំណត់ក៏ដោយ ក៏ឧស្សាហកម្មកាត់ដេរកម្ពុជា នៅតែមានកំណើនខ្ពស់ក្នុង ៤ឆ្នាំបន្តមកទៀត ដោយឡើងដល់ ២,៨ពាន់លានដុល្លារ នៅឆ្នាំ២០០៨ គឺបានន័យថា កម្ពុជាមានឧត្តមភាពប្រៀបធៀបខ្លាំងក្នុងឧស្សាហកម្មកាត់ដេរ (Cuyver *et al.* 2008)។

វិបត្តិហិរញ្ញវត្ថុពិភពលោក បានប៉ះពាល់វិស័យកាត់ដេរកម្ពុជាយ៉ាងធ្ងន់ធ្ងរ ។ ចាប់ពីត្រីមាសទី៤ ឆ្នាំ២០០៨ មក មានការធ្លាក់ចុះយ៉ាងគំហុកនូវចំនួនរោងចក្រ និង ផលិតកម្ម ព្រមទាំងកិច្ចសន្យាម៉ៅការបន្តទៅឲ្យគ្រឹះស្ថានវាយនភ័ណ្ឌខ្នាតតូច និងមធ្យម ក្នុងស្រុក (Siang 2009) ។ ចំនួនរោងចក្រដំណើរការ ធ្លាក់ចុះពីចំនួនខ្ពស់បំផុត ៣១០រោងចក្រ នៅខែកញ្ញា ២០០៨ មកត្រឹម ២៦២រោងចក្រ នៅខែឧសភា ២០០៩ ។ ការនាំចេញផលិតផលកាត់ដេរសរុបរបស់កម្ពុជា បានធ្លាក់ចុះជាបន្តបន្ទាប់ ពីខែវិច្ឆិកា ២០០៨ ដល់ ឧសភា ២០០៩ ហើយកម្មកររោងចក្រ ៦២.០០០នាក់ (ប្រហែល ១៨% នៃចំនួនសរុប) បានបាត់បង់ការងារនៅ ចន្លោះខែកញ្ញា ២០០៨ និង ឧសភា ២០០៩ ។

សំណង់ ជាអនុវិស័យឧស្សាហកម្មធំលំដាប់ទី២ នៅកម្ពុជា និងស្ថិតក្នុងចំណោមផ្នែកសំខាន់ៗទាំងបួន ដែលជាសរសរទ្រសេដ្ឋកិច្ចកម្ពុជា ដោយមានចំណែកជាមធ្យម ៥,៦% ក្នុង ផសស ក្នុងអំឡុងឆ្នាំ១៩៩៨-២០០៨ ប៉ុន្តែអត្រាកំណើនរបស់វាបានឡើងចុះយ៉ាងខ្លាំង និងចុះដល់អវិជ្ជមានក្នុងឆ្នាំ១៩៩៨ (-១៥,៧%) ដោយសារតែអស្ថិរភាពនយោបាយក្នុងឆ្នាំ១៩៩៧ និង វិបត្តិហិរញ្ញវត្ថុអាស៊ី ក្នុងឆ្នាំ១៩៩៧-៩៨ និងម្តងទៀតក្នុងឆ្នាំ២០០១ (-១,៨%) ។ បន្ទាប់ពីនោះមក វាមានកំណើន ១៨,៧% រៀងរាល់ឆ្នាំ ពីឆ្នាំ២០០២-០៦ មុននឹងធ្លាក់ចុះមកត្រឹម ៦,៧% ក្នុងឆ្នាំ២០០៧ និង ៥,៨% ក្នុងឆ្នាំ២០០៨ ។ សំណង់ មានទំនាក់ទំនងខ្លាំងជាមួយអចលនទ្រព្យ ។ គម្រោងសំណង់ភាគច្រើន ជាអចលនទ្រព្យពាណិជ្ជកម្ម និងលំនៅឋាន ដែលទទួលបានហិរញ្ញប្បទានភាគច្រើនពីបរទេស ដូច្នេះវាងាយរងគ្រោះដោយសារការប៉ះទង្គិចពីខាងក្រៅ ។ ការធ្លាក់ចុះយ៉ាងគំហុកក្នុងឆ្នាំ២០០៧ និង ២០០៨ ជាសញ្ញាបង្ហាញពីសេដ្ឋកិច្ចដែលរត់ក្តៅពេក (មានការឡើងថ្លៃកម្លាំងពលកម្ម និងសម្ភារៈសំណង់) និង ការបារម្ភអំពីកំណើនមិនឋិតថេរនៃអចលនទ្រព្យដែលអាចផ្ទុះបែកដូចពពុះទឹក (World Bank 2009) ។ វិបត្តិហិរញ្ញវត្ថុពិភពលោកបានធ្វើឲ្យបែកពពុះ កំណើនទីផ្សារអចលនទ្រព្យ ដែលធ្វើឲ្យសកម្មភាពសាងសង់ និងតម្រូវការជាទូទៅ ធ្លាក់ចុះ ។ ដោយមានការរឹតបន្តឹងជាសកលនូវសាច់ប្រាក់ និង ទ្រព្យងាយប្តូរជាសាច់ប្រាក់ វិនិយោគិនបរទេសជាច្រើន បានផ្អាក ឬលុបចោលគម្រោងវិនិយោគនៅកម្ពុជា ។ ឧទាហរណ៍ គម្រោងសំណង់ធំៗជាច្រើន ដែលផ្តល់ហិរញ្ញប្បទានដោយក្រុមហ៊ុនកូរ៉េខាងត្បូង ត្រូវបានលុបចោល ឬកាត់បន្ថយចុះវិញ ដោយសារការធ្លាក់ថ្លៃនៃប្រាក់វ៉ុនកូរ៉េ និង កង្វះសាច់ប្រាក់ងាយស្រួលនៅតាមក្រុមហ៊ុនធំៗជាច្រើន ។ ជាលទ្ធផលគេរំពឹងថា សំណង់ត្រូវធ្លាក់ចុះ ៥,៧% នៅឆ្នាំ២០០៩ (Jalilian *et al.* 2009)។

## ២. ស្ថានភាពបច្ចុប្បន្ននៃវិស័យឧស្សាហកម្ម

### *២.១. កាត់ដេរ និងវាយនភ័ណ្ឌ*

ចំនួនរោងចក្រកាត់ដេរ កើនឡើងពីត្រឹម ៨រោងចក្រ នៅឆ្នាំ១៩៩៤ រហូតដល់ ៣១០រោងចក្រ នៅឆ្នាំ២០០៨ ។ រោងចក្រនីមួយៗ ប្រើកម្មករជាមធ្យមជាង ១០០០នាក់ នៅអំឡុងឆ្នាំ២០០៤-០៩ (តារាង ២) ។ ពលករមានការអប់រំតិចតួចជាច្រើននាក់ ជាពិសេសនារីមកពីជនបទ បានធ្វើ

ចំណាកស្រុក មកចូលបម្រើក្នុងទីផ្សារពលកម្ម ហើយការងារ និងប្រាក់ផ្ញើទៅផ្ទះរបស់ពួកគេ បានជួយកាត់បន្ថយ ភាពក្រីក្រមួយចំណែក ។

**តារាង ២៖ រោងចក្រកាត់ដេរកម្ពុជា**

| | 1995 | 1997 | 1999 | 2000 | 2002 | 2003 | 2004 | 2005 | 2006 | 2007 | 2008 |
|---|---|---|---|---|---|---|---|---|---|---|---|
| ចំនួនរោងចក្រ | 20 | 67 | 152 | 190 | 188 | 197 | 206 | 230 | 305 | 288 | 285 |
| ចំនួនពលករកម្ពុជាបម្រើការ (ពាន់នាក់) | 187 | 516 | 966 | 1226 | 2104 | 234 | 246 | 270 | 317 | 348 | 327 |
| ចំនួនយោធិកមធ្យមក្នុងរោងចក្រ | 935 | 770 | 636 | 645 | 1119 | 1188 | 1194 | 1174 | 1039 | 1208 | 1147 |

*ប្រភព៖ Natsuda (2009)*

វិស័យកាត់ដេរជាង ៩០% បានកកើតឡើងដោយសារវិនិយោគិនបរទេសមកពី តៃវ៉ាន់ ហុងកុង ចិន កូរ៉េ ម៉ាឡេស៊ី និង សិង្ហបុរី (ក្រាហ្វិក ២) ។ Natsuda *et al.* (២០០៩) បានរៃកញ្ចែកថា រោងចក្រកាត់ដេរដែលមានម្ចាស់ជាបរទេស អាចចូល និងចេញពីប្រទេសមួយយ៉ាងឆាប់រហ័ស ។ ឧទាហរណ៍ ក្រុមហ៊ុនមកពីអាស៊ីអាគ្នេយ៍ស្ទើរតែទាំងអស់ បានចាកចេញពី Mauritius ដែលជាប្រទេសផលិតសំលៀកបំពាក់ដ៏សំខាន់បំផុតមួយ នៅភាគខាងត្បូងវាលខ្សាច់សាហារ៉ាទ្វីបអាហ្វ្រិក បន្ទាប់ពីចប់កិច្ចព្រមព្រៀងក្រណាត់គ្រប់មុខ ។ វិស័យកាត់ដេរ ទំនងនៅតែងាយរងគ្រោះ ពីព្រោះផលិតកម្ម ការនាំចេញ ការគ្រប់គ្រង ត្រូវសម្រេចឡើងនៅឯការិយាល័យក្នុងប្រទេសឆ្ងាយៗ (ADB 2004) ។ ទោះយ៉ាងនេះក្តី កម្ពុជានៅតែបន្តការនាំចេញផលិតផលវាយនភ័ណ្ឌ និងកាត់ដេរ ។

**ក្រាហ្វិក ២៖ ម្ចាស់កម្មសិទ្ធិរោងចក្រកាត់ដេរ គិតតាមប្រទេស**




*ប្រភព៖ GMAC (May 2010)*

យោងតាមក្រសួងពាណិជ្ជកម្ម ការនាំចេញផលិតផលកាត់ដេរ និងវាយនភ័ណ្ឌ កើនឡើងមួយជាបី ពី ៩៦២លានដុល្លារ ក្នុងឆ្នាំ២០០០ ដល់ ២៩៣៨លានដុល្លារ ក្នុងឆ្នាំ២០០៨ (ក្រាហ្វិក ៣) ប៉ុន្តែវាធ្លាក់ចុះ ១៤% ដល់ ២៥៦៥លានដុល្លារ ក្នុងឆ្នាំ២០០៩ ដោយសារ

វិបត្តិហិរញ្ញវត្ថុសាកល ។ រហូតដល់ចប់កូតាកិច្ចព្រមព្រៀង Multi-Fibre នៅថ្ងៃទី១ មករា ២០០៥ ការរីកលូតលាស់យ៉ាងលឿននៃវិស័យកាត់ដេរ និង វាយនភ័ណ្ឌ អាស្រ័យយ៉ាងខ្លាំងលើលក្ខខណ្ឌអនុគ្រោះនៃ GSP និង MFN ។ ក្រោយការចប់កូតា វិស័យនេះពឹងផ្អែកលើឧត្តមភាពប្រៀបធៀបនៃភាពសម្បូរ និងថ្លៃកម្លាំងពលកម្មទាប ហើយនិងការលើកទឹកចិត្តខាងពន្ធ (ការលើកលែងពន្ធនាំចូល និង រួចពន្ធលើប្រាក់ចំណេញ) ។

ក្រាហ្វិក ៣៖ ការនាំចេញទំនិញកម្ពុជា (គិតជាលានដុល្លារ)




*ប្រភព៖ Ministry of Commerce (2010)*

ក្រាហ្វិក ៤ បង្ហាញពីគោលដៅនៃការនាំចេញផលិតផលកាត់ដេរ និង វាយនភ័ណ្ឌកម្ពុជាសម្រាប់ឆ្នាំ២០០០-០៩ ។ គោលដៅធំបំផុត គឺសហរដ្ឋអាមេរិក ដែលមានចំណែក ៦០% ក្នុងឆ្នាំ២០០០-០៨ និង ៥៩% ក្នុងឆ្នាំ២០០៩ ធៀបនឹងសហភាពអឺរ៉ុប ដែលមានប្រហែល ២៥% ។ ការផ្តោតលើទីផ្សារសហរដ្ឋអាមេរិក បង្ហាញពីភាពងាយរងគ្រោះធ្ងន់ធ្ងរមួយនៃវិស័យនេះ ដោយសារការប៉ះទង្គិចពីខាងក្រៅ (Jalilian *et al*. 2009) ។

ទោះបីវិស័យកាត់ដេរកម្ពុជារីកលូតលាស់យ៉ាងលឿន ចាប់ពីចុងទសវត្សរ៍១៩៩០ ក្តី ក៏វាត្រូវប្រឈមទាំងបញ្ហាក្នុងស្រុក និងអ្នកប្រកួតប្រជែងពីខាងក្រៅ ដូចជា ចិន ឥណ្ឌា បង់ក្លាដែស វៀតណាម និង ឥណ្ឌូនេស៊ី ហើយអភិបាលកិច្ចទន់ខ្សោយ គឺជាឧបសគ្គយ៉ាងធំរារាំងការអភិវឌ្ឍបន្ថែមទៀត ។ ការសិក្សាធ្វើឡើងដោយវិទ្យាស្ថានសេដ្ឋកិច្ចកម្ពុជា (EIC 2007) បានកត់សម្គាល់ថា ទី១ ចំណាយក្រៅផ្លូវការក្នុងឧស្សាហកម្មកាត់ដេរ មានប្រហែល ៤% នៃចំណាយលើផលិតកម្មសរុប ។ ទី២ របបការិយាធិបតេយ្យស្មុគស្មាញ ទំនងបានកាត់បន្ថយសមត្ថភាពប្រកួតប្រជែងខាងឧស្សាហកម្ម ។ ដើម្បីនាំចេញ ក្រុមហ៊ុនដែលធ្វើប្រតិបត្តិការនៅកម្ពុជា ត្រូវមានឯកសារជាមធ្យមចំនួន៨ ហត្ថលេខាចំនួន១០ និង រយៈពេល ៤៣ថ្ងៃ ។ ទី៣ រោងចក្រកាត់ដេរនៅកម្ពុជា ផ្តោតលើការងារ "កាត់ដេរ និង តម្រឹម" ដែលជាចុងបញ្ចប់នៃខ្សែចង្វាក់ផលិតកម្ម និងបង្កើតតម្លៃសម្លៀកបំពាក់បានតិចជាងគេ ហើយសម្ភារៈ និងវត្ថុធាតុដើម ភាគច្រើនសុទ្ធតែនាំចូលពី ចិន ហុងកុង និងតៃវ៉ាន់ ។ កង្វះការគាំទ្រ

ពីរដ្ឋាភិបាល និងវិនិយោគ គឺជាបញ្ហាប្រឈមមួយទៀត (EIC 2007) ។ ទី៤ វិស័យកាត់ដេរបានរងគ្រោះយ៉ាងយូរ ដោយសារការផ្គត់ផ្គង់សាធារណៈមានតម្លៃខ្ពស់ ជាពិសេសអគ្គិសនីផលិតដោយម៉ាស៊ីនភ្លើងប្រើប្រេងឥន្ធនៈ និងមានសមត្ថភាពទាប (Saing 2009) ។ Werner International (cited in USAID 2007) បញ្ជាក់ថា ចំណាយជាមធ្យមលើអគ្គិសនីនៅកម្ពុជា ខ្ពស់ពីរដងជាងនៅចិន ឥណ្ឌា ប៉ាគីស្ថាន និងឥណ្ឌូនេស៊ី ។ ទី៥ ផលិតភាពពលកម្មក្នុងវិស័យឧស្សាហកម្មកម្ពុជា វាទាបជាងនៅប្រទេសអាស៊ានឯទៀតទាំងអស់ (APO 2009) ។ ការកែលំអផលិតភាព តាមរយៈការបណ្តុះបណ្តាលកម្លាំងពលកម្មមានជំនាញទាប និង/ឬ ការប្រើបរិក្ខារដេរទំនើប ត្រូវធ្វើជាចាំបាច់ដើម្បីរក្សាសមត្ថភាពប្រកួតប្រជែងក្នុងវិស័យនេះ ។

ក្រាហ្វិក ៤៖ គោលដៅនាំចេញវាយនភ័ណ្ឌកម្ពុជា




*ប្រភព៖ ក្រសួងពាណិជ្ជកម្ម (2010)*

## ២.២. សំណង់ និង រ៉ែ

សម្ភារៈសំណង់ ដូចជា ឥដ្ឋថ្មតា ជាដើម ជាផលិតផលក្នុងស្រុក ។ ដោយសារការបន្តពង្រីកតំបន់ទីក្រុង និងសំណង់ឧស្សាហកម្ម តម្រូវការសម្ភារៈសំណង់ នឹងបន្តកើនឡើង ។ ដើម្បីឲ្យវាផ្តល់ជាប្រាក់ចំណូល និង ការងារក្នុងស្រុក គេត្រូវបង្កើនសមត្ថភាពផលិតសម្ភារៈសំណង់ និងសម្ភារៈបន្ទាប់បន្សំ ដូចជា លូបេតុង បន្ទះប្លង់សេចាក់ស្រាប់ បន្ទះដែកជ្រលក់សង្កសី ឥដ្ឋនិងក្បឿងប្រណិត ។ សម្ភារៈសំណង់ មានលក្ខណៈធំសំពីងសំពោង និង ធ្ងន់ ដូច្នេះវាសមស្របសម្រាប់ផលិតកម្មជំនួសការនាំចូល ។

ការចេញអាជ្ញាប័ណ្ណ ដែលមានលក្ខណៈការិយាធិបតេយ្យស្មុគស្មាញក្នុងផ្នែកសំណង់ វាអាចកាត់បន្ថយសមត្ថភាពប្រកួតប្រជែងក្នុងផ្នែកនេះ ។ គេប៉ាន់ស្មានថា ត្រូវចំណាយពេលប្រហែល ៧១០ថ្ងៃ ដើម្បីទទួលបានលិខិតអនុញ្ញាតឲ្យសាងសង់សព្វគ្រប់ដើម្បីបញ្ចប់គម្រោង ធៀបនឹងប្រទេសវៀតណាម ត្រឹម ២០០ថ្ងៃ និង ប្រទេសថៃ ត្រឹម ១៥០ថ្ងៃ (UNDP 2009)។ ក្រុមហ៊ុនសំណង់នៅកម្ពុជា បញ្ជាក់ថា ជារឿយៗខ្លួនត្រូវបង់កម្រៃក្រៅផ្លូវការ ដើម្បីកាត់បន្ថយរយៈពេល

ទទួលបានការអនុញ្ញាតតាមច្បាប់ ។ ស្តង់ដារសំណង់ ហាក់ដូចនៅធូររលុង ។ ក្រុមហ៊ុនសំណង់បរទេស អះអាងថា ជារឿយៗពួកគេបានប្រើស្តង់ដារសំណង់មកពីប្រទេសរបស់ពួកគេ ពីព្រោះអាជ្ញាធរហាក់ដូចមិនបានត្រួតពិនិត្យគម្រោងយ៉ាងដិតដល់ទេ ។ កង្វះលិខិតបទដ្ឋាន អាចនាំឲ្យមានគុណភាពអន់ និង សំណង់គ្រោះថ្នាក់ ។

ធនធានរ៉ែ នៅកម្ពុជា ភាគច្រើនមិនទាន់បានរុករកនៅឡើយ ។ ដើម្បីទាក់ទាញក្រុមហ៊ុនរ៉ែបរទេស និងក្នុងស្រុក ច្បាប់ស្តីពីការគ្រប់គ្រងរ៉ែ និងការយករ៉ែ ត្រូវបានប្រកាសឲ្យប្រើនៅថ្ងៃទី ១៣ កក្កដា ២០០១ ។ យោងតាមគោលនយោបាយរុករករ៉ែរបស់កម្ពុជា អ្នកវិនិយោគត្រូវស្នើសុំពីក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា (CDC) នូវអាជ្ញាប័ណ្ណរុករករ៉ែ សម្រាប់រយៈពេលពី ២ ទៅ ៦ឆ្នាំ ហើយបន្ទាប់មក ត្រូវរៀបចំម្ភារសិក្សាពីភាពអាចធ្វើបាននៅក្នុងតំបន់គោលដៅ ។ ក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល ផ្តល់ការជួយឧបត្ថម្ភ ជាការណែនាំខាងបច្ចេកទេស ។ បន្ទាប់ពីការរុករករ៉ែបានជោគជ័យ វិនិយោគិន និងក្រុមហ៊ុន ត្រូវប្រគល់ផែនការគម្រោងមេមួយសម្រាប់ការអភិវឌ្ឍរ៉ែ ។ ប្រសិនបើទទួលបានជោគជ័យ CDC នឹងផ្តល់អាជ្ញាប័ណ្ណឲ្យយករ៉ែ ហើយក៏មានការតម្រូវឲ្យបង់សួយ និងថ្លៃឈ្នួលកន្លែងយករ៉ែ ជូនរដ្ឋ ។

ក្នុងពីរបីឆ្នាំកន្លងទៅ ក្រុមហ៊ុនបរទេសមកពី អូស្ត្រាលី ចិន កូរ៉េខាងត្បូង ថៃ សហរដ្ឋអាមេរិក បានចូលរួមរុករករ៉ែនៅកម្ពុជា-ទាំងរ៉ែក្នុងដី ប្រេងកាត និង ហ្គាសក្នុងសមុទ្រ ។ ថ្មីៗនេះ រដ្ឋាភិបាល បានលើកទឹកចិត្ត និងសំរួលដល់វិនិយោគក្នុងការយករ៉ែ ដោយសារមានការរកឃើញរ៉ែសំខាន់ៗមួយចំនួន ដូចជា ក្រូម បុកស៊ីត ទង់ដែង មាស នីកែល ត្បូងថ្ម ថ្មកំបោរ តង់ស្តែន ប្រេងកាត និង ហ្គាស ។ ជាលទ្ធផល ការយករ៉ែ បានប្តូរពីការជីកទ្រង់ទ្រាយតូចដោយសហគមន៍មូលដ្ឋានទៅជាការទាញយករ៉ែទ្រង់ទ្រាយធំដោយក្រុមហ៊ុនធំៗ ។ រដ្ឋាភិបាល ផ្តល់រួចហើយនូវអាជ្ញាប័ណ្ណរុករករ៉ែ សម្រាប់ ១០០កន្លែងផ្សេងគ្នា ហើយដំណើរការហាក់ដូចកំពុងបង្កើនល្បឿន ។

ការយករ៉ែ រួមចំណែកតែ 0,៤១% ប៉ុណ្ណោះ ដល់ ផសស នៅកម្ពុជា ក្នុងឆ្នាំ២០០៦ (ឆ្នាំចុងក្រោយដែលមានទិន្នន័យ) និងបានកើន 0,0២ ឯកតាភាគរយ ខ្ពស់ជាងក្នុងឆ្នាំ២០០៥ ។ តាមការប៉ាន់ស្មាន ការយករ៉ែប្រើពលករ ១៩.000នាក់ ឬ 0,២% នៃចំនួនការងារសរុបក្នុងឆ្នាំ២០០៥ និង ២0.000នាក់ ក្នុងឆ្នាំ២០០៦ ឬ 0,៣% នៃចំនួនការងារសរុប (IMF 2008) ។

## ៣. ក្របខ័ណ្ឌគោលនយោបាយឧស្សាហកម្ម

### *៣.១. គោលនយោបាយឧស្សាហកម្មទូទៅ*

រដ្ឋាភិបាលបានបង្កើតផែនការអភិវឌ្ឍន៍ជាច្រើន ជាអាទិ ផែនការអភិវឌ្ឍន៍សេដ្ឋកិច្ច-សង្គមកិច្ចឆ្នាំ១៩៩៦-២000 ផែនការអភិវឌ្ឍន៍សេដ្ឋកិច្ច-សង្គមកិច្ចឆ្នាំ២០០១-២០០៥ គម្រោងវិនិយោគសាធារណៈឆ្នាំ១៩៩៦-៩៨ យុទ្ធសាស្ត្រជាតិកាត់បន្ថយភាពក្រីក្រឆ្នាំ២០០៣-0៥ គោលដៅអភិវឌ្ឍន៍សហស្សវត្សរ៍កម្ពុជា គម្រោងអភិវឌ្ឍន៍យុទ្ធសាស្ត្រជាតិ (NSPD) ឆ្នាំ២០០៦-១0 ។ NSPD (2006-10) វាយលំអិតពីគោលដៅ និងអាទិភាពខាងគោលនយោបាយ ដែលបានដាក់ចេញក្នុងយុទ្ធសាស្ត្រចតុកោណ និងគ្របដណ្តប់លើទិដ្ឋភាពជាច្រើននៃកំណើនសេដ្ឋកិច្ច មានជាអាទិ អភិបាលកិច្ច ការពង្រឹងវិស័យកសិកម្ម កំណើនវិស័យឯកជន និង ការបង្កើតការងារ ការស្តារជួសជុលនិងសាងសង់ហេដ្ឋារចនាសម្ព័ន្ធ ការកសាងសមត្ថភាព និងការអភិវឌ្ឍធនធានមនុស្ស ។ NSDP (2006-10) មានដាក់បញ្ចូលទាំងឯកសារគោលនយោបាយផ្សេងៗជាច្រើន ដើម្បីផ្តល់ជាក្របខ័ណ្ឌសម្រាប់ កំណើន ការងារ សមធម៌ និង ប្រសិទ្ធភាព ក្នុងការកាត់បន្ថយភាពក្រីក្រ និងសម្រេចបានការអភិវឌ្ឍប្រកបដោយចីរភាព ។

ផែនការសកម្មភាពអភិវឌ្ឍន៍ឧស្សាហកម្មរបស់រដ្ឋាភិបាល (១៩៩៨-២០០៣ លើកឡើងក្នុង RGC 2002) មានគោលដៅពីរ គឺការគាំទ្រការអភិវឌ្ឍឧស្សាហកម្មផ្ដោតលើការនាំចេញ និង ការអភិវឌ្ឍទំនិញប្រើប្រាស់ជ្រើសរើសមួយចំនួនសម្រាប់ជំនួសការនាំចូល ។ គោលដៅទាំងនេះ អាចសម្រេចបានតាមការជម្រុញ៖ (១) ឧស្សាហកម្មប្រើប្រាស់កម្មករច្រើន ដូចជា ខាងផលិតផលកាត់ដេរ វត្ថុក្មេងលេង និង គ្រឿងសម្រាប់បំពាក់ជើង (២) ឧស្សាហកម្មផ្អែកលើធនធានធម្មជាតិ ដូចជា ការកែច្នៃត្រីនិងសាច់ ស៊ីម៉ង់ត៍ ឥដ្ឋ ក្បឿង (៣) សហគ្រាសធុនតូច និងមធ្យម (៤) កសិឧស្សាហកម្ម តាមរយៈការពង្រឹងក្របខ័ណ្ឌច្បាប់សម្រាប់ការគ្រប់គ្រងដីក្នុងរយៈពេលវែង ដោយផ្ដល់គ្រឿងលើកទឹកចិត្តខាងពន្ធដារដល់សហគ្រាសកែច្នៃផលិតផលកសិកម្ម (៥) ការផ្ទេរបច្ចេកវិជ្ជា និងបង្កើនគុណភាពផលិតផលឧស្សាហកម្ម (៦) ការបង្កើតតំបន់ឧស្សាហកម្ម តាមរយៈការអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធ ការកែលំអគុណភាពសេវាកម្ម ការលើកទឹកចិត្តវិនិយោគ និង (៧) ទេសចរណ៍វប្បធម៌ និងធម្មជាតិ ។

ក្រាហ្វិក ៨៖ យុទ្ធសាស្ត្រចតុកោណ




*ប្រភព៖ RGC (2009)*

របាយការណ៍របស់ធនាគារពិភពលោក (២០០៩) បានបង្ហាញថា កម្ពុជាមានឧបករណ៍គោលនយោបាយឧស្សាហកម្មច្រើនប្រភេទ ដូចជា កូតានាំចេញពលកម្មស្តង់ដារ រយៈពេលរួចពន្ធ ការលើកលែងពន្ធនាំចូល និងអាករលើតម្លៃបន្ថែម (VAT) ចំពោះធាតុចូលដែលនាំចូលសម្រាប់ផលិតទំនិញនាំចេញ ការលើកទឹកចិត្តវិនិយោគ ការជម្រុញការនាំចេញ តំបន់សេដ្ឋកិច្ចពិសេស (SEZ) មូលនិធិសម្រាប់ការទទួលបានទីផ្សារនាំចេញ វេទិការដ្ឋាភិបាល-វិស័យឯកជន អន្តរាគមន៍លើខ្សែរយៈកំណត់តម្លៃ និង សម្បទានដីសេដ្ឋកិច្ច ។ របាយការណ៍ក៏បានគូសបញ្ជាក់ដែរថា ឧបករណ៍គោលនយោបាយភាគច្រើន ខ្វះគណនេយ្យភាព និងការសម្របសម្រួល ហើយគ្រឿង

លើកទឹកចិត្ត ក៏ផ្តោតមិនចំគោលដៅ ។ ដូច្នេះ ត្រូវប្រឹងប្រែងជាអាទិភាព បង្កើនតម្លាភាព និង គណនេយ្យភាព ក្នុងការអនុវត្តឧបករណ៍គោលនយោបាយដែលមានស្រាប់ ។

តំបន់សេដ្ឋកិច្ចពិសេស (SEZ)

គម្រោងការ SEZ បានប្រកាសចេញក្នុងឆ្នាំ២០០៥ ដោយអនុក្រឹត្យលេខ១៤៨ ស្តីពីការបង្កើត និងគ្រប់គ្រងតំបន់សេដ្ឋកិច្ចពិសេស (រួមមាន តំបន់ផលិតកែច្នៃនាំចេញ និង តំបន់ពាណិជ្ជកម្មសេរី) ដើម្បីទាក់ទាញឧស្សាហកម្មដែលលែងរស់រានបាននៅក្នុងប្រទេសថៃ ម៉ាឡេស៊ី តៃវ៉ាន់ ឬជប៉ុន ។ SEZ មានផ្តល់សេវាកម្មច្រកចេញចូលតែមួយ តាមរយៈការិយាល័យរដ្ឋបាល SEZ ដែលមានសមាជិកជាតំណាងមកពី គណៈកម្មាធិការតំបន់សេដ្ឋកិច្ចពិសេសកម្ពុជា អគ្គនាយកដ្ឋានគយ និងរដ្ឋាករ កាំកុងត្រូល ក្រសួងពាណិជ្ជកម្ម ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ ។ រហូតមកទល់ពេលនេះ រដ្ឋាភិបាលបានអនុម័តតំបន់សេដ្ឋកិច្ចពិសេសចំនួន ២១តំបន់ នៅតាមបណ្តោយព្រំដែនប្រទេសថៃ និង វៀតណាម (ខេត្តកោះកុង ប៉ោយប៉ែត បាវិត ភ្នំដិន) នៅក្រុងព្រះសីហនុ និងរាជធានីភ្នំពេញ ក្នុងនេះមាន ៦តំបន់ បានចាប់ធ្វើប្រតិបត្តិការហើយ ។ អ្នកអភិវឌ្ឍន៍តំបន់ និង អ្នកវិនិយោគក្នុងតំបន់ទាំងអស់ ទទួលបានគ្រឿងលើកទឹកចិត្ត ដូចមានសង្ខេបក្នុងតារាង ៣៖

**តារាង ៣៖ គ្រឿងលើកទឹកចិត្តសម្រាប់អ្នកអភិវឌ្ឍន៍ និងវិនិយោគិន SEZ**

| អត្ថប្រយោជន៍ | គ្រឿងលើកទឹកចិត្ត |
|---|---|
| អ្នកអភិវឌ្ឍន៍តំបន់ | • រួចពន្ធលើប្រាក់ចំណូលសម្រាប់រយៈពេលមិនលើស ៩ឆ្នាំ<br>• ការនាំចូលបរិក្ខារ និងសម្ភារៈសំណង់សម្រាប់កសាងហេដ្ឋារចនាសម្ព័ន្ធក្នុងតំបន់ បានរួចពន្ធនាំចូល និងពន្ធផ្សេងទៀត<br>• ការលើកលែងពន្ធគយលើការនាំចូលគ្រឿងចក្រ និងឧបករណ៍សម្រាប់កសាងផ្លូវភ្ជាប់ពីទីក្រុង ទៅតំបន់នោះ និង ហេដ្ឋារចនាសម្ព័ន្ធសម្រាប់សេវាសាធារណៈផ្សេងទៀត<br>• ការនាំចូលជាបណ្តោះអាសន្ននូវមធ្យោបាយដឹកជញ្ជូន និង គ្រឿងចក្រសម្រាប់កសាងហេដ្ឋារចនាសម្ព័ន្ធ<br>• សម្បទានដីពីរដ្ឋសម្រាប់បង្កើត SEZ តាមបណ្តោយព្រំដែន ឬ តំបន់ដាច់ដោយឡែក |
| អ្នកវិនិយោគក្នុងតំបន់ | • គ្រឿងលើកទឹកចិត្តខាងពន្ធគយ និងពន្ធដារ ដូចគ្នានឹងគម្រោងវិនិយោគមានលក្ខណៈសម្បត្តិគ្រប់គ្រាន់ផ្សេងទៀត<br>• អ្នកវិនិយោគក្នុងតំបន់ដែលទទួលបានគ្រឿងលើកទឹកចិត្តជា VAT មានអត្រា 0% ត្រូវកត់ត្រាទឹកប្រាក់ពន្ធដែលលើកលែង លើរាល់ការនាំចូលទាំងអស់ ។ កំណត់ត្រានេះនឹងត្រូវលុបចោល ប្រសិនបើធាតុចេញនៃផលិតកម្មត្រូវបាននាំចេញទៅវិញ ។ ក្នុងករណីដែលធាតុចេញនៃផលិតកម្ម ត្រូវបាននាំចូលទៅក្នុងទីផ្សារក្នុងស្រុក អ្នកវិនិយោគក្នុងតំបន់ត្រូវបង់មកវិញនូវ VAT ដែលបានកត់ត្រា ដោយធៀបនឹងបរិមាណនៃការនាំចេញ |
| ទូទៅ | • សិទ្ធិផ្ទេរប្រាក់ចំណូលលើវិនិយោគ និង បៀវត្សរ៍ទាំងអស់ ដែលទទួលបានក្នុងតំបន់ ទៅកាន់ធនាគារមានទីតាំងក្នុងប្រទេសផ្សេងទៀត បន្ទាប់ពីបានបង់ពន្ធរួច<br>• ការធានាលើវិនិយោគដូចមានចែងក្នុងមាត្រា៨ ៩ និង ១០ នៃច្បាប់ស្តីពីវិនិយោគ និងបទបញ្ញត្តិពាក់ព័ន្ធនានា<br>• គ្មានការរើសអើងចំពោះជនបរទេស មិនធ្វើជាតូបនីយកម្ម និង មិនធ្វើការកំណត់ថ្លៃ |

តារាង ៤៖ ការវិវត្តគោលនយោបាយពាណិជ្ជកម្ម

| ឆ្នាំ | គោលនយោបាយ |
|---|---|
| 1960s | ការនាំចេញផលិតផលកសិកម្ម ភាគច្រើន ស្រូវ កៅស៊ូ និង ពោត |
| 1970s | ការដួលរលំស្ទើរតែទាំងស្រុងនៃពាណិជ្ជកម្មក្រៅប្រទេស |
| 1980s | ប្រព័ន្ធពាណិជ្ជកម្មថ្មីសម្រាប់គ្រប់គ្រងលើកម្រិត និងធាតុផ្សំនៃពាណិជ្ជកម្ម តាមរយៈ ការរឹតត្បិតលើបរិមាណ និង អង្គភាពធ្វើពាណិជ្ជកម្មរបស់រដ្ឋ ។ ពន្ធគយ និងពន្ធលើពាណិជ្ជកម្ម គេដាក់អនុវត្តក្នុងបំណងរកប្រាក់ចំណូលតែប៉ុណ្ណោះ ។<br>សេរីភាវូបនីយកម្មផ្តោតលើទីផ្សារនៅចុងទសវត្សរ៍១៩៨០ បានលុបបំបាត់សិទ្ធិផ្តាច់មុខរបស់រដ្ឋលើពាណិជ្ជកម្មក្រៅប្រទេស ។<br>ច្បាប់វិនិយោគបរទេស ដែលប្រកាសឲ្យប្រើក្នុងឆ្នាំ១៩៨៩ បានអនុញ្ញាតឲ្យក្រុមហ៊ុនឯកជនចូលរួមក្នុងពាណិជ្ជកម្មក្រៅប្រទេស ។ |
| 1990s | ចាប់ពីឆ្នាំ១៩៩៣ មក ការរឹតត្បិតលើលទ្ធភាពរបស់សហគ្រាស និងបុគ្គល ដើម្បីចូលរួមក្នុងពាណិជ្ជកម្មអន្តរជាតិ ត្រូវបានដកចេញមួយភាគធំ ។ |
| 1994 | ការរឹតត្បិតខាងបរិមាណលើពាណិជ្ជកម្មទាំងអស់ ត្រូវបានលុបចោលក្នុងឆ្នាំ១៩៩៤ ។ |
| 1996 | កម្ពុជាទទួលបានលក្ខខណ្ឌអនុគ្រោះ MFN ពីសហរដ្ឋអាមេរិក ។ |
| 1997 | កម្ពុជាទទួលបានលក្ខខណ្ឌអនុគ្រោះ GPS ដែលសំដៅបង្កើនសមាហរណកម្ម ប្រទេសលូតលាស់តិចជាងគេ ឲ្យចូលក្នុងសេដ្ឋកិច្ចពិភពលោក ។ |
| 1999 | នៅខែមេសា កម្ពុជាបានក្លាយជាសមាជិកអាស៊ាន ។ បានប្តេជ្ញាកាត់បន្ថយជាបណ្តើរៗនូវអត្រាពន្ធគយភាគច្រើន ត្រឹមឆ្នាំ២០១០ សម្រាប់ពាណិជ្ជកម្មជាមួយសមាជិកអាស៊ាន ។ |
| 2000 | ការសុំចូលជាសមាជិកនៃ WTO បាននាំឲ្យមានកែលំអរចនាសម្ព័ន្ធពន្ធគយ ។ |
| 2003 | កម្ពុជាបានចូលជាសមាជិក WTO ។ |
| 2005 | កូតាទីផ្សារនាំចេញនៅសហរដ្ឋអាមេរិក និង សភាពអឺរ៉ុប ត្រូវផុតកំណត់ ។ |
| 2008 | ការរឹតត្បិតខាងបរិមាណលើការនាំចូលវាយនភ័ណ្ឌ និងសំលៀកបំពាក់មកពីប្រទេសចិន បានផុតកំណត់នៅចុងឆ្នាំនេះ ។ |

*ប្រភព៖ RGC (2002) cited in UNDP (2004)*

### គោលនយោបាយពាណិជ្ជកម្ម

នៅចុងទសវត្សរ៍១៩៨០ ប្រទេសកម្ពុជាចាប់ផ្តើមអនុវត្តរបបទីផ្សារសេរី ដោយមានការលុបចោលសិទ្ធិផ្តាច់មុខរបស់រដ្ឋ លើពាណិជ្ជកម្មក្រៅប្រទេសនៅឆ្នាំ១៩៨៧ និងការប្រកាសឲ្យប្រើច្បាប់វិនិយោគបរទេសនៅឆ្នាំ១៩៨៩ ដែលអនុញ្ញាតឲ្យក្រុមហ៊ុនឯកជនចូលរួមក្នុងពាណិជ្ជកម្មក្រៅប្រទេស ។ នៅដើមទសវត្សរ៍១៩៩០ គោលនយោបាយពាណិជ្ជកម្ម មានការធ្វើសេរីភាវូបនីយកម្មយ៉ាងខ្លាំង ដោយលុបបំបាត់ ការរឹតត្បិតលើក្រុមហ៊ុននិងបុគ្គលដែលចូលរួមក្នុងជំនួញអន្តរជាតិ ការរឹតត្បិតភាគច្រើនខាងបរិមាណ និង ការផ្តល់អាជ្ញាប័ណ្ណលើការនាំចូល ។ នៅចុងទសវត្សរ៍១៩៩០ គឺជាដំណាក់កាលឈានទៅមុខដោយចេតនា ឆ្ពោះទៅកាន់របបពាណិជ្ជកម្មកាន់តែសេរីខ្លាំង ។ ក្នុងឋានៈជាសមាជិកនៃសមាគមប្រជាជាតិអាស៊ីអាគ្នេយ៍ (អាស៊ាន) កម្ពុជា ក៏ជាសមាជិកនៃតំបន់ពាណិជ្ជកម្មសេរីអាស៊ាន ហើយត្រូវប្តេជ្ញាកាត់បន្ថយពន្ធគយ លើពាណិជ្ជកម្មជាមួយប្រទេសអាស៊ានឯទៀតៗ ។ កម្ពុជា ត្រូវកាត់បន្ថយអត្រាពន្ធគយបន្ថែមទៀត និងកែទម្រង់រចនាសម្ព័ន្ធថែមទៀត

នៅពេលបានក្លាយជាសមាជិកពេញសិទ្ធិនៃអង្គការពាណិជ្ជកម្មពិភពលោក (WTO) ក្នុងឆ្នាំ២០០៣ ។ តារាង ៤ សង្ខេបពីការផ្លាស់ប្តូរសំខាន់ៗក្នុងគោលនយោបាយពាណិជ្ជកម្មក្រៅប្រទេស ។

**គោលនយោបាយលើវិនិយោគផ្ទាល់ពីបរទេស**

ជាចំណែកមួយនៃសេរីភាវូបនីយកម្មពាណិជ្ជកម្ម រដ្ឋាភិបាល បានដាក់អនុវត្តរបបវិនិយោគ ដើម្បីទាក់ទាញវិនិយោគបរទេស ។ រដ្ឋសភាជាតិ បានអនុម័តច្បាប់ស្តីពីវិនិយោគក្នុងឆ្នាំ១៩៩៤ ។ ច្បាប់នេះ បានធ្វើវិសោធនកម្មក្នុងឆ្នាំ២០០៣ ដើម្បីកាត់បន្ថយភាពមិនច្បាស់លាស់ បង្កើនតម្លាភាព និងកាត់បន្ថយបន្ទុករដ្ឋបាល ។

ច្បាប់ស្តីពីវិនិយោគ បានផ្តល់គ្រឿងលើកទឹកចិត្តច្រើនថែមទៀត ដល់វិនិយោគិនបរទេស មានជាអាទិ៍៖

- រយៈពេលលើកលែងពន្ធ រួមមាន រយៈចាប់ផ្តើម រយៈពេលអាទិភាព និងរយៈពេលបីឆ្នាំ ។ រយៈពេលចាប់ផ្តើម គឺឆ្នាំទី១ នៃការទទួលបានប្រាក់ចំណេញ ឬ ៣ឆ្នាំ បន្ទាប់ពីគម្រោងវិនិយោគដែលមានលក្ខណៈគ្រប់គ្រាន់ រកចំណូលបានជាលើកទីមួយ ដោយត្រូវយកឆ្នាំណាមួយដែលមកដល់មុន ។ រយៈពេលអាទិភាព មានកំណត់ច្បាស់ក្នុងច្បាប់គ្រប់គ្រងហិរញ្ញវត្ថុ ។
- ការលើកលែងពន្ធគយ ១០០% លើធាតុចូលដែលនាំចូល និង ទំនិញមូលធន ប្រសិនបើមានការនាំចេញ ៨០% នៃផលិតកម្ម ឬមានទីតាំងក្នុងតំបន់ជំរុញពិសេស ។
- ការលើកលែងពន្ធនាំចេញ ១០០% ។
- កិច្ចសន្យាជួលដីមានរយៈពេលដល់ ៩៩ឆ្នាំ និងអាចបន្តទៀតបាន ។

ច្បាប់ស្តីពីវិនិយោគ ផ្តល់គ្រឿងលើកទឹកចិត្តច្រើនជាងប្រទេសឯទៀតៗក្នុងតំបន់ ហើយបើកចំហជាង ចំពោះវិនិយោគិនបរទេស (តារាង ៥) ។

**តារាង ៥៖ ការប្រៀបធៀបច្បាប់វិនិយោគបរទេសក្នុងតំបន់**

| ប្រទេស | គ្រឿងលើកទឹកចិត្តជាពន្ធលើប្រាក់ចំណូល | អត្រាពន្ធលើប្រាក់ចំណេញ | ពន្ធនាំចូល |
|---|---|---|---|
| កម្ពុជា | រួចពន្ធរហូតដល់ ៦ឆ្នាំ | ២០% | រួចពន្ធទាំងស្រុងលើធាតុចូល និង ទំនិញមូលធន ប្រសិនបើមានការនាំចេញ ៨០% នៃផលិតផល ឬមានទីតាំងក្នុងតំបន់ពិសេស ។ |
| ឡាវ | មាន តែមិនបានបញ្ជាក់ | ២០-៣៥% | ពន្ធ១%លើគ្រឿងម៉ាស៊ីន និង គ្រឿងបន្លាស់ ។ វត្ថុធាតុដើម និងសម្ភារៈអន្តរការីនាំចេញទៅវិញ ត្រូវបានរួចពន្ធទាំងស្រុង ។ |
| មីយ៉ាន់ម៉ា | រួចពន្ធ៣ឆ្នាំ នឹងអាចបន្តប្រសិនបើមានប្រយោជន៍ដល់រដ្ឋ | ៣០% | រួចពន្ធ ឬបន្ថយពន្ធលើគ្រឿងម៉ាស៊ីន និង គ្រឿងបន្លាស់សម្រាប់ផលិត ។ រួចពន្ធ ឬបន្ថយពន្ធរយៈពេល៣ឆ្នាំ លើវត្ថុធាតុដើម ។ |
| ថៃ | រួចពន្ធ ៣-៨ឆ្នាំ | ៣០% | អាចរួចពន្ធទាំងស្រុងលើគ្រឿងម៉ាស៊ីន និង រួចពន្ធ ៥ឆ្នាំ លើវត្ថុធាតុដើម និងសម្ភារៈចាំបាច់ៗ ។ |
| វៀតណាម | រួចពន្ធ ១-៤ឆ្នាំ បូករយៈពេលបន្តជាប់ពន្ធត្រឹម ៥០% | ១០-២០% | គ្រឿងម៉ាស៊ីន វត្ថុធាតុដើម គ្រឿងបន្លាស់សម្រាប់បម្រើការនាំចេញ រួចពន្ធទាំងស្រុង។ |

*ប្រភព៖ Hing (2003)*

## ៤. សេចក្តីសន្និដ្ឋាន

កម្ពុជា ព្យាយាមកសាងសេដ្ឋកិច្ចរបស់ខ្លួនឡើងវិញ តាមរយៈគោលនយោបាយសង្គមនិយម នៅដើមទសវត្សរ៍១៩៨០ ។ ប៉ុន្តែកម្ពុជាបានជំនួសសេដ្ឋកិច្ចតាមផែនការប្រមូលផ្តុំរបស់ខ្លួន ដោយសេដ្ឋកិច្ចទីផ្សារ ហើយចាប់ធ្វើសេរីភាវូបនីយកម្មជាបន្តបន្ទាប់នៅចុងទសវត្សរ៍១៩៨០ ដើម្បីទាក់ទាញវិនិយោគិនបរទេស ។ ក្នុងនេះ កម្ពុជាបានផ្តល់ឲ្យវិនិយោគិនបរទេសនូវគ្រឿងលើកទឹកចិត្ត ច្រើនជាងប្រទេសឯទៀតក្នុងតំបន់ ។ បន្ទាប់ពីទទួលបានលក្ខខណ្ឌអនុគ្រោះ MFN និង GSP ក្នុងឆ្នាំ១៩៩៦ និង ១៩៩៧ វិស័យកាត់ដេរបានក្លាយជាឧស្សាហកម្មមាំទាំបំផុត និង ជាប្រភពការងារ និងចំណូលរូបិយវត្ថុបរទេសដ៏សំខាន់ ។

ការធ្វើសមាហរណកម្មរបស់កម្ពុជា ចូលក្នុងសហគមន៍តំបន់ និង អន្តរជាតិ (អាស៊ាន ឆ្នាំ១៩៩៩ និង WTO ឆ្នាំ២០០៣) រំពឹងថានឹងផ្តល់ឲ្យកម្ពុជានូវទីផ្សារធំជាងមុន ព្រមទាំងបញ្ហាប្រឈមសម្រាប់ឧស្សាហកម្មក្នុងស្រុក ។ Di Maio (2008) បានគូសបញ្ជាក់ពីបទបញ្ញត្តិថ្មីៗរបស់ WTO ដែលរឹតត្បិតការប្រើប្រាស់ឧបត្ថម្ភធន និង ការគាំពារដោយរើសមុខ ជាពិសេសឧបត្ថម្ភធនសម្រាប់ការនាំចេញ (មានទាំងតំបន់ផលិតកែច្នៃនាំចេញ) និង ឧបត្ថម្ភធនជម្រុញការប្រើប្រាស់ធាតុចូលផលិតក្នុងស្រុក (ជាជាងរបស់នាំចូល) ត្រូវបានហាមឃាត់ ហើយការតម្រូវជាភាគរយនៃធាតុផ្សំផលិតក្នុងស្រុក និងការរឹតត្បិតជាបរិមាណលើការនាំចូល ក៏មិនស្របច្បាប់ដែរ ។ កិច្ចព្រមព្រៀង WTO ថ្មី អនុញ្ញាតឲ្យសមាជិកប្រើវិធានការគាំពារដើម្បីការពារខ្លួន តែក្នុងពីរករណីប៉ុណ្ណោះ គឺ (១) នៅពេលការនាំចូលអាចធ្វើឲ្យជញ្ជីងទូទាត់បាត់ស្ថិរភាព (២) នៅពេលការប្រកួតប្រជែងពីបរទេស គំរាមកំហែងដល់ឧស្សាហកម្មជាក់លាក់ណាមួយ ដោយសារការនាំចូលស្ទុះឡើង និងរបៀបរបបធ្វើពាណិជ្ជកម្មមិនយុត្តិធម៌ ។ ដោយសារហេតុផលនេះ គោលនយោបាយឧស្សាហកម្មកម្ពុជា ត្រូវតែខុសប្លែកពីគោលនយោបាយប្រទេសឯទៀត ឧ. ខ្លាអាស៊ីខាងកើត (កូរ៉េខាងត្បូង ហុងកុង សិង្ហបុរី និង តៃវ៉ាន់) ឬ អាស៊ាន៤ (ម៉ាឡេស៊ី ថៃ ឥណ្ឌូនេស៊ី និង ហ្វីលីពីន) ក្នុងអតីតកាល ។ ស្រដៀងគ្នានឹងអាស៊ាន៤ ដែរ កម្ពុជាបានពឹងផ្អែកយ៉ាងខ្លាំងលើយុទ្ធសាស្ត្រកំណើនជម្រុញដោយវិនិយោគផ្ទាល់ពីបរទេស ប៉ុន្តែបានដករបាំងពន្ធគយ ការរឹតត្បិតលើការនាំចូល និងការតម្រូវឲ្យប្រើរបស់ក្នុងស្រុក លឿនជាង អាស៊ាន៤ ។ គោលនយោបាយឧស្សាហកម្មគួរតែឆ្លុះបញ្ចាំងពីការពិតជាក់ស្តែងដែល សេរីភាវូបនីយកម្មនៅកម្ពុជាបានកើតឡើងយ៉ាងលឿន ។ ការកំណត់គោលនយោបាយសមស្រប គួរជាបញ្ហាចំបងដែលក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល និងរដ្ឋាភិបាលកម្ពុជាត្រូវពិចារណា ។ នេះក៏ជាបញ្ហាដែលត្រូវសិក្សាស្រាវជ្រាវទៅអនាគតដែរ ។

## ឯកសារយោង


Asian Development Bank (2004), *Cambodia's Garment Industry: Meeting the Challenge of the Post-quota Environment* (Manila: ADB)

Asian Productivity Organisation (2009), *APO Productivity Data Book* (Tokyo: APO)

Ballard, Brett (2005), *Pro-poor Tourism in the Greater Mekong Sub-region: A Survey of Five Case Studies* (Phnom Penh: CDRI)

Cambodian Development Research Institute (2007), *Annual Development Review 2006-2007* (Phnom Penh: CDRI)

Cuyver L., J. Plasmans, R. Soeng & D. Van Den Bulcke (2008), *Determinants of Foreign Direct Investment in Cambodia: Country-Specific Factor Differentials*, Research Paper 2008-003 (Antwerp: University of Antwerp)

Economic Institute of Cambodia (2007), *Export Diversification and Value Addition for Human Development* (Phnom Penh: EIC)

Hatsukano Naomi (2010), *Industrial Location in Cambodia - Industrial Policies and Economic Statistics,* in Kuroiwa (ed.), Spatial Statistics and Industrial Location in CLMV: An Interim Report, Chosakenkyu Hokokusho, Institute of Developing Economies-Japan External Trade Organisation

Hang Chuon Naron (2009), Cambodian Economy Charting the Course of a Brighter Future: A Survey of Progress, Problems and Prospects (Phnom Penh: SNEC)

Hing Thoraxy (2003), *Cambodia's Investment Potential* (Phnom Penh: JICA)

Hing Vutha & Tuot Sokphally (2007), *Pro-Poor Tourism: Siem Reap Case Study* (Phnom Penh: CDRI)

Hing Vutha, Chan Sophal & Sok Sina (2007), "Cambodia's Agricultural Production and Trade", *Cambodian Economic Review,* Issue 3, pp. 69-93 (Phnom Penh: CDRI)

International Finance Cooperation (2008), *Microfinance in Cambodia: Taking the Sector to the Next Level,* Business Issue Bulletin (Phnom Penh: IFC)

International Monetary Fund (2010), *Republic of Korea: Article IV Consultation—Staff Report* (Washington, DC: IMF)

International Monetary Fund (2008), C*ambodia in World Economic Outlook Database* (Washington, DC: IMF)

Jalilian, Hossein, Chan Sophal, Glenda Reyes, Siang Chanhang, Phann Dalis & Pon Dorina (2009), *The Global Financial Crisis and Developing Countries: Cambodia* (Phnom Penh: CDRI)

Japan International Cooperation Agency (2007), *The Study on Economic Policy Support in the Kingdom of Cambodia* (Phnom Penh: JICA)

Kenichi Ohno (2006), Chapter 1: Integral Manufacturing: The Way Forward for Vietnam, in Kenichi Ohno (ed.), *Industrial Policy Formulation in Thailand, Malaysia and Japan* (Hanoi: National Graduate Institute of Policy Studies) pp.1-16

Lin, Justin Yifu (2010), *New Structural Economics: A Framework for Rethinking Development* (Washington, DC: World Bank)

Michele Di Maio (2008), *Industrial Policies in Developing Countries: History and Perspectives* (Macerata,Italy: University of Marcerata Department of Economics)

Ministry of Commerce (2010), *Monthly Report* (Phnom Penh: MOC)

Ministry of Economic and Finance (2010), *Macro-economic Framework 2010,* (Phnom Penh: MEF)

Ministry of Tourism (2010), *Monthly Report,* (Phnom Penh: MOT)

National Bank of Cambodia (2008), *Annual Report 2008,* (Phnom Penh)

National Institute of Statistics (2006, 2007), National Accounts of Cambodia (Phnom Penh: MOP)

Natsuda Kaoru, Goto Kenta & Thoburn John (2009), "Challenges to the Cambodian Garment Industry in the Global Garment Value Chain", RCAPS Working Paper No. 09-3, http://www.apu.ac.jp/rcaps/modules/publication/content/RCAPS_WP_09-3.pdf (accessed 24 October 2010)

Royal Government of Cambodia (2009), *National Strategic Development Plan Update 2009–2013* (Phnom Penh: RGC)

Royal Government of Cambodia (2002), *National Poverty Reduction Strategy 2003–2005* (Phnom Penh: RGC)

Siang Chan Hang (2009), "Impacts of the Global Economic Crisis on Garment Workers and Remittances: Lessons from Cambodia", ARTNeT-GMS Notes, Brief No. 3

Sin Meng Srun (2009), "Rice for Economic Growth and Food Security" (memo) (Phnom Penh: Economic, Social and Cultural Council)

Tong Kimsun and Hem Socheth with the assistance of Pon Dorina, Phann Dalis and Hem Metta (2010a), "Chinese Investment in Cambodia", in Hossein Jalilian (ed.), Annual Development Review 2009-2010 (Phnom Penh: CDRI) pp. 180-199

Tong Kimsun (2010b), "Agriculture as the Key Source of Growth: A Focus on Paddy and Rice Production", published under title "Promoting Export of Cambodia's White Gold", *Cambodia Development Review*, April–June 2010, Volume 14, Issue 2, pp. 6–10, (Phnom Penh: CDRI)

Tong Kimsun (2010c), "The Social Impact of the Global Recession on Cambodia: How the Crisis Impacts on Poverty", in Armin Bauer & Myo Thant (eds.), *Poverty and Sustainable Development in Asia: Impact and Responses to the Global Economic Crisis* (Manila: ADB) pp. 141-148

United Nations Development Programme (2004), *The Macroeconomics of Poverty Reduction in Cambodia* (Phnom Penh: UNDP)

United Nations Development Programme (2006), *A SWOT Analysis of the Cambodia Economy* (Phnom Penh: UNDP)

United Nations Development Programme (2009), *Cambodia Country Competitiveness: Driving Economic Growth and Poverty Reduction* (Phnom Penh: UNDP)

United States Aid Agency (2007), *Factory-Level Value Chain Analysis of Cambodia's Apparel Industry* (Phnom Penh: USAID)

World Bank (2009), *Sustaining Rapid Growth in a Challenging Environment: Cambodia Country Economic Memorandum* (East Asia and Pacific Region: World Bank)

World Bank (2006), *Doing Business in 2006* (Washington, DC: World Bank)

World Bank (2003), *Towards A Private Sector-Led Growth Strategy for Cambodia Volume 1: Value Chain Analysis* (East Asia and Pacific Region: Private Sector Development, World Bank)

# -II-
# ការវាយតម្លៃផលប៉ះពាល់នៃប្រទេសចិនលើការកាត់បន្ថយភាពក្រីក្រក្នុងមហាអនុតំបន់មេគង្គ៖ ករណីសិក្សានៅកម្ពុជា

*ដោយកញ្ញា អ៊ុច ចាន់ដារ៉ានី លោក សាំង ច័ន្ទហង្ស និង កញ្ញា ផាន់ ដាលីស*[១]

## ១. សេចក្ដីផ្ដើម

ក្នុងបីទសវត្សរ៍ចុងក្រោយនេះ ប្រទេសចិនមានបំលាស់ប្តូរសេដ្ឋកិច្ចធំសម្បើម ការអភិវឌ្ឍយ៉ាងលឿន និងការចូលរួមយ៉ាងសកម្មលើកិច្ចការនយោបាយ និងសេដ្ឋកិច្ចពិភពលោក និងក្នុងតំបន់ ។ ជោគជ័យគួរឲ្យស្ងើចនេះ បានក្លាយជាប្រធានបទវែកញែកយ៉ាងផុសផុល ដោយគេមើលឃើញប្រទេសចិនជាការគំរាមកំហែងផង និងឱកាសល្អខាងសេដ្ឋកិច្ចសម្រាប់ប្រទេសឯទៀតផង ។ ប្រទេសក្នុងមហាអនុតំបន់មេគង្គ (GMS) ដែលមានទីតាំងភូមិសាស្ត្រនៅជិតចិន ជាតំបន់មួយមានសក្តានុពលច្រើន និងសន្ទុះខ្លាំងសម្រាប់ការអភិវឌ្ឍ ហើយអាចក្លាយជាទីផ្សារយុទ្ធសាស្ត្រ និងផ្តល់ជារបៀបរបបស្ថាប័នសម្រាប់ការពង្រឹងសមាហរណកម្មតំបន់របស់ចិន ។

កម្ពុជា ចាត់ទុកប្រទេសចិនជាដៃគូអភិវឌ្ឍន៍ ដែលអាចជួយខ្លួនឲ្យរីកលូតលាស់បានកាន់តែលឿន និងកាត់បន្ថយគំលាតជាមួយប្រទេសអាស៊ីដទៃទៀត[២] ។ វត្តមានកាន់តែច្រើនរបស់ប្រទេសចិន នៅកម្ពុជា បានបំផុសការយកចិត្តទុកដាក់លើការរួមចំណែក និងផលប៉ះពាល់នៃប្រទេសនេះមកលើកម្ពុជា ។ ក្នុងការពិភាក្សាពីបញ្ហាទាំងនេះ យើងគួរធ្វើការសិក្សាពីកំណើនតួនាទីរបស់ចិននៅកម្ពុជា និងផលប៉ះពាល់របស់កំណើននេះ ។ ការសិក្សានេះ សំដៅពិនិត្យករណីប្រទេសកម្ពុជា និងវិភាគផលប៉ះពាល់តាមរយៈវិស័យបីសំខាន់ៗ គឺមាន (១) ពាណិជ្ជកម្ម (២) វិនិយោគ និង (៣) ជំនួយអភិវឌ្ឍន៍រវាងកម្ពុជានិងចិន ព្រមទាំងស្រាវជ្រាវអំពីទំនាក់ទំនងពាណិជ្ជកម្មរវាងកម្ពុជា-ចិន និងផលប៉ះពាល់លើភាពក្រីក្រ ដោយពិនិត្យជាសំខាន់អំពីតួនាទីនៃពាណិជ្ជកម្មរបស់ប្រទេសចិននៅក្នុងផលិតផលអតិពលកម្ម ។ ការចូលរួមចំណែករបស់ចិនក្នុងការកាត់បន្ថយភាពក្រីក្រនៅកម្ពុជា ក៏ត្រូវបានវិភាគតាមរយៈករណីសិក្សាអំពី វិនិយោគចិនក្នុងវិស័យកាត់ដេរ និងជំនួយអភិវឌ្ឍន៍ផ្លូវការ (ODA) របស់ចិន ក្នុងគម្រោងសាងសង់ហេដ្ឋារចនាសម្ព័ន្ធចំនួន ២គម្រោង ។

## ២. និន្នាភាពទូទៅនៃទំនាក់ទំនងវិនិយោគ និងពាណិជ្ជកម្មកម្ពុជា-ចិន

### ទំនាក់ទំនងវិនិយោគ និងពាណិជ្ជកម្មកម្ពុជា-ចិន

ទំនាក់ទំនងសេដ្ឋកិច្ច និងពាណិជ្ជកម្មរវាងកម្ពុជា-ចិន បានរីកដុះដាលក្នុងប៉ុន្មានឆ្នាំថ្មីៗ ។ ក្នុងឆ្នាំ១៩៩៦ កម្ពុជា និង ចិន បានចុះហត្ថលេខាលើកិច្ចព្រមព្រៀងស្តីពី ពាណិជ្ជកម្ម ការការពារ

---

១ កញ្ញា អ៊ូច ចាន់ដារ៉ានី និង លោក សាំង ច័ន្ទហង្ស ជាអ្នកស្រាវជ្រាវ និង កញ្ញា ផាន់ ដាលីស ជាជំនួយការស្រាវជ្រាវ នៅវិទ្យាស្ថាន CDRI ។

២ តាមប្រសាសន៍ ឯកឧត្តម គាត ឈុន ឧបនាយករដ្ឋមន្ត្រី និងរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ក្នុងកិច្ចសំភាសន៍ជាមួយសារព័ត៌មាន China Daily កាលពីថ្ងៃទី១៨ កញ្ញា ២០១០ ក្នុងវែបសាយ http://www.cdeclips.com/en/business/fullstory.html?id=51941 (ដកស្រង់ថ្ងៃទី ២៥កញ្ញា ២០១០) ។

និងជម្រុញវិនិយោគ ហើយក្នុងឆ្នាំ២០០០ បានបង្កើតគណៈកម្មាធិការសហប្រត្តិបត្តិការសេដ្ឋកិច្ច និងពាណិជ្ជកម្ម មួយឡើង[៣] ។ នៅថ្ងៃទី ២៧-២៩ មិថុនា ២០០៨ ស្ថានទូតចិនប្រចាំនៅកម្ពុជា ក្រសួងពាណិជ្ជកម្មកម្ពុជា និងក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា បានរួមគ្នាប្រារព្ធពិធីខួបលើកទី១៥ នៃកិច្ចសហប្រតិបត្តិការសេដ្ឋកិច្ច និងពាណិជ្ជកម្មកម្ពុជា-ចិន ដោយបានរៀបចំតាំងពិពណ៌ដ៏ធំមួយ មានការចូលរួមពី សហគ្រាសរដ្ឋនិងឯកជនរបស់ចិន សហគ្រាសក្នុងតំបន់ និង ក្រុមសហគមន៍ចិននៅកម្ពុជា ដើម្បីបង្កើតឱកាសប្រាស្រ័យទាក់ទងកម្រិតខ្ពស់ និងពង្រីកឥទ្ធិពលសហគ្រាសចម្រុះពាណិជ្ជកម្ម និងវិនិយោគ ។

នៅក្រោមក្របខ័ណ្ឌអាស៊ាន ប្រទេសអាស៊ាន និង ចិន បានឈានដល់ដំណាក់កាលដ៏សំខាន់មួយ ក្នុងការអភិវឌ្ឍទំនាក់ទំនងសេដ្ឋកិច្ច និងពាណិជ្ជកម្មជាមួយគ្នា តាមរយៈការបង្កើតតំបន់ពាណិជ្ជកម្មសេរីអាស៊ាន-ចិន (ACFTA) ។ អាស៊ាន និង ចិន បានចុះហត្ថលេខាលើកិច្ចព្រមព្រៀងក្របខ័ណ្ឌមួយនៅទីក្រុងភ្នំពេញ ក្នុងខែវិច្ឆិកា ២០០២ ស្តីពីការប្តេជ្ញាបង្កើតតំបន់ពាណិជ្ជកម្មសេរីអាស៊ាន-ចិន ក្នុងរយៈពេល១០ឆ្នាំ ។ ACFTA គ្រោងមានដំណើរពេញលេញនៅមុនឆ្នាំ២០១០ សម្រាប់សមាជិកបឋម ៦ប្រទេស របស់អាស៊ាន (សិង្ហបុរី ថៃ ម៉ាឡេស៊ី ឥណ្ឌូនេស៊ី ព្រុយនេ និង ហ្វីលីពីន) និងនៅមុនឆ្នាំ២០១៥ សម្រាប់សមាជិកអាស៊ានថ្មី ៤ប្រទេស (ឡាវ កម្ពុជា មីយ៉ាន់ម៉ា និង វៀតណាម) ។

ក្របខ័ណ្ឌខាងលើនេះ សំដៅបង្កើនកិច្ចសហប្រត្តិបត្តិការខាងវិនិយោគ និងពាណិជ្ជកម្ម និង កាត់បន្ថយរបាំងពាណិជ្ជកម្មរវាងអាស៊ាន និង ចិន ដោយគ្របដណ្តប់លើពាណិជ្ជកម្មទំនិញនិងសេវា ការវិនិយោគ និង ការពង្រីកសហប្រតិបត្តិការក្នុងវិស័យផ្សេងៗ ដូចជា ការសម្របសម្រួលពាណិជ្ជកម្ម ការផ្លាស់ប្តូរបច្ចេកវិទ្យា ការអភិវឌ្ឍធនធានមនុស្ស និង គម្រោងអភិវឌ្ឍអនុតំបន់ (រួមទាំង កិច្ចសហប្រតិបត្តិការអភិវឌ្ឍន៍អាងទន្លេមេគង្គអាស៊ាន[៤]) ។ ការរៀបចំសំខាន់បំផុតមួយក្នុងកិច្ចព្រមព្រៀងក្របខ័ណ្ឌនេះ គឺ "កម្មវិធីប្រមូលផលដើមដៃ (EHP)" ដែលបានអនុវត្តក្នុងចន្លោះឆ្នាំ២០០៤ និង ២០០៦ សម្រាប់អាស៊ាន-៥ ហើយគ្រោងដាក់អនុវត្តសម្រាប់សមាជិកថ្មី និងហ្វីលីពីន នៅឆ្នាំ២០១០ ។ កម្ពុជារំពឹងថានឹងទទួលបានឱកាស និងផលចំណេញខាងសេដ្ឋកិច្ច ព្រមទាំងត្រូវជួបបញ្ហាប្រឈមមួយចំនួនក្រោមក្របខ័ណ្ឌ ACFTA និង EHP នេះ ។

កម្មវិធីសហប្រត្តិបត្តិការមហាអនុតំបន់មេគង្គ រវាង ៦ប្រទេសតាមដងទន្លេមេគង្គ (កម្ពុជា ឡាវ មីយ៉ាន់ម៉ា ថៃ វៀតណាម ខេត្តយ៉ូនណាន់ប្រទេសចិន) ដែលបង្កើតឡើងដោយធនាគារអភិវឌ្ឍន៍អាស៊ី (ADB) ក្នុងឆ្នាំ១៩៩២ ជាចំណងទាក់ទងពាណិជ្ជកម្ម និងសេដ្ឋកិច្ច ដ៏សំខាន់មួយទៀតរវាងកម្ពុជា និង ចិន ។ របៀបវារៈ GMS ផ្តោតលើ "សមាសធាតុរឹង hardware" ក្នុងទម្រង់ជាហេដ្ឋារចនាសម្ព័ន្ធរូបវ័ន្ត ជាពិសេសហេដ្ឋារចនាសម្ព័ន្ធឆ្លងកាត់ព្រំដែន ដើម្បីបង្កើនការតភ្ជាប់ និងទំនាក់ទំនងឆ្លងកាត់តំបន់ ។ ម្យ៉ាងវិញទៀត កម្មវិធី GMS បានប្រឹងប្រែងដោះស្រាយបញ្ហា "សមាសធាតុទន់ software" រួមផ្សំ ដូចជា ការសម្រួលពាណិជ្ជកម្ម និងវិនិយោគឆ្លងកាត់ព្រំដែនជាដើម ដើម្បីជួយទ្រទ្រង់សមាហរណកម្មសេដ្ឋកិច្ចក្នុងតំបន់ GMS ។ សមាសធាតុទាំងនេះ ជួយបំពេញលើវិធានការសេរីភាវូបនីយកម្មជាច្រើន ដែលជាកាតព្វកិច្ចនៃសមាជិកភាព ក្នុងតំបន់ពាណិជ្ជកម្មសេរីអាស៊ាន (AFTA) ។

ប្រទេសចិន ដើរតួនាទីសកម្មក្នុង GMS ជាអ្នកទទួលផល និងអ្នកឧបត្ថម្ភដល់កម្មវិធី GMS ។ ក្នុងបំណងបង្កើនកំណើន និងឱកាសសេដ្ឋកិច្ចកាន់តែច្រើន នៅប៉ែកខាងត្បូងនៃប្រទេសខ្លួន (ខេត្ត Yunnan និង Guangxi) និង ជម្រុញកំណើនវិនិយោគចិនក្នុងប្រទេស GMS ប្រទេសចិន ក៏ផ្តល់

៣ វេបសាយ http://www.mfa.gov.cn/eng/wjb/zzjg/yzs/gjlb/2696/ (២៦ ឧសភា ២០១០) ។

៤ ការអភិវឌ្ឍផ្លូវដែកសិង្ហបុរី-ក្រុង Kunming និង ផ្លូវធំបាងកក-Kunming

ជាជំនួយអភិវឌ្ឍន៍ធនធានមនុស្ស និងហិរញ្ញវត្ថុ ដល់កម្មវិធី GMS និង សមាជិកនៃកម្មវិធី ។ កម្ពុជាទទួលបានអត្ថប្រយោជន៍មួយចំនួន តាមរយៈការចូលរួមក្នុងការអភិវឌ្ឍគម្រោង GMS តាមវិស័យផ្សេងៗ ដូចជា បរិស្ថាន ទេសចរណ៍ ថាមពល និងការអភិវឌ្ឍធនធានមនុស្ស ជាដើម ។

**ទំនាក់ទំនងជំនួយបរទេសកម្ពុជា- ចិន**

ប្រទេសចិនចាប់ផ្ដើមផ្ដល់ជំនួយបរទេសដល់កម្ពុជា ចាប់ពីពាក់កណ្ដាលទសវត្សរ៍១៩៥០ មកម្លេះ ។ ប៉ុន្មានឆ្នាំថ្មីៗនេះ ចិន និង កម្ពុជា បានបន្តពង្រីកសហប្រតិបត្តិការក្នុងវិស័យ វប្បធម៌ ទេសចរណ៍ និង កសិកម្ម ដោយមានការធ្វើទស្សនកិច្ចទៅវិញទៅមកនៃសមាជិកសភា កងទ័ព អ្នកសារព័ត៌មាន និង មន្ត្រីសុខាភិបាលនៃប្រទេសទាំងពីរ[៥] ។ ជំនួយបរទេសរបស់ចិន ដល់កម្ពុជាត្រូវបានចាត់ទុកជាប្រភពដ៏ចាំបាច់សម្រាប់ជម្រុញវិនិយោគ និងពាណិជ្ជកម្មរវាងប្រទេសទាំងពីរ ។

ជំនួយអភិវឌ្ឍន៍របស់ចិន មានប្រជាប្រិយភាពនៅកម្ពុជា ដោយសារមានលក្ខខណ្ឌសេដ្ឋកិច្ច និងសម្ពាធនយោបាយតិច បើធៀបនឹងប្រទេសឯទៀត (Phou Sambath, ND) ។ ទាក់ទិននឹងការបើកផ្ដល់ជំនួយវិញ រដ្ឋាភិបាលចិន បានបង្កើតនូវគោលនយោបាយជំនួយអភិវឌ្ឍន៍ និងជំនួយបរទេសផ្លូវការ សម្រាប់ប្រទេសទទួលជំនួយ ដូចជា កម្ពុជា ជាដើម (Gregory T. Chin & B. Michael Frolic 2007) ឆ្លងតាមមេរៀនដែលចិនទទួលបានពីជំនួយបរទេសលើកមុនៗរបស់ខ្លួន ។ ដោយមិនចង់ធ្វើតាមអ្វីដែលខ្លួនយល់ថា ជាឥរិយាបថមិនល្អរបស់ម្ចាស់ជំនួយអន្តរជាតិនោះ ចិនក៏បានបង្កើតគោលការណ៍ ៨យ៉ាង សម្រាប់ការលៃចែកជំនួយរបស់ខ្លួន ។ គោលការណ៍ទាំងនេះក៏សំដៅកាត់បន្ថយសំពាធលើប្រទេសទទួលជំនួយផងដែរ និងមានដូចខាងក្រោម (Gregory T. Chin & B. Michael Frolic 2007)៖

- ទាំងម្ចាស់ជំនួយ និងប្រទេសទទួលជំនួយ ត្រូវធានានូវសមភាព និង ផលប្រយោជន៍ទៅវិញទៅមក
- គោរពអធិបតេយ្យភាព និងមិនបង្ខំដាក់លក្ខខណ្ឌ
- ផ្ដល់កំចីឥតការប្រាក់ ឬមានការប្រាក់ទាប ក្នុងនាមអ្នកក្រជួយអ្នកក្រ
- ជម្រុញប្រទេសទទួលជំនួយឲ្យអភិវឌ្ឍឡើងប្រកបដោយភាពឯករាជ្យ និងពឹងផ្អែកតិចលើប្រទេសដទៃ
- គាំទ្រ និងទទួលយកគម្រោងដែលមានតម្រូវការវិនិយោគតិច និងអាចសម្រេចបានក្នុងរយៈពេលខ្លី
- លៃចែកបរិក្ខារ និងសម្ភារៈ មានគុណភាពល្អ ស៊ីគ្នានឹងថ្លៃនៅទីផ្សារ
- ផ្ដល់ជំនួយបច្ចេកទេសប្រកបដោយប្រសិទ្ធភាព
- ផ្ដល់ប្រាក់កម្រៃសមរម្យដល់ជំនាញការ ស្របតាមអត្រាទីផ្សារក្នុងស្រុក

រាជរដ្ឋាភិបាលកម្ពុជា ក៏មានការប្ដេជ្ញាខ្ពស់ដែរលើ (១) ការធានាប្រើប្រាស់ជំនួយអន្តរជាតិដែលទទួលបានដោយមានប្រសិទ្ធភាព ដូចជា ការប្រើប្រាស់ជំនួយប្រកបដោយប្រសិទ្ធភាព តម្លាភាព និងគណនេយ្យភាព ជាដើម (២) ការពង្រឹងតួនាទីបុគ្គលសំខាន់ៗដែលពាក់ព័ន្ធនឹងការធ្វើផែនការ និងការអនុវត្តកម្មវិធី និង (៣) ការវាយតម្លៃលើផលប៉ះពាល់នៃផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ (NSDP) (Chan Sophal *et al.* 2008) ។

---

៥ វេបសាយ http://www.mfa.gov.cn/eng/wjb/zzjg/yzs/gjlb/2696/ (២៦ ឧសភា ២០១០) ។

## ៣. របកគំហើញការសិក្សា[៦]

ពាណិកម្មកម្ពុជា-ចិន និងឥទ្ធិពលលើការកាត់បន្ថយភាពក្រីក្រ

ការសិក្សានេះ ប្រើក្របខ័ណ្ឌបង្កើតឡើងដោយ Jenkins និង Edwards (2004) ដើម្បីពិនិត្យឥទ្ធិពលរបស់ចិន មកលើភាពក្រីក្រនៅកម្ពុជា តាមរយៈវិស័យជាក់លាក់បី គឺការនាំចេញទៅប្រទេសចិន (ផលិតផលអតិពលកម្ម) ការនាំចូលពីប្រទេសចិន (ទំនិញប្រើប្រាស់សម្រាប់ជនក្រីក្រ) និងការនាំចេញទៅទីផ្សារទីបី (ផលិតផលអតិពលកម្ម) ។

ពីឆ្នាំ១៩៩២ ដល់ ២០០៨ ចំណែកនៃការនាំចេញទៅប្រទេសចិន បានផ្លាស់ប្តូរគួរឲ្យកត់សម្គាល់ ។ ចំណែកនៃការនាំចេញផលិតផលកសិកម្មអតិពលកម្ម ធ្លាក់ចុះយ៉ាងខ្លាំងពី ៥១,៤% ក្នុងឆ្នាំ១៩៩២ មកត្រឹម ៩,១% ក្នុងឆ្នាំ២០០០ ប៉ុន្តែក្រោយមកវាស្ទុះឡើងវិញបាន ២៩,៦% ក្នុងឆ្នាំ២០០៨ ។ ចំណែកការនាំចេញត្រី និងសត្វរស់ បានកើនឡើងនៅចន្លោះឆ្នាំ២០០០ និង ២០០៨ ។ ចំណែកការនាំចេញសំលៀកបំពាក់ និងផលិតផលវាយនភ័ណ្ឌអតិពលកម្ម ទៅប្រទេសចិន ក៏មាននិន្នាការកើនឡើងដែរ ពីឆ្នាំ១៩៩២ (៣,២%) ដល់ឆ្នាំ២០០៨ (២៨,២%) ។ កំណើននៃចំណែកផលិតផលទាំងពីរនេះ ទំនងជាអាចចូលរួមចំណែកដល់ការកាត់បន្ថយភាពក្រីក្រនៅកម្ពុជា តាមរយៈការបង្កើតការងារយ៉ាងច្រើនឲ្យប្រជាជនកម្ពុជា ។

ការនាំចូលផលិតផលកសិកម្មអតិពលកម្មពីប្រទេសចិន មានចំណែកតូច និងបានធ្លាក់ចុះក្នុងចន្លោះឆ្នាំ១៩៩២ និង ២០០៨ ។ ប្រទេសទាំងពីរ ហាក់មិនមានការប្រកួតប្រជែងខាងទីផ្សារផលិតផលកសិកម្មក្នុងស្រុកទេ ។ ប៉ុន្តែកំណើនជាទៀងទាត់នៃការនាំចូលក្រុមផលិតផលកសិកម្មជាក់លាក់ប្រភេទនេះមួយចំនួន ទោះក្នុងបរិមាណតូចក្តី អាចបង្កើតការប្រកួតប្រជែងនៅពេលអនាគត ។ ការស្ទុះឡើងយ៉ាងខ្លាំងនៃចំណែកការនាំចូលសំលៀកបំពាក់ និងទំនិញវាយនភ័ណ្ឌអតិពលកម្មនៅចន្លោះឆ្នាំ១៩៩២ និង ២០០៨ មិនបានបង្កើតជាការប្រកួតប្រជែងក្នុងទីផ្សារក្នុងស្រុកទេ ព្រោះផលិតផលទាំងនោះ គេយកវាមកផ្គុំសម្រាប់នាំចេញទៅទីផ្សារក្រៅប្រទេស ។ កំណើនចំណែកការនាំចូលផលិតផលនេះ ហាក់បានរួមចំណែកជួយបង្កើតការងារក្នុងប្រទេសកម្ពុជា ដូច្នេះ វាមានផលវិជ្ជមានលើការកាត់បន្ថយភាពក្រីក្រនៅកម្ពុជា ប៉ុន្តែវារារាំងឱកាសបង្កើតឧស្សាហកម្មនៅដើមខ្សែ (backward linkages) ក្នុងសេដ្ឋកិច្ចកម្ពុជា ។

ការនាំចូលទំនិញប្រើប្រាស់សម្រាប់ជនក្រីក្រ បានកើនឡើងក្នុងចន្លោះឆ្នាំ១៩៩២ និង ២០០០ ប៉ុន្តែមាននិន្នាការធ្លាក់ចុះនៅចន្លោះឆ្នាំ២០០០ និង ២០០៨ ។ ចំណុចនេះបង្ហាញថា ពីឆ្នាំ២០០០ ដល់ ២០០៨ ការនាំចូលផលិតផលប្រើប្រាស់មានតម្លៃថោកពីប្រទេសចិន បានថយចុះអត្ថប្រយោជន៍បន្តិចសម្រាប់ជនក្រីក្រ ដូច្នេះ វាហាក់មិនសូវបានរួមចំណែកកាត់បន្ថយភាពក្រីក្រនៅកម្ពុជាទេ ។ ផលិតផលសម្រាប់ជនក្រីក្រ ដែលតែងនាំចូលជាទៀងទាត់ មានដូចជា ត្រី គ្រាប់ធញ្ញជាតិ បន្លែ ផ្លែឈើ ភេសជ្ជៈ សំលៀកបំពាក់ ខោអាវជជុះ និង ផលិតផលផ្សេងៗប៉ុន្មានមុខទៀត ។

ការវិភាគការនាំចេញទៅទីផ្សារទីបី បង្ហាញថា កម្ពុជា និង ចិន អាចក្លាយជាដៃគូប្រកួតប្រជែងលើផ្នែកទំនិញកម្មន្តសាល ដូចជា សម្លៀកបំពាក់ និងវាយនភ័ណ្ឌ ប៉ុន្តែមិនមែនផលិតផលកសិកម្មទេ ។ ការពិនិត្យលំអិតលើសម្លៀកបំពាក់នាំចេញឈានមុខ ១២យ៉ាង ទៅសហរដ្ឋអាមេរិក និងសហភាពអឺរ៉ុប បង្ហាញថា កម្ពុជាមានសក្តានុពលក្នុងការប្រកួតប្រជែងជាមួយចិន ក្នុងទីផ្សារសហរដ្ឋអាមេរិក ប៉ុន្តែមិនមែនក្នុងទីផ្សារសហភាពអឺរ៉ុបទេ ព្រោះសម្លៀកបំពាក់កម្ពុជាមានចំណែកតូចក្នុងទីផ្សារសហភាពអឺរ៉ុប (ពី ០,០១% ទៅ ១,០%) ។ ក្នុងចំណោមផលិតផលឈានមុខ ១២យ៉ាង

---

៦ សម្រាប់ការពន្យល់លំអិតពីវិធីសាស្រ្តដាក់អនុវត្ត និង តំបន់/គម្រោងបានជ្រើសយកសម្រាប់ការសិក្សានេះ សូមមើលក្នុងរបាយការណ៍អភិវឌ្ឍន៍ប្រចាំឆ្នាំ២០១០-២០១១ ជាភាសាអង់គ្លេស របស់វិទ្យាស្ថាន CDRI ។

ក្នុងទីផ្សារសហរដ្ឋអាមេរិក ការធ្លាក់ចុះចំណែកនៃសំលៀកបំពាក់ចាក់ដោយម្ជុលរបស់ចិន (SITC 8459) និងកំណើនចំណែកនៃផលិតផលប្រភេទនេះរបស់កម្ពុជា បង្កើតជាឱកាសសម្រាប់អ្នកផ្គត់ផ្គង់ក្នុងស្រុក ប៉ុន្តែកំណើនយ៉ាងខ្លាំងនៃចំណែកទីផ្សារនៃផលិតផលដទៃទៀតរបស់ចិន អាចគម្រាមកំហែងដល់ផលិតករកម្ពុជា ដែលជះឥទ្ធិពលអវិជ្ជមានដល់ការកាត់បន្ថយភាពក្រីក្រនៅកម្ពុជា ។

### វិនិយោគចិន និងឥទ្ធិពលលើការកាត់បន្ថយភាពក្រីក្រ

ការសិក្សានេះ ក៏វិភាគផងដែរពីឥទ្ធិពលនៃវិនិយោគចិន លើការកាត់បន្ថយភាពក្រីក្រនៅកម្ពុជា តាមរយៈការប្រើប្រាស់ក្របខ័ណ្ឌរបស់ Jenkins and Edwards's (2004) ។ ការសិក្សាផ្ដោតលើវិនិយោគផ្ទាល់ពីបរទេស (FDI) ខាងផ្នែកអតិពលកម្ម ដែលមានសារៈសំខាន់សម្រាប់ការកាត់បន្ថយភាពក្រីក្រ និងការបង្កើតការងារនៅកម្ពុជា ។ ករណីសិក្សាលើវិស័យកាត់ដេរ ដែលបានទាក់ទាញខ្លាំងនូវវិនិយោគពីចិន បានពិនិត្យពីផលប៉ះពាល់នៃវិនិយោគនេះមកលើការកាត់បន្ថយភាពក្រីក្រនៅកម្ពុជា តាមរយៈ៖ (១) ឱកាសបង្កើនប្រាក់ចំណូលដល់ជនក្រីក្រតាមរយៈការបង្កើតការងារ និង ប្រាក់ឈ្នួលខ្ពស់ (២) ប្រាក់ផ្ញើទៅផ្ទះ (៣) ការអភិវឌ្ឍជំនាញដល់ជនក្រីក្រនៅជនបទ ។ អង្កេតនេះ បានធ្វើឡើងនៅក្រុងភ្នំពេញ ដោយជ្រើសយកកម្មករកាត់ដេរ ៣០០នាក់ ធ្វើជាគំរូតាង (១៥០នាក់ ធ្វើការក្នុងរោងចក្រចិន និង ១៥០នាក់ទៀត ធ្វើការក្នុងរោងចក្រផ្សេងពីចិន) ។

ករណីសិក្សាបង្ហាញថា វិនិយោគចិនក្នុងវិស័យកាត់ដេរនៅកម្ពុជា រួមចំណែកមួយកម្រិតដល់ការកាត់បន្ថយភាពក្រីក្រនៅកម្ពុជា តាមរយៈការបង្កើតការងារសម្រាប់ប្រជាជនមកពីតំបន់ជនបទ ។ អង្កេតបង្ហាញថា ៧០% នៃកម្មករ ធ្លាប់ជាអ្នកប្រកបមុខរបរខ្លួនឯង ហើយក្នុងនោះមាន ៤៥% កំពុងធ្វើការក្នុងរោងចក្ររបស់ចិន និង ៥៥% ក្នុងរោងចក្រមិនមែនរបស់ចិន ។ កម្មករក្នុងរោងចក្រកាត់ដេរទាំងពីរប្រភេទ រកចំណូលបានជាមធ្យម ប្រមាណ ៨០ដុល្លារ/ខែ ឬ ២,៦៧ដុល្លារ/ថ្ងៃ (២,០៣ដុល្លារ/ថ្ងៃ គិតតាមថ្លៃថេរឆ្នាំ២០០៦) ដែលខ្ពស់ជាងបន្ទាត់ភាពក្រីក្រក្នុងក្រុងភ្នំពេញ គឺ ០,៧៦ដុល្លារ/ថ្ងៃ (០,៧១ដុល្លារ/ថ្ងៃ គិតតាមថ្លៃថេរឆ្នាំ២០០៦) ។

អង្កេតបង្ហាញទៀតថា ៦៤% នៃប្រាក់ផ្ញើទៅផ្ទះរបស់កម្មករ ពួកសមាជិកគ្រួសាររបស់កម្មករ យកវាទៅចំណាយលើម្ហូបអាហារប្រចាំថ្ងៃ ។ ប្រាក់ផ្ញើទៅផ្ទះ មិនមែនប្រើសម្រាប់តែម្ហូបអាហារប្រចាំថ្ងៃនោះទេ ប៉ុន្តែសម្រាប់គោលបំណងផ្សេងៗទៀតដែរ ដូចជា វិនិយោគក្នុងវិស័យកសិកម្ម សងបំណុល និង សន្សំទុកសម្រាប់កូនៗ ។ ចំពោះការអភិវឌ្ឍជំនាញសម្រាប់កម្មករវិញ អង្កេតរកឃើញថា ទាំងរោងចក្ររបស់ចិន និងមិនមែនរបស់ចិន មិនមានផ្ដល់កម្មវិធីបណ្ដុះបណ្ដាលច្បាស់លាស់ដើម្បីបង្កើនជំនាញ ឬចំណេះដឹងឲ្យកម្មករ ទាក់ទងនឹងការងារបច្ចុប្បន្នរបស់ពួកគេទេ ។ មានតែកម្មករធ្វើការក្នុងរោងចក្រចិន ២នាក់ ប៉ុណ្ណោះ ដែលបានឆ្លើយសម្ភាសន៍ប្រាប់ថា ខ្លួនបានទទួលការបណ្ដុះបណ្ដាលក្នុងផ្នែករចនាម៉ូដ និងច្បាប់ការងារ ។

សរុបមក វិនិយោគរបស់ប្រទេសចិនក្នុងវិស័យកាត់ដេរហាក់រួមចំណែកបានច្រើនណាស់ក្នុងការកាត់បន្ថយភាពក្រីក្រនៅកម្ពុជា តាមរយៈការបង្កើតឱកាសការងារ និងរកចំណូល សម្រាប់ជនក្រីក្រនៅតំបន់ជនបទ ។ ទាំងរោងចក្រកាត់ដេររបស់ចិន និងមិនមែនរបស់ចិន គួរបង្កើនការអភិវឌ្ឍចំណេះដឹង និងជំនាញរបស់កម្មករ ដើម្បីបង្កើតស្ថិរភាពការងារឲ្យកម្មកររបស់ខ្លួន ។

### ជំនួយអភិវឌ្ឍន៍ផ្លូវការរបស់ចិន និង ឥទ្ធិពលលើការកាត់បន្ថយភាពក្រីក្រ

ការវាយតម្លៃលើផលប៉ះពាល់នៃជំនួយអភិវឌ្ឍន៍របស់ចិន លើការកាត់បន្ថយភាពក្រីក្រ បានធ្វើឡើងតាមរយៈករណីសិក្សាលើ ២គម្រោងហេដ្ឋារចនាសម្ព័ន្ធ ក្នុងនោះ គម្រោងមួយបានបញ្ចប់ហើយ និងមួយទៀតកំពុងដំណើរការ ។ គម្រោងទាំងពីរ ទទួលបានហិរញ្ញប្បទានពីជំនួយអភិវឌ្ឍន៍ផ្លូវការ

(ODA) របស់ចិន និង រួមមាន ការស្តារជួសជុលផ្លូវជាតិលេខ៧ ពីខេត្តក្រចេះទៅត្រពាំងក្រៀល (ច្រកឆ្លងកាត់ព្រំដែនទៅឡាវ) និង ការសាងសង់ស្ពានព្រែកតាមាក់ក្នុងខេត្តកណ្តាល ។ ករណីសិក្សាទាំងនេះ ផ្តោតជាចំបងលើការវាយតម្លៃពីផលប៉ះពាល់ ដែលគម្រោងនីមួយៗអាចមានទៅលើជីវភាពរស់នៅ និងការអភិវឌ្ឍសង្គមរបស់ប្រជាជនមូលដ្ឋាន ជាពិសេសផលប៉ះពាល់ដែលប្រជាជនមូលដ្ឋានគិតថាអាចកើតឡើង ។

តាមករណីសិក្សាទាំងនេះ គម្រោងហាក់ផ្តល់ផលចំណេញច្រើនជាងការខាតបង់ ជាពិសេសការសាងសង់ផ្លូវ និង ស្ពាន ។ ឱកាសបង្កើនការដាំដំណាំ និងលទ្ធភាពចូលទៅដល់ទីផ្សារ បានលើកកម្ពស់គុណភាពការរស់នៅរបស់អ្នកភូមិ ។ ផ្លូវ និង ស្ពាន ជួយបង្កើនឱកាសទទួលបានការអប់រំ និងសេវាថែទាំសុខភាពកាន់តែប្រសើរ ។ អ្នកភូមិ អាចរៀនសូត្របានកាន់តែច្រើនពីមជ្ឈដ្ឋានខាងក្រៅដោយធ្វើដំណើរទៅខេត្ត ឬទៅក្រុងភ្នំពេញ ។ អង្គការអភិវឌ្ឍន៍នានាក៏អាចទៅដល់ភូមិ ហើយផ្តល់ជាសេវាសង្គមផ្សេងៗឲ្យដល់អ្នកភូមិ និងជួយអ្នកភូមិក្នុងការគ្រប់គ្រងធនធានព្រៃឈើ ។ សរុបមកគម្រោងទាំងពីរ បាននាំមកនូវឱកាសល្អជាច្រើនសម្រាប់លើកកម្ពស់ជីវភាពសហគមន៍ ។

## ៤. អនុសាសន៍គោលនយោបាយ

ផ្នែកពាណិជ្ជកម្ម

ដើម្បីជួយរួមចំណែកបានកាន់តែប្រសើរក្នុងការកាត់បន្ថយភាពក្រីក្រនៅកម្ពុជា ជំហាននានាដូចខាងក្រោមគួរតែអនុវត្តៈ

- ប្រើប្រាស់ឲ្យបានកាន់តែប្រសើរនូវឱកាសនាំចេញផលិផលកសិកម្ម ដែលកម្ពុជាមានជំនាញឯកទេស ពោលគឺផលិតផលអតិពលកម្ម ដូចជា ត្រី សត្វរស់ អង្ករ កៅស៊ូ និងគ្រាប់ស្វាយចន្ទី ដែលទទួលបានលក្ខខណ្ឌអនុគ្រោះពីប្រទេសចិន ក្រោមក្របខ័ណ្ឌ ACFTA ដើម្បីជួយសម្រាលជញ្ជីងពាណិជ្ជកម្មអវិជ្ជមាន និងកាត់បន្ថយភាពក្រីក្រ ។
- បង្កើនលទ្ធភាពទទួលបានហិរញ្ញវត្ថុពាណិជ្ជកម្ម ដោយសហគ្រាសធុនតូច និងមធ្យម (SME) សម្រាប់ការចូលរួមដោយប្រយោលក្នុងសកម្មភាពនាំចេញ ។
- លើកកម្ពស់ផលិតផលកសិកម្មកម្ពុជា តាមរយៈ ពិពណ៌ពាណិជ្ជកម្ម ឬទស្សនកិច្ចពាណិជ្ជកម្មក្នុងប្រទេសចិន ។
- បញ្ចុះបញ្ចូលផលិតករចិនក្នុងវិស័យកាត់ដេរនៅកម្ពុជា ឲ្យទិញវត្ថុធាតុដើមពីផលិតករក្នុងស្រុក ឬបង្កើតឧស្សាហកម្មដើមខ្សែនានា (backward linkage industries) នៅក្នុងប្រទេសកម្ពុជា ។
- លើកទឹកចិត្ត និងគាំទ្រ ផលិករក្នុងស្រុកឲ្យចូលរួមក្នុងឧស្សាហកម្មដើមខ្សែ សម្រាប់បម្រើវិស័យកាត់ដេរ ។
- អនុវត្តបែបបទគយដោយប្រើប្រព័ន្ធកុំព្យូទ័រ ដើម្បីកាត់បន្ថយចំនួនឯកសារ ចំនួនហត្ថលេខា និងថ្លៃឈ្នួលក្រៅផ្លូវការ ។ ប្រព័ន្ធបែបនេះ មានដូចជា ប្រព័ន្ធសាកល ASYCUDA ដាក់ប្រើនៅកំពង់ផែក្នុងខេត្តព្រះសីហនុ ដែលជួយកាត់បន្ថយភាពមិនអាចព្យាករណ៍បាននានា និងបង្កើនទំនុកចិត្តវិនិយោគិន ។
- បង្កើតជាកម្មវិធីផ្សេងៗ ដើម្បីជម្រុញគម្រោង ODA ឲ្យជួយដល់ការកសាងសមត្ថភាពនៅកម្ពុជា ។

ផ្នែកវិនិយោគ

ធនធានធម្មជាតិដ៏សម្បូរ ព្រៃឈើ សក្តានុពលខាងវារីអគ្គិសនី ធនធានរ៉ែ ធនធានប្រេងកាត និង កម្លាំងពលកម្មយ៉ាងច្រើន ធ្វើឲ្យប្រទេសចិនយកចិត្តទុកដាក់ដល់កម្ពុជា ក្នុងការផ្តល់ជំនួយអភិវឌ្ឍន៍ និងធ្វើវិនិយោគ ។ ដូចបានរកឃើញក្នុងករណីសិក្សាពីវិស័យកាត់ដេរ វិនិយោគរបស់ចិនក្នុងឧស្សាហកម្មនេះ មានផលប៉ះពាល់វិជ្ជមានដល់ការបង្កើតការងារ/ប្រាក់ចំណូល ប៉ុន្តែមិនសូវមានឥទ្ធិពលលើការអភិវឌ្ឍជំនាញទេ ។ បញ្ហាចំបងគឺ តើវិនិយោគរបស់ចិន បានផ្តល់អត្ថប្រយោជន៍កម្រិតណាដល់សេដ្ឋកិច្ចក្នុងស្រុក នៅក្នុងទំនាក់ទំនងគួបកម្លាំងគ្នានេះ ។ ដូច្នេះ ត្រូវមានអន្តរាគមន៍ខាងគោលនយោបាយ ដើម្បីបង្កើតលក្ខខណ្ឌដ៏ចាំបាច់ និងកាន់តែប្រសើរ សំដៅទាក់ទាញវិនិយោគចិន និងវិនិយោគបរទេសដទៃទៀត ទៅក្នុងវិស័យនានាដែលមានសក្តានុពលជួយផ្ទេរជំនាញ និងបច្ចេកវិទ្យាឲ្យកម្ពុជា ហើយបង្កើនភាពច្នៃប្រឌិត ផលិតភាព គុណភាពផលិតកម្មក្នុងស្រុក និងផលិតកម្មនៅ ដើមខ្សែ និងចុងខ្សែ ( backward & forward linkages ) ។

ជំនួយអភិវឌ្ឍន៍ផ្លូវការ ( ODA )

ក្រៅពីផលប៉ះពាល់វិជ្ជមាននៃវត្តមានផ្លូវថ្នល់ និងស្ពានថ្មីៗនោះ ទាំងថ្នាក់ជាតិ និង ថ្នាក់មូលដ្ឋាន គួរយកចិត្តទុកដាក់លើសកម្មភាពមួយចំនួនដូចតទៅ៖

- គួរមានពិពិធកម្ម ឬការផ្តល់ឱកាសរកចិញ្ចឹមជីវិត សម្រាប់អ្នកដែលបានបាត់បង់ប្រាក់ចំណូល អំពីសកម្មភាពលក់ដូរនៅក្បែរសាឡាងចំលង និង បាត់បង់លទ្ធភាពប្រើប្រាស់ដីធ្លី និងធនធានព្រៃឈើ ។
- សេចក្តីណែនាំពីសុវត្ថិភាពលើដងផ្លូវ និងព័ត៌មានផ្នែកចរាចរណ៍ គួរតែផ្សព្វផ្សាយឲ្យបានទូលំទូលាយទៅដល់អ្នកភូមិតាមរយៈក្រុមប្រឹក្សាឃុំ ។
- បង្កើនការចរចាជាមួយរដ្ឋាភិបាលចិន ដើម្បីឲ្យមានពលករកម្ពុជាកាន់តែច្រើនបានចូលរួមក្នុងគម្រោង ODA របស់ចិន សំដៅលើកកម្ពស់ការផ្ទេរជំនាញ និងបច្ចេកវិទ្យាដល់ប្រទេសកម្ពុជាតាមរយៈ ODA ។
- គួរមានបង្កើតជាកម្មវិធីនានា ដើម្បីលើកកម្ពស់ការកសាងសមត្ថភាពនៅកម្រិតមូលដ្ឋានឆ្លងតាម ODA របស់ចិន ។

# ឯកសារយោង

Carl, Middleton & Sam, Chanthy (2008), Cambodia's Hydropower Development and China's Involvement (Phnom Penh: RCC)

CDC (2007, 2008 & 2009), "The Cambodia Aid Effectiveness Report"

CDRI (2008), Impact of High Food Prices in Cambodia, Survey Report (Phnom Penh: CDRI)

Cuyvers, Ludo, Soeng, Reth & Bulcke, Daniel Van Den (2006), Foreign Direct Investment of Least Developed Countries: The Case of Cambodia's Textile, Garment, Furniture, Transportation and Tourism Industries, CAS Discussion Paper No. 09

Gregory, T. Chin & B. Michael, Frolic (2007), "Emerging Donors in International Development Assistance: The China Case", (PBDD: Partnership & Business Development Division, York University)

Hem, Socheth, Tong, Kimsun & Ker, Bopha (2009), Maximizing Opportunities of Chinese Investment in Natural Resources in Cambodia (Phnom Penh: CDRI)

Hettige, Hemamala, Martin, Paul, Singh, Manjula & Wheeler, David (1995), The Industrial Pollution Projection System, World Bank Policy Research Working Paper No. 1431

Hing, Vutha & Hossein Jalilian (2008), Environmental Impacts of the ASEAN-China Free Trade Agreement on the Greater Mekong Sub-Region (Canada: IISD)

Hing, Vutha & Nou, Keosothea (2006), The Early Harvest Programme: Implications for Cambodian Agriculture, Special Report No. 4 (Phnom Penh: CDRI)

Jenkins, Rhys & Chris Edwards (2004), How Does China's Growth Affect Poverty Reduction in Asia, Africa and Latin America? Expanded Report to DFID (Norwich: UEA)

Jenkins, Rhys, Peters, Enrique Dussel & Moreira, Mauricio Mesquita (2007), The Impact of China on Latin America and the Caribbean, *World Development*, Vol. 36, No.2, pp. 235-253

John, Humphrey & Hubert, Schmitz (2007), China: Its Impact on the Developing Asian Economies, Working Paper 295 (UK: Institute of Development Studies)

Kaplinsky, Raphael & Messner, Dirk (2007), Introduction: The Impact of Asian Drivers on the Developing World, *World Development*, Vol. 36, No. 2, pp.197-209

Kheang, Un (ND), China's Foreign Investment and Assistance: Implications for Cambodia's Development and Democratization

L. ALan, Neil & Andrew (2004), Trade Liberalization and Poverty: The Evidence So Far, Journal of Economic Literature, Vol. XLII, pp. 72-115

Ludo, Joseph, Reth & Daniel (2008), Determinants of Foreign Direct Investment in Cambodia: Country-Specific Factor Differentials, University of Antwerp

Ludo, Reth & Daniel (2006), Foreign Direct Investment and Development of Least Developed Countries: The Case of Cambodia's Textile, Garment, Furniture, Transportation and Tourism Industries, CAS Discussion Paper No.49, CAS & CIMDA

Ludo, Reth, Joseph & Daniel (2008), Productivity Spillovers from Foreign Direct Investment in the Cambodian Manufacturing Sector: Evidence from Establishment-Level Data, University of Antwerp

Menon, Jayant (2005), "Building Blocks or Stumbling Blocks? Regional Cooperation Arrangements in Southeast Asia", *ADB Institute Discussion Paper No.41* (Tokyo: Asian Development Bank Institute)

Martyn, Davies (2008), "How China Delivers Development Assistance to Africa", Centre for Chinese Studies, University of Stellenbosch

Matthew, Coghlan (2007), China's Poverty Footprint in Cambodia (Phnom Penh: OGB)

Neak, Samsen & Yem, Sokha (2006), Trade and Poverty Link: The Case of the Cambodian Garment Industry (Phnom Penh: EIC)

Ngaire, Woods (2008), "Whose aid? Whose influence? China, Emerging Donors and the Silent Revolution in Development Assistance", The Royal Institute of International Affairs

Ngo, Ngoun Theary (2007), *Extractive Industry Transparency Initiative in Cambodia, Cambodia Development Watch,* Vol. 3, No.2, pp.7-10 (Phnom Penh: NGO Forum on Cambodia)

Nuno, Crespo & Maria, Paula Fontoura (ND), Determinant Factors of FDI Spill-overs: What Do We Really Know? ISEG-Universidade Techica de Lisboa

OECD (2008), China's Outward Direct Investment, OECD Investment Policy Reviews: China 2008

Okamoto, Yumiko (2005), China and India: Challenges and Opportunities for ASEAN from Japanese Perspectives (Kyoto: Doshisha University)

Phou, Sambath (ND), "Cambodia-China Relation: Past, Present and Future", PhD Student, IIMBA

Raphael & Dirk (2008), Introduction: The Impact of Asian Drivers on the Developing World, World Development Vol. 36, No. 2, pp. 197-2009

Renato, Maria & Rogerio (2002), Foreign Direct Investment Spillovers: Additional Lessons from a Country Study

Rhys, Enrique & Mauricio (2008), The Impact of China on Latin America and the Caribbean, World Development Vol. 36 No. 2, pp. 235-253

Saing, Chan Hang (2009a), Export Competitiveness of the Cambodian Rubber Sector Relative to other Greater Mekong Sub-region Suppliers: A Simple Descriptive Analysis, ARTNeT-GMS Discussion Paper No.1

Saing, Chan Hang (2009b), Impacts of the Global Financial Crisis on Garment Workers and Remittances: Lesson from Cambodia, ARTNeT-GMS Notes No.3

Sandra, Poncet (2007), Inward and Outward FDI in China, (University Paris 1 CNRS and CEPII)

Saw, Sheng & Chin (2005), ASEAN-China Relations: Realities and Prospects, Institute of Southeast Asian Studies, Singapore

Tatsufumi, Yamagata (2006), The Garment Industry in Cambodia: Its Role in Poverty Reduction through Export-Oriented Development, Discussion Paper No. 62, Institute of Developing Economies

The World Bank (2009), Sustaining Rapid Growth in a Challenging Environment, Cambodia Country Economic Memorandum, East Asia and Pacific Region

Wu, Hsiu-Ling & Chien-Hsun Chen (2001), "An Assessment of Outward Foreign Direct Investment from China's Transitional Economy", Europe-Asia Studies, Vol. 53, No. 8 (Glasgow: Central and East European Studies) pp. 1235-1254

Yu, Ching Wong & Charles, Adams (2002), Trends in Global and Regional Foreign Direct Investment Flows, Regional Office for Asia and the Pacific International Monetary Fund

Zhu, Zhenming (ND), "China's Economic Aid to CLMV and Its Economic Cooperation with Them"

# -III-
# ប្រើប្រាស់វិធីសាស្ត្រប៉ាន់ស្មានឥទ្ធិពលប្រព្រឹត្តិកម្ម (PSM) ដើម្បីទទួលបានក្រុមប្រៀបធៀប ២ ក្នុងអង្កេតមូលដ្ឋាន៖ ករណីគម្រោងបញ្ជូនចរន្តអគ្គិសនីនៅមហាអនុតំបន់មេគង្គ

*ដោយលោក ហ៊ីង វុត្ថា លោក សាំង ច័ន្ទហង្ស និងលោក យៀង សុធី*[១]

## ១. សេចក្តីផ្តើម

គម្រោងស្រាវជ្រាវនេះ គឺជាអង្កេតសេដ្ឋកិច្ច-សង្គមកិច្ចមូលដ្ឋានលើកដំបូង ដែល CDRI អនុវត្តឡើងក្រោមជំនួយទ្រទ្រង់ពីធនាគារអភិវឌ្ឍន៍អាស៊ី សម្រាប់គម្រោងបញ្ជូនចរន្តអគ្គិសនីនៅមហាអនុតំបន់មេគង្គ (GMS) ។ ការសិក្សានេះ ធ្វើឡើងដើម្បីបង្កើតសំណុំទិន្នន័យ ដោយមានសូចនាករសេដ្ឋកិច្ច-សង្គមកិច្ចសព្វគ្រប់សម្រាប់ការតាមដានត្រួតពិនិត្យលើជំនួយ ព្រមទាំងវាយតម្លៃពីលទ្ធផលនៃគម្រោង និងផលប៉ះពាល់នៅឆ្នាំបន្តបន្ទាប់ទៀត ក្រោយពេលបញ្ចប់គម្រោង ។ ការសិក្សានេះប្រើឧបករណ៍វិភាគមួយហៅថា Propensity Score Matching (PSM)[២] ដើម្បីទទួលបានក្រុមគ្រួសារដែលមានលក្ខណៈស្រដៀងគ្នា២ក្រុម ដែលមួយក្រុមនៅក្នុងតំបន់ត្រូវអនុវត្តគម្រោង និងមួយក្រុមទៀតនៅក្នុងតំបន់ក្រៅគម្រោង ។ វិធីសាស្ត្រនេះ អាចជួយឲ្យរកឃើញគ្រួសារមានលក្ខណៈផ្គូផ្គងគ្នាល្អ សម្រាប់ប្រើក្នុងការប្រៀបធៀបរវាងតំបន់មិនអនុវត្តគម្រោង និងតំបន់ត្រូវអនុវត្តគម្រោង ហើយគេអាចពិចារណាជម្រុះគ្រួសារប្រៀបធៀបខ្លះ (គ្រួសារដែលមានលក្ខណៈខុសគ្នាខ្លាំងពេក) ចេញពីអង្កេតត្រូវធ្វើបន្តទៀត ។

## ២.វិធីសាស្ត្រ

ការសិក្សានេះ យក "គ្រួសារ" ធ្វើជាឯកតាវាស់វែង ដើម្បីបង្កើតសូចនាករសេដ្ឋកិច្ច-សង្គមកិច្ចមូលដ្ឋាន និងប្រើបញ្ជីសំណួររៀបរយមួយ ដើម្បីប្រមូលព័ត៌មានសំខាន់ៗលើគ្រួសារ ។ ការរចនារៀបចំគំរូតាង បែងចែកគ្រួសារជាពីរក្រុម៖ ក្រុមក្នុងគម្រោង (treatment group ) និងក្រុមក្រៅគម្រោង (control group) ។ ក្រុមក្នុងគម្រោង ជាគ្រួសារនៅក្នុងតំបន់ដែលត្រូវអនុវត្តគម្រោង (១គីឡូម៉ែត្រ សងខាងបណ្តាញចែកចាយអគ្គិសនី) ។ ក្រុមស្រាវជ្រាវបានជ្រើសយក ១៧ភូមិ ត្រូវជា ៤៥០គ្រួសារ ដោយផ្អែកលើការពិគ្រោះយោបល់ជាមួយទីប្រឹក្សារបស់អគ្គសនីកម្ពុជា (EDC) និងលើរបាយការណ៍មួយមានចំណងជើងថា "របាយការណ៍ពិនិត្យតាមដានគុណប្រយោជន៍" ដែលមានបញ្ជាក់ក្នុងឯកសារបំផុសគំនិតសម្រាប់គម្រោងបញ្ជូនចរន្តអគ្គិសនី GMS ។ ក្រុមក្រៅគម្រោងជាគ្រួសាររស់នៅក្រៅតំបន់ដែលត្រូវអនុវត្តគម្រោង ហើយទំនងជាមិនពាក់ព័ន្ធនឹងគម្រោងបណ្តាញចែកចាយអគ្គិសនីទេ ។ ក្រុមស្រាវជ្រាវបានជ្រើសយក ៣០០គ្រួសារ ក្នុង ១០ភូមិ នៅ ៣ឃុំ មកធ្វើជាគំរូតាងសម្រាប់ក្រុមក្រៅគម្រោង ។

---

១ លោក ហ៊ីង វុត្ថា លោក សាំង ច័ន្ទហង្ស និងលោក យៀង សុធី ជាអ្នក ស្រាវជ្រាវ នៅវិទ្យាស្ថាន CDRI ។

២ Propensity Score Matching ជាវិធីសាស្ត្រស្រាវជ្រាវមួយដែលព្យាយាមផ្តល់នូវការប៉ាន់ស្មានមិនលំអៀងពីឥទ្ធិពលនៃប្រព្រឹត្តិកម្ម ។

បន្ទាប់ពីការប្រមូល និងសំអាតទិន្នន័យ ក្រុមស្រាវជ្រាវបានយកវិធីសាស្ត្រ PSM មកប្រើដើម្បីធានាលទ្ធភាពអនុវត្តវិធីផ្ទៀងផ្ទាត់ភាពខុសប្លែកគ្នាទ្វេដង (application of the double difference method) ។ គ្រួសារក្នុងក្រុមក្នុងគម្រោង ត្រូវបានប្រៀបធៀបជាមួយនឹងគ្រួសារក្នុងក្រុមក្រៅគម្រោង ដោយប្រើ "propensity score" (ប្រូបាប៊ីលីតេប៉ាន់ស្មាននៃការចូលរួមដោយផ្អែកលើលក្ខណៈបានសង្កេតឃើញ) ។ ក្នុងនេះ តម្លៃកាន់តែកៀកគ្នា មានន័យថា ការផ្គូផ្គងកាន់តែបានស្រដៀងគ្នាល្អ ។ វិធីសាស្ត្រនេះ មានគោលដៅចំបង រកឲ្យបានគ្រួសារចំនួន ២ក្រុម (ក្រុមក្នុងគម្រោង និងក្រុមក្រៅគម្រោង) ដែលមានលក្ខណៈស្រដៀងគ្នាបំផុត ។

## ៣. សូចនាករសេដ្ឋកិច្ច-សង្គមកិច្ចសំខាន់ៗ

សូចនាករសេដ្ឋកិច្ច-សង្គមកិច្ចសំខាន់ៗ បានពីអង្កេតគ្រួសារ មានជាសង្ខេបដូចតទៅ៖

- គ្រួសារក្នុងភូមិគំរូតាង មានសមាជិកប្រហែល ៥នាក់ ជាមធ្យម ក្នុងនោះ សមាជិកគ្រួសារស្ថិតក្នុងអាយុធ្វើការ មានចំនួនច្រើនជាងគេ រីឯសមាជិកវ័យក្មេង ឬចាស់ជរាមិនអាចធ្វើការបាន មានសរុបប្រហែល ១៧% នៃចំនួនប្រជាជនក្នុងក្រុមក្នុងគម្រោង និងក្រុមក្រៅគម្រោង ។
- អត្រាសមាជិកគ្រួសារក្នុងបន្ទុក ដែលជាផលចែករវាងចំនួនសមាជិកមិនមែនជាកម្លាំងពលកម្ម (សមាជិកក្នុងបន្ទុក) និងចំនួនសមាជិកជាកម្លាំងពលកម្ម (សមាជិកផលិត) មានតួលេខខ្ពស់ទាំងនៅក្នុងក្រុមក្នុងគម្រោង (៧០%) និងក្រុមក្រៅគម្រោង (៦០%) ។
- មុខរបរបឋមចំបងៗ របស់មេគ្រួសារ និងសមាជិកគ្រួសារ ទាំងក្នុង ក្រុមក្នុងគម្រោង និងក្រុមក្រៅគម្រោង គឺការងារកសិកម្ម នេសាទ និងវត្ថុប្រមាញ់ ។ ការងារមិនមែនកសិកម្មរបស់មេគ្រួសារ រួមមាន ការងារកាត់ដេរ សំណង់ ការជីករ៉ែ និងការងារកែច្នៃ និងសិប្បកម្ម ក្នុងនោះ ការងារកាត់ដេរប្រើពលករភាគច្រើនជានារី ។ ម៉្យាងទៀត គ្រួសារភាគច្រើនក្នុងក្រុមក្នុងគម្រោង (៩៣,៧%) និងក្រុមក្រៅគម្រោង (៨៨,៩%) ប្រកបមុខរបរខ្លួនឯង ។
- ទាក់ទិននឹងចំណូលប្រចាំថ្ងៃក្នុងមនុស្សម្នាក់ គ្រួសារក្នុងក្រុមក្នុងគម្រោង ទំនងរកប្រាក់ចំណូលបានច្រើនជាង គ្រួសារក្នុងក្រុមក្រៅគម្រោងដែលរស់នៅឆ្ងាយពីទីក្រុង និងផ្លូវជាតិ ។ គ្រួសារក្នុងក្រុមក្រៅគម្រោង ចូលរួមជាចំបងក្នុងសកម្មភាពកសិកម្ម ជាពិសេសការដាំដំណាំ រីឯគ្រួសារក្រុមក្នុងគម្រោង ចូលរួមជាចំបងក្នុងសកម្មភាពអាជីវកម្ម និងការលក់ដូរតូចតាច ។ លើសពីនេះទៀត គ្រួសារក្នុងក្រុមក្នុងគម្រោង មានចំណាយប្រើប្រាស់ប្រចាំថ្ងៃជាមធ្យមក្នុងមនុស្សម្នាក់ ខ្ពស់ជាងគ្រួសារក្នុងក្រុមក្រៅគម្រោង ។ ចំណាយប្រើប្រាស់ជាអាហារ មិនខុសគ្នាខ្លាំងទេ រវាងគ្រួសារក្នុងក្រុមទាំងពីរ ប៉ុន្តែចំណាយប្រើប្រាស់មិនមែនអាហារ វាខុសគ្នាច្រើន ។
- លំនាំនៃការបែងចែកដីកសិកម្មក្នុងក្រុមនីមួយៗ ស្រដៀងគ្នានឹងលំនាំទូទៅនៃការបែងចែកដីក្នុងគ្រួសារទាំងអស់ដែរ ។ ក្រុមក្នុងគម្រោង មានភាគរយគ្រួសារដែលគ្មានដីធ្លី និងភាគរយគ្រួសារដែលមានដីកសិកម្មតិចជាង ១ហិកតា ខ្ពស់ជាងក្រុមក្រៅគម្រោង ។ ប៉ុន្តែគ្រួសារដែលមានដីកសិកម្មធំៗ (លើសពី ១ហិកតា) ក្នុងក្រុមក្រៅគម្រោង ហាក់មានច្រើនជាងក្នុងក្រុមក្នុងគម្រោង ។
- ចំពោះហិរញ្ញវត្ថុគ្រួសារវិញ ប្រហែលពាក់កណ្តាលនៃគ្រួសារក្នុងក្រុមក្រៅគម្រោង ត្រូវខ្ចីប្រាក់គេសម្រាប់ដោះស្រាយចំណាយប្រើប្រាស់ និងចំណាយផលិតកម្ម ហើយជាងពាក់កណ្តាលបន្តិចនៃគ្រួសារក្នុងក្រុមក្នុងគម្រោង ក៏ត្រូវខ្ចីបុលគេដូចគ្នា ដែលបង្ហាញពី

ភាពស្រដៀងគ្នានៃស្ថានភាពបំណុលគ្រួសារក្នុងក្រុមទាំងពីរ ។ ចំពោះប្រភពនៃប្រាក់កំចីវិញ ដោយសារគ្រួសារក្នុងក្រុមក្នុងគម្រោង មានទីតាំងភូមិសាស្ត្រនៅក្បែរទីរួមខេត្ត ជាពិសេសនៅជិតផ្លូវជាតិ ពួកគាត់ហាក់មានលទ្ធភាពទទួលបានកំចីតាមប្រព័ន្ធផ្លូវការ ប្រសើរជាងគ្រួសារក្នុងក្រុមក្រៅគម្រោង ។

- ប្រជាជនសរុបប្រហែល ៧០% ចេះអក្សរ និង ៣០% មិនចេះអក្សរ ។ ជាទូទៅ បុរសចេះអក្សរមានចំនួនច្រើននាក់ ជាងនារីចេះអក្សរ ហើយស្ថិតិ (t-statistic) បញ្ជាក់ពីភាពស្រដៀងគ្នារវាងក្រុមក្នុងគម្រោង និងក្រុមក្រៅគម្រោង ។ ការអប់រំជារួមក្នុងគំរូតាងទាំងមូល និងក្នុងចំណោមមេគ្រួសារ មានកម្រិតទាបជាខ្លាំង ។ ទិន្នន័យអង្កេតក៏បង្ហាញដែរថា អត្រាចុះឈ្មោះចូលរៀនថ្នាក់បឋមសិក្សា មាន ៩៦% សម្រាប់ក្រុមក្រៅគម្រោង និង ៩៩% សម្រាប់ក្រុមក្នុងគម្រោង ធៀបនឹងកម្រិត ៨៩% សម្រាប់ទូទាំងប្រទេស ។
- ប្រហែល ១ភាគ៣ នៃគ្រួសារក្នុងគំរូតាង បានរាយការណ៍ថា មានបញ្ហាសុខភាពក្នុងអំឡុង ៤សប្តាហ៍ មុនពេលចុះអង្កេត ហើយបញ្ហាកើតមានទូទៅជាងគេ គឺផ្តាសាយ និងគ្រុនក្តៅ ។ ប្រជាជនភាគច្រើនដែលជួបបញ្ហាសុខភាព បានស្វែងរកការព្យាបាលលើបញ្ហាសុខភាពមួយមុខ ឬច្រើនមុខ ។ ជាទូទៅកន្លែងទទួលបានសេវាថែទាំសុខភាព រួមមាន មន្ទីរពេទ្យ ឬ គ្លីនិកឯកជន ឱសថស្ថានឯកជន និងផ្ទះរបស់គិលានុបដ្ឋាកមានការបណ្តុះបណ្តាល ឬបុគ្គលិកសុខាភិបាលផ្សេងទៀត ។ មានប្រជាជនមិនច្រើននាក់ទេ ដែលទៅស្វែងរកការព្យាបាលនៅមណ្ឌលសុខភាពខេត្ត ឬស្រុក និងមានកាន់តែតិចនាក់ទៀត ដែលទៅព្យាបាលនៅមន្ទីរពេទ្យជាតិ ។
- ការយល់ដឹងរបស់មេគ្រួសារ លើបញ្ហាសុខភាពសាធារណៈសំខាន់ៗ មានកម្រិតខ្ពស់ ។ មេគ្រួសារជាង ៨០% បានដឹងពីគ្រោះថ្នាក់នៃការជក់បារី រោគសញ្ញាជម្ងឺគ្រុនឈាម វិធានការការពារ ការចាក់ថ្នាំបង្ការដល់កុមារ ជម្ងឺអេដស៍និងវិធីបង្ការ ជម្ងឺផ្តាសាយបក្សី ការពន្យាកំណើតកូន ជម្ងឺរបេង និងគ្រុនចាញ់ ។ ប្រព័ន្ធផ្សព្វផ្សាយអេឡិចត្រូនិក ហាក់ដូចមានប្រសិទ្ធភាពជាងគេក្នុងការផ្សព្វផ្សាយព័ត៌មាន ។ ប្រភពព័ត៌មានផ្សេងទៀត រួមមាន មណ្ឌលសុខភាព អង្គការមិនមែនរដ្ឋាភិបាលចុះជួយសហគមន៍ និងមិត្តអប់រំមិត្ត ។
- ចំណេះដឹងល្អតែងមានអមដោយរបៀបរបបអនុវត្តល្អខាងថែទាំសុខភាពមួយចំនួន ក្នុងនេះការជក់បារី ឃើញមានតិចណាស់ក្នុងក្រុមទាំងពីរ ។ ការអនុវត្តល្អខាងសុខភាពមួយទៀត គឺការចាក់ថ្នាំបង្ការដល់កុមារ និងស្ត្រីមានគត៌ ។ អត្រាអ្នកទៅពិនិត្យផ្ទៃពោះ ហាក់មានកម្រិតខ្ពស់ ហើយស្ទើរគ្រប់គ្រួសារបានយកកូនទៅចាក់ថ្នាំបង្ការ ។
- ពេលវេលាចំណាយលើសកម្មភាពពេលល្ងាចប្រចាំថ្ងៃ ប្រែប្រួលខុសគ្នាខ្លាំងរវាងមេគ្រួសារជាបុរស និងជានារី ប៉ុន្តែមិនខុសគ្នាគួរឲ្យគត់សម្គាល់ទេ រវាងគ្រួសារក្នុងក្រុមក្នុងគម្រោង និងក្រុមក្រៅគម្រោង ។ មេគ្រួសារជាបុរស ចំណាយពេលប្រហែល ៥០% ក្នុងសកម្មភាពកំសាន្ត ដូចជា មើលទូរទស្សន៍ និងស្តាប់វិទ្យុ និង ២៥% ក្នុងសកម្មភាពសង្គមផ្សេងៗ ប៉ុន្តែចំណាយពេលតិចជាខ្លាំងលើសកម្មភាពបង្កើតប្រាក់ចំណូល និងការអប់រំ ។ មេគ្រួសារជានារី ចំណាយពេលច្រើនណាស់លើការងារក្នុងផ្ទះ មើលទូរទស្សន៍ និងស្តាប់វិទ្យុ ប៉ុន្តែចំណាយពេលតិចលើសកម្មភាពទំនាក់ទំនងសង្គម ការបង្កើតប្រាក់ចំណូល និងការអប់រំ ។
- ប្រភពថាមពលចំបងក្នុងភូមិសិក្សា គឺអុស អាគុយឡាន និងប្រេងកាត ។ គេចំណាយថាមពលជាសំខាន់សម្រាប់ការដុតបំភ្លឺ ចំអិនអាហារ ដាំទឹក និងការកំសាន្ត ។ គ្រួសារចំណាយជាមធ្យម ១០,៥៩ដុល្លារក្នុងមួយខែ លើថាមពល ហើយគ្រួសារក្នុងក្រុម

ក្នុងគម្រោង ចំណាយច្រើនជាងគ្រួសារក្នុងក្រុមក្រៅគម្រោង (១១,៣ដុល្លារ ធៀបនឹង ១០,៤១ដុល្លារ) ប៉ុន្តែចំនួនខុសគ្នានេះ មិនធំគួរកត់សម្គាល់ខាងស្ថិតិទេ ។ ចំណាយលើអុស និងអាគុយឡាន គួបបញ្ចូលគ្នា មានចំណែកធំជាងគេក្នុងចំណាយលើថាមពលសរុប ។

- គ្រួសារភាគច្រើន មានអាគុយឡានមួយ សម្រាប់ប្រើជាប្រភពអគ្គិសនីចំបង ។ ចំពោះសំណួរថា តើចង់តភ្ជាប់នឹងបណ្តាញចរន្តអគ្គិសនីដែរឬទេ គ្រួសារភាគច្រើនបញ្ជាក់ពីការចាប់អារម្មណ៍ជាខ្លាំង ដោយពួកគាត់ត្រូវការវាជាសំខាន់សម្រាប់ការបំភ្លឺ និងការកំសាន្ត (ទូរទស្សន៍ និងវិទ្យុ) ។ ហេតុផលផ្សេងទៀតដែលពួកគាត់បានលើកឡើង រួមមានតម្លៃទាបនៃអគ្គិសនីបណ្តាញ បើធៀបនឹងប្រភពអគ្គិសនីផ្សេងទៀត ជាពិសេសសម្រាប់ការបំភ្លឺឲ្យកូនរៀន និងរបររកស៊ីផ្សេងៗ ។
- ប្រសិនបើមានបណ្តាញអគ្គិសនីរាយទៅដល់ គ្រួសារនីមួយៗ ពេញចិត្តចំណាយពី ១០,២២ ដល់ ១៤,២៤ដុល្លារ លើថ្លៃតភ្ជាប់ ។ ចំពោះថ្លៃអគ្គិសនី គ្រួសារក្នុងក្រុមក្រៅគម្រោង ចង់ឲ្យអ្នកផ្គត់ផ្គង់យកថ្លៃ ០,១៣ដុល្លារ/គីឡូវ៉ាត់ម៉ោង (Kwh) រីឯគ្រួសារក្នុងក្រុមក្នុងគម្រោង សុំឲ្យយក ០,១២ដុល្លារ/គីឡូវ៉ាត់ម៉ោង (Kwh) ។

## ៤. ការផ្គូផ្គងគ្រួសារក្នុងក្រុមក្នុងគម្រោង និងក្រុមក្រៅគម្រោង

### ៤.១. ជំហានក្នុងការប៉ាន់ស្មាន

វិធីសាស្ត្រ PSM ឃើញមានប្រើជាទូទៅក្នុងការវាយតម្លៃគោលនយោបាយទីផ្សារពលកម្ម និងកំពុងតែពេញនិយមឡើងនៅក្នុងវិស័យផ្សេងៗទៀត សម្រាប់ស្ថានភាពដែលមានក្រុមមួយស្ថិតនៅក្នុងគម្រោង និងក្រុមមួយទៀតស្ថិតនៅក្រៅគម្រោង (Caliendo & Kopeinig) ។ វិធីសាស្ត្រនេះមានគោលបំណងចំបង ដើម្បីប៉ាន់ស្មានពីឥទ្ធិពលនៃប្រព្រឹត្តិកម្មទៅលើក្រុមទាំងពីរនោះ ។ ដើម្បីទទួលបានគ្រួសារស្រដៀងៗគ្នាអំពីក្រុមទាំងពីរនេះ ដំបូងគេត្រូវគណនារក propensity score (ប្រូបាប៊ីលីតេប៉ាន់ស្មាន) នៃការចូលរួមរបស់គ្រួសារក្នុងគម្រោង ដោយប្រើគំរូ standard logistic regression (probit/ logit) ។ អថេរឯករាជ្យជ្រើសរើសសម្រាប់គំរូនេះ មិនត្រូវរងការប៉ះពាល់ដោយការចូលរួមរបស់គ្រួសារក្នុងគម្រោងទេ ។ បន្ទាប់ពីទទួលបាន propensity score ហើយគេប្រើវាដើម្បីផ្គូផ្គងគ្រួសារនៃក្រុមទាំងពីរ ដោយជ្រើសយកបច្ចេកទេសផ្គូផ្គងមួយក្នុងចំណោមបច្ចេកទេសជាច្រើន រួមមាន one-to-one matching, K-nearest neighbours matching, radius matching, kernel matching, local linear regression matching, spline matching និង Mahalanobis matching ។

ប្រសិទ្ធភាពនៃវិធីប៉ាន់ស្មានដើម្បីផ្គូផ្គងខុសៗគ្នា វាប្រែប្រួលពីករណីមួយទៅករណីមួយទៀត ហើយពឹងផ្អែកខ្លាំងលើរចនាសម្ព័ន្ធទិន្នន័យដែលគេមាន (Zhao 2000 cited in Caliendo & Kopeinig 2008:45) ។ ម្យ៉ាងទៀត ដើម្បីវាយតម្លៃពីគុណភាពនៃការផ្គូផ្គងនេះ គេត្រូវពិនិត្យពីលំអៀងស្តង់ដារនៃអថេរមិនប្រែប្រួលនីមួយៗក្នុង logistic regression នៅមុននិងក្រោយពេលធ្វើការផ្គូផ្គង ។ ការសិក្សាជាក់ស្តែងភាគច្រើនអះអាងថា លំអៀងស្តង់ដារក្រោម ៣% ឬ ៥% បន្ទាប់ពីការផ្គូផ្គង គួរចាត់ទុកថាមានលក្ខណៈគ្រប់គ្រាន់ (Caliendo & Kopeinig, 2008:48) ។

### ៤.២. ទិន្នន័យ និងការកំណត់គំរូ

ដើម្បីប៉ាន់ស្មានពីប្រូបាប៊ីលីតេ នៃការចូលរួមរបស់គ្រួសារក្នុងក្រុមទាំងពីរ អង្កេតសម្រាប់គម្រោងបញ្ជូនចរន្តអគ្គិសនី បានប្រើគំរូ probit regression ដូចមានបង្ហាញក្នុងសមីការខាងក្រោម៖

$$ADB_project = \beta_0 + \beta_1 hhsize + \beta_2 hhage + \beta_3 hhagesqr + \beta_4 hheduc + \beta_5 hheducsqr + \beta_6 hhsex + \beta_7 candle\ \exp + \beta_8 firewood\ \exp + \beta_9 charcoal\ \exp + \beta_{10}\ kerosene\ \exp + \beta_{11} carbattery\ \exp + \beta_{12} smallbattery\ \exp + \beta_{13} hhoccup + \beta_{14} landtype + \beta_{15} housebrick + \beta_{16} index\ homequip + \beta_{17} indextransport + \beta_{18} indexagri + \beta_{19} telephone + \beta_{20} credit + \beta_{21} primschool + \beta_{22} ngoserv\ \beta_{23} toilet + \beta_{24} hhhealth + \beta_{25} wateracc + \beta_{26} literacy + \mu$$

ទិន្នន័យបានពីអង្កេតគ្រួសារ និងអង្កេតភូមិ បានយកមកប្រើក្នុងការវិភាគនេះ ដើម្បីត្រួតពិនិត្យទាំងប្រជាសាស្ត្រគ្រួសារ និងលក្ខណៈសម្គាល់របស់ភូមិ ។

## ៤.៣. លទ្ធផលជាក់ស្តែង

លទ្ធផលនៃគំរូ probit regression មុនពេលផ្គូផ្គង មានបង្ហាញក្នុងតារាង ១ ដែលក្នុងនោះប្រូបាប៊ីលីតេប៉ាន់ស្មាននៃការចូលរួម ឬហៅថា propensity score បានយកមកប្រើ ដើម្បីផ្គូផ្គងគ្រួសារនៃក្រុមប្រៀបធៀបទាំងពីរ ។ មានអថេរសម្រាប់ផ្ទៀងផ្ទាត់មួយចំនួន ដែលមានទំនាក់ទំនងខ្លាំងជាមួយការសម្រេចចិត្តរបស់គ្រួសារ លើការតភ្ជាប់បណ្តាញបញ្ជូនអគ្គិសនី និងមានគំលាតខ្ពស់ខាងស្ថិតិនៅចន្លោះកម្រិត ១% ទៅ ៥% ។ ឧទាហរណ៍ ក្នុងអំឡុង ៦ខែចុងក្រោយនេះ ប្រសិនបើមេគ្រួសារមានធ្វើការងារកាន់តែច្រើនមុខ ប្រូបាប៊ីលីតេនៃគ្រួសារនោះ បានតភ្ជាប់នឹងបណ្តាញអគ្គិសនីក៏កាន់តែមានកម្រិតខ្ពស់ ។ ភស្តុតាងដូចគ្នា ក៏បានរកឃើញដែរក្នុងការចំណាយលើទៀន ចំណាយលើប្រេងកាត ស្ថានភាពលំនៅឋាន បរិក្ខារប្រើនៅផ្ទះ និងវត្តមានសេវាអង្គការមិនមែនរដ្ឋាភិបាល និងសាលាបឋមសិក្សាក្នុងភូមិ ។

តារាង ១៖ Probit Regression នៃគំរូតាងមួយមាន ៧៨៨គ្រួសារ

| អថេរឯករាជ្យ | មេគុណ | លំអៀងស្តង់ដារ | តម្លៃ z |
|---|---|---|---|
| ទំហំគ្រួសារ | 0.04 | 0.03 | 1.24 |
| អាយុគ្រួសារ | -0.01 | 0.03 | -0.41 |
| អាយុគ្រួសារលើកជាការ៉េ | 0.00 | 0.00 | 0.39 |
| ការអប់រំរបស់គ្រួសារ | -0.06 | 0.06 | -0.99 |
| ការអប់រំរបស់គ្រួសារលើកជាការ៉េ | 0.01 | 0.00 | 1.28 |
| ភេទរបស់គ្រួសារ | 0.05 | 0.13 | 0.36 |
| ចំណាយលើទៀន | 0.00 | 0.00 | 1.99** |
| ចំណាយលើអុស | 0.00 | 0.00 | 0.54 |
| ចំណាយលើធ្យូង | 0.00 | 0.00 | -0.24 |
| ចំណាយលើប្រេងកាត | 0.00 | 0.00 | 1.97** |
| ចំណាយលើអាគុយឡាន | 0.00 | 0.00 | -0.66 |
| ចំណាយលើថ្មពិល | 0.00 | 0.00 | 0.96 |
| មុខរបររបស់គ្រួសារ | 0.20 | 0.08 | 2.68*** |
| ប្រភេទដីធ្លី | -0.24 | 0.25 | -0.96 |
| ផ្ទះសង់ពីឥដ្ឋ | 0.71 | 0.25 | 2.85*** |
| សន្ទស្សន៍បរិក្ខារក្នុងផ្ទះ | 0.12 | 0.04 | 2.75*** |
| សន្ទស្សន៍ការដឹកជញ្ជូន | 0.04 | 0.05 | 0.74 |

| | | | |
|---|---|---|---|
| សន្ទស្សន៍បរិក្ខារកសិកម្ម | -0.11 | 0.04 | -2.65*** |
| ទូរស័ព្ទ | -0.32 | 0.10 | -3.12*** |
| ឥណទាន | 0.09 | 0.11 | 0.89 |
| សាលាបឋមសិក្សា | 1.00 | 0.13 | 7.88*** |
| សេវាអង្គការមិនមែនរដ្ឋាភិបាល | 0.67 | 0.15 | 4.49*** |
| បង្គន់ | -0.01 | 0.12 | -0.10 |
| សុខភាពគ្រួសារ | 0.12 | 0.11 | 1.11 |
| លទ្ធភាពទទួលបានទឹកប្រើប្រាស់ | 0.15 | 0.11 | 1.43 |
| អក្ខរកម្ម | 0.11 | 0.18 | 0.58 |
| អញ្ញត្តិថេរ (constant) | -0.92 | 0.71 | -1.31 |
| ចំនួនការសង្កេត | 744 | | |
| Pseudo $R^2$ | 0.169 | | |

*Note: level of significance: * at 10 percent; ** at 5 percent; *** at 1 percent level*

តារាង២ បង្ហាញថាប្រតិបត្តិការផ្គូផ្គង ដោយប្រើវិធីសាស្ត្រ K-nearest neighbour (k=3) ផ្តល់នូវលទ្ធផលគួរជាទីពេញចិត្ត សម្រាប់ប្រាក់ចំណូលសរុបមធ្យម ចំណាយប្រើប្រាស់ ពេលវេលាសិក្សារបស់មនុស្សពេញវ័យក្នុងគ្រួសារ និងពេលវេលាសម្រាប់បង្រៀនកូន ប៉ុន្តែភាពខុសគ្នាក្នុងសមាសភាគប្រាក់ចំណូល ដូចជា ដំណាំ ធនធានទ្រព្យរួម បៀវត្សរ៍ និងប្រាក់ផ្ញើទៅផ្ទះជាដើម រវាងគ្រួសារក្នុងក្រុមទាំងពីរនេះ នៅមានកម្រិតខ្ពស់នៅឡើយ ។

**តារាង ២៖ ការប្រៀបធៀបពីអថេរលទ្ធផល (outcome variables) បន្ទាប់ពីការផ្គូផ្គង**

| អថេរលទ្ធផល | ភាពខុសគ្នា (មិនផ្គូផ្គង) | | ភាពខុស (ផ្គូផ្គង) | |
|---|---|---|---|---|
| | មិនផ្គូផ្គង | T-statistics | ផ្គូផ្គង (ATT) | T-statistics |
| ចំណូល | 984.57 | 2.26** | 167.06 | 0.31 |
| ចំណូលពីដំណាំ | -538.73 | -3.12*** | -1042.53 | -4.18*** |
| ចំណូលពីសត្វចិញ្ចឹម | 172.90 | 1.31 | 276.00 | 1.52 |
| ចំណូលពីធនធានរួម | 25.53 | 2.10** | 27.38 | 2.52*** |
| ចំណូលពីបៀវត្សរ៍ | 367.30 | 2.95*** | 272.71 | 1.75* |
| ចំណូលពីប្រាក់ផ្ញើទៅផ្ទះ | 122.15 | 2.21** | 121.37 | 1.90* |
| ចំណូលពីការធ្វើជំនួញ | 839.13 | 2.36** | 520.24 | 1.18 |
| ចំណូលផ្សេងៗ | -3.70 | -0.08 | -8.11 | -0.13 |
| ចំណាយប្រើប្រាស់ | 1118.82 | 2.44*** | 143.65 | 0.24 |
| ចំណាយប្រើប្រាស់ជាអាហារ | 138.16 | 0.90 | 98.53 | 0.48 |
| ចំណាយប្រើប្រាស់មិនមែនអាហារ | 980.66 | 2.62*** | 45.12 | 0.09 |
| ការសិក្សារបស់បុរស | 1.67 | 0.84 | -4.10 | -1.43 |
| ការសិក្សារបស់នារី | 2.06 | 1.07 | 4.86 | 1.89* |
| ការបង្រៀនរបស់គ្រួសារ | -0.05 | -0.06 | 0.07 | 0.06 |

*ប្រភព៖ លទ្ធផលការផ្គូផ្គងបានពីទិន្នន័យអង្កេត*

លទ្ធផលនេះបង្ហាញថា បន្ទាប់ពីបានកំណត់ច្បាស់លក្ខណៈសម្គាល់គ្រួសារ និងសម្គាល់ភូមិ គេក៏ទទួលបានគ្រួសារក្នុងក្រុមក្នុងគម្រោង និងក្រុមក្រៅគម្រោង ដែលមានលក្ខណៈស្រដៀងគ្នាក្នុងប្រាក់ចំណូលសរុបមធ្យម ឥរិយាបថនៃការប្រើប្រាស់ និងការលៃពេលសម្រាប់ការអាន និងបង្រៀននៅផ្ទះ ។

ទោះបីប្រតិបត្តិការផ្គូផ្គង មិនអាចផ្តល់លទ្ធផលប្រសើរជាងមុន ទាក់ទងនឹង ចំណូលគ្រួសារពីប្រភពផ្សេងៗក្តី ក៏លំអៀងមេដ្យាននៃប្រតិបត្តិការផ្គូផ្គងនេះបានថយចុះច្រើន ។ កម្រិតលំអៀងនៃអថេរមិនប្រែប្រួលមុនពេលផ្គូផ្គង គឺ ១៣,៥០៥ % ហើយបានថយចុះមកត្រឹម ៣,៩៦៥% បន្ទាប់ពីធ្វើការផ្គូផ្គង ។ លទ្ធផលនេះ បង្ហាញពីភាពគួរឲ្យជឿទុកចិត្តជាងមុននៃលទ្ធផលផ្គូផ្គង និងបង្ហាញពីតុល្យភាពនៃក្រុមប្រៀបធៀបទាំងពីរ ឬ ការកាត់បន្ថយភាគរយលំអៀងនៃអថេរមិនប្រែប្រួលទាំងអស់ក្នុងសមីការ logit regression ។ តាមរយៈប្រតិបត្តិការផ្គូផ្គងនេះ មាន ៣៥គ្រួសារត្រូវបានជម្រុះចោល ដូច្នេះ គំរូតាងចុងក្រោយមានទំហំ ៧០៩គ្រួសារ ។

តារាង ៣៖ សង្ខេបចំនួនគ្រួសារដែលត្រូវរក្សាទុក (on support) និងជម្រុះចោល (off support)

| psmatch2: treatment assignment | pasmatch2: common support | | សរុប |
|---|---|---|---|
| | Off support | On support | |
| គ្រួសារក្រៅគម្រោង | 0 | 300 | 300 |
| គ្រួសារក្នុងគម្រោង | 35 | 409 | 444 |
| សរុប | 35 | 709 | 744 |

*ប្រភព៖ ការគណនារបស់អ្នកនិពន្ធផ្អែកលើទិន្នន័យអង្កេត*

## ៥. សេចក្តីសន្និដ្ឋាន

អត្ថបទនេះ បង្ហាញពីការប្រើប្រាស់វិធីសាស្ត្រ PSM—k-nearest neighbour matching (k=3) ដើម្បីបង្កើតលទ្ធផលផ្គូផ្គងមួយរវាង គ្រួសារនៅក្នុងក្រុមក្រៅគម្រោង ជាមួយនឹងគ្រួសារមានលក្ខណៈស្រដៀងគ្នាក្នុងក្រុមក្នុងគម្រោង ហើយប្រើប្រាស់លទ្ធផលនោះជាសូចនាករមូលដ្ឋានសម្រាប់គម្រោងបញ្ជូនចរន្តអគ្គិសនីនៅមហាអនុតំបន់មេគង្គ របស់ធនាគារអភិវឌ្ឍន៍អាស៊ី ។ ប្រតិបត្តិការផ្គូផ្គងនេះ បានផ្តល់លទ្ធផលគួរពេញចិត្ត សម្រាប់សមាសភាគ ចំណាយប្រើប្រាស់ ពេលវេលាសិក្សារបស់មនុស្សប្រុសពេញវ័យ ពេលវេលាបង្រៀនក្រុមគ្រួសារនិងកូនៗ ប៉ុន្តែភាពខុសគ្នាក្នុងចំណូលសរុបរបស់គ្រួសារទាំងពីរក្រុម ចំណូលបានពីប្រភពផ្សេងៗ ដូចជា ដំណាំ ធនធានទ្រព្យរួមពលកម្ម បៀវត្សរ៍ និងប្រាក់ផ្ញើទៅផ្ទះ នៅតែមានគំលាតខាងស្ថិតិខ្ពស់ដដែល ទោះបីបានថយចុះខ្លះក្តី ។ លទ្ធផលនេះបង្ហាញថា បន្ទាប់ពីបានកំណត់ច្បាស់ពីលក្ខណៈសម្គាល់គ្រួសារ និងសម្គាល់ភូមិ គេអាចទទួលបាននូវគ្រួសារក្នុងក្រុមក្នុងគម្រោង និងក្រៅគម្រោងដែលមានលក្ខណៈស្រដៀងគ្នា ដូចជា ឥរិយាបទចំណាយប្រើប្រាស់ ចំណាយសរុប និងការលៃពេលវេលាសម្រាប់ការអាននិងបង្រៀននៅផ្ទះ ជាដើម ។

ការវិភាគដោយប្រើវិធីសាស្ត្រ PSM អាចជួយឲ្យរកឃើញគ្រួសារដែលមានលក្ខណៈសម្គាល់ផ្គូផ្គងគ្នាល្អសម្រាប់យកមកប្រើក្នុងការប្រៀបធៀបរវាងតំបន់មិនអនុវត្តគម្រោង និងតំបន់ត្រូវអនុវត្តគម្រោង ហើយគេអាចពិចារណាជម្រុះគ្រួសារប្រៀបធៀបខ្លះ (គ្រួសារមានលក្ខណៈសម្គាល់ខុសគ្នាខ្លាំងពេក) ចេញពីអង្កេតដែលត្រូវធ្វើឡើងដើម្បីតាមដានបន្តទៀត ។ ក្រោយការផ្គូផ្គង មាន ៣៥គ្រួសារ ត្រូវបានកាត់ចេញពី ៧៤៤គ្រួសារក្នុងគំរូតាងដើម ហើយបង្កើតបានជាគំរូតាងថ្មីមួយមាន ៧០៩គ្រួសារ ។ សម្រាប់ការសិក្សាវាយតម្លៃតាមដានបន្តទៀត ក្រុមស្រាវជ្រាវគួរយកភូមិគំរូតាងដែលបានផ្គូផ្គងរួច ជាកន្លែងសិក្សា ដើម្បីអាចកាត់បន្ថយចំណាយលើអង្កេតបានខ្លះ ។

## ឯកសារយោង


Asian Development Bank (2003), Greater Mekong Sub-region Transmission Project, report and recommendation of the president to the Board of Directors, RRP: CAM 34390 (Manila: ADB)

Asian Development Bank (2008a), Building a Sustainable Energy Future: The Greater Mekong Sub-region (Manila: ADB)

Asian Development Bank (2008b), Assessing the Socioeconomic Effects of the Greater Mekong Sub-region Projects, Regional Technical Assistance Report, Project Number 42148 (Manila: ADB)

Caliendo, Marco & Sabine Kopeinig (2008), Some Practical Guidance for the Implementation of Propensity Score Matching, *Journal of Economic Surveys*, Vol. 22, No.1, pp. 31-72

Cecelski, Elizabeth (2002), Enabling Equitable Access to Rural Electrification: Current Thinking on Energy, Poverty and Gender, Briefing Paper (Washington, DC: World Bank)

Electricite du Cambodge (2005), Greater Mekong Sub-region Transmission Project, Inception Report (Phnom Penh: EDC)

Electricite du Cambodge (2009), Greater Mekong Sub-region Transmission Project, Quarterly Report No.16 (Phnom Penh: EDC)

Human Development Research Centre (2002), Economic and Social Impact Evaluation Study of the Rural Electrification Program in Bangladesh (Dhaka: HDRC)

Murshid, K.A.S. (1998), Food Security in an Asian Transitional Economy: The Cambodian Experience, Working Paper No. 6 (Phnom Penh: CDRI)

World Bank (2009), Poverty Profile and Trend in Cambodia: Findings from the 2007 Cambodia Socioeconomic Survey. (Washington, DC: World Bank)

World Bank (2008a), The Welfare Impact of Rural Electrification: A Reassessment of the Cost and Benefit, An Independence Evaluation Group Impact Evaluation (Washington, DC: World Bank)

World Bank (2008b), Cambodia: Sharing Growth, Equity and Development Report 2007 (Phnom Penh: World Bank)

World Bank (2007), Cambodia: Sharing Growth, Equity and Development Report 2007 (Phnom Penh: World Bank)

World Bank (2006), Cambodia: Halving Poverty by 2015? (Phnom Penh: World Bank)

Zhao, Zhong (2000), Data Issues of Using Matching Methods to Estimate Treatment Effects: An Illustration with NSW Data Set, (China: China Centre for Economic Research)

# -IV-
# ក្របខ័ណ្ឌគោលនយោបាយ និងស្ថានភាព ទេសន្តរប្រវេសន៍ពលកម្មនៅកម្ពុជា

*ដោយលោក ហ៊ីង វុត្ថា លោក លន់ ពិដេ និងកញ្ញា ផាន់ ដាលីស*[១]

## ១. សេចក្ដីផ្ដើម

ទេសន្តរប្រវេសន៍ពលកម្មនៅកម្ពុជា បានវិវត្តយ៉ាងច្រើននៅទសវត្សរ៍ចុងក្រោយនេះ ចេញពីទេសន្តរប្រវេសន៍ជនភៀសខ្លួននៅទសវត្សរ៍១៩៨០ និង ១៩៩០ ក្នុងអំឡុងពេលមានសង្គ្រាមស៊ីវិល និងអស្ថិរភាពនយោបាយ មកជាទេសន្តរប្រវេសន៍ដែលសំខាន់ជាខ្លាំងសម្រាប់សេដ្ឋកិច្ចជាតិ និងជីវភាពរស់នៅរបស់ក្រុមគ្រួសារ ។ ពលករកម្ពុជាភាគច្រើន ធ្វើចំណាកស្រុកតាមច្រកមិនផ្លូវការ ឬមិនស្របច្បាប់ ដោយមានជនចំណាកស្រុកមុនៗ ឬឈ្មួញកណ្ដាល ការជួយនាំផ្លូវទៅកាន់កន្លែងពលកម្មនៅប្រទេសគោលដៅ ។ ប្រព័ន្ធជ្រើសរើសពលករស្របច្បាប់ កើតមានឡើងនៅចុងទសវត្សរ៍១៩៩០ ប៉ុន្តែជាទូទៅគេគិតថា ដំណើរការតាមប្រព័ន្ធនេះត្រូវចំណាយប្រាក់ច្រើន និងស្មុគស្មាញ ។ ចលនាកម្លាំងពលកម្មឆ្លងកាត់ច្រកព្រំដែននៅកម្ពុជា បានវិវត្តជាច្រើនឆ្នាំក្នុងស្ថានភាពមួយដែលមានក្របខ័ណ្ឌត្រួតពិនិត្យទន់ខ្សោយ និងគ្មានគោលនយោបាយទេសន្តរប្រវេសន៍ច្បាស់លាស់ ។ កន្លងមក រដ្ឋាភិបាលបានប្រឹងប្រែង និងជឿនលឿនច្រើនហើយ ក្នុងការបង្កើតគោលនយោបាយទេសន្តរប្រវេសន៍ និងលើកកម្ពស់ក្របខ័ណ្ឌច្បាប់ ដើម្បីធ្វើការគ្រប់គ្រង និងត្រួតពិនិត្យទេសន្តរប្រវេសន៍បានកាន់តែប្រសើរ ។ អត្ថបទនេះ ពិនិត្យឡើងវិញពីស្ថានភាពទេសន្តរប្រវេសន៍ពលកម្ម និង វាយតម្លៃពីគោលនយោបាយ និងក្របខ័ណ្ឌច្បាប់នៅកម្ពុជា ។

## ២. ស្ថានភាពទេសន្តរប្រវេសន៍ពលកម្មនៅកម្ពុជា

ទេសន្តរប្រវេសន៍ពលកម្មនៅកម្ពុជា បានកើនឡើងយ៉ាងខ្លាំង ទាំងជាចំនួននៃពលករ និងចំនួនប្រទេសគោលដៅ ។ ក្នុងអំឡុងឆ្នាំ១៩៩៨-២០០៩ មានពលករកម្ពុជា ៤៥.៦៥៦នាក់ ដែលត្រូវបានបញ្ជូនតាមច្រកផ្លូវការទៅធ្វើការនៅបរទេស តាមរយៈកិច្ចព្រមព្រៀងទ្វេភាគី និងមានពលករមួយសែននាក់ផ្សេងទៀត ដែលបានចេញទៅធ្វើការនៅបរទេស ដោយគ្មានលិខិតអនុញ្ញាត ឬឯកសារត្រឹមត្រូវទៅតាមបទបញ្ញត្តិខាងអន្តោប្រវេសន៍ទេ ។

ទេសន្តរប្រវេសន៍ស្របច្បាប់ (regular migration)

ទេសន្តរប្រវេសន៍រៀបរយស្របច្បាប់ ឬហៅម៉្យាងទៀតថា ទេសន្តរប្រវេសន៍មានសំណុំបែបបទត្រឹមត្រូវ គឺសំដៅដល់ចលនាបំលាស់ទីតាមច្រកស្របច្បាប់ (IOM Glossary on Migration) ។ ចំនួនពលករកម្ពុជាស្របច្បាប់ បានកើនឡើងជាបន្តបន្ទាប់នៅចុងទសវត្សរ៍នេះ ។ ក្នុងចន្លោះឆ្នាំ ១៩៩៨ និង ២០០៩ កម្ពុជាបានបញ្ជូនពលករ ៤៥.៦៥៦នាក់ ទៅធ្វើការនៅប្រទេសក្រៅ ក្នុងនោះប្រហែល ៥២% ទៅម៉ាឡេស៊ី ៣៤% ទៅថៃ និង ១៤% ទៅកូរ៉េខាងត្បូង ។

---

១ លោក ហ៊ីង វុត្ថា លោក លន់ ពិដេ ជាអ្នកស្រាវជ្រាវ និងកញ្ញា ផាន់ ដាលីស ជាជំនួយការស្រាវជ្រាវ នៅវិទ្យាស្ថាន CDRI ។

ក្រាហ្វិក ១៖ ពលករចំណាកស្រុកកម្ពុជាត្រូវបានបញ្ជូនជាផ្លូវការទៅបរទេសសរុប (បែងចែកតាមភេទ)




*ប្រភព៖ ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ*

ក្រាហ្វិក ២៖ ពលករចំណាកស្រុកកម្ពុជាត្រូវបានបញ្ជូនជាផ្លូវការទៅបរទេសសរុប (បែងចែកតាមប្រទេសគោលដៅ)




*ប្រភព៖ ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ*

ទេសន្តរប្រវេសន៍មិនស្របច្បាប់ (irregular migration)

យោងតាមសេចក្តីសម្រេចរបស់មហាសន្និបាតអង្គការសហប្រជាជាតិ លេខ 3449 (XXX)[២], ពលករចំណាកស្រុកមិនស្របច្បាប់ សំដៅលើ "ពលករចូលទៅក្នុងប្រទេសដទៃទៀតដោយមិនស្របច្បាប់ និង/ឬ ដោយលួចលាក់ ដើម្បីទទួលបានការងារធ្វើ" ។ ពាក្យ ពលករចំណាកស្រុកមិនស្របច្បាប់ អាចប្រើបានដូចគ្នានឹងពាក្យ ពលករចំណាកស្រុកឆ្លងកាត់ព្រំដែនលួចលាក់ ឬគ្មានលិខិតអនុញ្ញាត ឬឯកសារបញ្ជាក់ ឬពលករដែលបានធ្វើចំណាកស្រុកស្របច្បាប់ ប៉ុន្តែបានបាត់បង់សិទ្ធិស្របច្បាប់របស់ខ្លួន ដោយសារការស្នាក់នៅលើសពេលកំណត់ (Brennan 1984; Lee 2005; GCIM 2005; Levoy and Geddie 2010) ។ ក្នុងការសិក្សានេះ ពលករចំណាកស្រុកកម្ពុជាមិនស្របច្បាប់ សំដៅដល់ជនចូលទៅធ្វើការនៅប្រទេសក្រៅ ដោយគ្មានឯកសារស្របច្បាប់ តាមការតម្រូវរបស់ប្រទេសនោះ ។ ឯកសារចាំបាច់ៗ រួមមាន លិខិតឆ្លងដែនមានសុពលភាព ទិដ្ឋាការ និងលិខិតអនុញ្ញាតការងារ ។

ទេសន្តរប្រវេសន៍មិនស្របច្បាប់នៅកម្ពុជា អាចចែកចេញជាពីរប្រភេទ ។ ប្រភេទទីមួយ គឺទេសន្តរប្រវេសន៍រយៈពេលខ្លីតាមព្រំដែន កម្ពុជា-ថៃ ។ ការងារជាធម្មតា គឺការងារកសិកម្ម ហើយពលករចំណាកស្រុកដឹងឮពីឱកាសការងារនេះ តាមរយៈពលករចំណាកស្រុកពីមុនៗ ដែលអាចជាសាច់ញាតិ មិត្តភក្តិ ឬអ្នកភូមិជាមួយគ្នា ។ ជនចំណាកស្រុកពីមុនៗ ជាអ្នកជួយសម្រួលដល់ការស្វែងរកការងារ ហើយបន្ទាប់មក ក្លាយជាបណ្តាញចំណាកស្រុក សម្រាប់តភ្ជាប់ទំនាក់ទំនងរវាងក្រុមគ្រួសារដែលភាគច្រើនរស់នៅតំបន់ជនបទកម្ពុជា និង ទីផ្សារការងារជាគោលដៅនៅក្នុងប្រទេសថៃ ។ ប្រភេទទីពីរ គឺទេសន្តរប្រវេសន៍រយៈពេលវែង ដែលជាការធ្វើដំណើរចូលជ្រៅទៅក្នុងប្រទេសថៃ ឬម៉ាឡេស៊ី ដើម្បីធ្វើការនៅលើទូកនេសាទ ការងារសំណង់ និងការងារតាមរោងចក្រ ។ ក្នុងករណីភាគច្រើន ពលករចំណាកស្រុកធ្វើដំណើរជាក្រុមតូចៗជាមួយនឹងឈ្មួញកណ្តាល (ឬមេខ្យល់) ដែលជូនពួកគេទៅព្រំដែន និងទៅកាន់កន្លែងធ្វើការនៅប្រទេសថៃ ។ សេវាសំខាន់ៗផ្តល់ដោយឈ្មួញកណ្តាល រួមមាន ការសម្រួលដល់ការឆ្លងកាត់ព្រំដែន (ឧ. ការដឹកជញ្ជូនទៅព្រំដែន) ការសុំបានលិខិតអនុញ្ញាតការងារ និងការធានារកការងារឲ្យធ្វើនៅក្នុងប្រទេសគោលដៅ ។ ពលករចំណាកស្រុក ត្រូវបង់ជាមុននូវថ្លៃជួយសម្រួលនេះ ដែលស្ថិតក្នុងចន្លោះពី ១០០ ទៅ ២០០ដុល្លារ ។

២ បានពីវេបសាយ http://www.un.org/documents/ga/res/30/ares30.htm

ក្នុងករណីខ្លះ ពលករចំណាកស្រុកធ្វើដំណើរជាក្រុមតូចៗ ដោយមានការជួយពីអ្នកធ្លាប់ធ្វើចំណាកស្រុកពីមុន ដែលដឹងពីស្ថានភាពការងារ និងមានទំនាក់ទំនងល្អជាមួយនិយោជក ។

## ៣. គោលនយោបាយទេសន្តរប្រវេសន៍ពលកម្ម

គោលនយោបាយស្តីពី ទេសន្តរប្រវេសន៍ពលកម្មសម្រាប់កម្ពុជា ទើបបានបង្កើតឡើងនាពេលថ្មីៗ ដោយឆ្លងតាមការពិគ្រោះយោបល់ច្រើនដំណាក់កាល និងមានការចូលរួមពីអ្នកពាក់ព័ន្ធសំខាន់ៗមកពីស្ថាប័នសាធារណៈ ទីភ្នាក់ងារផ្តល់ជំនួយ អង្គការពលករ អង្គការនិយោជក ទីភ្នាក់ងារជ្រើសរើសពលករ និង អង្គការមិនមែនរដ្ឋាភិបាល ។ គោលនយោបាយនេះ គូសបញ្ជាក់ពីបញ្ហាប្រឈម ៣ ធំៗ ។ បញ្ហាប្រឈមទីមួយខាងគោលនយោបាយ ជាប់ទាក់ទងនឹងអភិបាលកិច្ចទេសន្តរប្រវេសន៍ និងផ្តោតលើការកែលំអគោលនយោបាយដែលមានស្រាប់ ក្របខ័ណ្ឌច្បាប់ និងការគ្រប់គ្រងទេសន្តរប្រវេសន៍ពលកម្មប្រកបដោយប្រសិទ្ធភាព ។ បញ្ហាប្រឈមទីពីរ ទាក់ទងនឹងការការពារ និងការផ្តល់អំណាចទៅឲ្យពលករចំណាកស្រុក ។ គោលនយោបាយនេះ រួមមាន ការប្រើវិធីសាស្ត្រផ្អែកលើសិទ្ធិ ដើម្បីទប់ស្កាត់ជាមុន និងការពារប្រឆាំងនឹងសកម្មភាពរំលោភបំពានលើពលករចំណាកស្រុក និង ការពង្រឹងអនុវត្តច្បាប់ និងបទបញ្ញាថ្នាក់ជាតិ ស្របតាមស្តង់ដារពលកម្មអន្តរជាតិ និង កិច្ចព្រមព្រៀងក្នុងតំបន់ ។ បញ្ហាប្រឈមខាងគោលនយោបាយទី៣ គឺទេសន្តរប្រវេសន៍ និងការអភិវឌ្ឍ ដែលរួមមាន ការបញ្ជ្រាបបញ្ហាធំៗពាក់ព័ន្ធនឹងទេសន្តរប្រវេសន៍ពលកម្មទៅក្នុងផែនការអភិវឌ្ឍជាតិ ការបង្កើតប្រព័ន្ធទទួលស្គាល់ជំនាញទទួលបានពីទេសន្តរប្រវេសន៍ពលកម្ម ការជម្រុញការប្រើប្រាស់ប្រាក់ផ្ញើទៅផ្ទះរបស់ពលករចំណាកស្រុក ឲ្យបានជាប្រយោជន៍ដល់ការអភិវឌ្ឍសហគមន៍ និងការផ្តល់សេវាជួយសម្រួលមាតុភូមិនិវត្តន៍ និងការចូលមករួមរស់ក្នុងសង្គមជាតិវិញ ។

## ៤. ក្របខ័ណ្ឌច្បាប់គ្រប់គ្រងលើទេសន្តរប្រវេសន៍ពលកម្ម

បទបញ្ញត្តិច្បាប់ចំបង ដែលគ្រប់គ្រងលើទេសន្តរប្រវេសន៍ពលកម្មនៅកម្ពុជា គឺអនុក្រឹត្យលេខ ៥៧ ស្តីពី ការបញ្ជូនពលករខ្មែរទៅធ្វើការនៅបរទេស ។ ក្នុងគោលបំណងផ្តល់លក្ខណៈផ្លូវការដល់ដំណើរការទេសន្តរប្រវេសន៍ពលកម្ម អនុក្រឹត្យនេះ បានផ្តល់ឲ្យក្រសួងសង្គមកិច្ច ការងារ បណ្តុះបណ្តាលវិជ្ជាជីវៈ និងយុវនីតិសម្បទា (MoSALVY) ដែលបច្ចុប្បន្នប្រែឈ្មោះជា ក្រសួងការងារ និង បណ្តុះបណ្តាលវិជ្ជាជីវៈ (MoLVT) នូវសិទ្ធិអំណាចចេញការអនុញ្ញាតឲ្យដល់ក្រុមហ៊ុនផ្សេងៗ ដែលមានបំណងបញ្ជូនពលករខ្មែរទៅធ្វើការនៅបរទេសតាមរយៈ "ប្រកាស" ឬ បទបញ្ជាក្រសួង ។ អនុក្រឹត្យនេះចែកចេញជា ២២មាត្រា ដែលភាគច្រើនកំណត់ពីក្របខ័ណ្ឌច្បាប់នៃកិច្ចសហប្រត្តិបត្តិការរវាងក្រសួង និងក្រុមហ៊ុនជ្រើសរើសពលករ ហើយនិងវិធានការខាងនីតិវិធីលើបញ្ហាសំខាន់ៗនៃការជ្រើសរើសពលករ ដែលរួមមាន សំណើជ្រើសរើសពលករ ការតម្រូវឲ្យ បង់ប្រាក់កក់ កិច្ចសន្យាការងារ និង ការបណ្តុះបណ្តាលមុនពេលចេញដំណើរ សម្រាប់ឲ្យទីភ្នាក់ងារជ្រើសរើសពលករឯកជនអនុវត្តតាម ។

ច្បាប់ និងបទបញ្ជាផ្សេងៗ ទាក់ទងនឹងបញ្ហាចំណាកស្រុកកម្លាំងពលកម្ម រួមមាន៖

- ប្រកាសលេខ១០៨ ស្តីពី ការអប់រំពីជម្ងឺអេដស៍ សុវត្ថិភាពការធ្វើចំណាកស្រុក និងសិទ្ធិការងារសម្រាប់ពលករកម្ពុជា ធ្វើការនៅបរទេស
- អនុក្រឹត្យលេខ៧០ ស្តីពី ការបង្កើតក្រុមប្រឹក្សាភិបាលបណ្តុះបណ្តាល និងបញ្ជូនពលករទៅបរទេស
- ប្រកាស ០១២/០៧ ស្តីពី ការបង្កើតក្រុមការងារចំណាកស្រុកកម្លាំងពលកម្ម
- អនុក្រឹត្យលេខ ៦៨/២០០៩ ស្តីពី ថ្លៃលិខិតឆ្លងដែនសម្រាប់ពលករចំណាកស្រុក

ក្រៅពីច្បាប់ជាតិ ទេសន្តរប្រវេសន៍ពលកម្មនៅកម្ពុជា ក៏ស្ថិតនៅក្រោមការគ្រប់គ្រងនៃច្បាប់អន្តរជាតិ ក្នុងទម្រង់ជាអនុស្សារណៈនៃការយោគយល់ កិច្ចព្រមព្រៀងក្នុងតំបន់ និង អនុសញ្ញាអន្តរជាតិ ផងដែរ ។ ប្រទេសកម្ពុជា បានចុះហត្ថលេខាលើអនុស្សារណៈនៃការយោគយល់ ស្តីពីការបញ្ជូនពលករចំណាកស្រុក ជាមួយប្រទេសម៉ាឡេស៊ី ក្នុងឆ្នាំ១៩៩៧ ជាមួយថៃ ក្នុងឆ្នាំ២០០៣ សាធារណរដ្ឋកូរ៉េ ក្នុងឆ្នាំ២០០៣ និង ប្រទេសគុយវេទ ក្នុងឆ្នាំ២០០៩ ។ កម្ពុជា ជាប្រទេសហត្ថលេខីមួយ នៅក្នុងសេចក្តីប្រកាសតំបន់អាស៊ាន ស្តីពី ការការពារ និង ការលើកកម្ពស់សិទ្ធិពលករចំណាកស្រុក និងក្នុងអនុសញ្ញាអង្គការសហប្រជាជាតិ ស្តីពី ការការពារពលករចំណាកស្រុក និងសមាជិកគ្រួសាររបស់ពួកគេ ។ កម្ពុជា ជាប្រទេសមួយក្នុងចំណោម ១៨ ប្រទេស[៣] ដែលអនុម័តប្រើសេចក្តីប្រកាសទីក្រុងបាងកក ស្តីពី ចំណាកស្រុកខុសច្បាប់ក្នុងឆ្នាំ១៩៩៩ ។

## ៥. ការវាយតម្លៃរួមនៃគោលនយោបាយទេសន្តរប្រវេសន៍ និងក្របខ័ណ្ឌច្បាប់

ដោយកម្ពុជា ជាប្រទេសថ្មីថ្មោងក្នុងការងារគ្រប់គ្រងទេសន្តរប្រវេសន៍ពលកម្ម ដូច្នេះ មិនទាន់បានបង្កើតនូវគោលនយោបាយ និង ក្របខ័ណ្ឌច្បាប់ដ៏សមស្រប និងមានប្រសិទ្ធភាពនៅឡើយទេ ។ គោលនយោបាយស្តីពីទេសន្តរប្រវេសន៍ពលកម្ម នៅខ្វះភាពរលូនគ្នា និងមិនទាន់ដាក់បញ្ចូលទៅក្នុងផែនការអភិវឌ្ឍន៍ជាតិនៅឡើយ ។ ក្របខ័ណ្ឌច្បាប់ មានលក្ខណៈដាច់ដោយដុំ និងនៅមានកម្រិត ហើយសមត្ថភាពស្ថាប័ន ក៏នៅទន់ខ្សោយ ។

កង្វះភាពរលូនគ្នាខាងគោលនយោបាយ

ដូចប្រទេសជាច្រើនទៀតនៅក្នុងមហាអនុតំបន់មេគង្គ (GMS) ដែរ កម្ពុជាមិនទាន់បានបង្កើតនូវគោលនយោបាយទេសន្តរប្រវេសន៍ពលកម្មមួយ ដែលរលូនល្អនៅឡើយទេ ។ កង្វះភាពរលូនល្អខាងគោលនយោបាយនេះ កើតមាននៅពីរកម្រិតខុសគ្នា គឺកម្រិតផ្ទៃក្នុងរដ្ឋាភិបាល និង រវាងរដ្ឋាភិបាល និងអ្នកពាក់ព័ន្ធនានា ។ នៅកម្រិតគោលនយោបាយរដ្ឋាភិបាល មានសេចក្តីថែងតិចតួចណាស់ អំពីទេសន្តរប្រវេសន៍ពលកម្មនៅក្នុងគោលនយោបាយ និងផែនការអភិវឌ្ឍន៍ជាតិ បើទោះមានការទទួលស្គាល់កាន់តែច្រើន ពីការរួមចំណែកនៃទេសន្តរប្រវេសន៍ពលកម្មឆ្លងកាត់ព្រំដែនទៅក្នុងកំណើន ការអភិវឌ្ឍ និង ការកាត់បន្ថយភាពក្រីក្រនៅក្នុងប្រទេសក្តី ។ ម៉្យាងវិញទៀត ទោះបីទេសន្តរប្រវេសន៍ជាបញ្ហាស្មុគស្មាញ ដែលស្ថិតក្រោមសមត្ថកិច្ចក្រសួង និងស្ថាប័នជាច្រើនក្តី ក៏គេកម្រឃើញមានការបន្សីគ្នាខាងគោលនយោបាយ ទាំងតាមខ្សែបណ្តោយ និងខ្សែទទឹង ។ ក្រៅពី MoLVT បញ្ហាទេសន្តរប្រវេសន៍ មិនដែលឃើញមានលើកឡើងទេ ទាំងនៅក្នុងផែនការអភិវឌ្ឍន៍តាមវិស័យផ្សេងៗ ឬក៏នៅក្នុងផែនការអភិវឌ្ឍន៍សហគមន៍ ។ ជាលទ្ធផល ការផ្លាស់ប្តូរព័ត៌មាន ការពិគ្រោះយោបល់អន្តរក្រសួង និង ការអនុវត្តកម្មវិធី និងគោលនយោបាយទេសន្តរប្រវេសន៍រួមគ្នា មានលក្ខណៈទន់ខ្សោយ និងមានកម្រិត ។

ទាក់ទងនឹងការចូលរួមពីអ្នកពាក់ព័ន្ធវិញ គេឃើញមានការលូតលាស់គួរឲ្យកត់សម្គាល់លើកិច្ចសហការរួមគ្នារវាងរាជរដ្ឋាភិបាល និងអង្គការអន្តរជាតិ ដែលធ្វើការងារលើបញ្ហាទេសន្តរប្រវេសន៍ ។ ប៉ុន្តែកិច្ចសហការនេះ កន្លងមកមិនបានអនុវត្តស្មើគ្នាល្អទេ ក្នុងចំណោមអ្នកពាក់ព័ន្ធនានា ដូចជា រដ្ឋាភិបាល អង្គការមិនមែនរដ្ឋាភិបាល សហគមន៍អាជីវករ និង សមាគមចំណាកស្រុក

---

៣ ប្រទេសបានចូលរួម គឺមាន អូស្ត្រាលី បង់ក្លាដេស ប្រុយណេ កម្ពុជា ចិន ហុងកុង ឥណ្ឌូនេស៊ី ជប៉ុន សាធារណរដ្ឋកូរ៉េ ឡាវ ម៉ាឡេស៊ី មីយ៉ាន់ម៉ា ញូហ្ស៊ីលែន ញូហ្គីនៀ (Papua New Guinea) ហ្វីលីពីន សិង្ហបុរី ស្រីលង្កា ថៃ និង វៀតណាម ។

ទាំងនៅកម្រិតតំបន់ និងថ្នាក់ជាតិ ។ ការចូលរួមក្នុងការពិភាក្សាគ្រប់ជ្រុងជ្រោយ មានការថ្លឹងថ្លែងល្អ និងមានព័ត៌មានច្បាស់លាស់ រវាងអ្នកពាក់ព័ន្ធសំខាន់ៗស្តីពី បញ្ហាខាងការអភិវឌ្ឍ និងទេសន្តរប្រវេសន៍ ក៏នៅមានលក្ខណៈមិនទៀងទាត់ដែរ ។

### កង្វះដែនគ្របដណ្តប់គ្រប់ជ្រុងជ្រោយ

ក្របខ័ណ្ឌច្បាប់ នៅខ្វះដែនគ្របដណ្តប់ឲ្យបានគ្រប់ជ្រុងជ្រោយ ដើម្បីគ្រប់គ្រងលើបាតុភូតចំណាកស្រុកដ៏ស្មុគស្មាញ ។ បច្ចុប្បន្នអនុក្រឹត្យលេខ៥៧ ជាឧបករណ៍ច្បាប់បឋម សម្រាប់គ្រប់គ្រងលើទេសន្តរប្រវេសន៍ពលកម្ម ប៉ុន្តែវាមានដែនគ្របដណ្តប់តូចណាស់ ដោយមានត្រឹមតែ ២២មាត្រា ដែលភាគច្រើនកំណត់ពីក្របខ័ណ្ឌច្បាប់ នៃកិច្ចសហប្រតិបត្តិការរវាង MoLVT និង ក្រុមហ៊ុនជ្រើសរើសពលករ និង វិធានការខាងនីតិវិធីលើបញ្ហាសំខាន់ៗមួយចំនួន ក្នុងការជ្រើសរើសពលករ ដូចជា ការតម្រូវឲ្យបង់ប្រាក់កក់ នីតិវិធីជ្រើសរើសពលករ កិច្ចសន្យាការងារ និងវគ្គបណ្តុះបណ្តាលមុនពេលចេញដំណើរ ។ ច្បាប់នេះគ្មានសេចក្តីចែងលើបញ្ហាសំខាន់ៗមួយចំនួន ដូចជា ការទទួលខុសត្រូវនិងកាតព្វកិច្ចរបស់រដ្ឋាភិបាល និងទីភ្នាក់ងារជ្រើសរើសពលករ សិទ្ធិនិងកាតព្វកិច្ចរបស់ពលករចំណាកស្រុក ការត្រួតពិនិត្យលើកន្លែងការងារ និងសកម្មភាពការពារនានា និង ការចូលមករួមរស់ក្នុងសេដ្ឋកិច្ច និងសង្គមកម្ពុជាវិញ ។ យោងតាមបទពិសោធន៍ប្រទេសដែលបញ្ជូនចេញពលករចំណាកស្រុក បញ្ហាទាំងនេះសំខាន់ខ្លាំងណាស់សម្រាប់ការគ្រប់គ្រងនីតិវិធីធ្វើចំណាកស្រុក និងការការពារពលករចំណាកស្រុក ដែលតាមធម្មតាតែងមានចែងនៅក្នុងបទបញ្ញត្តិច្បាប់ ស្តីពីចំណាកស្រុក ។ អនុក្រឹត្យលេខ៥៧ មានវិសាលភាពតូចណាស់ពាក់ព័ន្ធនឹងការការពារ ព្រោះគ្របដណ្តប់តែលើពលករកម្ពុជា ដែលក្រុមហ៊ុនជ្រើសរើសពលករមានអាជ្ញាប័ណ្ណ បានបញ្ជូនទៅធ្វើការនៅបរទេសដោយស្របច្បាប់ ។ អនុក្រឹត្យនេះ មិនគ្របដណ្តប់លើពលករចំណាកស្រុកខុសច្បាប់ ដែលតំណាងឲ្យជាង ៩៥% នៃពលករចំណាកស្រុកកម្ពុជាសរុប និងដែលមានទាំងអ្នកប្រើប្រេកចំណាកស្រុកមិនផ្លូវការនេះ ដោយចេតនា និងដោយអចេតនា ។

### កង្វះភាពច្បាស់លាស់

ក្របខ័ណ្ឌច្បាប់ ជាទូទៅគេឃើញនៅមានភាពស្រពេចស្រពិល ដោយបទបញ្ញត្តិភាគច្រើនមានលក្ខណៈទូលំទូលាយ និងខ្វះភាពច្បាស់លាស់ ។ តួយ៉ាង មាត្រា១០ មានចែងដោយសង្ខេបពីសិទ្ធិរបស់ពលករ ប៉ុន្តែផ្តោតតែលើការឈប់សម្រាកប្រចាំឆ្នាំប៉ុណ្ណោះ ដោយមិនមានចែងពីសិទ្ធិជាមូលដ្ឋានរបស់ពលករចំណាកស្រុក ដូចជា សិទ្ធិទទួលបានព័ត៌មានត្រឹមត្រូវនិងពេញលេញ សេរីភាពក្នុងការធ្វើដំណើរ សិទ្ធិទទួលបានការអប់រំនិងសេវាថែទាំសុខភាពប្រកបដោយសមធម៌ និងសិទ្ធិបានចូលរួមក្នុងសកម្មភាពវប្បធម៌ ។ មាត្រា២០ ចែងថា បុគ្គលណាដែលបំពានលើបទបញ្ញត្តិច្បាប់ នឹងត្រូវទទួលទោសទណ្ឌ ប៉ុន្តែគ្មានសេចក្តីបញ្ជាក់ពីទោសទណ្ឌនោះទេ (Lee 2007a) ។

### កង្វះប្រព័ន្ធគ្រប់ជ្រុងជ្រោយ និងសត្តិសិទ្ធិសម្រាប់គ្រប់គ្រងពលករ

គេយល់ថា ការគ្រប់គ្រងទេសន្តរប្រវេសន៍ពលកម្មបច្ចុប្បន្ន នៅខ្វះប្រព័ន្ធគ្រប់គ្រងដែលគ្រប់ជ្រុងជ្រោយ និងសត្តិសិទ្ធិ ។ ទីភ្នាក់ងារជ្រើសរើសពលករឯកជន ដំណើរការដោយមានសិទ្ធិសម្រេចអារកាត់ដោយខ្លួនឯងកម្រិតខ្ពស់ ក្នុងការជ្រើសរើសពលករ ទីកន្លែងធ្វើការ និងដំណើរការបញ្ជូនពលករ ដោយគ្មានការត្រួតពិនិត្យតាមផ្លូវច្បាប់ឲ្យដិតដល់លើសកម្មភាពរបស់ពួកគេទេ ។ ដោយសារទីភ្នាក់ងារឯកជន មានគោលដៅស្វែងរកប្រាក់ចំណេញ គួបផ្សំនឹងការពុំមានយន្តការច្បាស់លាស់សម្រាប់ត្រួតពិនិត្យលើសកម្មភាពជ្រើសរើសពលកររបស់ក្រុមហ៊ុនទាំងនោះផង ក៏កើតមានចន្លោះ

ប្រហោង សម្រាប់ឲ្យពួកគេឆ្លៀតឱកាសកេងយកចំណេញលើពលករចំណាកស្រុក ធ្វើឲ្យពលករទាំងនោះ ងាយរងគ្រោះពីការបំពាន និងការជញ្ជក់យកចំណេញផ្សេងៗ ។ កន្លងមក មានករណីជាច្រើនដែលទីភ្នាក់ងារជ្រើសរើសពលករឯកជនប្រព្រឹត្តមិនត្រឹមត្រូវ ដូចជា ការយកប្រាក់ច្រើនហួសពីពលករ ការដកហូតលិខិតឆ្លងដែនរបស់ពលករទុក ការមិនធ្វើកិច្ចសន្យាការងារតាមស្តង់ដារត្រឹមត្រូវ និងការមិនធានាចំពោះសុខុមាលភាព និងការការពារពលករ (Lee 2007a) ។ ទាក់ទងនឹងការផ្សព្វផ្សាយព័ត៌មានវិញ ពលករចំណាកស្រុកទទួលបានពត៌មានតិចតួច ពីសិទ្ធិរបស់ខ្លួន តួនាទី និងកាតព្វកិច្ចរបស់និយោជក និងទីភ្នាក់ងារជ្រើសរើសពលករ កន្លែងធ្វើការ និងលក្ខខណ្ឌក្នុងការរស់នៅ ដំបូន្មានជាក់ស្តែងលើបញ្ហាសុខភាពនិងសុវត្ថិភាព ទីតាំងនិងលេខទូរស័ព្ទទំនាក់ទំនងរបស់ស្ថានទូតកម្ពុជា ក៏ដូចជា វិធីនិងកន្លែងស្វែងរកជំនួយនៅពេលមានធុរៈអាសន្ន (Lee 2007a) ។ កង្វះព័ត៌មានស្របគ្នា និងកង្វះទំនាក់ទំនងដ៏សក្តិសិទ្ធិពីសំណាក់ស្ថាប័នសាធារណៈទទួលបន្ទុកលើបញ្ហាទាំងនេះ ធ្វើឲ្យពលករចំណាកស្រុកងាយរងគ្រោះពីសកម្មភាពមិនត្រឹមត្រូវផ្សេងៗរបស់ទីភ្នាក់ងារជ្រើសរើសពលករ និងនិយោជកនៅបរទេស ។

## ៦. សេចក្តីសន្និដ្ឋាន

តាមរយៈការវាយតម្លៃរហ័សលើស្ថានភាពទេសន្តរប្រវេសន៍ និងក្របខ័ណ្ឌគោលនយោបាយនៅកម្ពុជា អត្ថបទនេះបានរែកញែកថា ស្របពេលដែលពលករចំណាកស្រុកបានកើនឡើងគួរឲ្យកត់សម្គាល់ក្នុងមួយទសវត្សរ៍កន្លងមក ហើយនឹងបន្តកើនឡើងទៀតក្នុងពេលអនាគត ការគ្រប់គ្រងទេសន្តរប្រវេសន៍ និងការទាញយកប្រយោជន៍មកបម្រើការអភិវឌ្ឍ បានក្លាយជាបញ្ហាប្រឈមមួយដ៏ធំ សម្រាប់ប្រទេសថ្មីថ្មោងក្នុងការងារគ្រប់គ្រងទេសន្តរប្រវេសន៍ ដូចជា កម្ពុជា ជាដើម ។ ការវិភាគពីកង្វះខាតខាងគោលនយោបាយ ក៏បានបង្ហាញនូវបញ្ហាប្រឈមខាងគោលនយោបាយសំខាន់ៗមួយចំនួន ដែលភាគច្រើនពាក់ព័ន្ធនឹងការបង្កើតគោលនយោបាយទេសន្តរប្រវេសន៍ពលកម្មឲ្យសមស្រប ក្របខ័ណ្ឌច្បាប់ ការគ្រប់គ្រងប្រកបដោយប្រសិទ្ធភាព ការប្រើប្រាស់វិធីសាស្ត្រផ្អែកលើសិទ្ធិ ដើម្បីបញ្ចៀស និងការពារពលករទល់នឹងការបៀតបៀននានា និង ការដាក់បញ្ចូលបញ្ហាទេសន្តរប្រវេសន៍ពលកម្ម ទៅក្នុងរបៀបវារៈអភិវឌ្ឍន៍ជាតិ ។ កម្ពុជា បានឈានដល់ចំណុចសំខាន់មួយដែលត្រូវដោះស្រាយរាល់ទិដ្ឋភាពសំខាន់ៗនៃការធ្វើទេសន្តរប្រវេសន៍ ។ ការចូលរួមចំណែកដ៏មានប្រយោជន៍ និងមានផ្លែផ្កា នៃទេសន្តរប្រវេសន៍ពលកម្ម នៅក្នុងការអភិវឌ្ឍជាតិ និងការលើកកម្ពស់ជីវភាពគ្រួសារ ត្រូវផ្អែកលើលទ្ធភាព និងសមត្ថភាពរបស់ប្រទេស ក្នុងការបំពេញចន្លោះខ្វះខាតខាងគោលនយោបាយ និងក្របខ័ណ្ឌច្បាប់ ។

## ឯកសារយោង


Brennan, E. M. (1984), "Irregular Migration: Policy Responses in Africa and Asia", International Migration Review 18(3), pp. 409-425

Cambodian Development Resource Institute (2007), Moving Out of Poverty? *Trends in Community Well-being and Household Mobility in Nine Cambodian Villages* (Phnom Penh: CDRI)

Chan, Sophal (2009), *Costs and Benefits of Cross-country Labour Migration in the GMS: Cambodia Country Study*, Working Paper Series No.47 (Phnom Penh: CDRI)

Global Commission on International Migration (2005), *Migration in an Interconnected World: New Directions for Action* (Geneva: Global Commission on International Migration)

International Council on Social Welfare (2007), *Trafficking Labour Exploitation in ASEAN* (Utrecht: ICSW)

International Organisation for Migration (2003), *Labour Migration in Asia: Trends, Challenges and Policy Responses in Countries of Origin* (Geneva: IOM)

International Organisation for Migration (2010), *Analyzing the Impact of Remittances from Cambodian Migrant Workers in Thailand on Local Communities in Cambodia* (Phnom Penh: IOM)

Koser, K. (2005), *Irregular Migration, State Security and Human Security*, (Geneva: Global Commission on International Migration)

Koslowski, R. (2004), Possible Steps towards an International Regime for Mobility and Security, paper presented to the Workshop on Global Mobility Regimes, Stockholm, June

Lee, C. C. (2007b), "Female Labour Migration in Cambodia" in United Nations for Economic and Social Commission for Asia and the Pacific (ed.), *Perspectives on Gender and Migration*,(Bangkok: United Nations)

Lee, C.C. (2007a), *Exploitative Labour Brokerage Practices in Cambodia: The Role and Practices of Private Recruitment Agencies* (unpublished paper)

Lee, T. L. (2005), *Statelessness, Human Rights and Gender: Irregular Migrant Workers from Burma in Thailand* (Leiden: Koninklijke Brill NV)

Levoy, M. & E. Geddie (2010), "Irregular Migration: Challenges, Limits and Remedies", *Refugee Survey Quarterly*, 28(4), pp. 87-113

Maltoni, Bruno (2006a), *Review of Labour Migration Dynamics in Cambodia* (Phnom Penh: IOM)

Maltoni, Bruno (2006b), *Impact of Remittance on Local Communities in Cambodia: The Case of Pre Veng Province* (World Bank unpublished paper)

Marshall, P. (2001), *Globalization, Migration and Trafficking: Some Thoughts from the South-East Asian Region*, UN Inter-Agency Project on Trafficking in Women and Children in the Mekong Sub-region (Kuala Lumpur: United Nations)

Massey, Douglas S., Joquin Arango, Graeme Hugo, Ali Kouaouci, Adela Pellegrino, J. Edward Taylor (1993), *Theories of International Migration: A Review and Appraisal, Population and Development Review,* Vol. 19, No. 3, pp. 431-466

Ministry of Labour and Vocational Training (2009), *Action Plan to Implement the Rectangular Strategy, Phase II 2009-2013* (Phnom Penh: MoLVT)

Ministry of Labour and Vocational Training (2010), *Policy on Labour Migration for Cambodia* (Phnom Penh: MoLVT)

Ministry of Social Affairs, Veterans and Youth Rehabitltation (2005), *The Return and Reintegration of victims of Trafficking from Cambodia to Thailand 31st of December 2004 to 31st December 2005 and Repatriation from Cambodia to Vietnam of Vietnamese Victims of Trafficking from 31st December2004 to 31st December 2005,* (Phnom Penh: MoSVY)

Naro, N. (2009), *Human Trafficking in Cambodia: Reintegration of the Cambodian Illegal Migrants from Vietnam and Thailand,* Working Paper No 181 (Singapore: S. Rajaratnam School of International Studies)

Rukumnuaykit, Pungpond (2006), *A Synthesis Report on Labour Migration Policies, Management and Immigration Pressure in Thailand* (Bangkok: ILO)

Shah, N. (2009), *The Management of Irregular Migration and Its Consequences for Development: Gulf Cooperation Council,* Working Paper No.19 (Bangkok: ILO)

Stoyanova, M. (2008), *Challenges of Irregular Migration*, Human Rights Council (Geneva: Friedrich Ebert Stiftung)

World Bank (2010), *Migration and Remittance Factbook 2011*, Second Edition (Washington, DC: World Bank)

# ផ្នែកទី ២
# ភាពក្រីក្រ កសិកម្ម និង
# អភិវឌ្ឍន៍ជនបទ

# -V-
# ជម្រើសគោលនយោបាយសម្រាប់ក្រុមជនងាយរងគ្រោះ៖ កំណើនប្រាក់ចំណូល និង ការគាំពារសង្គម

*ដោយលោក គឹម សុធន និងលោកស្រី ខៀវ ភិរម្យ[១]*

## ១. សេចក្តីផ្តើម

ការបំផ្លិចបំផ្លាញធនធានមនុស្ស សង្គម និងហេដ្ឋារចនាសម្ព័ន្ធនៅកម្ពុជា ក្នុងអំឡុងពេលពីរទសវត្សរ៍នៃសង្គ្រាម ជាដើមហេតុដ៏សំខាន់មួយនៃភាពក្រីក្រ ដែលបណ្តាលឲ្យមានភាពងាយរងគ្រោះក្នុងចំណោមប្រជាជនកម្ពុជា ជាពិសេសអ្នកក្រីក្រនៅតាមទីជនបទ ។ កត្តារួមចំណែកដទៃទៀត មានដូចជា ការផាត់ចេញពីសង្គម កង្វះលទ្ធភាពទទួលបានសេវាសាធារណៈ និងឱកាសការងារមានតិច ។ ម្យ៉ាងវិញទៀត កំណើនវិស័យកសិកម្មមិនគ្រប់គ្រាន់ និងសេដ្ឋកិច្ចនៅជនបទមានមូលដ្ឋានតូចចង្អៀត ធ្វើឱ្យប្រជាជនភាគច្រើននៅជនបទងាយទទួលឥទ្ធិពលពីហានិភ័យ និងការប៉ះទង្គិចផ្សេងៗ ដែលអាចរុញច្រានពួកគេឲ្យធ្លាក់ចុះក្នុងភាពក្រីក្រធ្ងន់ធ្ងរ ។ ឧទាហរណ៍ ការធ្លាក់ចុះក្នុងពេលថ្មីៗនៃវិស័យជំរុញកំណើនសេដ្ឋកិច្ចសំខាន់ៗនៅកម្ពុជា ជាអាទិ៍ វិស័យកាត់ដេរ ទេសចរណ៍ និងសេវាកម្ម (ដោយសារវិបត្តិសេដ្ឋកិច្ចសាកល) បាននាំឲ្យមានការបាត់បង់ការងារ និងការថយចុះប្រាក់ផ្ញើទៅផ្ទះ ។ ការធ្លាក់ចុះនេះ បានប៉ះពាល់ដោយផ្ទាល់ទៅលើកម្មករ និងក្រុមគ្រួសារ ធ្វើឱ្យពួកគេរឹតតែងាយរងគ្រោះដោយការប៉ះទង្គិចផ្សេងៗទៅលើប្រាក់ចំណូល និងចំណាយប្រើប្រាស់ប្រចាំថ្ងៃ ។

អត្ថបទនេះ ពិនិត្យជារួមពីទំនាក់ទំនងរវាងកំណើនសេដ្ឋកិច្ច ភាពក្រីក្រ ភាពងាយរងគ្រោះ និងកិច្ចគាំពារខាងសង្គមកិច្ច ដោយផ្អែកលើស្ថិតិ និងទិន្នន័យថ្មីៗ ព្រមទាំងឯកសារស្រាវជ្រាវផ្សេងៗ ដែលមានស្រាប់ ។ ដោយឡែកការសិក្សាមាន (១) កំណត់ក្រុមជនងាយរងគ្រោះ និងមូលហេតុសំខាន់ៗនៃភាពងាយរងគ្រោះ (២) ពិនិត្យពីគោលនយោបាយលើកិច្ចគាំពារខាងសង្គមកិច្ចដែលមានស្រាប់ និងសកម្មភាពផ្សេងៗដែលរដ្ឋាភិបាលកម្ពុជា និងដៃគូនានាបានអនុវត្ត (៣) ពិភាក្សាពីប្រសិទ្ធភាពនៃកម្មវិធីគាំពារសង្គមកិច្ច ដែលមានស្រាប់ និង (៤) លើកជាជម្រើសគោលនយោបាយសម្រាប់ជួយក្រុមជនងាយរងគ្រោះ ដោយផ្អែកលើកំណើនប្រាក់ចំណូល ការគាំពារសង្គម និងចន្លោះខ្វះខាតខាងចំណេះដឹង ។

## ២. ទំនាក់ទំនងរវាងកំណើនសេដ្ឋកិច្ច ភាពក្រីក្រ និង ភាពងាយរងគ្រោះ

ភាពក្រីក្រនៅកម្ពុជា មានលក្ខណៈសម្គាល់ជាចំណាយប្រើប្រាស់ និងប្រាក់ចំណូលកម្រិតទាប ស្ថានភាពអាហារូបត្ថម្ភអន់ខ្សោយ ការអប់រំកម្រិតទាប កង្វះលទ្ធភាពបានប្រើប្រាស់សេវាសាធារណៈ និងឱកាសសេដ្ឋកិច្ច ភាពងាយរងគ្រោះពីហានិភ័យ និងការផាត់ចេញពីសកម្មភាពនយោបាយ សង្គម និងសេដ្ឋកិច្ច ។ អត្រាកំណើន ផសស មធ្យមប្រចាំឆ្នាំនៅកម្ពុជា ដល់ទៅ ៩,៥% នៅឆ្នាំ១៩៩៩-២០០៨ (ក្រាហ្វិក ១) បានធ្វើឲ្យកម្ពុជាមានការផ្លាស់ប្តូរយ៉ាងជ្រាលជ្រៅ ហើយ

---

១ លោក គឹម សុធន ជាអ្នកស្រាវជ្រាវ និង លោកស្រី ខៀវ ភិរម្យ ជំនួយការស្រាវជ្រាវ នៃកម្មវិធីភាពក្រីក្រ កសិកម្ម និងអភិវឌ្ឍន៍ជនបទ នៅវិទ្យាស្ថាន CDRI ។ អ្នកនិពន្ធ សូមថ្លែងអំណរគុណចំពោះ កញ្ញា ហ្គូវ គីមហុង និង លោក ឈឹម ឈន់ ដែលបានចូលរួមជួយស្វែងរកឯកសារយោង ។

សង្គមជាតិក៏បានដាក់អនុវត្ត យុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ ហើយសម្រេចបានការកាត់បន្ថយភាពក្រីក្រ ការកែលំអជីវភាពរស់នៅ ការលើកកម្ពស់កម្រិតអប់រំ និងស្ថានភាពសុខភាព ប្រសើរជាងមុន ។ ប៉ុន្តែកំណើនសេដ្ឋកិច្ចភាគច្រើន មានមូលដ្ឋាននៅតំបន់ទីក្រុង ហើយការបែងចែកផលប្រយោជន៍នៃកំណើន មានលក្ខណៈមិនស្មើគ្នា ដែលនាំឲ្យមានវិសមភាពកាន់តែធំឡើង (ធនាគារពិភពលោក ឆ្នាំ២០០៧)[២] ។

វិសមភាពធំ បង្កឧបសគ្គដល់កំណើនសេដ្ឋកិច្ចប្រកបដោយចីរភាព រារាំងដល់កិច្ចប្រឹងប្រែងកាត់បន្ថយភាពក្រីក្រ និងអាចធ្វើឲ្យខូចខាតដល់កំណើនសេដ្ឋកិច្ចផង ហើយក៏នាំទៅដល់អស្ថិរភាព និងភាពបាក់បែកក្នុងសង្គម (ធនាគារពិភពលោក ២០០៦ក) ។ ប្រទេសកម្ពុជាមានប្រជាជនសរុប ១៣,៤លាននាក់ ក្នុងនោះមាន ៨០% ពឹងផ្អែកលើសេដ្ឋកិច្ចជនបទ ដែលមានកំណើនទាប និងមិនគ្រប់គ្រាន់ទេ (ក្រាហ្វិក ២)[៣] ។ កំណើនតាមលំនាំនេះ កន្លងមកផ្តល់អត្ថប្រយោជន៍តិចតួចណាស់ដល់ប្រជាជនភាគច្រើន ជាពិសេសអ្នកនៅតំបន់ជនបទ ដូច្នេះប្រជាជនក្រីក្រនៅជនបទ នៅតែងាយរងគ្រោះជាខ្លាំងដោយហានិភ័យមកពីប្រភពផ្សេងៗ ។ ការសិក្សាជាច្រើនពីភាពក្រីក្របានលើកឡើងថា ការប្រឈមនឹងហានិភ័យ និងការប៉ះទង្គិចផ្សេងៗ ជាកត្តាដ៏ចំបងមួយដែលធ្វើឲ្យក្រុមគ្រួសារងាយរងគ្រោះត្រូវជាប់ផុង ឬធ្លាក់ខ្លួនកាន់តែជ្រៅក្នុងភាពក្រីក្រ (Fitzgerald *et al.* 2007; Ballard *et al.* 2007; So 2009; Kem *et al.* 2010) ។

ក្រាហ្វិក ១៖ កំណើន ផសស(១៩៩៤-២០១៣ គិតតាមថ្លៃថេរឆ្នាំ២០០០)




*ប្រភព៖ Data from MEF*[៤]

ក្រាហ្វិក ២៖ ប្រភពកំណើនតាមវិស័យ (១៩៩៤-២០១៣)




*ប្រភព៖ Data from MEF*

២ ផសស ក្នុងមនុស្សម្នាក់ កើនពី ២៨៥ដុល្លារ នៅឆ្នាំ១៩៩៧ ដល់ ៥៩៣ដុល្លារ នៅឆ្នាំ២០០៧ (ទិន្នន័យពីមូលនិធិរូបិយវត្ថុអន្តរជាតិ) ។ ការវាយតម្លៃនិន្នាការភាពក្រីក្រ របស់ធនាគារពិភពលោក ក្នុងឆ្នាំ២០០៩ បង្ហាញថា មេគុណ Gini (ការវាស់វែងវិសមភាពចំណូល) សម្រាប់ប្រទេសកម្ពុជាទាំងមូល បានកើនយ៉ាងលឿនពី ០,៣៩៦ នៅឆ្នាំ២០០៤ ដល់ ០,៤៣១ នៅឆ្នាំ២០០៧ ។

៣ វិនិយោគផ្ទាល់ពីបរទេស (FDI) ប្រមូលផ្តុំនៅក្នុងវិស័យសេវាកម្ម និងឧស្សាហកម្ម រីឯវិស័យកសិកម្មនៅបន្តខ្វះខាតការវិនិយោគទុន និងមានការអភិវឌ្ឍមិនគ្រប់គ្រាន់ ។ ទិន្នន័យពីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ បង្ហាញថា ចំណែក ផសស នៃវិស័យកសិកម្ម បានធ្លាក់ចុះ តាំងពីឆ្នាំ១៩៩៤ មក (ក្រាហ្វិក ២) ។ នៅឆ្នាំ២០០៩ កម្ពុជាមានផលិតភាពស្រូវ ២,៨តោន/ហិកតា ដែលជាតួលេខទាបបំផុតនៅក្នុងតំបន់ (ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ២០១០) ។

៤ ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ។

## ៣. អ្នកណាខ្លះជាជនងាយរងគ្រោះ? ហេតុអ្វីបានជាងាយរងគ្រោះ?

យុទ្ធសាស្ត្រជាតិលើការគាំពារសង្គម (NSPS) ដែលត្រូវដាក់អនុវត្តក្នុងពេលខាងមុខ បានកំណត់និយមន័យជនងាយរងគ្រោះថាជា (១) អ្នករស់នៅក្រោមបន្ទាត់ភាពក្រីក្រ (២) អ្នកមិនអាចទប់ទល់នឹងការប៉ះទង្គិច ឬទទួលការប៉ះទង្គិចញឹកញាប់ (អ្នកមានជីវភាពនៅក្រោម ឬនៅជិតបន្ទាត់ភាពក្រីក្រ ច្រើនតែជាជនងាយរងគ្រោះបំផុត) និង (៣) ទារក កុមារ នារីក្នុងវ័យបន្តពូជ គ្រួសារមានអសន្តិសុខស្បៀង ជនជាតិភាគតិច ជនចាស់ជរា អ្នកឈឺរ៉ាំរ៉ៃ អ្នកផ្ទុកមេរោគអេដស៍ និងជនពិការ ។ ដោយប្រើនិយមន័យនេះ គេអាចកំណត់បាននូវក្រុមជនងាយរងគ្រោះ ព្រមទាំងកត្តា និងមូលហេតុដែលបង្កភាពងាយរងគ្រោះ ។

### *៣.១. ប្រជាជនជាង ២៥% រស់នៅក្រោមបន្ទាត់ភាពក្រីក្រ*

គេប៉ាន់ស្មានថា នៅចុងឆ្នាំ២០០៩ មានគ្រួសារកម្ពុជា ២៧,៤% កំពុងរស់នៅក្រោមបន្ទាត់ភាពក្រីក្រ (ក្រសួងផែនការ ២០០៩) ។ ប៉ុន្តែបើសិនគិតតាមសន្ទស្សន៍ភាពក្រីក្រពហុវិស័យ (MPI)[៥] នោះអត្រាភាពក្រីក្រនៅកម្ពុជា ត្រូវកើនដល់ ៥៤% ដែលតំណាងឲ្យប្រជាជនប្រហែល ៧,៧លាននាក់ (Alkire *et al.* 2010) ។ សន្ទស្សន៍ភាពក្រីក្រគិតតាមការរាប់ចំនួនប្រជាជនក្នុងអង្កេតសេដ្ឋកិច្ច-សង្គមកិច្ចកម្ពុជាឆ្នាំ២០០៧ បង្ហាញថា អត្រាភាពក្រីក្រ គឺ ០,៨៣ នៅទីក្រុងភ្នំពេញ និង ២១,៨៥ នៅតំបន់ទីក្រុងដទៃទៀត ដែលបញ្ជាក់ថា ប្រជាជនក្រីក្រ ៧,៨% នៅកម្ពុជា កំពុងរស់នៅតំបន់ទីក្រុង (ធនាគារពិភពលោក ២០០៩) ។ នៅតំបន់ជនបទវិញ គ្រួសារក្រីក្រភាគច្រើនរស់នៅតាមខេត្តឆ្ងាយៗ ដូចជា រតនគិរី មណ្ឌលគិរី ក្រចេះ ស្ទឹងត្រែង ព្រះវិហារ និងខេត្តខ្លះទៀតនៅជុំវិញវាលទំនាបបឹងទន្លេសាប (កំពង់ធំ សៀមរាប ពោធិ៍សាត់) (ក្រាហ្វិក ៣) ។ ការសិក្សាមួយរបស់អង្គការស្បៀងអាហារ និងកសិកម្ម (FAO) នៅឆ្នាំ២០០៧ បានរកឃើញថា ខេត្តទាំងនេះជាតំបន់អសន្តិសុខស្បៀង[៦] (ក្រាហ្វិក ៤) ដោយមានប្រជាជន ២,៦លាននាក់ កំពុងប្រឈមមុខនឹងកង្វះខាតស្បៀងអាហារ (កម្មវិធីស្បៀងអាហារពិភពលោក ២០០៧) ។ គិតតាមតួលេខខាងលើនេះ អង្កេតសុខភាព និងប្រជាសាស្ត្រកម្ពុជា រកឃើញថា ៤៣% នៃកុមារអាយុពី ០-៥ឆ្នាំ រងគ្រោះដោយកង្វះអាហារូបត្ថម្ភរ៉ាំរ៉ៃ (ក្រិន) ២៨% មានសភាពស្គមស្គាំង និង ៨% មានកង្វះអាហារូបត្ថម្ភធ្ងន់ធ្ងរ ។ នៅឆ្នាំ២០០៩ កម្ពុជាមានសន្ទស្សន៍ភាពអត់ឃ្លានសាកល (GHI)[៧] ដល់ ២១,២ ដែលជាអត្រាខ្ពស់គួរឲ្យបារម្ភ ទោះបីកម្ពុជាតែងមានប្រវត្តិផលិតស្រូវអង្ករបានគ្រប់គ្រាន់ក៏ដោយ ។

---

៥ MPI ជា សន្ទស្សន៍ភាពក្រីក្រពហុវិស័យធ្ងន់ធ្ងរ ។ វាឆ្លុះបញ្ចាំងពីកង្វះខាតសេវាសំខាន់ៗបំផុត និងមុខងារចំបងៗនៃជីវភាពរស់នៅ ។ សន្ទស្សន៍នេះ បង្ហាញពីភាពក្រីក្រតាមលំនាំផ្សេងមួយ ដោយពិនិត្យលើភាពខ្វះខាតមួយសំណុំផ្សេងទៀត ក្រៅពីកង្វះខាតនូវប្រាក់ចំណូល ។ MPI វាស់វែងលើវិស័យ ៣ គឺសុខភាព ការអប់រំ និង កម្រិតជីវភាព ហើយប្រើសូចនាករ ១០ ដើម្បីវាស់វែងភាពក្រីក្រ ។ តាមវិធីវាស់វែងនេះ ក្រុមគ្រួសារមួយ ត្រូវបានកំណត់ថា ជាគ្រួសារក្រីក្រពហុវិស័យ បើសិនជាបន្សំនៃសូចនាករនានាសម្រាប់ក្រុមគ្រួសារនោះ បង្ហាញនូវភាពខ្វះខាតលើសពី ៣០% ។

៦ អសន្តិសុខស្បៀង កើតមាននៅពេលដែលមនុស្សខ្វះសារធាតុចិញ្ចឹម ដោយសារតែគ្មានស្បៀងអាហារ កង្វះលទ្ធភាពផ្នែកសេដ្ឋកិច្ច ឬសង្គមកិច្ចក្នុងការទទួលបានអាហារគ្រប់គ្រាន់ និងការបរិភោគអាហារមិនគ្រប់គ្រាន់ (កម្មវិធីស្បៀងអាហារពិភពលោក ឆ្នាំ២០០៥) ។

៧ នៅឆ្នាំ២០០៩ GHI របស់ប្រទេសជិតខាងកម្ពុជា គឺវៀតណាម ១១,៩ ឡាវ ១៩,០ និង ថៃ ៨,២ ដែលសុទ្ធតែល្អជាងអត្រារបស់កម្ពុជា ។

ជនក្រីក្រ ងាយរងគ្រោះខ្លាំងពីហានិភ័យជាលក្ខណៈបុគ្គល ឬជាលក្ខណៈសាកល ឬទាំងពីរមុខ[៨] ។ ហានិភ័យជាលក្ខណៈបុគ្គល ដែលតែងជួបប្រទះ រួមមាន ជម្ងឺមិនឆ្លងរាតត្បាត គ្រោះថ្នាក់ សមាជិកគ្រួសារស្លាប់ ការបាត់បង់សត្វចិញ្ចឹម បំណុល ចោរកម្ម អំពើហិង្សា ការខូចខាតដំណាំ ក្នុងកម្រិតគ្រួសារ បរាជ័យក្នុងអាជីវកម្ម ការប៉ះទង្គិចចំណូលគ្រួសារដោយសារការបាត់បង់ការងារ ឬការថយចុះប្រាក់ចំណូល ជាដើម ។ ចំពោះ ហានិភ័យជាលក្ខណៈសាកល ដូចជា គ្រោះធម្មជាតិ (ឧ. ទឹកជំនន់ ការរាំងស្ងួត) ជម្ងឺរាតត្បាត ជម្លោះក្នុងសង្គម (ទំនាស់ដីធ្លី ការថយចុះស្តុកធនធានធម្មជាតិ) និង វិបត្តិសេដ្ឋកិច្ចជាដើម វាតែងប៉ះពាល់ជនក្រីក្រធ្ងន់ធ្ងរជាងក្រុមផ្សេងៗទៀតនៅក្នុងសង្គម ។

ក្រុមជនងាយរងគ្រោះក្នុងសង្គម មានជាអាទិ (១) ប្រជាជនក្រីក្រនៅទីក្រុង (២) អ្នកផ្ទុកវីរុសអេដស៍ និងមានជម្ងឺអេដស៍ (៣) កុមារ និងយុវជន (៤) មនុស្សចាស់ជរា (៥) ជនពិការ (៦) ជនជាតិភាគតិច និង (៧) គ្រួសារមានស្ត្រីជាមេគ្រួ និងនារីក្នុងវ័យបន្តពូជ ។ ក្រុមនេះបានទទួលរងក្នុងកម្រិតខុសៗគ្នានូវហានិភ័យជាលក្ខណៈបុគ្គល ឬសាកល ឬក៏ទាំងពីរមុខ ។

ក្រាហ្វិក ៣៖ របាយអត្រាគ្រួសារក្រីក្រ (គិតជា %) នៅតាមស្រុក ឆ្នាំ២០០៩



*ប្រភព៖ ទិន្នន័យតាមឃុំ ២០០៣-២០០៨ ក្រសួងផែនការ*

*គូសផែនទីដោយ NCDD PST M&E unit ឆ្នាំ ២០០៩*

ក្រាហ្វិក ៨៖ តំបន់អសន្តិសុខស្បៀង




*ប្រភព៖ FAO 2007*

ការសិក្សារបស់ធនាគារពិភពលោក ស្តីពី "ហានិភ័យ និងភាពងាយរងគ្រោះនៃប្រជាជនកម្ពុជា" (២០០៦ខ) បានប្រៀបធៀបភាពងាយរងគ្រោះនៃក្រុមនីមួយៗ ដោយផ្អែកលើភាពងាយប៉ះពាល់ពីហានិភ័យ និងសមត្ថភាពដោះស្រាយហានិភ័យទាំងនោះ ។ ការសិក្សាបង្ហាញថា ក្រុមកុមារនិងយុវជន មានទំហំធំជាងគេក្នុងចំណោមក្រុមជនងាយរងគ្រោះទាំងអស់ មានស្ថានភាពអាហារូបត្ថម្ភអន់ខ្សោយ ត្រូវធ្វើការងារក្នុងប្រភេទយ៉ាប់យ៉ឺនបំផុត មានការអប់រំទាប ខ្វះខាតជំនាញ និងឱកាសទទួលបានការងារសមរម្យ ។ ជនពិការ និង ជនក្រីក្រ នៅទីក្រុង ស្ថិតនៅលំដាប់ទីពីរ និងទីបី ក្នុងចំណាត់ថ្នាក់ភាពងាយរងគ្រោះ និងលទ្ធភាពគ្រប់គ្រងហានិភ័យ ហើយបន្ទាប់មក គឺក្រុមចាស់ជរា ជនជាតិភាគតិច និង គ្រួសារមានស្ត្រីជាមេគ្រួ ។ ការសិក្សាដោយ So (2009), Kem *et al.* (2010) និង Ngo *et al.* (2010) បានបង្ហាញដែរថា ដោយសារលទ្ធភាពទាបក្នុងការដោះស្រាយហានិភ័យពីវិបត្តិសេដ្ឋកិច្ច ក្រុមជនងាយរងគ្រោះ និងគ្រួសាររបស់ពួកគេ ជាពិសេស

៨ ហានិភ័យជាលក្ខណៈបុគ្គលវាប៉ះពាល់ដល់បុគ្គល ឬគ្រួសារខ្លះៗប៉ុណ្ណោះ រីឯហានិភ័យជាលក្ខណៈសាកលវាប៉ះពាល់ដល់មនុស្សច្រើនក្នុងពេលតែមួយ ។

គ្រួសារមានស្ត្រីជាមេគ្រួ កាន់តែងាយរងគ្រោះពីការប៉ះពាល់ដល់ចំណូល និងចំណាយប្រើប្រាស់ ដែលរុញច្រានពួកគេឲ្យជាប់ផុងកាន់តែជ្រៅក្នុងភាពក្រីក្រ ។ ដូច្នេះ យុទ្ធសាស្ត្រណាដែលអាចជួយកាត់បន្ថយភាពងាយរងគ្រោះ និងហានិភ័យពីវិបត្តិនានាឲ្យក្រុមជនងាយរងគ្រោះបំផុតនោះ សុទ្ធតែអាចចាត់ទុកជាយុទ្ធសាស្ត្រដ៏សមស្រប សម្រាប់ប្រយុទ្ធនឹងភាពក្រីក្រ និងជម្រុញកំណើនឲ្យមានចីរភាព និងសមធម៌ ។

## *៣.២. កិច្ចគាំពារសង្គមកិច្ច និងការកាត់បន្ថយភាពងាយរងគ្រោះ*

កិច្ចគាំពារសង្គមកិច្ច ពេលខ្លះគេប្រើវាជា "ប្រព័ន្ធ" មួយសម្រាប់ដោះស្រាយភាពងាយរងគ្រោះទាំងជាលក្ខណៈបុគ្គល និងលក្ខណៈសាកល (Davies *et al.* 2008; Vakis 2006) ។ នាបច្ចុប្បន្ន ការដាក់អនុវត្តប្រព័ន្ធសុវត្ថិភាពសង្គម និងកិច្ចគាំពារសង្គមកិច្ច ដើម្បីជួយក្រុមជនងាយរងគ្រោះ បានក្លាយជាជម្រើសមួយដែលមានអាទិភាពខ្ពស់ ។

រដ្ឋធម្មនុញ្ញ និងច្បាប់ជាច្រើន បានកំណត់ឲ្យរដ្ឋាភិបាលមានភារកិច្ចផ្តល់នូវប្រព័ន្ធសុវត្ថិភាពសង្គមផ្សេងៗជូនដល់ប្រជាជន ។ គោលដៅជាច្រើនជាប់ទាក់ទងនឹងការគាំពារសង្គម ក៏មានអាទិភាពខ្ពស់នៅក្នុងផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ (NSDP) ដែរ ។ យោងតាម NSDP ក្រសួងមន្ទីរ និងស្ថាប័នពាក់ព័ន្ធនានា ក៏បានអនុម័តផែនការសកម្មភាព និងគោលនយោបាយមួយចំនួន ។ កម្មវិធីគាំពារសង្គមច្រើនបែបច្រើនយ៉ាងសម្រាប់ជនក្រីក្រ ព្យាយាមដោះស្រាយបញ្ហាភាពងាយរងគ្រោះ និងការអភិវឌ្ឍធនធានមនុស្ស ។ កម្មវិធីគាំពារសង្គមចំបងៗដែលមានចែងក្នុង NSDP រួមមាន សេវាសុវត្ថិភាពសង្គម បេឡាជាតិសម្រាប់សុវត្ថិភាពសង្គម ការបណ្តុះបណ្តាលវិជ្ជាជីវៈ អាហាររូបករណ៍សម្រាប់ជនក្រីក្រ កម្មវិធីផ្តល់អាហារូបត្ថម្ភតាមសាលានិងរបបយកទៅផ្ទះ មូលនិធិសមធម៌សុខភាព ការធានារ៉ាប់រងផ្នែកសុខភាពនៅតាមសហគមន៍ កម្មវិធីអាហារូបត្ថម្ភ ជំនួយសង្គ្រោះបន្ទាន់ កម្មវិធីការងារសាធារណៈ សម្បទានដីសង្គមកិច្ច ការផ្គត់ផ្គង់ទឹកស្អាតនៅតំបន់ជនបទនិងអនាម័យ និង គម្រោងខ្នាតតូច ឬឥណទានខ្នាតតូច ។

ក្រាហ្វិក ៨៖ ចំណាយរដ្ឋាភិបាលលើការគាំពារសង្គមតាមក្រសួង (គិតជាភាគរយនៃ ផសស)




*ប្រភព៖ ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ឆ្នាំ២០១០*

ចំណាយរបស់រដ្ឋាភិបាលទៅលើការគាំពារសង្គម កើនឡើងរហូតក៏ពិតមែន ប៉ុន្តែវានៅមានកម្រិតទាប បើធៀបនឹងប្រទេសឯទៀតក្នុងតំបន់ (ក្រាហ្វិក ៥) ។ ក្នុងពេលជាមួយគ្នា ប្រាក់បើកផ្តល់ដោយដៃគូអភិវឌ្ឍន៍នានារបស់រដ្ឋាភិបាល សម្រាប់គម្រោងសុវត្ថិភាពសង្គម បានកើនដល់ ៥១លានដុល្លារអាមេរិកក្នុងឆ្នាំ២០១០ ។ ក្នុងចំណោមសរុប ១៥០០អង្គការមិនមែនរដ្ឋាភិបាល មានជិតពាក់កណ្តាលកំពុងអនុវត្តកម្មវិធីជាប់ទាក់ទងនឹងការគាំពារសង្គម ។ ប៉ុន្តែទោះបីជាមានការប្រឹងប្រែងយ៉ាងធំធេង និងការខិតខំផ្តោតលើជនក្រីក្រក្តី ក៏ការគាំពារសង្គមនៅតែមិនទាន់បានទៅដល់ប្រជាជនមួយភាគធំដែលកំពុងត្រូវការជំនួយទ្រទ្រង់នៅឡើយ ។ ប្រសិទ្ធភាព និងចីរភាពនៃកម្មវិធីគាំពារសង្គមក៏បានថយចុះ ដោយសារធនធានមានកម្រិត កង្វះយុទ្ធសាស្ត្រនិងនីតិវិធីកំណត់ប្រជាជនគោលដៅដែលច្បាស់លាស់ និងរលូនគ្នាល្អ ឬក៏ការកំណត់អាទិភាពនៃកម្មវិធីដោយផ្អែកលើចំណាប់អារម្មណ៍របស់ដៃគូអភិវឌ្ឍន៍ ។

## ៤. សេចក្តីសន្និដ្ឋាន ជម្រើសគោលនយោបាយ និងវិស័យស្រាវជ្រាវជាអាទិភាពនានា សម្រាប់ការគាំពារសង្គមកិច្ចប្រកបដោយប្រសិទ្ធភាព

ភាពក្រីក្រ វិសមភាពកំណើន ការផាត់ចេញពីសង្គម និង កង្វះលទ្ធភាពទទួលបានឱកាសល្អ និងសេវាសាធារណៈ គឺជាមូលហេតុចំបងនៃភាពងាយរងគ្រោះ ។ ប្រជាជនងាយរងគ្រោះនៅកម្រិតផ្សេងៗគ្នា ទទួលរងការប៉ះទង្គិចខុសៗគ្នា ។ គេរកឃើញដូចៗគ្នាថា ក្រុមជនងាយរងគ្រោះទាំងអស់ងាយរងការប៉ះទង្គិចណាស់ និងមានលទ្ធភាពតិចតួចក្នុងការដោះស្រាយវិបត្តិ ។ កន្លងមកមានការអនុវត្តអន្តរាគមន៍ខាងគាំពារសង្គមកិច្ចជាច្រើនបែបយ៉ាងរួចហើយ សម្រាប់កាត់បន្ថយភាពក្រីក្រ និងភាពងាយរងគ្រោះ ប៉ុន្តែវានៅមិនទាន់ច្រើនគ្រប់គ្រាន់ដើម្បីឈោងឲ្យដល់ក្រុមធំៗនៃប្រជាជនងាយរងគ្រោះនោះទេ ។ កម្រិតកំណត់នៃកម្មវិធីគាំពារសង្គមកិច្ចទាំងនេះ អាចក្លាយជាឧបសគ្គដល់ការរួបរួមគ្នាក្នុងសង្គម ការអភិវឌ្ឍធនធានមនុស្ស ការកែលំអជីវភាពរស់នៅ និង កំណើនមានសមធម៌និងមូលដ្ឋានធំទូលាយ និងគោលដៅចំបងនៃការកាត់បន្ថយភាពក្រីក្រ ។ ការស្វែងរកវិធីសាស្ត្រមួយ សម្រាប់ផ្តល់កិច្ចគាំពារសង្គមកិច្ចឲ្យបានសក្តិសិទ្ធិ វាប្រហែលគ្នានឹងការស្វែងរកវិធីសាស្ត្រសក្តិសិទ្ធិ និងគ្រប់ជ្រុងជ្រោយ សម្រាប់ដោះស្រាយភាពក្រីក្រនោះដែរ ។ ដើម្បីធានាឲ្យមានការគាំពារសង្គមកិច្ចដ៏សក្តិសិទ្ធិមួយ គួរយកចិត្តទុកដាក់លើការងារមួយចំនួនដូចតទៅ (១) ដោះស្រាយភាពក្រីក្រ និងភាពងាយរងគ្រោះនៅតំបន់ជនបទ ដោយធ្វើពិពិធកម្មសេដ្ឋកិច្ចជនបទ ហើយក្នុងនេះគួរផ្តល់អាទិភាពដល់ការជំរុញកំណើនវិស័យកសិកម្ម (២) ផ្តល់អាទិភាពដល់ការគាំពារសង្គមដែលនៅមានកម្រិតសព្វថ្ងៃ និងដែលផ្តោតលើក្រុមជនមានតម្រូវការបន្ទាន់ ឬងាយរងគ្រោះបំផុត ដូចជា ពួកយុវជន ឬមនុស្សចាស់ជរា (៣) ធានាឲ្យមានការសម្របសម្រួលកាន់តែប្រសើររវាងស្ថាប័នពាក់ព័ន្ធ ឧទាហរណ៍ តាមរយៈការប្រើប្រាស់យ៉ាងពេញលេញនូវនីតិវិធីកំណត់គោលដៅតាមលក្ខណៈរួម ដូចជា កម្មវិធីអត្តសញ្ញាណកម្មគ្រួសារក្រីក្រ (ID-Poor) ឬការប្រើវិធីសាស្ត្រផ្សេងៗ ដូចជា សន្ទស្សន៍ភាពក្រីក្រច្រើនមុខ (Multidimensional poverty index) ដើម្បីកំណត់អ្នកទទួលផលជាដើម (៤) ធ្វើការស្រាវជ្រាវច្រើនទៀតសម្រាប់ផ្តល់ព័ត៌មានថ្មីៗទាន់ពេល ព្រមទាំងធ្វើការតាមដានបម្រែបម្រួល និងផលប៉ះពាល់នៃការគាំពារសង្គមកិច្ចនៅពេលអនាគត ដែលអាចក្លាយជាព័ត៌មានដ៏សំខាន់ សម្រាប់ការផ្តល់សេវាគាំពារសង្គមកិច្ចឲ្យបានសក្តិសិទ្ធិ ដើម្បីកាត់បន្ថយហានិភ័យ និងភាពងាយរងគ្រោះ ។

# ឯកសារយោង


Alkire, Sabina & Maria Emma Santos (2010), *Cambodia Country Briefing*, Oxford Poverty and Human Development Initiative (OPHI) Multidimensional Poverty Index Country Briefing Series,, Oxford Poverty and Human Development Initiative website www.ophi.org.uk/policy/multidimensional-poverty-index/mpi-country-briefings/ (retrieved 27 August 2010)

Ballard, B. M. Sloth, C. Wharton, D. Fitzgerald, I. Mushid, K.A.S. Hansen, K. K. Phim, R. Lim, S. (2007), *We Are Living with Worry All the Time: A Participatory Poverty Assessment of the Tonle Sap* (Phnom Penh: Cambodia Development Resource Institute)

Davies, M. Leavy, J. Mitchell, & T. and Tanner (2008), *Social Protection and Climate Change Adaptation* (Brighton: Institute of Development Studies at the University of Sussex)

FAO (Food Agriculture Organisation) (2007), *Mapping of Food Security and Nutrition Situation and On-going Field Agent Efforts in Cambodia* (Phnom Penh: FAO)

Fitzgerald, I., So, S., Chan, S., Kem, S., & Tout, S. (2007), *Moving Out of Poverty? Trends in Community Well-being and Household Mobility in Nine Cambodian Villages* (Phnom Penh: Cambodia Development Resource Institute)

IFPRI (International Food Policy Research Institute) (2009), *Global Hunger Index: The Challenge of Hunger- Focus on Financial Crisis and Gender Inequality* (Washington DC: Dublin)

Kem, S. Theng, V. & Chhim, C. (forthcoming in 2010), *Rapid Assessment of Impact of Global Financial Crisis on Poor and Vulnerable People: Round 4* (Phnom Penh: Cambodian Development Resource Institute)

MoP (Ministry of Planning) (2009), Poverty and Select CMDGs, Maps and Charts 2003-2008, preliminary results of CDB-based Research and Analysis Project (Phnom Penh: MoP)

Ngo, S. & Chan, S. (2010), *More Vulnerable: The Implication of the Economic Downturn on Women in Cambodia* (Phnom Penh: Oxfam Research Report)

So, S. (2009), *Informal Risk Management and Safety Net Practices in Economic Crisis in Cambodia: Experiences of Poor and Vulnerable Workers and Households*, Annual Development Review, (5) (Phnom Penh: Cambodian Development Resources Institute) pp. 83-112

Vakis, R (2006), *Complementing Natural Disasters Management: The Role of Social Protection,* Discussion Paper No. 0542 (Washington, DC: World Bank)

WFP (World Food Programme) (2005), *Food Security Atlas of Cambodia* (Cambodia: World Food Programme)

World Bank (2007), *Sharing the Growth: Equity and Development Report 2007* (Phnom Penh: World Bank for the Cambodia Development Cooperation Forum)

World Bank (2009), Poverty Profile and Trend in Cambodia: Findings from the 2007 Cambodia Socio-Economic Survey (CSES) (Poverty Reduction and Economic Management Sector Unit, East Asia and Pacific Region, World Bank)

World Bank (2006a), *Cambodia: Halving Poverty by 2015? Poverty Assessment 2006* (Phnom Penh: World Bank)

World Bank (2006b), *Managing Risk and Vulnerability in Cambodia: An Assessment and Strategy for Social Protection* (Washington DC: World Bank)

# -VI-

# ភាពក្រីក្រមួយគ្រាៗ និង រ៉ាំរ៉ៃ ក្នុង ៩ ភូមិនៅកម្ពុជា៖ ទិន្នន័យអង្កេតជាបន្តបន្ទាប់-វិធីសាស្ត្រគិតលើទ្រព្យសម្បត្តិ

*ដោយលោក តុង គឹមស៊ុន*[១]


## សេចក្តីសង្ខេប

ការសិក្សាដែលមានស្រាប់ បានទទួលស្គាល់ជាទូទៅថា គោលនយោបាយខុសៗគ្នាមានផលប៉ះពាល់ខុសៗគ្នាទៅលើភាពក្រីក្ររ៉ាំរ៉ៃ និងមួយគ្រាៗ ។ ប៉ុន្តែសព្វថ្ងៃ មានការយល់ដឹងតិចតួចនៅឡើយពីភាពក្រីក្រប្រភេទនេះនៅប្រទេសកម្ពុជា ដោយសារកង្វះទិន្នន័យអង្កេតតាមពេលវេលាបន្តបន្ទាប់ (panel data) ។ ដើម្បីវាស់វែង ភាពក្រីក្ររ៉ាំរ៉ៃ និងភាពក្រីក្រមួយគ្រាៗ មានវិធីសាស្ត្រជាច្រើនដូចជា វិធីសាស្ត្រគិតលើប្រាក់ចំណូល ឬគិតលើចំណាយប្រើប្រាស់ ឬ គិតលើទ្រព្យសម្បត្តិ ។ អត្ថបទនេះ ប្រើសូចនាករកម្មសិទ្ធិលើទ្រព្យសម្បត្តិគ្រួសារ (ឬ វិធីសាស្ត្រគិតលើទ្រព្យសម្បត្តិ) ដើម្បីវាស់ពីភាពក្រីក្ររ៉ាំរ៉ៃ និង មួយគ្រាៗ ។ ដើម្បីតំណាងឲ្យ0ទ្រព្យសម្បត្តិគ្រួសារដែលប្រើប្រាស់បានយូរ យើងបានបង្កើតនូវតារាងសន្ទស្សន៍ទ្រព្យសម្បត្តិមួយឡើង តាមការវិភាគសមាសភាគគោល (principal component analysis) ។ យើងបែងចែកភាពក្រីក្រជា ភាពក្រីក្រមួយគ្រាៗ និង ភាពក្រីក្ររ៉ាំរ៉ៃ ហើយប្រើវិធីសាស្ត្រ Multinomial logit regression ដើម្បីកំណត់ពីមូលហេតុនៃភាពក្រីក្រមួយគ្រាៗ និង រ៉ាំរ៉ៃ ។ លទ្ធផលបង្ហាញថា គ្រួសារក្រីក្រមួយគ្រាៗ មានដល់ ៤0% នៃសមាជិកគ្រួសារដែលត្រូវបានជ្រើសរើសមកសិក្សា ហើយក្រីក្ររ៉ាំរ៉ៃ មាន ៣0% ។ ចំនួនបុរសមានអាយុពី១៥ ដល់ ៦៤ឆ្នាំ លក្ខណៈសម្បត្តិនៃមេគ្រួសារ (ឧ. កម្រិតការអប់រំ, មុខរបរ) ដីកសិកម្ម ទ្រព្យសម្បត្តិមិនមែនដីធ្លី និង សត្វចិញ្ចឹម ជាកត្តាសំខាន់សម្រាប់ភាពក្រីក្ររ៉ាំរ៉ៃ ប៉ុន្តែមិនសូវសំខាន់សម្រាប់ភាពក្រីក្រមួយគ្រាទេ ។ ភាពក្រីក្រមួយគ្រា មានទំនាក់ទំនងអវិជ្ជមាន ជាមួយទ្រព្យសម្បត្តិមិនមែនដីធ្លី ។


## ១.សេចក្តីផ្តើម

ការវិភាគពីភាពក្រីក្រនៅកម្ពុជា ផ្អែកជាសំខាន់លើទិន្នន័យអង្កេតគ្រួសារនៅត្រង់ចំណុចមួយនៃពេលវេលា (cross-section data) ដែលផ្តល់នូវតួលេខប៉ាន់ស្មាននៃអត្រាភាពក្រីក្រនៅពេលនោះ ។ យុទ្ធសាស្ត្រ និង គោលនយោបាយកាត់បន្ថយភាពក្រីក្រ ដែលការសិក្សាទាំងនោះលើកឡើង ទំនងអាចជួយដោះស្រាយភាពក្រីក្រក្នុងរយៈពេលវែង ជាជាងក្នុងរយៈពេលខ្លី ។ តួលេខប៉ាន់ស្មានភាពក្រីក្រពីមួយឆ្នាំទៅមួយឆ្នាំ បានបង្ហាញរូបភាពកាន់តែច្បាស់នៃភាពក្រីក្រ ។ ដូចមានពិភាក្សាយ៉ាងច្រើនក្នុងការសិក្សានានាកន្លងមក(e.g. Jalan & Ravallion 2000; Kedir & Mckay 2003; Haddad & Ahmed 2003) ភាពក្រីក្ររយៈពេលវែងហៅថា "ភាពក្រីក្ររ៉ាំរ៉ៃ" (chronic poverty) និង ភាពក្រីក្រ ដោយសារការប៉ះទង្គិចលើប្រាក់ចំណូល ដែលទំនងជាមានរយៈពេលខ្លី ហៅថា

---

១ លោក តុង គឹមស៊ុន ជាអ្នកស្រាវជ្រាវ នៅវិទ្យាស្ថាន CDRI ។ អ្នកនិពន្ធសូមអរគុណ បណ្ឌិត Jalilian Hossein និង អ្នកកែសម្រួលឯកសារពីផ្នែកខាងក្រៅវិទ្យាស្ថាន ចំពោះការជួយមតិលើអត្ថបទព្រាង ។

"ភាពក្រីក្រមួយគ្រាៗ" (transient poverty) ។ ភាពក្រីក្រប្រភេទនេះ ឆ្លុះបញ្ចាំងពីភាពងាយរងគ្រោះ៖ អ្នកមិនក្រ អាចធ្លាក់ខ្លួនក្រភ្លាមៗ ។

ការប៉ាន់ស្មានថ្មីៗរបស់ធនាគារពិភពលោក បង្ហាញថា វិបត្តិហិរញ្ញវត្ថុសាកល នាំឲ្យមានមនុស្ស ៥០លាននាក់ ថែមទៀត ធ្លាក់ខ្លួនក្រីក្របំផុតក្នុងឆ្នាំ២០០៩ និងប្រហែល ៦៤ លាននាក់ទៀត ធ្លាក់ខ្លួននៅចុងឆ្នាំ២០១០ (World Bank 2010a)។ នៅប្រទេសកម្ពុជា ការសិក្សាមួយធ្វើឡើងដោយ លោក តុង គឹមស៊ុន និងក្រុមស្រាវជ្រាវ (២០០៩) បានបញ្ជាក់ថា ចំនួនភាពក្រីក្រ បានកើនឡើង រវាងឆ្នាំ២០០៨ និង ២០០៩ ដោយសារការធ្លាក់ចុះសេដ្ឋកិច្ចឆ្នាំ២០០៩ ។ វិបត្តិសេដ្ឋកិច្ចសាកល បានបង្កឧបសគ្គយ៉ាងធំ ដល់ការសម្រេចគោលដៅអភិវឌ្ឍន៍សហស្សវត្សរ៍ឆ្នាំ២០១៥ ជាពិសេស គោលដៅនៃការកាត់បន្ថយភាពក្រីក្របំផុត និង ភាពអត់ឃ្លាន ។

ធនាគារពិភពលោក (២០០៩) រាយការណ៍ថា អត្រាអ្នកក្រីក្រនៅកម្ពុជា មាន ៣០,១% នៅឆ្នាំ២០០៧ ដែលខ្ពស់ជាងតួលេខគួរចុះដល់នៅដំណាក់កាលនេះ ដើម្បីសម្រេចបានគោលដៅ អភិវឌ្ឍន៍សហស្សវត្សរ៍ (MDG) ។ ដោយពិចារណាតាមអត្រាធ្លាក់ចុះភាពក្រីក្រជាមធ្យម ១% ក្នុង មួយឆ្នាំ និងកំណើនជនក្រីក្រដោយសារវិបត្តិសេដ្ឋកិច្ច គោលដៅ MDG នេះ ប្រហែលពិបាកសម្រេច បាន ហើយវាឆ្លុះបញ្ចាំងផងដែរថា គោលនយោបាយកាត់បន្ថយភាពក្រីក្របច្ចុប្បន្ន ពុំបានការពារ គ្រួសារងាយរងគ្រោះពីការធ្លាក់ខ្លួនក្រនោះទេ ។

ការសិក្សាពីឌីណាមិកនៃភាពក្រីក្រ បានកើនឡើងយ៉ាងច្រើន ក្នុងប្រទេសកំពុងអភិវឌ្ឍន៍ ឯទៀតៗ (e.g. Jalan & Ravallion (2000); Baulch & Hoddinott (2000); Kedir & Mckay (2003); Haddad & Ahmed (2003)) ។ ប៉ុន្តែនៅកម្ពុជា មិនដែលមានធ្វើការវិភាគឲ្យបានហ្មត់ចត់ ពីឌីណាមិកនៃភាពក្រីក្រទេ ដោយសារកង្វះព័ត៌មានអង្កេតតាមពេលវេលាបន្តបន្ទាប់(panel data) ។

សេដ្ឋវិទូខាងអភិវឌ្ឍន៍តែងប្រើប្រាក់ចំណូល និង ចំណាយប្រើប្រាស់ (ឧ. សូចនាកររូបិយវត្ថុ) ដើម្បីវាស់វែងពីសុខុមាលភាព ប៉ុន្តែភាពត្រឹមត្រូវនៃទិន្នន័យខាងរូបិយវត្ថុ ក៏នៅមានកម្រិតដែរ ។ ដើម្បី ដោះស្រាយបញ្ហានេះ យើងបានប្រើសូចនាករមិនមែនរូបិយវត្ថុ ដូចជា ទ្រព្យជាប់លាប់ លទ្ធភាព ទទួលបានការផ្គត់ផ្គង់សាធារណៈ និង លក្ខណៈលំនៅឋាន ដើម្បីបំពេញបន្ថែមលើការវាស់វែងជា រូបិយវត្ថុ ។ ទិន្នន័យមិនមែនរូបិយវត្ថុទាំងនេះ ផ្តល់ព័ត៌មានអំពីកម្រិតជីវភាពរយៈពេលវែង បាន ប្រសើរជាង ប្រាក់ចំណូល និង ចំណាយប្រើប្រាស់ ព្រោះមិនសូវមានបញ្ហាចោទខាងការវាស់វែង ។ ប៉ុន្តែទិន្នន័យមិនមែនរូបិយវត្ថុ អាចពណ៌នាមិនបានច្បាស់ពីការប៉ះទង្គិចរយៈពេលខ្លីទៅលើគ្រួសារ ។

ក្នុងប៉ុន្មានឆ្នាំថ្មីៗ មានការសិក្សាមួយចំនួន (Filmer & Princhett 1998; McKenzie 2004; Sahn & Stifel 2003; Kolenikov & Angeles 2004; Booysen *et al.* 2008) បានព្យាយាមបង្កើត វិធីសាស្ត្រថ្មីមួយ ដើម្បីបូកបញ្ចូលទ្រព្យសម្បត្តិគ្រួសារទៅក្នុងអថេរតែមួយ និងប្រើអថេរនេះជា សន្ទស្សន៍សម្រាប់ប៉ាន់ស្មានពីភាពក្រីក្រ ។ ដោយសារទិន្នន័យគ្រួសារបានមកពីការស្រាវជ្រាវលើ ចំណាយប្រើប្រាស់អាហារ និងមិនមែនអាហារ អាចមានបញ្ហាចោទខ្លះ (គុណភាពអាចមិនសូវល្អ) យើងបានប្រើវិធីសាស្ត្រ ផ្អែកលើទ្រព្យសម្បត្តិ ដែលស្នើឡើងដោយ Filmer and Pritchet (1998) ដើម្បីវាស់វែងភាពក្រីក្ររ៉ាំរ៉ៃ និងមួយគ្រាៗ និងប្រើ Multinomial logit regression ដើម្បីស្វែង រកកត្តាកំណត់សំខាន់ៗនៃការវាស់វែងភាពក្រីក្រទាំងពីរ ។ លទ្ធផលនេះ អាចជួយដល់អ្នកបង្កើត គោលនយោបាយ ក្នុងការកំណត់ចេញនូវយុទ្ធសាស្ត្រកាត់បន្ថយភាពក្រីក្រ ដែលផ្អែកលើភស្តុតាង និងមានប្រសិទ្ធភាព នៅក្នុងវិស័យដ៏សមស្របនានា ។

## ២. ការសិក្សាពីមុនមក

ក្នុងរយៈពេលមួយទសវត្សរ៍កន្លងទៅនេះ ការសិក្សាពីភាពក្រីក្របានកើនឡើងយ៉ាងច្រើននៅកម្ពុជា ។ ការសិក្សាដែលគេស្គាល់ច្រើនជាងគេ គឺការពិពណ៌នាពីភាពក្រីក្រនៅកម្ពុជា (Cambodia Poverty Profile) ដែលធ្វើការប៉ាន់ស្មានភាពក្រីក្រដោយប្រើ ទិន្នន័យសេដ្ឋកិច្ច-សង្គមកិច្ចកម្ពុជា (CSES) ឆ្នាំ១៩៩៣-៩៤ ១៩៩៧ ១៩៩៩ ២០០៣-០៤ និង ២០០៧ ។ របាយការណ៍នោះបង្ហាញថា អត្រាជនក្រីក្រដែលរាប់ឃើញ ធ្លាក់ចុះពី ៤៧% នៅឆ្នាំ១៩៩៣-៩៤ ដល់ត្រឹម ៣០% នៅឆ្នាំ២០០៧ ។ ប៉ុន្តែអង្កេតទូទាំងប្រទេសនេះ មិនបានបង្ហាញពីអ្វីដែលបានកើតឡើងចំពោះគ្រួសារនីមួយៗពីមួយឆ្នាំទៅមួយឆ្នាំ (ឌីណាមិកនៃភាពក្រីក្រ) ដោយពិនិត្យថា ហេតុអ្វីគ្រួសារខ្លះអាចចាកផុតពីភាពក្រីក្រ ខ្លះទៀតធ្លាក់ចូលក្នុងភាពក្រីក្រ និង ខ្លះទៀតនៅក្រីក្រដដែល ។

ការសិក្សាមានចំណងជើងថា ការចាកផុតពីភាពក្រីក្រ និពន្ធដោយ Fitzgerald & So (2007) បានពន្យល់ពីឌីណាមិកនៃភាពក្រីក្រនៅកម្ពុជា ។ ការសិក្សានេះ ប្រើទិន្នន័យអង្កេតក្នុងពីររយៈពេល ប្រើវិធីសាស្ត្រចម្រុះ (បែបគុណភាព និង បរិមាណ) និងធ្វើចំណាត់ថ្នាក់គ្រួសារជា (ក) ក្រខ្លាំង (ខ) ក្រមធ្យម(ក្នុងចន្លោះ ២០% ខាងលើ និងខាងក្រោមបន្ទាត់ក្រីក្រ) និង (គ) អ្នកធូរធារ ។ ការសិក្សានេះ រកឃើញថា ៥២% នៃគ្រួសារទាំងនោះ មិនបានផ្លាស់ប្តូរស្ថានភាពទេពីឆ្នាំ២០០១ ដល់ ២០០៤ ។ ប្រមាណ ១៤% នៃអ្នកក្រខ្លាំងក្នុងឆ្នាំ២០០១ បានឈានឡើងជា អ្នកក្រមធ្យម និង អ្នកធូរធារ ។ ប្រមាណ ៧% នៃអ្នកក្រមធ្យម បានធ្លាក់ខ្លួនក្រខ្លាំង ហើយ ១២% បានក្លាយជាអ្នកធូរធារ ចំណែកឯ ១៥% នៃអ្នកធូរធារ បានធ្លាក់ខ្លួនក្រមធ្យម និងក្រខ្លាំង ។ ការវិភាគតាមបែបពិពណ៌នាក្នុងការសិក្សានេះ អាចបានរំលងចោលនូវព័ត៌មានសេដ្ឋកិច្ចសំខាន់ៗផ្សេងទៀតមានឥទ្ធិពលព្រមៗគ្នាទៅលើកត្តាកំណត់ភាពក្រីក្រ ។ ដូច្នេះ ការវិភាគអាចផ្តល់នូវលទ្ធផលមិនច្បាស់លាស់ ។

ក្នុងប្រទេសកំពុងអភិវឌ្ឍន៍ឯទៀតៗ មានការសិក្សាជាច្រើនអំពី ឌីណាមិកនៃភាពក្រីក្រនេះ ។ Kedir and Mcday (2003) បានពិនិត្យពីភាពក្រីក្ររ៉ាំរ៉ៃនៅទីប្រជុំជនក្នុងប្រទេស Ethiopia ។ ពួកគាត់បានប្រើទិន្នន័យអង្កេតតាមពេលបន្តបន្ទាប់ (panel data) លើ ១៥០០គ្រួសារ ដែលប្រមូលបានក្នុងឆ្នាំ១៩៩៤-៩៧ ដោយឲ្យនិយមន័យ ក្ររ៉ាំរ៉ៃ ជាគ្រួសារដែលមានចំណាយសរុបពិតក្នុងមនុស្សម្នាក់ ទាបជាងបន្ទាត់ក្រីក្រក្នុងរយៈពេល ៣ឆ្នាំពេញ និង និយមន័យ ក្រមួយគ្រាៗ ជាគ្រួសារដែលមានចំណាយសរុបពិត ក្នុងមនុស្សពេញវ័យម្នាក់ក្នុងមួយខែ ទាបជាងបន្ទាត់ក្រីក្រ ក្នុងរយៈពេលមួយឆ្នាំ ឬពីរឆ្នាំ ។ ពួកគាត់រកឃើញថា គ្រួសារក្រមួយគ្រាៗ មានអត្រាខ្ពស់ជាងគ្រួសារក្ររ៉ាំរ៉ៃ ។ ដោយប្រើ multinomial logit regression ពួកគាត់បានអះអាងថា ភាពក្រីក្ររ៉ាំរ៉ៃមានចំណងទាក់ទងនឹង សមាសភាពគ្រួសារ ភាពអត់ការងារធ្វើ កង្វះកម្មសិទ្ធិលើទ្រព្យសម្បត្តិ ការងាររកបានមិនជាប់លាប់ កង្វះការអប់រំ លក្ខណៈជនជាតិ អាយុមេគ្រួសារ និងមេគ្រួសារជានារី ។

Hadad and Ahmed (2003) បានប្រើវិធីសាស្ត្រ quintile regression ចំពោះទិន្នន័យអង្កេតពីររយៈពេល លើ ៣៤៧គ្រួសារ នៅប្រទេសអេស៊ីប ដើម្បីកំណត់ពីមូលហេតុនៃភាពក្រីក្ររ៉ាំរ៉ៃ និង មួយគ្រាៗ និង បានចាត់ថ្នាក់ គ្រួសារមានចំណាយប្រើប្រាស់ពិតក្នុងមនុស្សម្នាក់ នៅក្រោមបន្ទាត់ក្រីក្រទាំងពីររយៈពេល ជាអ្នកក្ររ៉ាំរ៉ៃ និងគ្រួសារមានចំណាយប្រើប្រាស់ពិតក្នុងមនុស្សម្នាក់ធ្លាក់ក្រោមបន្ទាត់ក្រីក្រតែមួយឆ្នាំនៅក្នុងពីរឆ្នាំនោះ ជាអ្នកក្រមួយគ្រាៗ ។ ពួកគាត់បានរកឃើញថា ទំហំគ្រួសារ ចំនួនសមាជិកគ្រួសារមានអាយុតិចជាង១៥ឆ្នាំ អាយុមេគ្រួសារ ទ្រព្យជាសត្វចិញ្ចឹម ដីកសិកម្ម ការអប់រំរបស់សមាជិកគ្រួសារ និង ស្ថានភាពការងារ មានឥទ្ធិពលលើភាពក្រីក្ររ៉ាំរ៉ៃ ។ មានតែសមាជិកគ្រួសារដែលមានអាយុលើស ៦០ឆ្នាំ និងដីធ្វើកសិកម្ម ទេ ដែលបង្កើនភាពងាយកើតមានភាពក្រីក្រមួយគ្រាៗ ។

Jalan and Ravallion (2000) បានប្រើទិន្នន័យលើ ៥៨៥៤គ្រួសារ នៅភាគនីរតីនៃប្រទេសចិន ក្នុងអំឡុងឆ្នាំ១៩៨៥-៩០ ដើម្បីផ្ទៀងផ្ទាត់មើលថា តើការកំណត់ភាពក្រីក្រមួយគ្រាៗ និង ភាពក្រីក្ររ៉ាំរ៉ៃ ស្រដៀងគ្នាដែរឬទេ ។ ពួកគាត់បានឲ្យនិយមន័យភាពក្រីក្ររ៉ាំរ៉ៃ ថា មានចំណាយប្រើប្រាស់មធ្យម ទាបជាងបន្ទាត់ក្រីក្រ ។ គ្រួសារ គឺមានភាពក្រីក្រមួយគ្រាៗ ប្រសិនបើទិន្នន័យបង្ហាញថា ពួកគេបានធ្លាក់ខ្លួនក្រយ៉ាងហោចណាស់មួយដង និងមានចំណាយប្រើប្រាស់មធ្យមខ្ពស់ជាងបន្ទាត់ក្រីក្រ ។ ដោយប្រើ quintile regression ពួកគាត់រកឃើញថា អាយុរបស់មេគ្រួសារ សុខភាពរាងកាយ និង ដីដាំដុះ គឺជាអថេរសំខាន់ៗបំផុតសម្រាប់កំណត់ភាពក្រីក្រមួយគ្រាៗ ។ រីឯលក្ខណៈប្រជាសាស្ត្រ (ទំហំគ្រួសារ អាយុរបស់កូនៗ) ការអប់រំ ស្ថានភាពការងាររបស់សមាជិកគ្រួសារ សុខភាពរាងកាយ និងដីដាំដុះ ហាក់ដូចមានសារៈសំខាន់សម្រាប់ការកំណត់ភាពក្រីក្ររ៉ាំរ៉ៃ ។

ទោះបីជាកត្តាកំណត់សំខាន់ៗនៃភាពក្រីក្ររ៉ាំរ៉ៃ និងមួយគ្រាៗ ខុសគ្នាបន្តិចបន្តួច ពីប្រទេសមួយទៅប្រទេសមួយក្តី ក៏ជាទូទៅគេកត់សម្គាល់ថា សេវាសុខភាព និងសេវាអប់រំ ការបែងចែកទ្រព្យសម្បត្តិឡើងវិញ ការអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធ តែងជួយកាត់បន្ថយភាពក្រីក្ររ៉ាំរ៉ៃ ។ ប្រព័ន្ធធានារ៉ាប់រងលើការងារនិងសុខភាព កម្មវិធីផ្តល់ស្ថិរភាពដល់ប្រាក់ចំណូល មីក្រូឥណទាន និងបណ្តាញសុវត្ថិភាពសង្គមបណ្តោះអាសន្ន សំខាន់ខ្លាំងណាស់ សម្រាប់ភាពក្រីក្រមួយគ្រាៗ ។

## ៣. ទិន្នន័យ និងវិធីសាស្ត្រ

ការវិភាគព័ត៌មានជាក់ស្តែងនៅក្នុងអត្ថបទនេះ ផ្អែកលើលទ្ធផលស្រាវជ្រាវរបស់ CDRI នៅឆ្នាំ២០០១ ២០០៤-០៥ និង ២០០៨ ក្នុងភូមិចំនួន ៩ ។ ការពិពណ៌នាសង្ខេបអំពីភូមិដែលបានជ្រើសរើសមកសិក្សាទាំងនេះ មានចុះក្នុងឧបសម្ព័ន្ធ១ ។ ព័ត៌មានប្រមូលបាន រួមមាន ប្រជាសាស្ត្រគ្រួសារ ស្ថានភាពលំនៅឋាន ដីធ្លី ទីផ្សារឥណទាន ចំណាយប្រើប្រាស់ជាអាហារនិងមិនមែនអាហារ ទ្រព្យសម្បត្តិមិនមែនជាដីធ្លី ការចិញ្ចឹមសត្វ ប្រាក់ចំណូលគ្រួសារ ផលិតកម្មកសិកម្ម ចំណាយផលិតកម្ម ប្រាក់ខែ និងការប្រកបមុខរបរខ្លួនឯង ។

ទោះបីមានទិន្នន័យអង្កេតសម្រាប់បីឆ្នាំខុសៗគ្នាក្តី ក៏ការកំណត់ពីការប្រែប្រួលនៅតែមានបញ្ហាចោទ ។ ពីមួយឆ្នាំទៅមួយឆ្នាំមានចំណុចមិនស៊ីគ្នាខ្លះ បានកើតមានឡើង ដែលពិបាកកែតម្រូវវិញនៅដំណាក់កាលនេះ ។ សំណួរខ្លះបានផ្លាស់ប្តូរន័យទាំងស្រុង ហើយសំណួរខ្លះទៀតត្រូវបានបញ្ចូលគ្នា ឬបំបែកលម្អិត ដើម្បីបំពេញតាម គោលដៅនៃការសិក្សាក្នុងជុំនីមួយៗ ។ ការបណ្តុះបណ្តាល និងការបែងចែកអ្នកសួរសម្ភាសន៍ ក៏អាចជះឥទ្ធិពលខ្លះទៅលើការវាស់វែងប្រាក់ចំណូល និងការចំណាយរបស់គ្រួសារដែរ ។ មួយវិញទៀត ការប្រៀបធៀបនូវសូចនាកររូបិយវត្ថុនានា វាមានប្រយោជន៍លុះត្រាតែមានប្រើសន្ទស្សន៍បរិត្តផរណា ។ CDRI បានស្រង់ថ្លៃអីវ៉ាន់ជាអាហារ និងមិនមែនជាអាហារ ចំនួន១០៦មុខ ដើម្បីបង្កើតជាសន្ទស្សន៍ថ្លៃទំនិញប្រើប្រាស់ក្នុងភូមិ ចាប់តាំងពីឆ្នាំ២០០៤-០៥ មក ។ ប៉ុន្តែកង្វះទិន្នន័យលើថ្លៃទំនិញក្នុងឆ្នាំ២០០១ តម្រូវឲ្យមានការសន្មតមួយអំពីអត្រាអតិផរណាក្នុងភូមិពីឆ្នាំ២០០១ ដល់ ២០០៤-០៥ ។ ការសិក្សាពី "ការចាកផុតពីភាពក្រីក្រ" ដោយ Fitzgerald and So (2007) បានសន្មតថា អត្រាអតិផរណាក្នុងភូមិទាំងអស់ពីឆ្នាំ២០០១ ដល់ ២០០៤-០៥ មានប្រហែល ១៨% ដែលទំនងជាមិនសូវត្រឹមត្រូវទេ ព្រោះភូមិជ្រើសរើសទាំង ៩ ស្ថិតក្នុងតំបន់ខុសៗគ្នា ។ ម្យ៉ាងទៀត គុណភាពទិន្នន័យថ្លៃទំនិញ ក៏មិនសូវល្អដែរ ។ ដូច្នេះ ប្រាក់ចំណូល និងចំណាយប្រើប្រាស់ពិត ដែលគណនាតាមសន្ទស្សន៍ថ្លៃទំនិញប្រើប្រាស់ក្នុងភូមិ នៅមានចំណុចខ្វះខាតច្រើន ។

នៅពេលសាកសួរពីទ្រព្យសម្បត្តិរបស់គ្រួសារ (សួរតាមបញ្ជីរាយមុខសម្ភារៈមួយ ដែលមានជាអាទិ៍ កង់ ទូរទស្សន៍ ប្រភពទឹកហូប) អ្នកឆ្លើយសំណួរ ទំនងជាផ្តល់ព័ត៌មានបានពិតជាងការសួរពី

ចំណូល និង ចំណាយ ។ ទោះយ៉ាងនេះក្ដី ការប្រើរបស់តំណាងតែមួយ អាចនាំឲ្យមានការវាស់វែងពីសុខមាលភាពខាងសេដ្ឋកិច្ច-សង្គមកិច្ច ដែលមិនអាចជឿជាក់បាន និងគ្មានស្ថិរភាព ។ គោលគំនិតនៃការបង្កើតសន្ទស្សន៍ទ្រព្យសម្បត្តិ គឺត្រូវដាក់បញ្ចូលរបស់តំណាងមួយចំនួនទៅក្នុងអថេរតែមួយ ។ វិធីសាស្ត្រពេញនិយមជាងគេ គឺការដាក់ទម្ងន់ (weight) ឲ្យអថេរដែលបានសង្កេតឃើញ និងធ្វើការបូកសរុប ។ Pearson (1901) and Hotelling (1933) បានបង្កើតការវិភាគសមាសភាគគោល (Principal Component Analysis: PCA) នៅដើមសតវត្សទី២០ ក្នុងគោលបំណងស្រដៀងគ្នានៃការបូកបញ្ចូលពត៌មាន (cited in Kolenikov & Angeles 2004) ។ ក្នុងផ្នែកសេដ្ឋកិច្ច វិធីសាស្ត្រនេះគេប្រើក្នុងការសិក្សាពី ការព្យាករណ៍ ការអប់រំ និងភាពក្រីក្រ ។

**តារាង ១៖ សន្ទស្សន៍ចំនួនជនក្រីក្រតាមតំបន់ ឆ្នាំ២០០៤ និង ២០០៧**

| បន្ទាត់ក្រីក្រ (តំបន់) | 2004 | 2004* | 2007 |
|---|---|---|---|
| បន្ទាត់ក្រីក្រខាងអាហារ | | | |
| ភ្នំពេញ | 2.55 | 2.55 | 0.11 |
| ទីប្រជុំជនផ្សេងទៀត | 14.15 | 14.78 | 12.73 |
| តំបន់ជនបទ | 22.23 | 22.12 | 20.78 |
| ប្រទេសកម្ពុជា | 19.68 | 19.71 | 17.98 |
| បន្ទាត់ក្រីក្រសរុប | | | |
| ភ្នំពេញ | 4.60 | 4.60 | 0.83 |
| ទីប្រជុំជនផ្សេងទៀត | 24.73 | 25.78 | 21.85 |
| តំបន់ជនបទ | 39.18 | 39.05 | 34.70 |
| ប្រទេសកម្ពុជា | 34.68 | 34.78 | 30.14 |

** គិតតែក្នុងភូមិគំរូតាងនៃ CSES 2007*
*ប្រភព៖ World Bank (2009)*

ការវិភាគពីភាពក្រីក្រដ៏មានឥទ្ធិពលមួយដែលប្រើប្រាស់ PCA ដើម្បីបង្កើតសន្ទស្សន៍ទ្រព្យសម្បត្តិ បានធ្វើឡើងដោយ Filmer and Princhett (1998) ហើយការសិក្សានេះ ក៏បានប្រើ PCA ដើម្បីបង្កើតសន្ទស្សន៍ទ្រព្យសម្បត្តិដែរ ។ Albert (2009a) បានពិពណ៌នាពីការគណនាសន្ទស្សន៍ទ្រព្យសម្បត្តិដោយប្រើ PCA សម្រាប់ទិន្នន័យការសិក្សាពីឌីណាមិកភាពក្រីក្រ (PDS) ថាជាដំណើរការមានពីរដំណាក់កាល ។ ទី១ គេប្រើ PCA លើទិន្នន័យទ្រព្យសម្បត្តិនៃអង្កេតថ្នាក់ជាតិមួយ (ប៉ុន្តែសម្រាប់តែគ្រួសារជនបទប៉ុណ្ណោះ ព្រោះតំបន់ PDS ជាតំបន់ជនបទ) ។ ទី២ គេប្រើលទ្ធផលពិន្ទុនៃសមាភាគគោលទីមួយ ដើម្បីកំណត់ទម្ងន់សម្រាប់សន្ទស្សន៍សមាសភាគទ្រព្យសម្បត្តិលើទិន្នន័យ PDS ។ ដោយការសិក្សាមានគោលដៅពិនិត្យពី ឌីណាមិកនៃកម្រិតជីវភាព ដូច្នេះត្រូវមានបន្ទាត់ក្រីក្រមួយសម្រាប់សន្ទស្សន៍ទ្រព្យសម្បត្តិ ដើម្បីកំណត់អ្នកក្រពីទិន្នន័យ PDS ។ Albert (2009a) ក៏បានស្នើឲ្យប្រើអត្រាភាពក្រីក្រដែលបានពីការអង្កេតថ្នាក់ជាតិ (CSES 2003-04) ជាកម្រិតគោលសម្រាប់បន្ទាត់ក្រីក្រ ។ ដូចមានបង្ហាញក្នុងតារាង១ ចំនួនអ្នកក្រីក្រនៅជនបទធៀបនឹងបន្ទាត់ក្រីក្រសរុប មាន ៣៩% ហើយធៀបនឹងបន្ទាត់ក្រីក្រស្បៀងអាហារ មាន ២២% ក្នុងឆ្នាំ២០០៤ ។ ស្របតាមអត្រានៃភាពក្រីក្រ ដែលប៉ាន់ស្មានដោយវិធីសាស្ត្រចំណាយប្រើប្រាស់

គេមានបន្ទាត់ពីរសម្រាប់ប្រើះ (ក) លេខភាគរយទី៣៩ នៃសន្ទស្សន៍ទ្រព្យសម្បត្តិ (ខ) លេខភាគរយទី២២ នៃសន្ទស្សន៍ទ្រព្យសម្បត្តិ ។ ជាលទ្ធផល គ្រួសារអាចកំណត់ថាៈ

១. ក្រ ប្រសិនបើតម្លៃសន្ទស្សន៍ទ្រព្យសម្បត្តិ វាតិចជាង លេខភាគរយទី៣៩ នៃរបាយសន្ទស្សន៍ទ្រព្យសម្បត្តិរបស់ប្រជាជនរស់នៅតំបន់ជនបទ ។
២. ក្រខ្លាំង ប្រសិនបើតម្លៃនៃសន្ទស្សន៍ទ្រព្យសម្បត្តិ វាតិចជាងលេខភាគរយទី២២ នៃរបាយសន្ទស្សន៍ទ្រព្យសម្បត្តិនៃប្រជាជនរស់នៅតំបន់ជនបទ ។

**តារាង ២៖ ស្ថិតិពិពណ៌នា**

| | CSES 2004 | | PDS 2001 | | PDS 2004/05 | | PDS 2008 | |
|---|---|---|---|---|---|---|---|---|
| អថេរ | មធ្យម | គំលាតស្តង់ដារ | មធ្យម | គំលាតស្តង់ដារ | មធ្យម | គំលាតស្តង់ដារ | មធ្យម | គំលាតស្តង់ដារ |
| វិទ្យុ | 0.354 | 0.478 | 0.200 | 0.400 | 0.310 | 0.463 | 0.310 | 0.463 |
| ទូរទស្សន៍ | 0.407 | 0.491 | 0.245 | 0.431 | 0.447 | 0.498 | 0.571 | 0.495 |
| កង់ | 0.665 | 0.472 | 0.451 | 0.498 | 0.643 | 0.479 | 0.758 | 0.428 |
| ម៉ូតូ | 0.225 | 0.418 | 0.111 | 0.315 | 0.191 | 0.393 | 0.368 | 0.482 |
| រទេះអូសដោយសត្វ | 0.296 | 0.456 | 0.264 | 0.441 | 0.260 | 0.439 | 0.245 | 0.431 |
| ម៉ាស៊ីនដេរ | 0.040 | 0.197 | 0.054 | 0.227 | 0.077 | 0.267 | 0.075 | 0.264 |
| ម៉ាស៊ីនភ្លើង | 0.021 | 0.144 | 0.012 | 0.109 | 0.027 | 0.161 | 0.050 | 0.217 |
| ទូក | 0.101 | 0.302 | 0.415 | 0.493 | 0.485 | 0.500 | 0.438 | 0.496 |
| នង្គ័ល/រនាស់ | 0.464 | 0.499 | 0.426 | 0.495 | 0.395 | 0.489 | 0.302 | 0.460 |
| ម៉ាស៊ីនបូមទឹក | 0.017 | 0.128 | 0.127 | 0.333 | 0.152 | 0.360 | 0.227 | 0.419 |
| ម៉ាស៊ីនបោក | 0.874 | 0.332 | 0.005 | 0.069 | 0.010 | 0.098 | 0.021 | 0.142 |
| ម៉ាស៊ីនកិនស្រូវ | 0.023 | 0.151 | 0.025 | 0.157 | 0.036 | 0.187 | 0.056 | 0.229 |
| ទឹកហូបបានពីអណ្តូងស្នប់ដៃ | 0.292 | 0.455 | 0.209 | 0.407 | 0.172 | 0.377 | 0.167 | 0.373 |
| ទឹកហូបបានពីអណ្តូងជីក | 0.328 | 0.470 | 0.204 | 0.403 | 0.166 | 0.372 | 0.169 | 0.375 |
| ទឹកហូបបានពីស្រះ ឬ ទន្លេ | 0.255 | 0.436 | 0.578 | 0.494 | 0.628 | 0.484 | 0.595 | 0.491 |
| បង្គន់ | 0.643 | 0.479 | 0.105 | 0.307 | 0.100 | 0.301 | 0.163 | 0.370 |
| ផ្ទះឈើ | 0.388 | 0.487 | 0.440 | 0.497 | 0.586 | 0.493 | 0.757 | 0.429 |
| ផ្ទះឬស្សី/ស្លឹក | 0.397 | 0.489 | 0.511 | 0.500 | 0.385 | 0.487 | 0.237 | 0.426 |
| ដីកសិកម្ម >0 និង <1000 $m^2$ | 0.397 | 0.489 | 0.399 | 0.490 | 0.334 | 0.472 | 0.254 | 0.436 |
| ដីកសិកម្ម >1000 និង <3000$m^2$ | 0.258 | 0.438 | 0.239 | 0.427 | 0.316 | 0.465 | 0.270 | 0.444 |
| ដីកសិកម្ម >3000 និង <5000$m^2$ | 0.034 | 0.182 | 0.045 | 0.207 | 0.048 | 0.215 | 0.097 | 0.296 |
| ដីកសិកម្ម>5000 $m^2$ | 0.023 | 0.150 | 0.031 | 0.175 | 0.027 | 0.161 | 0.051 | 0.220 |

*CSES 2004: មានចុះតែការសង្កេតឃើញនៅជនបទប៉ុណ្ណោះ*

*ប្រភព៖ CSES 2004, CDRI 2001-08*

Albert (2009a) បានបង្កើតសន្ទស្សន៍ទ្រព្យសម្បត្តិចម្រុះមួយ ដោយប្រើអថេរជ្រើសរើសមួយចំនួនដែលអាចរកបានជាធម្មតានៅក្នុងអង្កេត PDS ទាំងបី និង CSES 2004 ។ អថេរទាំងនេះអាចបែងចែកជា លក្ខណៈនៃផ្ទះសំបែង (ប្រភេទផ្ទះ) ការទទួលបានការផ្គត់ផ្គង់សាធារណៈ និងកម្មសិទ្ធិជាទ្រព្យជាប់លាប់ ។ តារាង២ រាយមុខអថេរទាំងនេះ ព្រមទាំងតួលេខ មធ្យម និងគំលាតស្តង់ដារ របស់វា ហើយបង្ហាញថា សមាមាត្រគ្រួសារដែលមានសូចនាករទ្រព្យសម្បត្តិក្នុង PDS 2004-05 វាខុសគ្នាបន្តិចបន្តួចពី CSES 2004 ។ ឧទាហរណ៍ គ្រួសារដែលមាន ទូក ម៉ាស៊ីនបូមទឹក ផ្ទះឈើ និងទឹកហូបបានពីបឹងឬទន្លេ ក្នុង PDS 2004-05 មានចំនួនច្រើនជាង ចំនួនក្នុង CSES 2004 ប៉ុន្តែគ្រួសារដែលមានម៉ាស៊ីនបោកស្រូវ ឬបង្គន់ ក្នុង PDS 2004-05 មានតិចជាង CSES 2004 ។ ភាពខុសប្លែកគ្នាអាចបណ្តាលមួយផ្នែក ដោយសារ ការរៀបចំ និងទំហំចំនួនគ្រួសារដែលត្រូវបានជ្រើសរើសមកសិក្សា ដូច្នេះការប្រៀបធៀបតាមធម្មតាអាចមិនត្រឹមត្រូវទេ ។ ប្រសិនបើយកកត្តាទាំងអស់មកពិចារណា សូចនាករទ្រព្យសម្បត្តិក្នុង PDS 2004-05 អាចមានគុណភាពស្រដៀងគ្នានឹង CSES 2004 ដែលជាទិន្នន័យគ្រួសារថ្នាក់ជាតិ ។ ទោះជាលទ្ធផលជាក់ស្តែងរបស់ PDS មិនតំណាងថ្នាក់ជាតិក៏ដោយ ក៏វាបានផ្តល់នូវករណីសិក្សាគួរឲ្យចាប់អារម្មណ៍មួយ អំពីឌីណាមិកនៃភាពក្រីក្រ ហើយការវិភាគក៏មានលក្ខណៈរឹងមាំល្អ ។

តារាង ៣៖ សមាសធាតុសំខាន់ៗ និង ស្ថិតិសង្ខេបសម្រាប់សូចនាករទ្រព្យសម្បត្តិ (CSES 2004)

| អថេរ | កត្តាពិន្ទុ | CSES 2004 | ទាបបំផុត | កណ្តាល |
|---|---|---|---|---|
| វិទ្យុ | 0.1511 | 0.354 | 0.239 | 0.370 |
| ទូរទស្សន៍ | 0.3518 | 0.407 | 0.121 | 0.410 |
| កង់ | 0.2641 | 0.665 | 0.446 | 0.713 |
| ម៉ូតូ | 0.3036 | 0.225 | 0.050 | 0.180 |
| រទេះអូសដោយសត្វ | 0.3036 | 0.296 | 0.076 | 0.286 |
| ម៉ាស៊ីនដេរ | 0.1616 | 0.040 | 0.004 | 0.023 |
| ម៉ាស៊ីនភ្លើង | 0.0833 | 0.021 | 0.006 | 0.016 |
| ទូក | -0.0195 | 0.101 | 0.107 | 0.098 |
| នង្គ័ល/រនាស់ | 0.2895 | 0.464 | 0.215 | 0.496 |
| ម៉ាស៊ីនបូមទឹក | 0.0115 | 0.017 | 0.015 | 0.017 |
| ម៉ាស៊ីនបោកស្រូវ | 0.092 | 0.874 | 0.819 | 0.883 |
| ម៉ាស៊ីនកិនស្រូវ | 0.1663 | 0.023 | 0.000 | 0.009 |
| ទឹកហូបបានពីអណ្តូងស្នប់ដៃ | 0.0147 | 0.292 | 0.278 | 0.309 |
| ទឹកហូបបានពីអណ្តូងជីក | 0.0078 | 0.328 | 0.333 | 0.315 |
| ទឹកហូបបានពីស្រះ ឬ ទន្លេ | -0.0538 | 0.255 | 0.294 | 0.243 |
| បង្គន់ | 0.1232 | 0.643 | 0.542 | 0.670 |
| ផ្ទះឈើ | 0.4394 | 0.388 | 0.038 | 0.359 |
| ផ្ទះឬស្សី/ស្លឹក | -0.3969 | 0.397 | 0.745 | 0.335 |
| ដីកសិកម្ម >0 និង <1000m$^2$ | -0.1512 | 0.397 | 0.509 | 0.396 |

| | | | | |
|---|---|---|---|---|
| ដីកសិកម្ម >1000 និង <3000 m² | 0.1819 | 0.258 | 0.119 | 0.278 |
| ដីកសិកម្ម >3000 និង <5000 m² | 0.1071 | 0.034 | 0.006 | 0.031 |
| ដីកសិកម្ម>5000 m² | 0.0972 | 0.023 | 0.006 | 0.015 |
| សន្ទស្សន៍ទ្រព្យសកម្ម | | -0.1711 | -1.769 | -0.150 |

*កំណត់សម្គាល់៖ មានចុះតែការសង្កេតឃើញនៅជនបទប៉ុណ្ណោះ*

*ប្រភព៖ CSES 2004*

ជួរឈរទី១ នៃ តារាង៣ ផ្តល់កត្តាពិន្ទុនៃសមាសភាគគោលទី១ ។ កត្តាពិន្ទុមានតម្លៃវិជ្ជមានសម្រាប់ទ្រព្យជាប់លាប់ទាំងអស់ លើកលែងតែ ការមានទូក ខណៈដែល សម្ភារៈធ្វើផ្ទះដែលមានគុណភាពអន់ ដូចជា ឫស្សី ស្លឹក មានមេគុណអវិជ្ជមាន គឺដូចគ្នានឹង ការមិនសូវទទួលបានទឹកអាចហូបបាន ។ រឿងនេះមានន័យថា សន្ទស្សន៍នីមួយៗរបស់សមាសធាតុវិជ្ជមានឆ្លុះបញ្ចាំងកម្រិតជីវភាពខ្ពស់ ហើយសមាសភាគអវិជ្ជមាន ឆ្លុះបញ្ចាំងនូវកម្រិតជីវភាពទាប ។

ដោយប្រើកត្តាពិន្ទុនៃសមាភាគគោលទី១ និង បន្ទាត់ក្រីក្រគិតតាមសន្ទស្សន៍ទ្រព្យសម្បត្តិដែលគណនាតាម CSES 2004 គេអាចធ្វើការប៉ាន់ស្មាននូវ សន្ទស្សន៍ទ្រព្យសម្បត្តិ និង អត្រាភាពក្រីក្រក្នុង ៩ភូមិ បាន ។ គេឃើញថា អត្រាជនក្រីក្រក្នុងភូមិ និងតំបន់ទាំងអស់ បានធ្លាក់ចុះយ៉ាងគំហុកនៅអំឡុងឆ្នាំ២០០១-០៨ (តារាង៤) ។

**តារាង ៤៖ វត្តមានភាពក្រីក្រ (ភាគរយ)**

| ភូមិ | 2001 | 2004 | 2008 |
|---|---|---|---|
| ទួលក្រសាំង | 57.6 | 17.9 | 19.6 |
| អណ្តូងត្រាច | 62.1 | 36.3 | 20.6 |
| ត្រពាំងប្រី | 54.9 | 40.5 | 12.8 |
| ខ្សាច់ជីរស់ | 76.9 | 63.2 | 45.5 |
| ដងក្តារ | 65.0 | 54.0 | 40.1 |
| កំពង់ត្នោត | 63.2 | 46.1 | 44.9 |
| ព្រៃកក្អែង | 81.3 | 70.9 | 53.8 |
| កញ្ជរ | 58.6 | 38.6 | 24.1 |
| បាបោង | 41.0 | 29.7 | 20.1 |
| សរុប | 63.0 | 45.2 | 33.7 |
| តំបន់ | | | |
| ទន្លេសាប | 66.1 | 39.4 | 29.8 |
| វាលទំនាបទន្លេមេគង្គ | 62.5 | 52.1 | 38.7 |
| តំបន់ខ្ពង់រាប | 60.3 | 44.8 | 28.2 |
| តំបន់ឆ្នេរ | 63.2 | 46.1 | 44.9 |
| សរុប | 63.0 | 45.2 | 33.7 |

*ប្រភព៖ ទិន្នន័យអង្កេតឆ្នាំ២០០១-០៨ របស់ CDRI*

អត្រាភាពក្រីក្រឆ្នាំ២០០៨ មាន ៣៣,៧% ឬ ២៩,៤ឯកតាភាគរយទាបជាងឆ្នាំ២០០១ ដែលបង្ហាញថា អត្រាភាពក្រីក្របានថយចុះ ៣,៧% ក្នុងមួយឆ្នាំ ក្នុងរយៈពេលសិក្សា ។ ក្នុងចំណោមតំបន់ទាំងបួនខុសៗគ្នានេះ តំបន់ទន្លេសាបមានអត្រាជនក្រីក្រខ្ពស់ជាងគេនៅឆ្នាំ២០០១ ប៉ុន្តែ ៨ឆ្នាំក្រោយមក អត្រានេះបានធ្លាក់ចុះដល់តួលេខទាបបំផុតលំដាប់ទីពីរ និងទាបជាងកម្រិតមធ្យម ។

យើងកំណត់អ្នកក្ររ៉ាំរ៉ៃ ជាគ្រួសារដែលមានសន្ទស្សន៍ទ្រព្យសម្បត្តិ ទាបជាងបន្ទាត់ក្រីក្រ ក្នុង ៣ឆ្នាំពេញ និង អ្នកក្រម្តងម្កាល ជាគ្រួសារដែលមានសន្ទស្សន៍ទ្រព្យសម្បត្តិចុះទាបជាងបន្ទាត់ក្រីក្រក្នុងឆ្នាំណាមួយ(នៃឆ្នាំទាំង៣) ហើយ អ្នកមិនដែលក្រ ជាគ្រួសារដែលមានសន្ទស្សន៍ទ្រព្យសម្បត្តិខ្ពស់ជាងបន្ទាត់ក្រីក្រនៅគ្រប់ឆ្នាំ ។ យើងរកឃើញថា គ្រួសារភាគច្រើនជាអ្នកក្រម្តងម្កាល ។ ក្នុងចំណោមអ្នកក្រទាំងអស់ ប្រហែល ៥៧% ជាអ្នកក្រម្តងម្កាល ។ លទ្ធផលនេះគាំទ្រដល់មតិខាងដើមរបស់យើងដែលថា ការដោះស្រាយភាពក្រីក្រនៅជនបទ ត្រូវមានការយល់ដឹងច្បាស់អំពីលក្ខណៈនៃភាពក្រីក្រ ។ អ្នកក្រីក្រម្តងម្កាលមានច្រើនបំផុតនៅតំបន់ទន្លេសាប និងខ្ពង់រាប ហើយអ្នកក្ររ៉ាំរ៉ៃ មានច្រើនបំផុតនៅតំបន់ឆ្នេរ ។

តារាង ៩៖ ស្ថានភាពក្រីក្ររបស់គ្រួសារ បែងចែកតាមភូមិ និង តំបន់(%)

| ភូមិ | ក្ររ៉ាំរ៉ៃ | ក្រម្តងម្កាល | មិនដែលក្រ | សរុប |
|---|---|---|---|---|
| ទួលក្រសាំង | 11.6 | 50.0 | 38.4 | 100 |
| អណ្តូងត្រាច | 18.0 | 50.8 | 31.2 | 100 |
| ត្រពាំងប្រី | 15.7 | 52.9 | 31.4 | 100 |
| ខ្សាច់ជីរស់ | 44.8 | 36.8 | 18.4 | 100 |
| ដងក្តារ | 36.5 | 42.1 | 21.5 | 100 |
| កំពង់ត្នោត | 42.2 | 33.9 | 23.9 | 100 |
| ព្រែកក្មេង | 49.1 | 33.6 | 17.3 | 100 |
| កញ្ជរ | 23.6 | 39.6 | 36.8 | 100 |
| បាបោង | 15.5 | 36.4 | 48.2 | 100 |
| សរុប | 30.1 | 40.4 | 29.5 | 100 |
| តំបន់ | | | | |
| ទន្លេសាប | 25.6 | 45.3 | 29.1 | 100 |
| វាលទំនាបទន្លេមេគង្គ | 32.3 | 35.0 | 32.7 | 100 |
| តំបន់ខ្ពង់រាប | 27.3 | 43.2 | 29.6 | 100 |
| តំបន់ឆ្នេរ | 42.2 | 33.9 | 23.9 | 100 |
| សរុប | 30.1 | 40.4 | 29.5 | 100 |

*ប្រភព៖ ទិន្នន័យអង្កេតឆ្នាំ២០០១-០៨ របស់ CDRI*

តារាង ៦ ផ្តល់ស្ថិតិពិពណ៌នាលើគ្រួសារ និងលក្ខណៈភូមិសាស្ត្រ ក្នុងរយៈពេលដំបូង ។ គ្រួសារក្រុំរ៉ៃ ច្រើនតែជាគ្រួសារ មាន ទំហំតូច អត្រាមនុស្សក្នុងបន្ទុកទាប ចំនួនមនុស្សពេញវ័យប្រុស-ស្រីក្នុងអាយុពី១៥ ដល់ ៦៤ឆ្នាំ តិចជាង គ្រួសារក្រមួយគ្រាៗ និងមិនដែលក្រ ។ មេគ្រួនៃគ្រួសារក្រុំរ៉ៃ ច្រើនតែ ជាស្ត្រី គ្មានប្តី មានអាយុតិច និងមានការអប់រំតិចជាង គ្រួសារក្រមួយគ្រាៗ និងមិនដែលក្រ ។ គ្រួសារមិនដែលក្រ មានកូនអាយុ ០-៧ឆ្នាំ ចំនួនតិចជាងគ្រួសារក្រុំរ៉ៃ និងក្រមួយគ្រាៗ ។ ម្យ៉ាងទៀត គ្រួសារក្រុំរ៉ៃ មានដីដាំដុះ ទ្រព្យសម្បត្តិមិនមែនដី និង សត្វចិញ្ចឹមតិចជាងគេ ហើយគ្រួសារមិនដែលក្រ មានទ្រព្យសម្បត្តិទាំងនេះច្រើនជាងគេ ។ ដីដាំដុះ ទ្រព្យសម្បត្តិមិនមែនដី និងសត្វចិញ្ចឹម មានតិច អ្នកធ្វើការបុរស-ស្ត្រី មានតិច មេគ្រួសារជាស្ត្រី មានវ័យក្មេង មានការអប់រំទាប និងគ្មានប្តី អាចជាកត្តាដ៏សំខាន់នៃភាពក្រីក្រុំរ៉ៃ ។

តារាង ៦៖ ប្រជាសាស្ត្រ និងស្ថានភាពក្រីក្រនៃគ្រួសារ

| | ក្រុំរ៉ៃ | ក្រមួយគ្រាៗ | មិនដែលក្រ | សរុប |
|---|---|---|---|---|
| សមាជិកគ្រួសារ | 5.4 | 5.9 | 6.3 | 5.9 |
| កុមារអាយុ ០-៦ឆ្នាំ | 1.1 | 1.1 | 0.9 | 1.0 |
| កុមារអាយុ ៧-១៤ឆ្នាំ | 1.4 | 1.5 | 1.5 | 1.4 |
| មនុស្សពេញវ័យអាយុលើស ៦៤ឆ្នាំ | 0.2 | 0.2 | 0.3 | 0.2 |
| បុរសពេញវ័យអាយុ ១៥-៦៤ឆ្នាំ | 1.2 | 1.5 | 1.8 | 1.5 |
| នារីពេញវ័យអាយុ ១៥-៦៤ឆ្នាំ | 1.6 | 1.6 | 1.8 | 1.7 |
| មេគ្រួសារជាបុរស | 0.7 | 0.8 | 0.9 | 0.8 |
| អាយុមេគ្រួសារ | 42.4 | 42.5 | 45.9 | 43.4 |
| ការអប់រំរបស់មេគ្រួសារ (ឆ្នាំ) | 2.5 | 3.5 | 3.8 | 3.3 |
| មេគ្រួសារដែលរៀបការ | 0.8 | 0.9 | 0.9 | 0.8 |
| ដីដាំដុះក្នុងមួយនាក់ (ហិកតា) | 0.1 | 0.2 | 0.4 | 0.2 |
| ទ្រព្យមិនមែនដីក្នុងមួយនាក់(ម៉ឺនរៀល) | 3.8 | 11.4 | 23.8 | 12.8 |
| សត្វចិញ្ចឹមក្នុងមួយនាក់(ម៉ឺនរៀល) | 10.5 | 16.9 | 24.6 | 17.2 |
| ស្ថានភាពការងាររបស់មេគ្រួសារ (%) | | | | |
| ផ្សេងៗ | 19.3 | 22.8 | 32.8 | 24.7 |
| ពលករយកប្រាក់កម្រៃក្នុងភូមិ | 9.2 | 6.0 | 2.5 | 5.9 |
| ពលករប្រកបមុខរបរដោយខ្លួនឯង | 57.0 | 57.5 | 48.0 | 54.5 |
| ពលករយកប្រាក់កម្រៃនៅក្រៅភូមិ | 14.5 | 13.8 | 16.8 | 14.9 |
| សរុប | 100 | 100 | 100 | 100 |

*ប្រភព៖ ទិន្នន័យអង្កេតឆ្នាំ២០០១-០៨ របស់ CDRI*

## ៤. លទ្ធផលខាងសេដ្ឋកិច្ចមាត្រសាស្ត្រ

យើងប្រើ Multinomial logit model ដើម្បីពិនិត្យពីកត្តានានាដែលធ្វើឲ្យគ្រួសារនីមួយៗធ្លាក់ចូលក្នុងប្រភេទក្រីក្រ ។ អថេរសម្រាប់ជួយពន្យល់ រួមមាន មូលធនមនុស្ស ដី និង ទ្រព្យរូបវ័ន្ត និង ភូមិសាស្ត្រ ។ អថេរមូលធនមនុស្ស រួមមាន ភាពពឹងផ្អែក ចំនួនបុរស-នារីពេញវ័យអាយុ១៥-៦៤ឆ្នាំ អាយុមេគ្រួសារ និងការអប់រំ ភេទ សកម្មភាពសេដ្ឋកិច្ចចំបង និងស្ថានភាពមានប្តី/ប្រពន្ធរបស់គាត់ ។ យើងគិតបញ្ចូលដែរនូវ ដីកសិកម្ម ទ្រព្យជាប់លាប់ និង សត្វចិញ្ចឹមរបស់គ្រួសារ ព្រមទាំងខ្នាតមួយចំនួនទៀត ដែលតំណាងឲ្យតំបន់មានអាកាសធាតុអំណោយផលដល់កសិកម្មខុសគ្នាធំៗទាំងបួននេះ ។

យើងកំណត់តម្លៃ ១ សម្រាប់គ្រួសារក្រពុំរ៉ែ ២ សម្រាប់ក្រមួយគ្រាៗ និង ៣ សម្រាប់មិនដែលក្រ ។

តារាង ៧៖ ការប៉ាន់ស្មានដោយប្រើ Multinimial Logit លើកត្តាកំណត់ភាពក្រីក្រពុំរ៉ែ និង មួយគ្រាៗ

| | ផលប៉ះពាល់បន្ទាប់បន្សំ | | |
|---|---|---|---|
| | ក្រពុំរ៉ែ | ក្រមួយគ្រាៗ | មិនដែលក្រ |
| ភាពពឹងផ្អែក | -0.008 | -0.009 | 0.0173** |
| បុរសពេញវ័យអាយុ១៥-៦៤ឆ្នាំ | -0.044** | -0.002 | 0.046*** |
| នារីពេញវ័យអាយុ ១៥-៦៤ឆ្នាំ | -0.025 | -0.005 | 0.031** |
| អាយុមេគ្រួសារ | -0.001 | -0.004 | 0.006 |
| អាយុមេគ្រួសារលើកជាការ៉េ | 0.00001 | 0.00002 | -0.00004 |
| ការអប់រំរបស់មេគ្រួសារ | -0.019*** | 0.017*** | 0.002 |
| មេគ្រួសារជាបុរស | -0.002 | 0.098 | -0.096* |
| មេគ្រួសារដែលរៀបការ | -0.057 | -0.069 | 0.127** |
| មេគ្រួសារជាពលករយកប្រាក់កម្រៃក្នុងភូមិ | 0.243*** | 0.031 | -0.275*** |
| មេគ្រួសារប្រកបមុខរបរដោយខ្លួនឯង | 0.080* | -0.014 | -0.066* |
| មេគ្រួសារជាពលករយកប្រាក់កម្រៃនៅក្រៅភូមិ | 0.0242 | -0.052 | 0.027 |
| ដីកសិកម្ម (លោការីត) | -0.020*** | 0.0019 | 0.018*** |
| ទ្រព្យមិនមែនដី (លោការីត) | -0.048*** | -0.071*** | 0.119*** |
| សត្វចិញ្ចឹម (លោការីត) | -0.007** | 0.005 | 0.001 |
| តំបន់ទន្លេសាប | -0.178*** | 0.097* | 0.081* |
| តំបន់ទំនាបទន្លេមេគង្គ | -0.001 | 0.044 | -0.042 |
| តំបន់ខ្ពង់រាប | -0.175*** | 0.095* | 0.079* |
| ចំនួនការសង្កេត | 827 | | |
| LR chi2 | 389.63 | | |
| Prob>chi2 | 0.0000 | | |
| Log-likelihood | -704.732 | | |
| Pseudo R- Squared | 0.2166 | | |

*កំណត់សម្គាល់៖ *សារៈសំខាន់ខាងស្ថិតិនៅកម្រិត ១០% - ** សារៈសំខាន់ខាងស្ថិតិនៅកម្រិត ៥% - *** សារៈសំខាន់ខាងស្ថិតិនៅកម្រិត ១% ។ ប្រភព៖ ទិន្នន័យអង្កេតឆ្នាំ២០០១-០៨ របស់ CDRI*

តារាង៧ បង្ហាញថា កំណើនចំនួនបុរសអាយុ ១៥-៦៤ឆ្នាំ មានទំនាក់ទំនងអវិជ្ជមាន ជាមួយភាពក្រីក្ររ៉ាំរ៉ៃ និងមានទំនាក់ទំនងវិជ្ជមាន ជាមួយភាពមិនដែលក្រសោះ ។ កម្រិតអប់រំខ្ពស់នៃមេគ្រួសារកាត់បន្ថយលទ្ធភាពក្រីក្ររ៉ាំរ៉ៃរបស់គ្រួសារ ។ មេគ្រួសារជាអ្នកប្រកបមុខរបរខ្លួនឯង ឬជាពលករយកប្រាក់កម្រៃក្នុងភូមិ ច្រើនតែជាគ្រួសារដែលក្រីក្ររ៉ាំរ៉ៃ និង មិនសូវជាអ្នកមិនដែលក្រនោះទេ ។ លទ្ធផលនេះបញ្ជាក់ថា សកម្មភាពសេដ្ឋកិច្ចក្នុងភូមិ ភាគច្រើនមិនសូវមានសន្តិសុខ និងទទួលបានចំណូលតិច ។ ដីកសិកម្ម ទ្រព្យសម្បត្តិមិនមែនដី និងសត្វចិញ្ចឹមកាន់តែច្រើន ជួយកាត់បន្ថយលទ្ធភាពចុះក្រីក្ររ៉ាំរ៉ៃ ។ សត្វចិញ្ចឹម មិនសូវមានទំនាក់ទំនងជាមួយនឹង ភាពក្រីក្រមួយគ្រាៗ និង មិនដែលក្រទេ ។ ទ្រព្យសម្បត្តិមិនមែនដី ជាកត្តាសំខាន់បំផុត សម្រាប់កាត់បន្ថយលទ្ធភាពចុះក្រមួយគ្រាៗ ។ គ្រួសារមានបុរសជាមេគ្រួ មិនសូវក្លាយជាគ្រួសារមិនដែលក្រទេ ឯគ្រួសារដែលមេគ្រួមានគូស្រកច្រើនតែជាគ្រួសារមិនដែលក្រ ។

## ៥. សេចក្តីសន្និដ្ឋាន

លទ្ធផលរកឃើញជាក់ស្តែងរបស់យើងបង្ហាញថា កត្តាកំណត់ភាពក្រីក្ររ៉ាំរ៉ៃ វាខុសគ្នាពីភាពក្រីក្រមួយគ្រាៗ ។ ឧទាហរណ៍ ចំនួនបុរសក្នុងអាយុ ១៥-៦៤ឆ្នាំ លក្ខណៈមេគ្រួសារ (ឧ. កម្រិតអប់រំ មុខរបរ) ដីកសិកម្ម និងសត្វចិញ្ចឹម ជាកត្តាសំខាន់សម្រាប់ភាពក្រីរ៉ាំរ៉ៃ ប៉ុន្តែមិនមែនជាកត្តាសំខាន់សម្រាប់ភាពក្រីក្រមួយគ្រាៗឡើយ ។ មានតែទ្រព្យសម្បត្តិមិនមែនដីទេ ដែលមានទំនាក់ទំនងជាមួយការថយចុះ ភាពក្រីក្ររ៉ាំរ៉ៃ និង មួយគ្រាៗ ។ តំបន់បឹងទន្លេសាប និងខ្ពង់រាប មានភាពក្រីក្ររ៉ាំរ៉ៃតិចជាង និងភាពក្រីក្រមួយគ្រាៗច្រើនជាងតំបន់ឆ្នេរ ។ លទ្ធផលជាទូទៅនៃសិក្សានេះបញ្ជាក់ថា ត្រូវមានគោលនយោបាយផ្សេងគ្នា សម្រាប់ដោះស្រាយភាពក្រីក្រទាំងពីរប្រភេទនៅក្នុងតំបន់ទាំង៤ នេះ ។

ការសិក្សាបានកត់សម្គាល់ថា ទ្រព្យសម្បត្តិមិនមែនដី ដើរតួយ៉ាងសំខាន់ក្នុងការកាត់បន្ថយភាពក្រីក្រមួយគ្រាៗ ។ ទន្ទឹមនឹងនេះ ការសិក្សាក៏បានសម្គាល់ឃើញនូវកង្វះខាតឥណទាន កង្វះការធានារ៉ាប់រងជាផ្លូវការ និងកម្មវិធីការពារសង្គមកិច្ច ដែលនាំឲ្យគ្រួសារនៅជនបទត្រូវពឹងផ្អែកលើយន្តការក្រៅផ្លូវការផ្សេងៗដើម្បីទប់ទល់ហានិភ័យ (ឧ. ការបង្ករទុកទ្រព្យរូបវន្ត) ។ ប៉ុន្តែនៅពេលមានការប៉ះទង្គិចធ្ងន់ធ្ងរ និងជាទូទៅលើប្រាក់ចំណូល ដូចជាវិបត្តិសេដ្ឋកិច្ច និងហិរញ្ញវត្ថុសាកលនាពេលថ្មីៗ ទ្រព្យសម្បត្តិដែលបានបង្ករទុកក៏បានធ្លាក់ថ្លៃយ៉ាងខ្លាំង ពីព្រោះគ្រប់គ្នាព្យាយាមលក់ទ្រព្យសម្បត្តិស្រដៀងៗគ្នាក្នុងពេលតែមួយ បន្ទាប់ពីមានការប៉ះទង្គិចប្រាក់ចំណូល(Fafchamps & Gavian 1997) ។ ជាលទ្ធផល អ្នកខ្លះក៏រារែក ឬក៏មិនអាចលក់ទ្រព្យសម្បត្តិរបស់ខ្លួន ហើយក៏ធ្លាក់ខ្លួនក្រ ។ រឿងនេះបង្ហាញច្បាស់ថា ការធានារ៉ាប់រង កម្មវិធីការពារខាងសង្គមកិច្ច និង យន្តការផ្សេងទៀតសម្រាប់ការពារក្រុមជនងាយរងគ្រោះទាំងនោះ ជាគោលនយោបាយដ៏សំខាន់បំផុត ។ ការសិក្សាក៏បង្ហាញច្បាស់ថា ការបង្កើនមូលធនមនុស្ស និងទ្រព្យរូបវន្តរបស់គ្រួសារ គឺជាគោលនយោបាយសមស្របជាង ដើម្បីដោះស្រាយភាពក្រីក្ររ៉ាំរ៉ៃ ។

ឧបសម្ព័ន្ធ១៖ លក្ខណៈសំខាន់ៗនៃតួមិធ្វើអង្កេត (MOPS)

| ភូមិ | ស្រុក | ខេត្ត | លក្ខណៈវិនិច្ឆ័យមូលដ្ឋាននៃការជ្រើសរើស |
|---|---|---|---|
| វាលទំនាបបឹងទន្លេសាប | | | |
| អណ្ដូងត្រាច | សង្កែ | បាត់ដំបង | ស្រូវវស្សាយ៉ាងច្រើនដាំនៅតំបន់លិចទឹកបឹងទន្លេសាប, ចំណាកស្រុកចេញកម្រិតខ្ពស់ |
| ក្រសាំង | ថ្មគោល | បាត់ដំបង | ស្រូវវស្សាយ៉ាងច្រើនដាំនៅតំបន់លិចទឹកបឹងទន្លេសាប មានជនមាតុភូមិនិវត្តន៍មកពីជំរុំតាមព្រំដែនមករស់នៅច្រើន |
| ខ្សាច់ជីរស់ | កំពង់ស្វាយ | កំពង់ធំ | ស្រូវឡើងទឹក បូកនឹង ការនេសាទយ៉ាងច្រើនក្នុងតំបន់លិចទឹកបឹងទន្លេសាប |
| វាលទំនាបទន្លេមេគង្គ | | | |
| ព្រៃកន្ទេង | ល្វាឯម | កណ្ដាល | ស្រូវប្រាំង និង ការនេសាទយ៉ាងច្រើន |
| បាបោង | ពាមរ | ព្រៃវែង | ស្រូវប្រាំងមានដាំយ៉ាងច្រើន |
| តំបន់ខ្ពង់រាប/ភ្នំ | | | |
| កញ្ជរ | ឆ្លូង | ក្រចេះ | ស្រូវប្រាំង និងការពឹងផ្អែកច្រើនលើព្រៃឈើ |
| ដងក្ដារ | សន្ទុក | កំពង់ធំ | ទិន្នផលស្រូវវស្សាទាប និងពឹងផ្អែកច្រើនលើព្រៃឈើ |
| ត្រពាំងប្រី | ឧត្ដុង | កំពង់ស្ពឺ | ទិន្នផលស្រូវវស្សាទាប និងពឹងផ្អែកលើការលក់កម្លាំងពលកម្មឲ្យគេ |
| តំបន់ឆ្នេរ | | | |
| កំពង់ត្នោត | កំពត | កំពត | ទិន្នផលស្រូវវស្សាទាប ការនេសាទតាមឆ្នេរ និងស្រែអំបិល |

*ប្រភព៖ Chan and Acharya (2002)*

# ឯកសារយោង


Albert, Jose Ramon (2009a), "Poverty Dynamics Study 2008: Technical Report on Constructing Wealth Index and Recommendation for Future Studies", mimeo (Phnom Penh: World Bank)

Albert, Jose Ramon (2009b), "Poverty Dynamics Study 2008, Report I: Evaluation Report and Recommendations", mimeo (Phnom Penh: World Bank)

Albert, Jose Ramon (2009c), "Poverty Dynamics Study 2008, Report II: Technical Report on Methodology for Poverty Lines", mimeo (Phnom Penh: World Bank)

Baulch, R. & J. Hoddinott (2000), "Economic Mobility and Poverty Dynamics in Developing Countries", Journal of Development Studies, Vol.36(6), pp.1-24

Booysen, Frikkie, Servaas Van Der Berg, Ronelle Burger, Michael Von Maltitz & Gideon Du Rand (2008), "Using an Asset Index to Assess Trends in Poverty in Seven Sub-Saharan African Countries", World Development, 36(6), pp. 1113-1130

Chan Sophal & Acharya Sarthi (2002), *Facing the Challenges of Rural Livelihoods: A Perspective from Nine Villages in Cambodia*, Working Paper 25 (Phnom Penh: CDRI)

Fafchamps, M. & S. Gavian (1997), "The determinants of livestock prices in Niger", *Journal of African Economies*, 6, pp. 255-295

Filmer, Deon & Lant Pritchett (1998), *Estimating wealth effect without expenditure data-or tears: An application to educational enrollments in states of India*, World Bank Policy Research Working Paper No. 1994 (Washington, DC: World Bank)

Fitzgerald, Ingrid & So Sovannarith (2007), *Moving Out of Poverty: Trends in Community Well-Being and Household Mobility in Nine Cambodian Villages* (Phnom Penh: CDRI)

Haddad, Lawrence & Akhter Ahmed (2003), "Chronic and Transitory Poverty: Evidence from Egypt 1997-1999", *World Development,* Vol. 31, No. 1, pp. 71-85

Hotelling, H. (1933), "Analysis of a complex of statistical variables into principal components", *Journal of Educational Psychology*, 24(7), pp. 498-520

Jalan, Jyotsna & Martin Ravallion (2000), "Determinants of Transient and Chronic Poverty: Evidence for Rural China", *Journal of Development Studies*, 36(6), pp. 82-99

Kedir, Abbi M. & Andrew Mckay (2003), "Chronic Poverty in Urban Ethiopia: Panel Data Evidence", paper prepared for international conference on Staying Poor: Chronic Poverty and Development, hosted by Institute for Development Policy and Management, University of Manchester, UK, 7-9 April

Kolenikov, Stanislav & Gustavo Angeles (2004), *The Use of Discrete Data in Principal Component Analysis: Theory, Stimulations, and Applications to Socioeconomic Indices*, Working Paper of MEASURE/Evaluation project, No.WP-04-85 (Raleigh: Carolina Population Center, University of North Carolina)

Krishna, Anirudh (2009), "Subjective Assessments, Participatory Methods, and Poverty Dynamics", in Tony Addison, David Hulme & Ravi Kanbur (eds.), *Poverty Dynamics: Interdisciplinary Perspectives* (Oxford: Oxford University Press) pp. 183-201

McKenzie, David (2004), "Measuring Inequality with Asset Indicators", *Journal of Population Economics*, 18(2), pp. 1432-1475

Moser, Caroline & Andrew Felton (2009), "The Construction of an Asset Index: Measuring Asset Accumulation in Ecuador", in Tony Addison, David Hulme & Ravi Kanbur (eds.), *Poverty Dynamics: Interdisciplinary Perspectives* (Oxford: Oxford University Press) pp. 102-127

Olsson, Ulf (1979), "Maximum Likelihood Estimation of the Polychoric Correlation", *Psychometrika*, 44(4), pp. 443-460

Pearson, Karl (1901), "On lines and planes of closest fit to systems of points in space", *Philosophical Magazine*, 2, pp. 559-572

Pearson, Karl & Egon Pearson (1922), "On Polychoric Coefficients of Correlation", *Biometrika*, 14(1-2), pp. 127-156

Tong Kimsun, Saing Chan Hang & Hem Socheth (2009), "Trends in Living Standards of 90 Rural Households in Poverty Dynamics Study Villages", mimeo (Phnom Penh: CDRI)

Sahn, David & David Stifel (2003), "Exploring Alternative Measures of Welfare in the Absence of Expenditure Data", *Review of Income and Wealth*, 49(4), pp. 463-489

World Bank (2009), *Poverty Profile and Trend in Cambodia: Findings from the 2007 Cambodia Socio-Economic Survey (CSES)*, East Asia and Pacific Region (Washington, DC: World Bank)

World Bank (2010), *Global Economic Prospects: Crisis, Finance and Growth* (Washington, DC: World Bank)

# -VII-
# សិទ្ធិកាន់កាប់ដីធ្លី និងផលិតភាពស្រូវៈ ភស្តុតាងពីទីជនបទកម្ពុជា

*ដោយលោក តុង គឹមស៊ុន*[១]


**សេចក្តីសង្ខេប**

អត្ថបទនេះ ពិនិត្យពីទំនាក់ទំនងរវាងសិទ្ធិកាន់កាប់ដីធ្លី និងផលិតភាពស្រូវ ។ ផ្អែកតាមភស្តុតាងជាក់ស្តែងទទួលបានពី អង្កេតសេដ្ឋកិច្ច-សង្គមកិច្ចកម្ពុជាឆ្នាំ២០០៧ អត្ថបទនេះរកឃើញថា ឯកសារកម្មសិទ្ធិដីធ្លី ដូចជា សិទ្ធិសុំកម្មសិទ្ធិដីធ្លី លិខិតត្រួតពិនិត្យដីធ្លី លិខិតបញ្ជាក់កម្មសិទ្ធិ និងលិខិតអាជ្ញាធរដែនដី ធ្វើឲ្យផលិតភាពកើនឡើង ។ អត្ថបទនេះរកឃើញថា ឯកសារកម្មសិទ្ធិដីធ្លីជួយបង្កើនផលិតកម្មស្រូវ ប្រហែល ២០% ប៉ុន្តែវាទាបជាងតួលេខបានពីការសិក្សាដោយ Markussen (2008) ប្រហែល ១០ ឯកតាភាគរយ និងទាបជាងតួលេខបានពីការសិក្សាដោយធនាគារពិភពលោក (2006) ប្រហែល ៤៥ ឯកតាភាគរយ ដែលការសិក្សាទាំងនោះ សុទ្ធសឹងព្យាយាមវាយតម្លៃពីផលប៉ះពាល់នៃសិទ្ធិកាន់កាប់ដីធ្លី ទៅលើផលិតភាពកសិកម្ម ។ ការពង្រឹងសិទ្ធិលើទ្រព្យដីធ្លី មានសារៈសំខាន់ណាស់សម្រាប់សេដ្ឋកិច្ចនៅជនបទកម្ពុជា ។


## ១. សេចក្តីផ្តើម

ទោះបីអត្ថប្រយោជន៍នៃសិទ្ធិកាន់កាប់ដី មានការទទួលស្គាល់ទូលំទូលាយ និងមានបញ្ជាក់យ៉ាងច្រើននៅក្នុងឯកសារដែលមានស្រាប់ក្តី ក៏សិទ្ធិកាន់កាប់ដីធ្លីភាគច្រើនមិនទាន់មានសុវត្ថិភាពទេនៅកម្ពុជា ។ កន្លងមក ទំនាស់ដីធ្លីបានកើនឡើងលើសពី ២០% ក្នុងមួយឆ្នាំ ។ តាមទ្រឹស្តី សិទ្ធិលើទ្រព្យដីធ្លី មានសក្តានុពលជួយបង្កើនវិនិយោគ និងផលិតភាព (Besley 1995) ។ សិទ្ធិលើទ្រព្យដីធ្លីអាចមានសារៈសំខាន់សម្រាប់កម្ពុជា ជាពិសេសចំពោះដំណាំស្រូវដែលជាដំណាំសំខាន់ជាងគេក្នុងប្រទេស ហើយមានទិន្នផលទាបក្នុងចំណោមប្រទេសនៅអាស៊ីបូព៌ា អាស៊ីអាគ្នេយ៍ និងអាស៊ីខាងត្បូង (FAO 2010) ។

រាជរដ្ឋាភិបាលកម្ពុជា (RGC) បានអនុម័តកំណែទម្រង់ដី ដែលជាគោលនយោបាយដីធ្លីមួយកំណត់យកការងាររដ្ឋបាល (បញ្ជាក់បំភ្លឺ និងកត់ត្រាកម្មសិទ្ធិ និងសិទ្ធិផ្សេងៗ) ការគ្រប់គ្រង (ធានាឲ្យមានការគ្រប់គ្រងដីធ្លី និងធនធានធម្មជាតិប្រកបដោយប្រសិទ្ធភាពខ្ពស់) និងការបែងចែក (បែងចែកដីរដ្ឋសម្រាប់ការងារសាធារណៈ និងឯកជន ប្រកបដោយតម្លាភាព វិមជ្ឈការ និងត្រឹមត្រូវ) (RGC 2009) ជាគោលនយោបាយស្នូលក្នុងការពង្រឹងវិស័យកសិកម្ម ។ អាទិភាពចំបង គឺត្រូវពង្រឹងសុវត្ថិភាពកាន់កាប់ដីធ្លី តាមរយៈការចុះបញ្ជីដីធ្លី ជាពិសេសសម្រាប់កសិករ ។ រាជរដ្ឋាភិបាលកម្ពុជា (2009) បានកត់ត្រាថា ប័ណ្ណកម្មសិទ្ធិដីធ្លី ១,៦៦លានប័ណ្ណ បានចេញឲ្យប្រជាជនរួចហើយដែលស្មើនឹង ២៤% ទៅ ២៨% នៃក្បាលដីសរុប (៦ ទៅ ៧ លានក្បាលដី) ។ នៅក្នុងគោលដៅអភិវឌ្ឍន៍សហសវត្សរ៍ រដ្ឋាភិបាលបានកំណត់គោលដៅចេញប័ណ្ណកម្មសិទ្ធិដីធ្លី ឲ្យបាន ៣២% នៃចំនួនក្បាលដីសរុបនៅឆ្នាំ២០១០ និង ៦៥% នៅឆ្នាំ២០១៥ ។ ដោយមានជំនួយហិរញ្ញវត្ថុពីធនាគារ

---

១ លោក តុង គឹមស៊ុន ជាអ្នកស្រាវជ្រាវ នៅវិទ្យាស្ថាន CDRI ។ អ្នកនិពន្ធសូមអរគុណ បណ្ឌិត Jalilian Hossein និងអ្នកកែសម្រួលឯកសារពីផ្នែកខាងក្រៅវិទ្យាស្ថាន ចំពោះការជួយមតិលើអត្ថបទព្រាង ។

ពិភពលោក រដ្ឋាភិបាលបានចេញប័ណ្ណកម្មសិទ្ធិដី បានជាង ១លានប័ណ្ណ (ភាគច្រើននៅទីជនបទ) តាមរយៈគម្រោងរៀបចំដែនដី និងរដ្ឋបាលដីធ្លី (LMAP) នៅក្នុង ១៧៥ ឃុំ និង ១១ ខេត្តក្រុង ចាប់តាំងពីឆ្នាំ២០០២ មក ហើយមានខេត្ត ៣ ទៀត កំពុងដំណើរការក្រោមជំនួយពីទីភ្នាក់ងារអភិវឌ្ឍន៍អន្តរជាតិនៃប្រទេសកាណាដា (CIDA) (WB 2009) ។ ប៉ុន្តែកម្មវិធីចុះបញ្ជីដីធ្លី បានបញ្ចប់នៅខែកញ្ញា ២០០៩ ដោយសារ ធនាគារពិភពលោក និងរដ្ឋាភិបាល មិនអាចព្រមព្រៀងគ្នាទាក់ទងនឹងតំបន់ទីក្រុងមានទំនាស់មួយចំនួន (The Cambodia Daily, 7 September 2009, p. 1)[២] ។

ការសិក្សាពីសិទ្ធិកាន់កាប់ដីធ្លី និងឥទ្ធិពលទៅលើផលិតភាពកសិកម្មនៅកម្ពុជា មិនមែនជាការសិក្សាថ្មីទេ ហើយការសិក្សាស្តីអំពីឥទ្ធិពលនៃឯកសារបញ្ជាក់កម្មសិទ្ធិដី ទៅលើផលិតកម្មស្រូវដែលមានចំណែកធំជាងគេក្នុងដំណាំកសិកម្ម នៅមិនទាន់មានគ្រប់គ្រាន់ដែរ ។ អត្ថបទនេះ ព្យាយាមស្រាយបំភ្លឺថា តើសិទ្ធិកាន់កាប់ដីធ្លី មានឥទ្ធិពលវិជ្ជមាន និងច្រើនប៉ុណ្ណា ទៅលើផលិតភាពស្រូវ ។

## ២. ការសិក្សាលើឯកសារពាក់ព័ន្ធ

មានការសិក្សាមួយចំនួនតូចប៉ុណ្ណោះ ដែលបានធ្វើឡើង ស្តីពីផលប៉ះពាល់នៃសិទ្ធិកាន់កាប់ដីធ្លី ទៅលើផលិតភាពកសិកម្មនៅជនបទកម្ពុជា ក្នុងនោះមានអត្ថបទរបស់ Deininger (2005) ដែលមានចុះក្នុង World Bank (2006) និងអត្ថបទមួយទៀតដោយ Markussen (2008) ។ ដោយផ្អែកលើអង្កេតសេដ្ឋកិច្ច-សង្គមកិច្ចកម្ពុជា ឆ្នាំ២០០៣/០៤ Deininger (2005) និង Markussen (2008) រកឃើញថា សិទ្ធិកាន់កាប់ដីធ្លីប្រកបដោយសុវត្ថិភាព បានបង្កើនផលិតភាពកសិកម្ម ៦៥% និង ៣០-៣៥% ។ Deininger (2005) បង្ហាញទៀតថា សិទ្ធិកាន់កាប់ដីធ្លីបង្កើនថ្លៃជួលដី ៥៧% តម្លៃដីធ្លី ៣៨% និងចំណាយប្រើប្រាស់ក្នុងគ្រួសារ ២៤% រីឯ Markussen (2008) លើកថា សិទ្ធិលើទ្រព្យសម្បត្តិ មានឥទ្ធិពលតិចទៅលើលទ្ធភាពទទួលបានឥណទាន និងនាំឲ្យមានការថយចុះធនធានទ្រព្យរួម ។

ការសិក្សាពីប្រទេសដទៃទៀត បានផ្តល់លទ្ធផលផ្សេងៗគ្នា ។ ការសិក្សាខ្លះរកឃើញឥទ្ធិពលវិជ្ជមាន ជាអាទិ៍ Feder and Onchan (1987) រកឃើញឥទ្ធិពលវិជ្ជមាននៃប័ណ្ណកម្មសិទ្ធិដីទៅលើវិនិយោគកសិកម្ម និងកម្រិតប្រើប្រាស់មូលធនសង្គម នៅ ២ខេត្ត ក្នុងចំណោម ៣ខេត្តនៅប្រទេសថៃ ។ SMERU (2002) បានសង្កេតឃើញថា ការចុះបញ្ជីដីធ្លីនៅឥណ្ឌូនេស៊ី បានបង្កើនវិនិយោគ ការប្រើឥណទានមានវត្ថុបញ្ចាំ និងតម្លៃដីធ្លី ។ Do and Iyer (2006) ផ្តល់មតិថា ការចុះបញ្ជីដីធ្លី នៅវៀតណាម នាំឲ្យមានកំណើនពិពិធកម្មមុខដំណាំទៅដាំដំណាំឲ្យផលច្រើនឆ្នាំ និងមានពេលចំណាយច្រើនជាងមុនលើសកម្មភាពមិនមែនកសិកម្ម ។ Deininger and Jin (2003) រកឃើញថា ការកែលំអច្បាប់ផ្ទេរសិទ្ធិដីធ្លី នៅវៀតណាម នាំឲ្យមានកំណើនសកម្មភាពជួល និងលក់ដីធ្លី ហើយក្នុងប្រតិបត្តិការទាំងនេះ គេមាននិន្នាការផ្ទេរដីទៅឲ្យកសិករដែលមានសមត្ថភាពខ្ពស់ ប៉ុន្តែកាន់កាប់ដីតូច ។ Deininger and Jin (2002) បង្ហាញថា សិទ្ធិទ្រព្យសម្បត្តិដីធ្លីកាន់តែមានសុវត្ថិភាព នៅចិន បានបង្កើនវិនិយោគ ដោយមិនធ្វើឲ្យគ្រួសារនានាទទួលរងការប៉ះទង្គិចផ្សេងៗ

---

២ ក្រុមអ្នកអង្កេតរបស់ធនាគារពិភពលោក បានចាប់ផ្តើមស៊ើបអង្កេតក្នុងគម្រោងរៀបចំដែនដី និងរដ្ឋបាលដីធ្លីដែលទទួលហិរញ្ញប្បទានពីធនាគារនេះ បន្ទាប់ពីមានបណ្តឹងមួយដែលទទួលបានការគាំទ្រពី អង្គការស្ពានទៅកាន់សន្តិភាពកម្ពុជា (BABC) និងស្នើឡើងដោយ មជ្ឈមណ្ឌលស្តីពីការបង្ខំឲ្យចាកចេញពីលំនៅដ្ឋាន និងសិទ្ធិតាំងទីលំនៅ (COHRE) ដែលតំណាងឲ្យជាង ៤០០០ គ្រួសាររស់នៅជុំវិញបឹងកក់ ដែលបានរងគ្រោះ ឬស្ថិតក្រោមការគម្រាមកំហែងបណ្តេញចេញពីទីលំនៅ ។ LMAP មានគោលដៅជួយកែលំអសុវត្ថិភាពកាន់កាប់ដីធ្លី និងកាត់បន្ថយទំនាស់ដីធ្លី តាមរយៈការចុះបញ្ជីដីធ្លីមានលក្ខណៈជាប្រព័ន្ធ និងការចេញប័ណ្ណកម្មសិទ្ធិដីធ្លីទូទាំងប្រទេស ។

ច្រើនជាងមុនទេ ។ Jacoby, Li and Rozelle (2002) បង្ហាញថា កំណើនសុវត្ថិភាពសិទ្ធិកាន់កាប់ដីធ្លី នាំឲ្យវិនិយោគកើនឡើង ។ Besley (1995) កត់សម្គាល់ថា សិទ្ធិកាន់កាប់ទ្រព្យសម្បត្តិក្រៅផ្លូវការ នៅតំបន់ Wassa នៃប្រទេស Ghana មានឥទ្ធិពលវិជ្ជមានលើវិនិយោគ ប៉ុន្តែគ្មានឥទ្ធិពលអ្វីនៅតំបន់ Anloga ទេ ។ Hayes, Roth and Zepeda (1997) គូសបញ្ជាក់ពី ឥទ្ធិពលវិជ្ជមាននៃសុវត្ថិភាពសិទ្ធិកាន់កាប់ដីធ្លី ទៅលើផលិតភាពកសិកម្ម នៅតំបន់ជាយក្រុង នៃប្រទេស Gambia ។ Smith (2004) បង្ហាញពីលទ្ធផលស្រដៀងគ្នា នៅខេត្តភាគខាងត្បូងនៃប្រទេស Zambia ។ Holden, Deininger and Ghebru (2007) រកឃើញថា ប័ណ្ណបញ្ជាក់ដីធ្លី នាំឲ្យមានកំណើនការជួលដីនៅតំបន់ Tigray នៃប្រទេស Ethiopia ។ Goldstein and Udry (2005) រកឃើញថា សុវត្ថិភាពសិទ្ធិកាន់កាប់ដី មានឥទ្ធិពលវិជ្ជមានលើការវិនិយោគកសិកម្មនៅតំបន់ Akwapim នៃប្រទេសហ្គាណា ។

Place and Hazell (1993) បានរកឃើញថា សិទ្ធិកាន់កាប់ដីធ្លីមិនផ្លូវការ មានឥទ្ធិពលតិចតួចលើវិនិយោគ ផលិតភាព និងលទ្ធភាពទទួលឥណទាននៅប្រទេស Ghana, Kenya និង Rwanda ។ Place and Migot-Adholla (1998) មិនបានរកឃើញថា ការចុះបញ្ជីដីធ្លីមានឥទ្ធិពលអ្វីទៅលើវិនិយោគ និងផលិតភាពនៅតំបន់ជនបទនៃប្រទេស Kenya ទេ ។ Braselle *et al.* (2002) មិនអាចបញ្ជាក់ថា សុវត្ថិភាពសិទ្ធិកាន់កាប់ដី មានឥទ្ធិពលលើវិនិយោគនៅតំបន់ Bobo-Dioulasso នៃប្រទេស Burkina Faso ទេ ។

## ៣. ក្របខ័ណ្ឌជាក់ស្តែង និងទស្សនទាន

ក្នុងកិច្ចប្រឹងប្រែងបង្កើតជាម៉ូដែលសេដ្ឋកិច្ចមួយ ដែលភ្ជាប់ទំនាក់ទំនងរវាង សិទ្ធិកាន់កាប់ដីធ្លី ការលើកទឹកចិត្តវិនិយោគ និងផលិតភាព Besley (1995) បានបង្កើតទ្រឹស្តីមួយ ដោយផ្អែកលើសម្មតិកម្មចំបង ២ ៖ (១) ប័ណ្ណកម្មសិទ្ធិដីធ្លី អាចបង្កើនសុវត្ថិភាពកាន់កាប់ដីសម្រាប់កសិករ និងពង្រឹងឆន្ទៈពួកគាត់ ក្នុងការវិនិយោគរយៈពេលមធ្យម និងរយៈពេលវែង និង (២) ប័ណ្ណកម្មសិទ្ធិដីធ្លីអាចប្រើជាវត្ថុបញ្ចាំ ដើម្បីបង្កើនលទ្ធភាពទទួលបានឥណទាន ដែលត្រូវនាំទៅដល់កំណើនផលិតភាពកសិកម្ម ។ មួយវិញទៀត ទំនាក់ទំនងវិជ្ជមានរវាង សិទ្ធិកាន់កាប់ដីធ្លី វិនិយោគ និងឥណទានអាចពន្យល់យ៉ាងសាមញ្ញដូចតទៅ៖ បុគ្គលទាំងឡាយ នឹងមិនធ្វើវិនិយោគឡើយ ប្រសិនបើសមិទ្ធផលនៃការវិនិយោគរបស់ខ្លួន ត្រូវអ្នកដទៃក្តោបយកនោះ (Demsetz 1967; Alchian & Demsetz 1973) ហើយសិទ្ធិកាន់កាប់ដីធ្លីប្រកបដោយសុវត្ថិភាព ធ្វើឲ្យការប្រើដីជាវត្ថុបញ្ចាំ កាន់តែងាយស្រួលឡើង (Feder *et al.* 1988) ។ Feder *et al.* (1988) បានសន្និដ្ឋានថា ប័ណ្ណកម្មសិទ្ធិដីធ្លី អាចជម្រុញទីផ្សារដីធ្លីដែលជួយសម្រួលដល់ការផ្ទេរដី ទៅឲ្យកសិករអ្នកមានសមត្ថភាព ។ សេដ្ឋវិទូ ប្រើប្រាស់សម្មតិកម្មទាំងនេះ ដើម្បីធ្វើតេស្តរកមើលទំនាក់ទំនងរវាងសិទ្ធិកាន់កាប់ដីធ្លី ការវិនិយោគ និងផលិតភាព ។ ក្រាហ្វិក ១ បង្ហាញគំរូសាមញ្ញមួយនៃក្របខ័ណ្ឌទស្សនទាន ។

### បញ្ហានានាខាងវិធីសាស្ត្រស្រាវជ្រាវ និងយុទ្ធសាស្ត្រប៉ាន់ស្មាន

ដើម្បីវាយតម្លៃពីឥទ្ធិពលនៃសិទ្ធិកាន់កាប់ទ្រព្យសម្បត្តិ លើផលិតភាពកសិកម្ម ដែលផុសចេញពីការពិភាក្សាខាងលើ យើងប្រើប្រាស់ក្របខ័ណ្ឌវិភាគរបស់ Markussen (2008) ដែលលើកឡើងថា ផលិតកម្មកសិកម្មមានសមីការ៖

$$\frac{pY_{hj}}{Q_{hj}} = pA(x_{hj}, z_h, v) Q_{hj}^{\beta_Q - 1} L_{hj}^{\beta_L} V_{hj}^{\beta_V} K_{hj}^{\beta_K} \qquad (1)$$

$Y_{hj}$ ជាទិន្នផលលើក្បាលដី j ក្នុងគ្រួសារ h ហើយ p ជាថ្លៃផលិតផល Q ជាផ្ទៃដីសាបព្រួស L ជាសមាសធាតុពលកម្មគ្រួសារ V ជាសមាសធាតុក្រៅពីពលកម្មគ្រួសារ K ជាទ្រព្យសកម្មកសិកម្ម និង A ជារង្វាស់កត្តាផលិតភាពសរុប ដែលផ្អែកលើ វ៉ិកទ័រក្បាលដី គ្រួសារ និងចរិតលក្ខណៈភូមិ (x, z និង v រៀងគ្នា) ។ កត្តាផលិតភាពសរុប A (•) អាចមានទម្រង់មុខងារដូចខាងក្រោម៖

$$\ln A\left(x_{hi}, z_{h}, v\right) = \ln A + \alpha x_{hi} + \gamma z_{h} + \theta v \qquad (2)$$

ក្រាហ្វិក ១៖ ក្របខ័ណ្ឌទស្សនទានតន្ត្រាប់ទំនាក់ទំនងរវាង គោលនយោបាយ សិទ្ធិកាន់កាប់ដីធ្លី និង ប្រសិទ្ធភាពសេដ្ឋកិច្ច




*ប្រភព៖ Place (2009)*

សិទ្ធិកាន់កាប់ទ្រព្យសម្បត្តិ R ត្រូវបានតាងជាសមាសធាតុមួយនៅក្នុង $X_{hj}$ ។ សិទ្ធិលើទ្រព្យសម្បត្តិ នឹងបង្កើនផលិតភាព ដោយជះឥទ្ធិពលទៅលើកត្តាផលិតភាពសរុប តាមរយៈការពង្រឹងទឹកចិត្តវិនិយោគ ។ សមីការ (២) អាចសរសេរដូចខាងក្រោម៖

$$\ln\left(\frac{pY_{hj}}{Q_{hj}}\right) = \ln pA + \alpha_R R + \tilde{\alpha}\tilde{x}_{hj} + \gamma z_h + \theta v + (\beta_Q - 1)\ln Q_{hj} + \beta_L \ln L_{hj} + \beta_V \ln V_{hj} + \beta_K \ln K_{hj} + \varepsilon_{hj} \quad (3)$$

$\tilde{a}\tilde{x}_{hj}$ ជា $ax_{hj}$ ដោយគ្មាន R ។ សមីការនេះ ត្រូវការទិន្នន័យកម្រិតក្បាលដី ។ ប៉ុន្តែ សមាសធាតុពលកម្ម អាចរកបាននៅកម្រិតគ្រួសារប៉ុណ្ណោះ[៣] ។ ចំនួនពលកម្មនៅតាមគ្រួសារ ជាចំនួនសមាជិកគ្រួសារដែលមានអាយុចាប់ពី ១៥ ដល់ ៦៤ឆ្នាំ ។ ដី គឺជាផ្ទៃដីកសិកម្មដំណើរការ ដោយគ្រួសារជាក់លាក់មួយ គិតជាហិកតា ។ ទ្រព្យសកម្មកសិកម្ម ជាសន្ទស្សន៍នៃទ្រព្យសកម្ម សម្រាប់កសិកម្ម ដែលមានដូចជា រទេះ ត្រាក់ទ័រ នង្គ័ល រនាស់ គោយន្ត ម៉ាស៊ីនបូមទឹក គោក្របី និងសេះ[៤] ។ សមាសធាតុក្រៅពីពលកម្មគ្រួសារ មានដូចជា ការចំណាយលើគ្រាប់ពូជ សំណាប ជី ថ្នាំសម្លាប់សត្វល្អិត ជីលាមកសត្វឬរុក្ខជាតិរលួយ អគ្គិសនីសម្រាប់ការងារកសិកម្ម ថ្លៃទឹក ស្រោចស្រព ថ្លៃដឹកជញ្ជូនធាតុចូលនិងផលិតផល និងថ្លៃជួលកម្លាំងពលកម្ម ។ លក្ខណៈក្បាលដី មានដូចជា ដីស្រោចស្រព ដីស្ងួត ដីសើមលាយស្ងួត ឬដីចម្ការ ។ លក្ខណៈគ្រួសារ រួមមាន កម្រិតការ អប់រំរបស់មេគ្រួសារ អាយុមេគ្រួសារ អត្រាអ្នករស់នៅក្នុងបន្ទុក (អាយុក្រោម ១៤ឆ្នាំ និងលើ ៦៥ឆ្នាំ) និងស្ថានភាពដែលមេគ្រួសារជាបុរស ឬនារី ។ លក្ខណៈភូមិ រួមមាន គ្រោះរាំងស្ងួត ទឹកជំនន់ ការខូចខាតផលដំណាំដោយសារសត្វចង្រៃក្នុង ៥ឆ្នាំចុងក្រោយ ធនាគារ ឬអង្គភាពផ្តល់កម្ចីនៅ ក្នុងភូមិ និងក្រុមការងារផ្សព្វផ្សាយបច្ចេកទេសកសិកម្មក្នុងភូមិ ។

Besley (1995) គូសបញ្ជាក់ពីលទ្ធភាព ដែលសិទ្ធិកាន់កាប់ទ្រព្យសម្បត្តិដើរតួជា endogenous variables (អថេរផ្ទៃក្នុង) គឺ៖ កសិករនឹងធ្វើការកែលំអ ដើម្បីលើកកម្ពស់សិទ្ធិរបស់ ខ្លួន ។ ចំណុចនេះមានន័យថា ការប៉ាន់ស្មានដោយប្រើវិធីសាស្ត្រ ordinary least squares[៥] (OLS) វាមានភាពលំអៀង និងមិនស៊ីគ្នាល្អទេ ។ គេសម្គាល់ថា វិធីសាស្ត្រ instrumental variables or two stage least squares (2SLS) អាចប្រើបាន ដើម្បីដោះស្រាយបញ្ហា endogenity (សូមមើល Wooldridge 2002) ។ Besley (1995) បកស្រាយថា មានអថេរជាច្រើនដែលអាចកំណត់នូវសិទ្ធិ កាន់កាប់ដីធ្លីបាន ប៉ុន្តែប្រហែលមិនជះឥទ្ធិពលដោយផ្ទាល់លើវិនិយោគ (ផលិតភាព) ទេ ។ អថេរ ទាំងនេះ មាន (១) តើក្បាលដីនោះមានឯកសារផ្ទេរកម្មសិទ្ធិឬទេ? (២) តើគ្រួសារនោះធ្លាប់ប្តឹងផ្តល់ ពីសិទ្ធិកាន់កាប់ក្បាលដីឬទេ? (៣) តើគេទទួលបានដីនោះដោយរបៀបណា? និង (៤) តើគេកាន់ កាប់ក្បាលដីនោះបានប៉ុន្មានឆ្នាំហើយ? ដូចគ្នានឹង Besley (1995), Deininger and Castagnini (2004) និង Markussen (2008) យើងនឹងប្រើមធ្យោបាយនៃការបានដីមកជាកម្មសិទ្ធិ ធ្វើជា instrument សម្រាប់អថេរសិទ្ធិកាន់កាប់ដីធ្លី ។

## ៤. ទិន្នន័យ និងលទ្ធផលជាក់ស្តែង

ការវិភាគជាក់ស្តែងក្នុងការសិក្សានេះ ប្រើប្រាស់ស្ថិតិនៃការអង្កេតសេដ្ឋកិច្ច-សង្គមកិច្ចកម្ពុជា ឆ្នាំ២០០៧ ដែលធ្វើឡើងដោយវិទ្យាស្ថានជាតិស្ថិតិ ក្នុងអំឡុងខែកក្កដា-កញ្ញា ។ ការអង្កេតនេះ បានជ្រើសរើស ៣៥៩៣គ្រួសារ ក្នុងនោះ ២២២៨ គ្រួសារ មានទីលំនៅនៅជនបទ ។ អង្កេតនេះ

---

៣ ក្នុងអង្កេតសេដ្ឋកិច្ច-សង្គមកិច្ចកម្ពុជាឆ្នាំ២០០៣/២០០៤ គ្មានបញ្ជាក់ពី ធាតុចូលមិនមែនពលកម្មផ្សេងៗនៅ កម្រិតក្បាលដីទេ ។

៤ សន្ទស្សន៍ទ្រព្យសកម្មកសិកម្ម ត្រូវបានប៉ាន់ស្មាន ដោយប្រើប្រាស់វិធីសាស្ត្រវិភាគសមាសភាពគន្លឹះ (Principal Component Analysis Methord) ។

៥ Ordinary least square ជាវិធីសាស្ត្រប៉ាន់ស្មានប៉ារ៉ាម៉ែតដែលគេមិនស្គាល់តម្លៃ ។

ផ្តល់ព័ត៌មានស្តីពីចរិតលក្ខណៈនៃគ្រួសារ ដូចជា ភេទ អាយុ និងការអប់រំ ហើយក៏មានព័ត៌មានទាក់ទងនឹងទ្រព្យសកម្ម ដូចជា គោក្របី សេះ នង្គ័ល ម៉ាស៊ីនបោកស្រូវ និងរទេះ ជាដើម ។ គ្រួសារនីមួយៗ ក៏បានរាយការណ៍ពី តម្លៃដំណាំ និងសមាសធាតុពលកម្មដែលមិនមែនជាសមាជិកគ្រួសារ នៅលើក្បាលដីនីមួយៗ ។ ការអង្កេតបានស្នើឲ្យគ្រួសារនីមួយៗរាយការណ៍ពីសំណុំឯកសារបញ្ជាក់កម្មសិទ្ធិលើក្បាលដីនីមួយៗផងដែរ ។ ប័ណ្ណដីធ្លី ចែកជា ៦ប្រភេទ៖ សិទ្ធិសុំកម្មសិទ្ធិដីធ្លី លិខិតត្រួតពិនិត្យដីធ្លី លិខិតបញ្ជាក់កម្មសិទ្ធិ លិខិតអាជ្ញាធរដែនដី កិច្ចសន្យាជួលដី និងឯកសារផ្សេងទៀត ។ អង្កេតបានសាកសួរផងដែរពី វិនិយោគផ្សេងៗលើក្បាលដីនីមួយៗ ចាប់តាំងពីទទួលបានដីនោះមក ជាអាទិ៍ ការជីកអណ្តូង ការជីកប្រឡាយ ការធ្វើជម្រាលសម្រាប់ដាំដំណាំ ការធ្វើប្រឡាយរំដោះទឹក ការរានយកដីដាំដំណាំ ការដាំដើមឈើហូបផ្លែ ឬយកគ្រាប់ជាដើម ។ តារាង ១ ផ្តល់នូវតួលេខមធ្យមនៃអថេរដែលលើកឡើងខាងលើ ។

**តារាង ១៖ ស្ថិតិអំពីក្បាលដី (តួលេខមធ្យម លើកលែងតែបញ្ជាក់ផ្សេង)**

| | ក្បាលដីទាំងអស់ | ក្បាលដីមានឯកសារ | ក្បាលដីគ្មានឯកសារ |
|---|---|---|---|
| ក្បាលដីកាន់កាប់មានឯកសារ | 0.56 | | |
| ទំហំក្បាលដី (ហិកតា) | 0.90 | 0.96 | 0.84 |
| ផលិតកម្មស្រូវ (តោន/ហិកតា) | 2.11 | 2.22 | 1.97 |
| ដីទទួលការស្រោចស្រពយ៉ាងហោច ១ រដូវ | 0.36 | 0.39 | 0.33 |
| ដីដាំដុះរដូវវស្សា | 0.84 | 0.83 | 0.86 |
| ដីដាំដុះរដូវប្រាំង | 0.14 | 0.15 | 0.12 |
| ដីដាំដុះទាំងរដូវវស្សា និងរដូវប្រាំង | 0.01 | 0.02 | 0.01 |
| ដីរដ្ឋផ្តល់ចែកឲ្យ | 0.39 | 0.46 | 0.29 |
| ដីកេរ្តិ៍ ឬសាច់ញាតិផ្តល់ឲ្យ | 0.37 | 0.29 | 0.47 |
| ដីទិញ | 0.14 | 0.21 | 0.06 |
| ដីរាន ឬចូលកាន់កាប់ដោយសេរី | 0.06 | 0.03 | 0.09 |
| ដីទទួលបានតាមវិធីផ្សេងទៀត | 0.04 | 0.2 | 0.8 |
| វិនិយោគ | 0.08 | 0.11 | 0.05 |
| ចំនួនក្បាលដី | 2498 | 1441 | 1057 |

*កំណត់សម្គាល់៖ មានការដាក់ទម្ងន់លើសំណាក ។ មានដាក់បញ្ចូលតែគ្រួសារនៅជនបទប៉ុណ្ណោះ ។ ១១% នៃក្បាលដីស្រែកាន់កាប់ដោយគ្រួសារនៅជនបទ ដែលផ្តល់ទិន្នផលជាមធ្យមលើសពី ៧តោន/ហិកតា មិនបានដាក់បញ្ចូលទេ ។*

*ប្រភព៖ ការគណនារបស់អ្នកនិពន្ធ*

ក្បាលដី ៦០% មានឯកសារបញ្ជាក់ការកាន់កាប់ ។ ផលិតកម្មស្រូវមានចំនួន ២,១១តោន/ហិកតា ។ ក្បាលដីដែលមានឯកសារបញ្ជាក់ ផ្តល់ផលស្រូវប្រហាក់ប្រហែលនឹងបរិមាណថ្នាក់ជាតិ និងខ្ពស់ជាងផលស្រូវលើក្បាលដីគ្មានឯកសារបញ្ជាក់ ហើយច្រើនមានទំហំធំជាង និងមានការស្រោចស្រពល្អជាង ។ ម្យ៉ាងទៀត ដីមានឯកសារបញ្ជាក់ តែងមិនមែនជាដីកេរ្តិ៍ទទួលបានពីសាច់ញាតិ ដីបានពីការរាន ឬចូលកាន់កាប់ដោយសេរីនោះទេ ។ ក្បាលដីមានឯកសារបញ្ជាក់ ១១% ទទួលបានវិនិយោគជាការកសាងអណ្តូង ប្រឡាយ ជម្រាលសម្រាប់ដាំដុះ និងប្រឡាយរំដោះទឹក និងការរានយកដីដាំដំណាំ រីឯក្បាលដីគ្មានឯកសារបញ្ជាក់ មានតែ ៥% ប៉ុណ្ណោះ

ដែលទទួលបានការវិនិយោគ ។ ជាង ៧០% នៃក្បាលដីទាំងអស់ ទទួលបានវិនិយោគលើការធ្វើជម្រាលសម្រាប់ដាំដុះ ។ ជាទូទៅ ក្បាលដីមានឯកសារបញ្ជាក់ ទទួលបានវិនិយោគច្រើនជាង និងមានផលិតកម្មខ្ពស់ជាងក្បាលដីគ្មានឯកសារបញ្ជាក់ ដូចបានព្យាករណ៍នៅក្នុងក្របខ័ណ្ឌទស្សនទានក្នុងផ្នែកទី៣ ។

តារាង ២៖ ស្ថិតិអំពីក្រុមគ្រួសារ

| | មធ្យម (Mean) | គំលាតស្តង់ដារ |
|---|---|---|
| ចំនួនក្បាលដីក្នុងមួយគ្រួសារ | 1.69 | 1.00 |
| មេគ្រួសារ៖ បុរស | 0.81 | 0.40 |
| មេគ្រួសារ៖ អាយុ | 44.60 | 13.63 |
| មេគ្រួសារ៖ កម្រិតអប់រំ | 4.06 | 3.23 |
| ទំហំគ្រួសារ | 4.86 | 1.91 |
| កុមារអាយុក្រោម ១៥ឆ្នាំ | 1.80 | 1.41 |
| សមាជិកអាយុលើសពី ៦៥ឆ្នាំ | 0.19 | 0.47 |
| សមាជិកភេទប្រុសអាយុពី 15-65ឆ្នាំ | 1.34 | 0.91 |
| សមាជិកភេទស្រីអាយុពី 15-65ឆ្នាំ | 1.52 | 0.83 |
| សមាជិកក្នុងអាយុធ្វើការ (16-65ឆ្នាំ) | 2.86 | 1.37 |
| ចំនួនគ្រួសារ | 1470 | |

*កំណត់សម្គាល់៖ មានការដាក់ទម្ងន់លើគំរូតាង ។ មានដាក់បញ្ចូលតែគ្រួសារនៅជនបទប៉ុណ្ណោះ ។*
*ប្រភព៖ ការគណនារបស់អ្នកនិពន្ធ*

តារាង ៣ បង្ហាញថា សមាមាត្រអ្នកកសិករងការប៉ះពាល់ដោយគ្រោះរាំងស្ងួត កើនឡើងយ៉ាងច្រើនពីឆ្នាំ២០០១ ដល់ ២០០៥ រីឯសមាមាត្រអ្នកកសិករងការប៉ះទង្គិចដោយគ្រោះទឹកជំនន់បានថយចុះ ។ គ្រោះរាំងស្ងួតដែលអូសបន្លាយច្រើនឆ្នាំ អាចមានផលប៉ះពាល់រយៈពេលវែងលើកសិកម្ម ។ ទឹកជំនន់ អាចបង្កនូវការខូចខាតធ្ងន់ធ្ងរ ប៉ុន្តែក៏ធ្វើឲ្យដីមានជីជាតិនៅប៉ុន្មានឆ្នាំបន្ទាប់ពីនោះ ។

តារាង ៤ ផ្តល់លទ្ធផលនៃសមីការ (3) សម្រាប់ផលិតភាពស្រូវ ។ ជួរឈរទី២ និងទី៣ ជាលទ្ធផលនៃការប៉ាន់ស្មានលើ ២៤៥១ ក្បាលដី ដោយប្រើវិធីសាស្ត្រ OLS និង 2SLS ។ សូចនាករនៃឯកសារបញ្ជាក់កម្មសិទ្ធិ មានតម្លៃវិជ្ជមាន និងមានសារៈសំខាន់ខាងស្ថិតិ (statistical significant) នៅកម្រិត ៥% សម្រាប់វិធីសាស្ត្រទាំងពីរ ប៉ុន្តែវិធីសាស្ត្រ 2SLS មានមេគុណខ្ពស់ខ្លាំងជាង OLS ។ ចំណុចនេះគួរឲ្យភ្ញាក់ផ្អើលដែរ ដោយសារគេរំពឹងលទ្ធផលផ្ទុយពីនេះ ព្រោះសិទ្ធិលើទ្រព្យសម្បត្តិគួរបណ្តាលឲ្យមានភាពលំអៀង សម្រាប់ការប៉ាន់ស្មានដោយវិធីសាស្ត្រ OLS ។ តាមការវែកញែករបស់ Markussen (2008) លទ្ធផលទាំងនោះឆ្លុះបញ្ចាំងថា ឥទ្ធិពលចំបងនៃឧបករណ៍វាស់វែង គឺបំបាត់ភាពល្អៀងក្នុងការវាស់វែង ដែលកើតចេញពីការយល់ខុសដ៏សាមញ្ញ ដូចជា កង្វះចំណេះដឹងរបស់អ្នកឆ្លើយសម្ភាសន៍ ឬកំហុសក្នុងការកត់ត្រា និងភាពល្អៀង កើតចេញពីការប៉ាន់ស្មានឥទ្ធិពលស្រដៀងគ្នានៃប័ណ្ណកម្មសិទ្ធិដីធ្លីប្រភេទខុសៗគ្នា នៅក្នុងអថេរប័ណ្ណកម្មសិទ្ធិដីធ្លី ។

ទោះជាមេគុណនៃឯកសារកម្មសិទ្ធិដីធ្លីដែលប៉ាន់ស្មានដោយ 2SLS មានភាពលំអៀងទៅខាងលើ ដោយសារភាពល្អៀងក្នុងការវាស់វែងក្តី ក៏វានៅតែមានឥទ្ធិពលគួរឲ្យកត់សម្គាល់ទៅលើផលិតភាពស្រូវ ។ ក្បាលដីមានឯកសារបញ្ជាក់កម្មសិទ្ធិ ផ្តល់ផលប្រមាណ ២០% ច្រើនជាង

ក្បាលដីគ្មានឯកសារបញ្ជាក់កម្មសិទ្ធិ ហើយឯកសារបញ្ជាក់កម្មសិទ្ធិនេះ ជះឥទ្ធិពលលើទិន្នផលខ្លាំងជាងកត្តាដទៃទៀត ដូចជា ការស្រោចស្រព ឧបករណ៍កសិកម្មទំនើប មេគ្រួសារជាបុរស និងគម្រោងអភិវឌ្ឍន៍កសិកម្មរបស់រដ្ឋាភិបាល និង NGOs ជាដើម ។

តារាង ៣៖ ស្ថិតិអំពីត្ថមិ

| | មធ្យម | គំលាតស្តង់ដារ |
|---|---|---|
| ដីកសិកម្ម (ហិកតា) | 297.70 | 558.46 |
| ដីស្រោចស្រព (ហិកតា) | 80.48 | 222.37 |
| ដីដាំដុះ (ហិកតា) | 269.17 | 555.13 |
| ដីស្រែទទួលការស្រោចស្រព (ហិកតា) | 77.56 | 219.45 |
| គ្រោះរាំងស្ងួតក្នុង ៥ឆ្នាំចុងក្រោយ | 0.73 | 0.45 |
| គ្រោះរាំងស្ងួតក្នុងឆ្នាំ២០០១ | 0.12 | 0.33 |
| គ្រោះរាំងស្ងួតក្នុងឆ្នាំ២០០៣ | 0.31 | 0.47 |
| គ្រោះរាំងស្ងួតក្នុងឆ្នាំ២០០៥ | 0.35 | 0.48 |
| ទឹកជំនន់ក្នុង ៥ឆ្នាំចុងក្រោយ | 0.32 | 0.47 |
| ទឹកជំនន់ក្នុងឆ្នាំ២០០១ | 0.15 | 0.36 |
| ទឹកជំនន់ក្នុងឆ្នាំ២០០៣ | 0.11 | 0.31 |
| ទឹកជំនន់ក្នុងឆ្នាំ២០០៥ | 0.08 | 0.27 |
| ចំនួនភូមិ | 197 | |

*កំណត់សម្គាល់៖ មានដាក់បញ្ចូលតែគ្រួសារនៅជនបទប៉ុណ្ណោះ ។*
*ប្រភព៖ ការគណនារបស់អ្នកនិពន្ធ*

គួរកត់សម្គាល់ដែរថា ទំហំដីកសិកម្មមានមេគុណអវិជ្ជមាន និងសារៈសំខាន់ខាងស្ថិតិនៅកម្រិត ១% ដែលបង្ហាញថា ដីកសិកម្មទំហំធំ មានប្រសិទ្ធិភាពតិចជាងដីកសិកម្មតូចៗ ។ លទ្ធផលនេះ ស្របគ្នានឹងភស្តុតាងទទួលបានពីការសិក្សាដទៃទៀត ដូចជា Adesina and Djato (1996) និង Deininger and Castagnini (2006) ដែលបញ្ជាក់ពីទំនាក់ទំនងអវិជ្ជមានរវាងទំហំដីកសិកម្ម និងផលិតភាព នៅប្រទេស Cote d'Ivoire និង Uganda ។ លទ្ធផលស្រាវជ្រាវស្រដៀងគ្នាក៏បានរកឃើញនៅកម្ពុជា ក្នុងការសិក្សារបស់ World Bank (2004) និង Ballard and So (2004) ។ ចំណាយលើ សមាសធាតុមិនមែនកម្លាំងពលកម្ម និងទ្រព្យសកម្មកសិកម្មទំនើបៗ ទំនងជាបង្កើនផលិតភាពស្រូវបាន ២៥% និង ៥% រៀងគ្នា ហើយការស្រោចស្រពអាចបង្កើនផលិតភាពស្រូវបាន ១៧% ។ ទ្រព្យសកម្មកសិកម្មបែបប្រពៃណី (បុរាណ) ទំនងមិនបានរួមចំណែកក្នុងកំណើនផលិតភាពទេ ។

តារាង ៨៖ ឯកសារបញ្ជាក់កម្មសិទ្ធិដី និងផលិតភាពស្រូវ

| | អថេរនៅក្នុងចំណុះ៖ លោការីតនៃទិន្នផលស្រូវ (តោន/ហិកតា) | |
|---|---|---|
| | OLS | 2LS |
| ក្បាលដីមានឯកសារបញ្ជាក់ | 0.061** | 0.209** |
| ទំហំដី (លោការីត) | -0.434*** | -0.438*** |
| ចំណាយផ្សេងៗ (លោការីត) | 0.248*** | 0.250*** |
| ដីមានការស្រោចស្រពយ៉ាងហោច ១រដូវ | 0.175*** | 0.178*** |
| ដីកសិកម្មរដូវប្រាំង | 0.374*** | 0.378*** |
| ដីកសិកម្មរដូវប្រាំង និងវស្សា | 0.478*** | 0.459*** |
| ដីប្រភេទផ្សេងទៀត | 0.869*** | 0.961*** |
| សមាជិកគ្រួសារអាយុពី ១៥-៦៤ឆ្នាំ (លោការីត) | 0.006 | 0.005 |
| សន្ទស្សន៍ទ្រព្យសកម្មកសិកម្មក្រៅពីដីធ្លី (បែបប្រពៃណី) | -0.031*** | -0.032*** |
| សន្ទស្សន៍ទ្រព្យសកម្មកសិកម្មក្រៅពីដីធ្លី (បែបទំនើប) | 0.061*** | 0.058*** |
| កម្រិតអប់រំ (ចំនួនឆ្នាំសិក្សា) របស់មេគ្រួសារ | -0.016* | -0.021* |
| ទ្វេគុណនៃកម្រិតអប់រំ (ចំនួនឆ្នាំសិក្សា) របស់មេគ្រួសារ | 0.0008 | 0.0012 |
| ភេទរបស់មេគ្រួសារ (១=បុរស) | 0.138*** | 0.141*** |
| អាយុរបស់មេគ្រួសារ (ឆ្នាំ) | -0.001 | -0.001 |
| អត្រាអ្នករស់នៅក្នុងបន្ទុក | -0.072 | -0.068 |
| គ្រោះរាំងស្ងួតក្នុងឆ្នាំ២០០៥ | -0.078*** | -0.083*** |
| ទឹកជំនន់ក្នុងឆ្នាំ២០០៥ | -0.071 | -0.057 |
| គម្រោងអភិវឌ្ឍន៍កសិកម្មរបស់រដ្ឋាភិបាល (១=មាន) | 0.023 | 0.031 |
| គម្រោងអភិវឌ្ឍន៍កសិកម្មរបស់ NGOs (១=មាន) | -0.253*** | -0.269*** |
| គម្រោងអភិវឌ្ឍន៍កសិកម្មរបស់រដ្ឋាភិបាល និង NGOs (១= មាន) | 0.222** | 0.202** |
| ធនាគារ (១=មាន) | -0.074 | -0.094* |
| អញ្ញត្តិថេរ (Constant) | -2.825*** | -2.895*** |
| Fixed effects | ខេត្ត | ខេត្ត |
| ការសង្កេតឃើញ | 2451 | 2451 |
| R-squared | 0.4347 | 0.4259 |

*កំណត់សម្គាល់៖ *សារៈសំខាន់ខាងស្ថិតិនៅកម្រិត ១០% - ** សារៈសំខាន់ខាងស្ថិតិនៅកម្រិត ៥% - *** សារៈសំខាន់ខាងស្ថិតិនៅកម្រិត ១% ។*

*ប្រភព៖ ការគណនារបស់អ្នកនិពន្ធ*

គ្រួសារមានបុរសជាមេគ្រួ អាចផលិតផលស្រូវបាន ១៣% ច្រើនជាងគ្រួសារមាននារីជាមេគ្រួ ប៉ុន្តែបទពិសោធន៍ការងាររបស់មេគ្រួសារ ហាក់មិនមានផ្តល់ប្រយោជន៍អ្វីសម្រាប់ផលិតកម្មស្រូវទេ ។ ចំណុចគួរឲ្យចាប់អារម្មណ៍មួយទៀត គឺកម្រិតអប់រំរបស់មេគ្រួសារ មានមេគុណអវិជ្ជមាន និងមានសារៈសំខាន់ខាងស្ថិតិនៅកម្រិត ៥% ។ លទ្ធផលនេះអាចបណ្តាលមកពីមេគ្រួសារភាគច្រើនដែលបានជ្រើសរើសមកសិក្សា មិនបានបញ្ចប់ថ្នាក់បឋមសិក្សាទេ ដូច្នេះហើយ ទើបកម្រិតអប់រំមិនបានរួមចំណែកអ្វីច្រើននៅក្នុងទិន្នផលកសិកម្ម ។ មេគុណកម្លាំងពលកម្ម មិនមានសារៈសំខាន់ខាងស្ថិតិ មានន័យថា កម្លាំងពលកម្មមិនមែនជាកត្តាកំណត់សំខាន់មួយលើផលិតកម្មស្រូវទេ ។ ចំណុចនេះ ឆ្លុះបញ្ចាំងពី អតិរេកកម្លាំងពលកម្មនៅតំបន់ជនបទក្នុងប្រទេសកម្ពុជា (សូមមើល Tong 2005) ។

ដើម្បីស្វែងយល់ពីឥទ្ធិពលនៃធាតុអាកាសទៅលើផលិតភាព ការសិក្សាបានដាក់បញ្ចូលអថេរ ២ គឺគ្រោះរាំងស្ងួត និងទឹកជំនន់នៅក្នុងភូមិ ។ លទ្ធផលបង្ហាញថា ភូមិជួបគ្រោះរាំងស្ងួតនៅឆ្នាំ២០០៥ មានផលិតកម្មស្រូវទាបជាងភូមិមិនជួបការរាំងស្ងួត ៥% ។ ផ្ទុយទៅវិញ ភូមិរងគ្រោះដោយទឹកជំនន់នៅឆ្នាំ២០០៥ ហាក់មានផលិតកម្មស្រូវមិនទាបជាងភូមិឯទៀតៗទេ ។ លទ្ធផលនេះគាំទ្រសម្មតិកម្មដែលថា គ្រោះរាំងស្ងួតបន្តជះឥទ្ធិពលលើផលិតភាពនៅរដូវបន្ទាប់ពីនោះ ។ ការសិក្សានេះ ក៏បានព្យាយាមស៊ើបសួរដែរថា តើមានធនាគារ ឬកម្មវិធីផ្តល់ឥណទាន បានជួយសម្រាលកង្វះឥណទាន ជាពិសេសសម្រាប់កសិកម្មនៅទីជនបទដែរឬទេ ។ យើងរកឃើញថា វត្តមាននៃធនាគារ និងកម្មវិធីផ្តល់ឥណទាន មិនសុទ្ធតែនាំឲ្យមានកំណើនផលិតកម្មស្រូវនោះទេ ។

## ៥. សេចក្តីសន្និដ្ឋាន និងការពិភាក្សាគោលនយោបាយ

ការសិក្សាមុនៗ ដែលប្រើទិន្នន័យអង្កេតគ្រួសារតំណាងឲ្យទូទាំងប្រទេសបង្ហាញថា សិទ្ធិកាន់កាប់ដី ជួយបង្កើនផលិតភាពកសិកម្ម ។ សុវត្ថិភាពសិទ្ធិកាន់កាប់ដី មានពាក់ព័ន្ធនឹងការលើកទឹកចិត្តវិនិយោគទៅលើដីកសិកម្ម និងលទ្ធភាពទទួលឥណទានដោយប្រើដីធ្លីជាវត្ថុបញ្ចាំ ។

អត្ថបទនេះបានប្រើ ទិន្នន័យអង្កេតគ្រួសារទូទាំងប្រទេសថ្មីៗ (CSES 2007) បញ្ជាក់អំពីទំនាក់ទំនងរវាងសិទ្ធិកាន់កាប់ដីធ្លី និងផលិតភាពកសិកម្ម ដោយផ្តោតជាចំបងទៅលើដំណាំស្រូវ ។ ការសិក្សារកឃើញថា ឯកសារបញ្ជាក់កម្មសិទ្ធិដី ជះឥទ្ធិពលលើផលិតកម្មស្រូវគួរឲ្យកត់សម្គាល់ ។ គេក៏សង្កេតឃើញមាន ទំនាក់ទំនងអវិជ្ជមានរវាងទំហំដីកសិកម្ម និងផលិតភាពស្រូវ ដែលផ្តល់គំនិតថា ការបែងចែកដីកសិកម្មឡើងវិញ ជារឿងចាំបាច់ណាស់ ។ កសិករមួយភាគធំ នៅប្រើឧបករណ៍កសិកម្មបុរាណនៅឡើយ ប៉ុន្តែលទ្ធផលនៃការសិក្សានេះ បង្ហាញថា ឧបករណ៍បុរាណមិនបានរួមចំណែកក្នុងកំណើនផលិតភាពទេ ។ ម្យ៉ាងទៀត គ្រោះរាំងស្ងួតអាចបង្កការខូចខាតធ្ងន់ធ្ងរ និងយូរអង្វែងជាងគ្រោះទឹកជំនន់ ។ វត្តមាននៃធនាគារ និងកម្មវិធីផ្តល់ឥណទាន មិនសុទ្ធតែជួយបង្កើនផលិតកម្មស្រូវនោះទេ ។ រដ្ឋាភិបាល និងអង្គការមិនមែនរដ្ឋាភិបាល តែងអនុវត្តគម្រោងអភិវឌ្ឍន៍កសិកម្មនៅតាមភូមិដែលជាគោលដៅរៀងៗខ្លួន ។ លទ្ធផលនៃការសិក្សាបញ្ជាក់ថា គម្រោងដាច់ៗគ្នាទាំងនេះ មិនបានជួយបង្កើនផលិតកម្មកសិកម្មទេ ។ ប៉ុន្តែកិច្ចសហការជិតស្និទ្ធរវាង រដ្ឋាភិបាល និងអង្គការមិនមែនរដ្ឋាភិបាល អាចជួយរួមចំណែកយ៉ាងធំធេងក្នុងផលិតកម្មស្រូវ ។

ឧបសម្ព័ន្ធ ១៖ ឯកសារបញ្ជាក់កម្មសិទ្ធិដី និងផលិតភាពស្រូវ

| | អថេរចំណុះគេ៖ លោការីតនៃទិន្នផលស្រូវ (តោន/ហិកតា) | |
|---|---|---|
| | OLS | 2LS |
| ក្បាលដីកាន់កាប់មានឯកសារបញ្ជាក់ | 0.098** | 0.229** |
| ទំហំដីកសិកម្ម (លោការីត) | -0.678*** | -0.681*** |
| ចំណាយផ្សេងៗ (លោការីត) | 0.360*** | 0.363*** |
| ដីមានការស្រោចស្រពយ៉ាងតិច ១រដូវ | 0.109*** | 0.115*** |
| ដីកសិកម្មរដូវប្រាំង | 0.354*** | 0.356*** |
| ដីកសិកម្មរដូវប្រាំង និងវស្សា | 0.546*** | 0.535*** |
| ដីប្រភេទផ្សេងទៀត | 0.762*** | 0.858*** |
| សមាជិកគ្រួសារអាយុពី ១៥-៦៤ឆ្នាំ (លោការីត) | -0.007 | -0.007 |
| សន្ទស្សន៍ទ្រព្យសកម្មកសិកម្មក្រៅពីដីធ្លី (បែបប្រពៃណី) | -0.032*** | -0.034*** |
| សន្ទស្សន៍ទ្រព្យសកម្មកសិកម្មក្រៅពីដីធ្លី (បែបទំនើប) | 0.062*** | 0.059*** |
| កម្រិតអប់រំ (ចំនួនឆ្នាំសិក្សា) របស់មេគ្រួសារ | -0.014 | -0.019* |
| ទ្វេគុណនៃកម្រិតអប់រំ (ចំនួនឆ្នាំសិក្សា) របស់មេគ្រួសារ | 0.0009 | 0.001 |
| ភេទរបស់មេគ្រួសារ (១=បុរស) | 0.147*** | 0.150*** |
| អាយុរបស់មេគ្រួសារ (ឆ្នាំ) | -0.001 | -0.001 |
| អត្រាអ្នករស់នៅក្នុងបន្ទុក | -0.111 | -0.102 |
| គ្រោះរាំងស្ងួតក្នុងឆ្នាំ២០០៥ | -0.103*** | -0.106*** |
| ទឹកជំនន់ក្នុងឆ្នាំ២០០៥ | -0.103** | -0.088* |
| គម្រោងអភិវឌ្ឍន៍កសិកម្មរបស់រដ្ឋាភិបាល (១=មាន) | 0.150** | 0.154** |
| គម្រោងអភិវឌ្ឍន៍កសិកម្មរបស់ NGOs (១=មាន) | -0.190*** | -0.210*** |
| គម្រោងអភិវឌ្ឍន៍កសិកម្មរបស់រដ្ឋាភិបាល និង NGOs (១= មាន) | 0.289*** | 0.270*** |
| ធនាគារ (១=មាន) | -0.014 | -0.007 |
| អញ្ញត្តិថេរ | -4.155*** | -4.229*** |
| Fixed effects | ខេត្ត | ខេត្ត |
| ការសង្កេតឃើញ | 2666 | 2666 |
| R-squared | 0.5778 | 0.5725 |

*សម្គាល់៖ *សារៈសំខាន់ខាងស្ថិតិនៅកម្រិត ១០% - ** សារៈសំខាន់ខាងស្ថិតិនៅកម្រិត ៥% - *** សារៈសំខាន់ខាងស្ថិតិនៅកម្រិត ១% ។ ក្រុមគ្រួសារដែលរាយការណ៍ពី ទិន្នផលស្រូវជាមធ្យម លើសពី ៧តោន/ហិកតា ក៏បានដាក់បញ្ចូលក្នុងនេះដែរ ។*

*ប្រភព៖ ការគណនារបស់អ្នកនិពន្ធ*

## ឯកសារយោង


Alchian, Armen A., and Demsetz, Harold. (1973), "The Property Rights Paradigm." *J. Econ. Hist.* 33: 16-27

Adesina A. and Djato K. (1996), "Farm Size, Relative Efficiency and Agrarian Policy in Cote d'Ivoire: Profit Function Analysis of Rice Farms", *Agricultural Economics*, Vol.14 (2), pp.93-102

Ballard B.M. and So S. (2004), *Cambodia Land Titling Program: Baseline Survey Projects. Final Report: Rural Phase I*, Phnom Penh: Cambodia Development Resource Institute

Besley Timothy (1995), "Property Rights and Investment Incentives: Theory and Evidence from Ghana", *Journal of Political Economy*, Vol.103 (5), pp.903-937

Braselle Anne-Sophie, Gaspart Frederic, and Platteau Jeab-Philippe Platteau (2002), "Land Tenure Security and Investment Incentives: Puzzling evidence from Burkina Faso", *Journal Development Economics*, Vol. 67 (2), pp.373-418

Deininger Klaus (2005), "Quantifying the poverty impact of land policy interventions: The Case of Cambodia", mimeo (Phnom Penh: World Bank)

Deininger Klaus and Jin Songqing (2002), *The Impact of Property Rights on Household's Investment, Risk Coping, and Policy Preference.* Policy Research Working Paper 2931, Washington DC: World Bank

Deininger Klaus and Jin Songqing (2003), *Land Sales and Rental Markets in Transition: Evidence from Rural Vietnam*, Policy Research Working Paper 3013, Washington DC: World Bank

Deininger Klaus and Jin Songqing (2006), "Tenure Security and Land-related Investment: Evidence from Ethiopia", *European Economic Review*, Vol.50 (5), pp.1245-1277

Deininger and Castagnini (2006), "Incidence and Impact of Land Conflict in Uganda", *Journal of Economic Behavior and Organization*, Vol.60 (3), pp.321-345

Demsetz H. (1967), "Towards a Theory of Property Rights", *American Economic Review*, Vol.57 (2), pp.347-359

Do Q.T. and Iyer L. (2006), *Land Titling and Rural Transition in Vietnam*, working paper, Harvard University

Food and Agricultural Organization (2010), http://www.fao.org (accessed 23 November 2010)

Feder G. and Onchan T. (1987), "Land Ownership Security and Farm Investment in Thailand", *American Journal of Agricultural Economics*, Vol.69 (2), pp.311-320

Feder G., T. Oncha, Y. Chalamwong and C. Hongladarom (1988), *Land Policies and Farm Productivity in Thailand.* Johns Hopkins University Press, Baltimore, Maryland

Goldstein M. and Udry C. (2005), "The Profits of Power: Land Rights and Agricultural Investment in Ghana", mimeo (London: Yale University)

Hayes, Roth and Zepeda (1997), "Tenure Security, Investment and Productivity in Gambian Agriculture: A Generalized Probit Analysis", *American Journal of Agricultural Economics*, Vol.79 (2), pp.369-382

Holden S., Deininger K., and Ghebru H. (2007), *Impact of Land Certificate on Land Rental Market Participation in Tigray Region, Northern Ethiopia*, Paper Presented at the Nordic Conference in Development Economics in Copenhagen, June 18-19

Jacoby, Li and Rozelle (2002), "Hazards of Expropriation: Tenure Security and Investment in Rural China", *American Economic Review*, Vol.92 (5), pp.1420-1446

Markussen Thomas (2008), "Property Rights, Productivity, and Common Property Resources: Insight from Rural Cambodia", *World Development*, Vol.36 (11), pp.2277-2296

Place Frank and Hazell P. (1993), "Productivity Effects of Indigenous Land Tenure Systems in Sub-Saharan Africa", *American Journal of Agricultural Economics*, Vol.75 (1), pp. 360-373

Place Frank and Migot-Adholla S.E. (1998), "The Economic Effects of Land Registration on Smallholder farms in Kenya: Evidence from Nyeri and Kakamega Districts", *Land Economics*, Vol.74 (3), pp. 360-373

Place Frank (2009), "Land Tenure and Agricultural Productivity in Africa: A Comparative Analysis of the Economics Literature and Recent Strategies and Reforms", *World Development*, Vol. 37 (8), pp. 1326-1336

Royal Government of Cambodia (2009), *National Strategic Development Plan Update 2009-2013* (Phnom Penh: Cambodia)

SMERU Research Team (2002), "An Impact evaluation of systematic land titling under Land Administration Project (LAP)", mimeo (Jakarta: SMERU)

Smith E. Robert (2004), "Land Tenure, Fixed Investment, and Farm Productivity: Evidence from Zambia's Southern Province", *World Development*, Vol.32 (10), pp.1641-1661

Tong Kimsun (2005), "Labour surplus and productivity in Cambodian agriculture - the case of Takeo province", mimeo (Phnom Penh: CDRI)

The Cambodia Daily, Monday September 2009, Volume 43 Issue 39

The World Bank (2006), *Cambodia Halving Poverty by 2015? Poverty Assessment 2006* (East Asia and the Pacific Region: the World Bank)

The World Bank (2009), *Poverty Profile and Trend in Cambodia Findings from the 2007 Socio-Economic Survey (CSES).* (East Asia and the Pacific Region: the World Bank)

Wooldridge, J.M. (2002), *Econometric Analysis of Cross Section and Panel Data.* The MIT Press

Wooldridge, J.M. (2003), *Introductory Econometric A Modern Approach.* The MIT Press

# ផ្នែកទី ៣
# ធនធានធម្មជាតិ និងបរិស្ថាន

# -VIII-
# ការសិក្សាប្រកបដោយការចូលរួម និងការស្រាវជ្រាវសកម្ម ដើម្បីពង្រឹងការគ្រប់គ្រងប្រព័ន្ធធារាសាស្ត្រ ក្នុងបរិបទនៃការគ្រប់គ្រងអាងស្ទឹង

*ដោយលោក ចែម ផល្លា[១] និងបណ្ឌិត សុមេធ ប៉ារាឌី[១]*

## សេចក្តីសង្ខេប

ទឹកគឺជាបេះដូង និងជាដង្ហើមសេដ្ឋកិច្ចនៃប្រទេសកម្ពុជា ។ ជោគជ័យខ្លាំងនៃការគ្រប់គ្រងទឹកក្នុងប្រវត្តិសាស្ត្រកម្ពុជា គឺក្នុងសម័យអង្គរ ។ ការគ្រប់គ្រងទឹកបានល្អ បានផ្តល់លទ្ធភាពឲ្យការដាំដុះស្រូវបានច្រើនដងក្នុងមួយឆ្នាំ ដែលជាហេតុនាំឲ្យសេដ្ឋកិច្ចជាតិ បានរីកចម្រើននាសម័យនោះ ។ ជាក់ស្តែង ការនាំស្រូវ អង្ករចេញទៅបរទេសក្នុងទសវត្សរ៍ ១៩២០ បានជំរុញសេដ្ឋកិច្ចកម្ពុជាឲ្យស្ទុះឡើង ដែលនាំទៅដល់ការអភិវឌ្ឍវិស័យអប់រំ និងគមនាគមន៍ ជាដើម ។ ប៉ុន្តែការគ្រប់គ្រងទឹកនៅកម្ពុជា ត្រូវបានធ្លាក់ចុះមកវិញ ជាបន្តបន្ទាប់ ចាប់តាំងពីសម័យក្រោយអង្គរ តរៀងមក ។ ហេតុផលមួយ នៃការធ្លាក់ចុះនេះ បណ្តាលមកពីការខូចខាតបរិស្ថាន ។ ហេតុផលដទៃទៀតមានដូចជាកង្វះអភិបាលកិច្ចល្អ ដែលបណ្តាលមកពីការធ្លាក់ចុះ នៃសេដ្ឋកិច្ចជាតិ សង្គ្រាម និងជម្លោះផ្ទៃក្នុងនាសម័យនោះ ។ ហេតុផលទាំងនេះហើយ ដែលនាំឲ្យខ្វះការយកចិត្តទុកដាក់លើការគ្រប់គ្រងបណ្តោយឲ្យប្រព័ន្ធធារាសាស្ត្រ ដែលបានកសាងរួចទាំងនោះ លែងដំណើរការ និងខូចខាតទៅវិញ ។

ក្នុងសម័យបច្ចុប្បន្ននេះ ថ្វីត្បិតរាជរដ្ឋាភិបាល ខិតខំកសាងហេដ្ឋារចនាសម្ព័ន្ធធារាសាស្ត្របានជាច្រើនក្តី ក៏នៅមានប្រជាកសិករជាច្រើន ជួបប្រទះការខ្វះខាតទឹកស្រោចស្រពដែរ ជាពិសេសក្នុងរដូវប្រាំង ។ កង្វះខាតនេះ បណ្តាលមកពីកត្តាមួយចំនួន ដូចជាធនធានទឹកក្នុងធម្មជាតិមានកម្រិត ខ្វះហេដ្ឋារចនាសម្ព័ន្ធរូបវ័ន្ត និងសមត្ថភាពបច្ចេកទេស និងគ្រប់គ្រងក្នុងវិស័យនេះ ។ កង្វះខាតទាំងអស់នេះជាបច្ច័យ នាំឲ្យមានបញ្ហា ដូចជាប្រសិទ្ធភាពគ្រប់គ្រងទាប និងខ្វះសមភាពនៃការប្រើប្រាស់ទឹក ជាដើម ។ ក្នុងបរិបទនេះ ចំណេះដឹងជលសាស្ត្រ រួមចំណែកច្រើនក្នុងការរៀបចំហេដ្ឋារចនាសម្ព័ន្ធរូបវ័ន្ត ការគ្រប់គ្រង និងការបែងចែកទឹកស្រោចស្រព ។ បើអ្នកគ្រប់គ្រង មិនបានដឹងថា ទឹកនៅក្នុងទំនប់អាងមានប៉ុន្មាន ពេលណាទើបបរិមាណទឹកនេះ អាចប្រើប្រាស់បាន វាជាការលំបាកខ្លាំងណាស់ចំពោះពួកគេ ដើម្បីបែងចែកទឹកស្រោចស្រព ឲ្យបានគ្រប់ចំនួន ទាន់ពេលវេលា និងមានសមធម៌ដែលអ្នកប្រើប្រាស់បង់បាន ។

ការពង្រីកផលិតភាពកសិកម្ម អាចធ្វើបាន ដោយពង្រឹងការគ្រប់គ្រងទឹក ការប្រើប្រាស់ទឹក និងធានានូវនិរន្តរភាពបរិស្ថាន ។ ជាងនេះទៀត ការពង្រឹងសមធម៌នៃការប្រើប្រាស់ទឹក ការបែងចែកផលប្រយោជន៍នៃទឹក ដើម្បីកាត់បន្ថយជម្លោះ និងការកសាងសមត្ថភាពស្ថាប័នគ្រប់គ្រងធនធានទឹក[២] គឺជាការចាំបាច់ ។

---

១ លោក ចែម ផល្លា ជាអ្នកស្រាវជ្រាវ នៅវិទ្យាស្ថាន CDRI ហើយ បណ្ឌិត សុមេធ ប៉ារាឌី ជាអ្នកស្រាវជ្រាវ និងជាសាស្ត្រាចារ្យ នៅវិទ្យាស្ថានបច្ចេកវិទ្យាកម្ពុជា។

២ ក្រសួងធនធានទឹក និងឧតុនិយម ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ មន្ទីរធនធានទឹក និងឧតុនិយមខេត្ត មន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនេសាទខេត្ត ក្រុមប្រឹក្សាស្រុក ឃុំ និងសហគមន៍កសិករប្រើប្រាស់ទឹក ។

គោលការណ៍គ្រប់គ្រងធនធានទឹកចម្រុះ ត្រូវបានកំណត់នៅក្នុងច្បាប់ទឹកឆ្នាំ២០០៧ និង គោលនយោបាយជាតិសម្រាប់គ្រប់គ្រងធនធានទឹកឆ្នាំ២០០៤ ។ ប៉ុន្តែការអនុវត្តគោលការណ៍នេះ នៅមានកម្រិតនៅឡើយ ។ ដើម្បីអនុវត្តគោលការណ៍ខាងទឹកបាន ការសិក្សានេះបានផ្តល់អនុសាសន៍ថា គណៈកម្មាធិការគ្រប់គ្រងអាងស្ទឹងគួរតែបង្កើតឡើង ដើម្បី (១) បង្កើនប្រសិទ្ធភាព នៃការប្រើប្រាស់ទឹករវាង សហគមន៍នៅខ្សែទឹកខាងលើ និងខ្សែទឹកខាងក្រោម (២) បង្កើនការ ចូលរួមរបស់ស្ត្រីនិងបុរស សហគមន៍ អ្នកវិទ្យាសាស្ត្រក្នុងការគ្រប់គ្រងទឹក និង (៣) ច្របាច់ បញ្ចូលគ្នានូវតម្លៃសង្គម បរិស្ថាន និងសេដ្ឋកិច្ចនៃធនធានទឹក ។ សមត្ថភាពមន្ត្រីមន្ទីរធនធានទឹក និងឧតុនិយម និងសហគមន៍កសិករប្រើប្រាស់ទឹក គួរត្រូវបានពង្រឹងតាមរយៈការរៀនផងធ្វើការផង និងតាមប្រព័ន្ធអប់រំផ្លូវការ នៅថ្នាក់ជាតិ និងអន្តរជាតិ ។ គោលការណ៍គ្រប់គ្រងធនធានទឹកចម្រុះ ត្រូវអនុវត្តដោយគណៈកម្មាធិការគ្រប់គ្រងអាងស្ទឹង ដោយមានតំណាងមកពីអ្នកគ្រប់គ្រងប្រព័ន្ធ ធារាសាស្ត្រ ដែលពាក់ព័ន្ធទាំងអស់ក្នុងអាងស្ទឹង ។ ពួកគេត្រូវតែបានចូលរួមក្នុងគ្រប់ការសម្រេចចិត្ត ទាំងអស់ ក្នុងការបែងចែកទឹកស្រោចស្រព និងផែនការអភិវឌ្ឍន៍នានា ក្នុងអាងស្ទឹង ។

## ១. កម្មវិធីអភិវឌ្ឍន៍សមត្ថភាពស្រាវជ្រាវ និងគ្រប់គ្រងធនធានទឹក

កម្មវិធីអភិវឌ្ឍន៍សមត្ថភាពស្រាវជ្រាវ និងគ្រប់គ្រងធនធានទឹក បានទទួលហិរញ្ញប្បទានពី ទីភ្នាក់ងារអភិវឌ្ឍន៍អន្តរជាតិរបស់ប្រទេសអូស្ត្រាលី (AusAID) ។ កម្មវិធីនេះ បាននិងកំពុងអនុវត្ត ដោយវិទ្យាស្ថានបណ្តុះបណ្តាល និងស្រាវជ្រាវដើម្បីអភិវឌ្ឍន៍កម្ពុជា ដោយរួមសហការណ៍ជាមួយ សាកលវិទ្យាល័យភូមិន្ទភ្នំពេញ និងសាកលវិទ្យាល័យស៊ីដនី ។ ដើម្បីឲ្យលទ្ធផលនៃការសិក្សា ស្រាវជ្រាវនេះ បានប្រកបដោយផ្លែផ្កា ក្នុងការចូលរួមអភិវឌ្ឍគោលនយោបាយគ្រប់គ្រងធនធានទឹក ចាប់តាំងពីខែកក្កដាឆ្នាំ២០០៦ មក វិទ្យាស្ថាន និងដៃគូរបស់ខ្លួន បានពិភាក្សាយ៉ាងសកម្មជាមួយ ក្រសួងធនធានទឹក និងឧតុនិយម ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ មន្ទីរធនធានទឹក និង ឧតុនិយមខេត្ត មន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនេសាទខេត្ត ក្រុមប្រឹក្សាស្រុក ឃុំ និងសហគមន៍កសិករ ប្រើប្រាស់ទឹក និងអង្គការក្រៅរដ្ឋាភិបាលដទៃទៀត ។ កម្មវិធីសិក្សាស្រាវជ្រាវនេះ នឹងត្រូវបញ្ចប់ក្នុង ខែមិថុនា ឆ្នាំ២០១១ ។ គោលដៅធំៗនៃកម្មវិធីសិក្សាស្រាវជ្រាវនេះ គឺ៖

១. បង្កើតចំណេះដឹងទាក់ទងនឹងការគ្រប់គ្រងប្រព័ន្ធធារាសាស្ត្រ
២. កសាងសមត្ថភាពស្រាវជ្រាវទាក់ទងនឹងការគ្រប់គ្រងធនធានទឹក និង
៣. ផ្សព្វផ្សាយរាល់ចំណេះដឹង ដែលបានមកពីការសិក្សាស្រាវជ្រាវនេះ ដើម្បីលើកកម្ពស់ការ គ្រប់គ្រងធនធានទឹកនៅក្នុងប្រទេសកម្ពុជា

ដើម្បីសម្រេចគោលដៅខាងលើ សមាសភាគចំនួនបី គឺ៖ សមាសភាគធារាសាស្ត្ររូបវន្ត សេដ្ឋកិច្ច និងអភិបាលកិច្ចល្អ ត្រូវបានអនុវត្ត ។ ប៉ុន្តែក្នុងអត្ថបទនេះ មានបង្ហាញតែលទ្ធផលនៃ សមាសភាគធារាសាស្ត្ររូបវន្តប៉ុណ្ណោះ នៅក្នុងការសិក្សាលើអាងស្ទឹងជ្រៃបាក់ ក្នុងខេត្តកំពង់ឆ្នាំង ។

## ២. សមាសភាគធារាសាស្ត្ររូបវ័ន្ត

### *២.១. បញ្ហាប្រឈម*

បញ្ហាមួយក្នុងការគ្រប់គ្រងធនធានទឹក គឺកង្វះចំណេះដឹងស្តីពីដំណើរការជលសាស្ត្រនៃ អាងស្ទឹង ។ ការស្វែងយល់ពីអន្តរអំពើក្នុងអាងស្ទឹង ដូចជា ដំណើរការជលសាស្ត្រពីខ្សែទឹកលើទៅ ខ្សែទឹកក្រោម បានផ្តល់ព័ត៌មាន យ៉ាងសំខាន់ ដល់ការគ្រប់គ្រងទឹកក្នុងអាងស្ទឹង (CDRI ២០០៨) ។

អន្តរអំពើទាំងអស់នេះ បានភ្ជាប់សហគមន៍ និងផ្នែកផ្សេងៗទៀតនៃការប្រើប្រាស់ទឹក ដូចជា បរិមាណទឹក គុណភាពទឹក ប្រព័ន្ធជីវៈចម្រុះ និងហេតុប៉ះពាល់បរិស្ថានក្នុងអាងស្ទឹងជាដើម ឲ្យមាន ទំនាក់ទំនងគ្នាដ៏ស្មុគស្មាញ ។ បម្រែបម្រួលណាមួយនៃដំណើរការជលសាស្ត្រ នៅផ្នែកខាងលើនៃ អាងស្ទឹង ដូចជា ការស្ទាក់ទឹក ការបូមទឹកពីស្ទឹង ជាដើម បានប៉ះពាល់យ៉ាងខ្លាំងដល់បរិមាណទឹក និង ការប្រើប្រាស់ទឹកនៅខ្សែទឹកខាងក្រោមនៃអាងស្ទឹង ។ កង្វះចំណេះដឹងស្តីពីដំណើរការជលសាស្ត្រ និងផលប៉ះពាល់នៃបម្រែបម្រួលជលសាស្ត្រ អាចបង្កការបរាជ័យក្នុងការគ្រប់គ្រងធនធានទឹក ។

បញ្ហាមួយទៀត គឺកង្វះខាតទឹកស្រោចស្រពរបស់ប្រជាកសិករ ។ បញ្ហានេះ បានប៉ះពាល់ ដល់ប្រាក់ចំណូលរបស់កសិករ ដែលជាការរាំងស្ទះដល់យុទ្ធនាការកាត់បន្ថយភាពក្រីក្រ ។ កង្វះខាត ទឹកក្នុងស្ទឹង បានបង្កឲ្យមានការខូចខាតដល់បរិស្ថាន និងជម្លោះរវាងសហគមន៍ ដែលជះឥទ្ធិពល អាក្រក់ដល់ភាពសុខដុមរម្យនា និងសុខមាលភាពសង្គម ។ កង្វះថវិកាជាកត្តាចំបងមួយទៀត ព្រោះ កង្វះថវិកានេះហើយ ដែលធ្វើឲ្យសង្គមប្រឈមនឹងកង្វះខាតហេដ្ឋារចនាសម្ព័ន្ធរូបវ័ន្ត ដើម្បីទាញយក ទឹកពីធម្មជាតិមកប្រើប្រាស់ ។ កង្វះខាតទឹកបណ្តាលមកពីកត្តារូបវ័ន្ត[៣] ក៏ជាបញ្ហាប្រឈមធំមួយដែរ ។ កង្វះខាតទឹកបង្កការប្រជែងគ្នាខ្ពស់ក្នុងការប្រើប្រាស់ទឹក ។ ដើម្បីជម្នះការលំបាក ដែលបណ្តាល មកពីកង្វះខាតទឹកតាមរដូវកាលនោះ ប្រព័ន្ធធារាសាស្ត្រ បានក្លាយជាជម្រើសនាំមុខគេ ដើម្បីបង្កើន សក្តានុពលរក្សាទឹកក្នុងរដូវវស្សា ទុកប្រើប្រាស់ក្នុងរដូវប្រាំង ។ ដូច្នេះ ប្រព័ន្ធធារាសាស្ត្រជាច្រើន ត្រូវបានកសាងឡើង ។ ទោះជាមានសំណង់ធារាសាស្ត្រច្រើនក៏ដោយ បើសំណង់ទាំងនោះពុំមាន គុណភាពល្អ និងរៀបចំឲ្យបានត្រឹមត្រូវទេ វាមិនអាចដោះស្រាយបញ្ហាខ្វះខាតទឹក និងគ្រប់គ្រងទឹក ជំនន់បានឡើយ ។

អាងស្ទឹងជ្រៃបាក់ ក្នុងខេត្តកំពង់ឆ្នាំង ត្រូវបានជ្រើសរើស ធ្វើជាទីតាំងករណីសិក្សាសម្រាប់ សមាសភាគធារាសាស្ត្ររូបវ័ន្ត ។ ទឹកក្នុងអាងស្ទឹងនេះ ត្រូវបានប្រើប្រាស់យ៉ាងទូលំទូលាយសម្រាប់ ការបង្កបង្កើនផលស្រូវវស្សា ស្រូវប្រាំង សួនដំណាំ ការប្រើប្រាស់តាមលំនៅដ្ឋាន ការងារសាធារណៈ និងការចិញ្ចឹមសត្វ ។ មានប្រព័ន្ធធារាសាស្ត្របួនកន្លែងដែលបានកសាងជាផ្លូវការ និងមួយកន្លែងទៀត កសាងដោយសហគមន៍ក្នុងមូលដ្ឋានដោយខ្លួនឯង ។ សំណង់ធារាសាស្ត្ររូបវ័ន្តសំខាន់ៗ មានដូចជា ទំនប់តូចៗ សំណង់ស្ទាក់ទឹកក្នុងស្ទឹង សំណង់បង្វៀរ ប្រឡាយស្រោចស្រព និងសំណង់ចែកចាយ ទឹកតូចធំមួយចំនួន ។

ការគ្រប់គ្រងប្រព័ន្ធធារាសាស្ត្រនៅក្នុងអាងស្ទឹងនេះ មានលក្ខណៈស្មុគស្មាញខ្លាំង ។ កង្វះខាត ទឹកស្រោចស្រព ក្នុងរដូវប្រាំង គឺជាកង្វល់ដ៏ធំរបស់មន្ទីរធនធានទឹក និងឧតុនិយម និងប្រជាកសិករ ។ ប្រព័ន្ធធារាសាស្ត្រ ដែលបានកសាងរួចមានលក្ខណៈមិនគ្រប់គ្រាន់ ខ្វះផែនការគ្រប់គ្រងចម្រុះប្រកប ដោយការចូលរួម ។ ថ្វីត្បិតតែក្នុងប្រព័ន្ធនីមួយៗ មានតំណាងសហគមន៍កសិករប្រើប្រាស់ទឹក ជាអ្នក គ្រប់គ្រង ប៉ុន្តែពួកគេផ្តោតតែលើប្រព័ន្ធធារាសាស្ត្ររៀងៗខ្លួន ដែលជាហេតុនាំឲ្យខ្វះការទទួលខុស ត្រូវរួមគ្នាក្នុងកម្រិតអាងស្ទឹងទាំងមូល ។ ការកសាងហេដ្ឋារចនាសម្ព័ន្ធធារាសាស្ត្ររូបវ័ន្តទៀតសោត ក៏ខ្វះទិន្នន័យជលសាស្ត្រ និងខ្វះការរៀបចំប្រព័ន្ធគ្រប់គ្រង ដើម្បីផលប្រយោជន៍សង្គមនៃប្រព័ន្ធ ធារាសាស្ត្រទាំងនោះ (CDRI 2010) ។

មុនឆ្នាំ២០០៧ ការសហការគ្នារវាងសហគមន៍កសិករប្រើប្រាស់ទឹក នៃប្រព័ន្ធធារាសាស្ត្រ នៅខ្សែទឹកខាងលើ និងខ្សែទឹកខាងក្រោម កម្រកើតមានណាស់ ។ ការសហការគ្នាដែលបានធ្វើ ម្តងម្កាលនោះ ក៏ពុំសូវមានលទ្ធផលល្អដែរ ។ ការប្រជែងគ្នាយកទឹកស្រោចស្រព ចេះតែកើតមានរវាង សហគមន៍ស្រោចស្រពនៅខ្សែទឹកខាងលើ និងខាងក្រោម ជារៀងរាល់ឆ្នាំ កម្រលោះពេលណាស់ ។

៣ កង្វះខាតទឹកបណ្តាលមកពីកត្តារូបវ័ន្ត សំដៅលើការខ្វះខាតទឹក បណ្តាលមកពីកត្តាធម្មជាតិ (ដូចជា បម្រែ បម្រួលអាកាសធាតុជាដើម) ឬ បង្កដោយមនុស្ស ដែលធ្វើឲ្យគ្មានទឹកនៅក្នុងអាងស្ទឹង ។

បញ្ហានេះ ក៏ចេះតែបន្តរហូតមកដល់សព្វថ្ងៃ ។ បើសិនជាកង្វះខាតព័ត៌មានជលសាស្ត្រ ការគ្រប់គ្រងធនធានទឹក និងកិច្ចសហការគ្នាមិនល្អ នៅតែមានបន្តទៀតនោះ ការគ្រប់គ្រង និងការប្រើប្រាស់ទឹកក្នុងអាងស្ទឹងនេះ នឹងមានភាពស្មុគស្មាញកាន់តែខ្លាំងឡើងថែមទៀត ។ ការរៀបចំរបៀបគ្រប់គ្រងថ្មី ដែលណែនាំនូវវិធីសាស្ត្រល្អៗ ដើម្បីជាផលប្រយោជន៍របស់សហគមន៍ក្នុងការបង្កើនចំណូលសេដ្ឋកិច្ចគ្រួសារ គួរត្រូវបានសិក្សា និងបង្កើតឡើង ។

## ២.២. សំណួរស្រាវជ្រាវ

ដើម្បីសិក្សាស្រាវជ្រាវលើវិធីសាស្ត្រគ្រប់គ្រងទាំងនោះ សមាសភាគធារាសាស្ត្ររូបវន្ត បានផ្តោតសំខាន់លើសំណួរសិក្សាស្រាវជ្រាវ២ គឺ៖

១. តើចំណេះដឹងផ្នែកជលសាស្ត្រមានតួនាទីអ្វីខ្លះ ក្នុងការលើកកម្ពស់សមភាព និងនិរន្តរភាពនៃការប្រើប្រាស់ធនធានទឹក សម្រាប់បម្រើការផលិតស្បៀងអាហារ និងផលិតកម្មកសិកម្ម?

២. តើមានបញ្ហាសំខាន់ៗអ្វីខ្លះ ដែលរាំងស្ទះដល់ការអនុវត្តការបែងចែកទឹកស្រោចស្រពប្រកបដោយសមភាព ពាក់ព័ន្ធនឹងការរៀបចំស្ថាប័នគ្រប់គ្រងអាងស្ទឹង?

## ២.៣. គោលបំណង

គោលបំណងសំខាន់នៃការសិក្សាស្រាវជ្រាវនេះ គឺដើម្បីបង្កើតចំណេះដឹងស្តីពីអន្តរកម្ម រវាងការប្រើប្រាស់ទឹក ប្រព័ន្ធធារាសាស្ត្ររូបវន្ត ស្ថាប័ន និងគោលនយោបាយជុំវិញការគ្រប់គ្រងអាងស្ទឹងក្នុងបរិបទនៃការអភិវឌ្ឍធារាសាស្ត្រ និងការចិញ្ចឹមជីវិតរបស់ប្រជាកសិករ ។ ការសិក្សាស្រាវជ្រាវនេះផ្តោតលើទិដ្ឋភាពពីរយ៉ាង គឺ៖ ជលសាស្ត្រនៃអាងស្ទឹង និង គោលនយោបាយគ្រប់គ្រងធនធានទឹក ។

វត្ថុបំណងជាប់ទាក់ទងនឹងទិដ្ឋភាពទីមួយ គឺបង្កើតចំណេះដឹងជលសាស្ត្រលើអាងស្ទឹង ។ ដើម្បីសម្រេចបាននូវគោលបំណងនេះ ការសិក្សាស្រាវជ្រាវ បានបង្កើតបណ្តាញប្រមូលទិន្នន័យជលសាស្ត្រ និងឧតុនិយម ក្នុងអាងស្ទឹង និងវិភាគធារទឹកស្ទឹង ដើម្បីស្វែងយល់ពីបម្រែបម្រួលធារទឹកតាមរដូវ ។

វត្ថុបំណងទាក់ទងនឹងទិដ្ឋភាពទីពីរ គឺលើកកម្ពស់សមធម៌នៃការប្រើប្រាស់ទឹកសម្រាប់កសិកម្ម និងជំរុញការគ្រប់គ្រងធនធានទឹក និងធនធានធម្មជាតិដទៃទៀត ក្នុងអាងស្ទឹងឲ្យមាននិរន្តរភាព ។ ការសិក្សាដោយមានការចូលរួម និងការស្រាវជ្រាវសកម្ម សំដៅកំណត់ឲ្យបាននូវបញ្ហាប្រឈម និងកាលានុវត្តភាពនៃការដោះស្រាយបញ្ហា ដើម្បីលើកកម្ពស់ការគ្រប់គ្រងអាងស្ទឹង ។

# ៣. ប្រវត្តិនៃការគ្រប់គ្រងធនធានទឹក

ប្រវត្តិនៃការគ្រប់គ្រងធនធានទឹកនៅព្រះរាជាណាចក្រកម្ពុជា ត្រូវបានកត់ត្រាច្បាស់លាស់ចាប់តាំងពីសតវត្សទីពីរនៃគ្រិស្តសករាជ ពេលដែលប្រទេសនេះគេហៅថា នគរហ្វូណន់ ។ ខឿនសេដ្ឋកិច្ចរបស់នគរហ្វូណន់ គឺការធ្វើពាណិជ្ជកម្ម ។ ប៉ុន្តែចាប់តាំងពីសតវត្សទីប្រាំពីរតរៀងមក ខឿនសេដ្ឋកិច្ចនៃប្រទេសនេះ បានពឹងផ្អែកលើវិស័យកសិកម្មវិញ ដោយបានដាំដំណាំស្រូវ ដំណាំយកមើម និងការចិញ្ចឹមសត្វ (Vickery 1998) ។ ភាពល្បីរន្ទឺស្តីពី ការគ្រប់គ្រងទឹកគឺមានក្នុងសម័យអង្គរ នៅរវាងសតវត្សទី៩ ដល់សតវត្សទី១៤ ។ កម្ពុជាពូកែគ្រប់គ្រងទឹក ដើម្បីធ្វើកសិកម្ម ។ ទឹកភ្លៀង និងទឹកទន្លេ ត្រូវបានគ្រប់គ្រងក្នុងទំនប់អាង ដែលមានប្រព័ន្ធប្រឡាយខ្វាត់ខ្វែង ដូចជាបារាយទឹកថ្លាខាងលិច ក្នុងខេត្តសៀមរាបជាដើម ទុកសម្រាប់ការស្រោចស្រព និងការប្រើប្រាស់តាមលំនៅដ្ឋាន

(Kummu 2003) ។ ប្រព័ន្ធធារាសាស្ត្រទាំងនេះ បានផ្តល់អត្ថិភាពដល់ការបង្កបង្កើនផលស្រូវបានច្រើនដងក្នុងមួយឆ្នាំ ដែលបានលើកកម្ពស់កិត្យានុភាពសេដ្ឋកិច្ចរបស់ប្រទេសនាសម័យនោះ (Chandler 1993) ។ ប៉ុន្តែចាប់ពីសម័យក្រោយអង្គរចំណេរតមក ការគ្រប់គ្រងទឹកបានធ្លាក់ចុះ ។ ប្រជារាស្ត្រធ្វើស្រែ គឺសម្រាប់គ្រាន់តែមួយរស់ ។ ហេតុផលមួយនៃការធ្លាក់ចុះនេះ គឺការខូចខាតបរិស្ថាន ។ ហេតុផលដទៃទៀតមានដូចជា កង្វះអភិបាលកិច្ចល្អ ដែលបណ្តាលមកពីការធ្លាក់ចុះនៃសេដ្ឋកិច្ចជាតិ សង្គ្រាម និងជម្លោះផ្ទៃក្នុង នាសម័យកនោះ ។ ហេតុផលទាំងនេះ នាំឲ្យខ្វះការយកចិត្តទុកដាក់លើការគ្រប់គ្រង បណ្តោយឲ្យប្រព័ន្ធធារាសាស្ត្រដែលបានកសាងរួចទាំងនោះលែងដំណើរការ និងខូចខាតទៅវិញ ។

ក្នុងសម័យក្រោយៗមកទៀត មានសម័យក្រោយអង្គរ (១៤៣១ ដល់ ១៨៦២) សម័យអាណានិគមបារាំង (១៨៦៣ ដល់ ១៩៥៣) សម័យសង្គមរាស្ត្រនិយម (១៩៤១ ដល់ ១៩៦៩) សម័យសាធារណរដ្ឋ លន់ ណុល (១៩៧០ ដល់ ១៩៧៥) និងសម័យ ប៉ុល ពត (១៩៧៥ ដល់ ១៩៧៨) ការគ្រប់គ្រងធនធានទឹក និងស្ថានភាពសេដ្ឋកិច្ច ក៏ស្ថិតក្នុងសភាពធ្លាក់ចុះដែរ ។ ក្នុងសម័យទាំងនេះ ប្រជាកសិករចំណាយពេលវេលាយ៉ាងច្រើន ដើម្បីធ្វើស្រែចម្ការ ប៉ុន្តែពួកគេខ្វះមធ្យោបាយបច្ចេកទេស ខ្វះប្រព័ន្ធធារាសាស្ត្រ បានបណ្តាលឲ្យជីវភាពធ្លាក់ចុះយ៉ាងខ្លាំង ។ គេសង្កេតឃើញថា ក្នុងទសវត្សរ៍១៩២០ សេដ្ឋកិច្ចកម្ពុជា បានងើបឡើងវិញ ។ ថវិកា ដែលបានមកពីពន្ធដារត្រូវបានប្រើប្រាស់ ដើម្បីអភិវឌ្ឍវិស័យមួយចំនួន ។ ដោយផ្លូវគមនាគមន៍មានការរីកចម្រើន កម្ពុជាបាននាំចេញស្រូវអង្ករ និងកៅស៊ូរាប់សែនតោន ។ ការនាំចេញទាំងនេះ ជាប្រភពចំណូលរបស់រដ្ឋតាមរយៈការបង់ពន្ធដារ ដែលបង្កលក្ខណៈឲ្យរដ្ឋអាចអភិវឌ្ឍគមនាគមន៍ អគ្គិសនី និងវិស័យអប់រំបានល្អប្រសើរ (Chandler 1993) ។

អ្វីដែលប្រែប្រួលខ្លាំងក្នុងវិស័យធារាសាស្ត្រ គឺក្នុងរបប ប៉ុល ពត (១៩៧៥ ដល់ ១៩៧៩) ។ ប្រជាជនកម្ពុជាទាំងអស់ត្រូវបានប្រមូលផ្តុំ ដើម្បីធ្វើស្រែចម្ការ និងកសាងប្រព័ន្ធធារាសាស្ត្រ ។ ប៉ុន្តែភាគច្រើននៃប្រព័ន្ធទាំងនោះ បានកសាងដោយខ្វះបច្ចេកទេស បណ្តាលឲ្យវាដំណើរការមិនល្អ បង្កការស្មុគស្មាញដល់ការគ្រប់គ្រងធនធានក្នុងពេលបច្ចុប្បន្ននេះទៅវិញ ។

ការកសាងប្រព័ន្ធធារាសាស្ត្រក្នុងឆ្នាំ១៩៧៩ ដល់ ១៩៩៨ មានលក្ខណៈបន្ទាន់ ដើម្បីបំពេញតម្រូវការស្បៀងរបស់ប្រជាជន ។ ក្នុងពេលនោះ ហិរញ្ញប្បទានភាគច្រើនបានមកពីជំនួយបរទេស ដូចជា អង្គការសហប្រជាជាតិ និងអង្គការអន្តរជាតិនានា ។ ប្រព័ន្ធធារាសាស្ត្រ ដែលបានកសាងក្នុងពេលនោះ ក៏មានដំណើរការមិនសូវល្អដែរ ព្រោះប្រព័ន្ធភាគច្រើនមានតែហេដ្ឋារចនាសម្ព័ន្ធមេ ដូចជា ទំនប់ ប្រឡាយ ប៉ុន្តែនៅខ្វះសំណង់សិល្បៈការសម្រាប់ចែកចាយទឹក ហើយរចនាសម្ព័ន្ធគ្រប់គ្រងក៏នៅពុំទាន់រឹងមាំ ។

រដ្ឋកាលថ្មីនៃការគ្រប់គ្រងធនធានទឹក គឺចាប់ពីឆ្នាំ១៩៩៩ ពេលដែលក្រសួងធនធានទឹកត្រូវបានបង្កើតឡើង អមដោយមន្ទីរជំនាញគ្រប់ខេត្តក្រុង ហើយសហគមន៍កសិករប្រើប្រាស់ទឹក (សកបទ) ក៏ត្រូវបានបង្កើតផងដែរ ។ ក្នុងរបត់ថ្មីនេះ ហេដ្ឋារចនាសម្ព័ន្ធដែលបម្រើឲ្យការបង្កបង្កើនផលស្រូវវស្សា និងស្រូវប្រាំង ត្រូវបានលើកកម្ពស់ ។ ផ្ទៃដីប្រហែល ៤៣% បានទទួលទឹកស្រោចស្រព[៤] (MOWRAM 2009) ។ កាលពីឆ្នាំ២០០៦ ផ្ទៃដីស្រោចស្រព មានប្រហែល ៣២% (Sakhon 2007 ត្រូវបានសរសេរក្នុង Phalla និង Craig 2008) ។ ក្នុងឆ្នាំ២០០៨ ផ្ទៃដីស្រោចស្រពបានកើនឡើងចំនួន ១១% បើប្រៀបធៀបនឹងឆ្នាំ២០០៦ ។

---

៤ ក្នុងផ្ទៃដីបង្កបង្កើនផលស្រូវ ២,៦លានហិកតា ក្នុងឆ្នាំ២០០៨ មានផ្ទៃដី ១,១២លានហិកតាទទួលបានទឹកស្រោចស្រពពីប្រព័ន្ធធារាសាស្ត្រ ។

## ៤. ច្បាប់ និងគោលនយោបាយស្តីពីការគ្រប់គ្រងធនធានទឹក

គោលនយោបាយនាំចេញអង្ករ គឺដើម្បីលើកកម្ពស់សេដ្ឋកិច្ចជនបទ និងកាត់បន្ថយភាពក្រីក្ររបស់ប្រជាជន ។ ទឹកជាកត្តាជំរុញផលិតកម្មស្រូវ ។ កំណើនប្រជាជន និងសេដ្ឋកិច្ចជាកត្តាកំណត់ដើម្បីអភិវឌ្ឍកសិកម្ម និងទឹក ។ ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ និងក្រសួងធនធានទឹក និងឧតុនិយម មានភារកិច្ចរួមគ្នា ក្នុងការគ្រប់គ្រង និងអភិវឌ្ឍវិស័យកសិកម្ម និងទឹក ។ ក្នុងកិច្ចសហការណ៍របស់ក្រសួងទាំងពីរ រាជរដ្ឋាភិបាល បានបង្កើតក្រុមការងារបច្ចេកទេសកសិកម្ម និងទឹក (Technical Working Group on Agriculture and Water - TWGAW) ក្នុងគោលដៅសម្របសម្រួលការអភិវឌ្ឍក្នុងវិស័យទាំងពីរ ។ ក្នុងឆ្នាំ ២០០៧ តាមរយៈ TWGAW ក្រសួងទាំងពីរ បានបង្កើតយុទ្ធសាស្ត្រអភិវឌ្ឍន៍កសិកម្ម និងទឹកសម្រាប់ឆ្នាំ២០០៦ ដល់ឆ្នាំ ២០១០ និងក្រោយមកបានកែទម្រង់ទៅជាយុទ្ធសាស្ត្រអភិវឌ្ឍន៍កសិកម្ម និងទឹក សម្រាប់ឆ្នាំ២០០៩ ដល់ឆ្នាំ ២០១៣ (MAFF និង MOWRAM 2007 និង 2010) ។

ការអភិវឌ្ឍទាំងនេះ ក៏យោងតាមចក្ខុវិស័យស្តីពីការគ្រប់គ្រងធនធានទឹក ដែល (១) បង្កើនការទទួលបានសុវត្ថិភាពទឹកប្រើប្រាស់ មានដូចជា ទឹកបរិភោគ កសិកម្ម ឧស្សាហកម្ម និងវិស័យសេដ្ឋកិច្ចដទៃទៀត (២) ដោះស្រាយនិងកាត់បន្ថយការគំរាមកំហែង ការបាត់បង់ជីវិត និងជីវភាពរស់នៅរបស់ប្រជាជន ដែលបណ្តាលមកពីគ្រោះធម្មជាតិ (៣) ការគ្រប់ធនធានទឹកប្រកបដោយនិរន្តរភាព ។ ដោយកសិករពឹងផ្អែកទាំងស្រុងលើធនធានទឹក ក្នុងការបង្កបង្កើនផល កំណើននៃការទទួលបានទឹកស្រោចស្រព គឺជាការចាំបាច់ ។

ដើម្បីសម្រេចបាននូវចក្ខុវិស័យខាងលើនេះ ក្រសួងធនធានទឹក បានបង្កើតនូវផែនការសកម្មភាពយុទ្ធសាស្ត្រ ជំហានទីពីរ ២០០៩ ដល់ ២០១៣ ។ ផែនការសកម្មភាពយុទ្ធសាស្ត្រនេះ សំដៅពង្រឹងការអនុវត្តច្បាប់[៥] និងគោលនយោបាយ[៦] ស្តីពីការគ្រប់គ្រងធនធានទឹក ។ ការអនុវត្តគោលនយោបាយទាំងនេះ មានបំណងលើកកម្ពស់សេដ្ឋកិច្ចជាតិ និងសុខមាលភាពសង្គម ។ លក្ខណៈវិនិច្ឆ័យមួយចំនួន ដូចជា ពង្រឹងវិស័យកសិកម្ម ជួសជុល និងកសាងហេដ្ឋារចនាសម្ព័ន្ធរូបវ័ន្ត ជំរុញការចូលរួមរបស់វិស័យឯកជន បង្កើនឱកាសការងារ និងការកសាងធនធានមនុស្ស ត្រូវបានលើកឡើង និងអនុវត្តក្នុងផែនការយុទ្ធសាស្ត្រ (MOWRAM ២០០៩) ។

## ៥. តម្លៃនៃចំណេះដឹងជលសាស្ត្រ ក្នុងការគ្រប់គ្រងអាងស្តឹង ឬអាងទន្លេ

ការគ្រប់គ្រងធនធានទឹក គឺដើម្បីដោះស្រាយបញ្ហាបម្រែបម្រួលជលសាស្ត្រ ដែលបង្កឡើងដោយបាតុភូតធម្មជាតិ ដូចជា ទឹកជំនន់ និងការរាំងស្ងួត ជាដើម ។ បម្រែបម្រួលជលសាស្ត្រ អាចប៉ះពាល់សង្គម សេដ្ឋកិច្ច និងបរិស្ថាន ។ ដូច្នេះ ចំណេះដឹងផ្នែកជលសាស្ត្រ មានសារៈសំខាន់ណាស់ក្នុងការគ្រប់គ្រងទឹក ជាពិសេស ក្នុងពេលរៀបចំអភិវឌ្ឍគម្រោង និងលើកផែនការគ្រប់គ្រង ។ តួនាទីរបស់ចំណេះដឹងជលសាស្ត្រក្នុងការរៀបចំគម្រោង អាចប្រែប្រួល អាស្រ័យទំហំនៃគម្រោង ។ ឧទាហរណ៍ ការសិក្សាជលសាស្ត្របន្តិចបន្តួច ប្រហែលជាអាចអនុវត្តបានចំពោះគម្រោងអភិវឌ្ឍន៍ធារាសាស្ត្រខ្នាតតូច ព្រោះបម្រែបម្រួលជលសាស្ត្រនៃអាងស្តឹងធៀបនឹងកម្រិតមធ្យម គឺមានភាពខុសគ្នាតិចតួច ។ ប៉ុន្តែចំពោះ គម្រោងអភិវឌ្ឍន៍ធារាសាស្ត្រខ្នាតធំវិញ គេត្រូវការភាពសុក្រិតកម្រិតខ្ពស់នៃការសិក្សាជលសាស្ត្រ ព្រោះបម្រែបម្រួលជលសាស្ត្រនៃអាងស្តឹង ធៀបនឹងកម្រិតមធ្យម មានភាពខុសគ្នាធំ ។ ដូច្នេះ តម្រូវការផ្នែកទិន្នន័យ អាចទាមទាររយៈពេលវែង ឬខ្លី អាស្រ័យលើ

៥ ច្បាប់ស្តីពីការគ្រប់គ្រងធនធានទឹកនៃព្រះរាជាណាចក្រកម្ពុជាឆ្នាំ២០០៧ ។

៦ គោលនយោបាយជាតិ ស្តីពីការគ្រប់គ្រងធនធានទឹកនៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៤ ។

ទំហំនៃការអនុវត្តគម្រោង ដើម្បីឲ្យមានទិន្នន័យគ្រប់គ្រាន់សម្រាប់វិភាគស្ថិតិជលសាស្ត្រ (Fenemor *et al.* 2003) ។

## ៦. វិធីសាស្ត្រថ្មី ដើម្បីគ្រប់គ្រងធនធានទឹក ក្នុងបរិបទនៃការកែលម្អធារាសាស្ត្ររូបវ័ន្ត និងសង្គម

មានសហគមន៍ជាច្រើនជួបនឹងការខ្វះខាតទឹកប្រើប្រាស់ ។ គេរំពឹងថា បញ្ហានេះអាចរីកធំឡើងថែមទៀតក្នុងថ្ងៃអនាគត ដែលជាលទ្ធផលនៃបម្រែបម្រួលអាកាសធាតុ និងកំណើនការប្រើប្រាស់ទឹក ។ អាស្រ័យហេតុនេះ ប្រទេសកម្ពុជាបានសម្រេចអនុវត្តវិធីសាស្ត្រគ្រប់គ្រងធនធានទឹកចម្រុះ (IWRM-Integrated Water Resources Management) ដូចមានចែងក្នុងច្បាប់ស្តីពីការគ្រប់គ្រងធនធានទឹក ឆ្នាំ២០០៧ គោលនយោបាយស្តីពីការគ្រប់គ្រងធនធានទឹក ឆ្នាំ២០០៤ ជាដើម ។ម្យ៉ាងទៀត វិធីសាស្ត្រគ្រប់គ្រងអាងស្តុង (ឬអាងទន្លេ) ចម្រុះប្រកបដោយការចូលរួម (PICM-Participatory Integrated Catchment Management) គឺជាផ្នែកមួយនៃវិធីសាស្ត្រគ្រប់គ្រងធនធានទឹកចម្រុះ ហើយវិធីសាស្ត្រនេះ ត្រូវបានទទួលស្គាល់ និងអនុវត្តក្នុងបណ្តាប្រទេសជាច្រើនក្នុងពិភពលោកយើងនេះ ដើម្បីជំនួសការអភិវឌ្ឍតាមបែបឯកវិស័យ ។ មានការសិក្សាជាច្រើន បានធ្វើឡើង ដើម្បីវាយតម្លៃការអនុវត្តវិធីសាស្ត្រនេះ មានជាអាទិ៍ German និងអ្នកផ្សេងទៀត (២០០៦) ជាដើម ។ ការសិក្សារបស់ German បានវាយតម្លៃលើគោលការណ៍គ្រឹះ ផលប្រយោជន៍ និងវិធីសាស្ត្រគ្រប់គ្រងអាងស្តុងចម្រុះប្រកបដោយការចូលរួម ថាជា វិធីសាស្ត្រមួយប្រកបដោយសក្តានុពលសម្រាប់លើកស្ទួយការគ្រប់គ្រងទឹកប្រកបដោយនិរន្តរភាពខ្ពស់ ។

វិធីសាស្ត្រអាចអនុវត្តបានក្នុងគ្រប់ផ្នែកនៃវិទ្យាសាស្ត្រពិត និងវិទ្យាសាស្ត្រសង្គម ។ អ្នកក្សេត្រវិទូមើលឃើញ PICM ថាជា វិធីសាស្ត្រដើម្បីជួយពង្រីកបច្ចេកវិទ្យាសម្រាប់អភិរក្សធនធានទឹក និងធនធានដី ។ រីឯអ្នកឯកទេសក្នុងវិស័យធនធានទឹក មើលឃើញវិធីសាស្ត្រគ្រប់គ្រងធនធានទឹកប្រកបដោយការចូលរួម ថាបាន ជួយពង្រឹងបន្ថែមលើការផ្តល់សេវាបរិស្ថាន និងសេវាសាធារណៈដទៃទៀតដល់សហគមន៍ជនបទ (German *et al.* 2006) ។ ចំណែកអ្នកអភិរក្សធនធានធម្មជាតិ បានមើលឃើញវិធីសាស្ត្រនេះ ថាបាន ជួយពង្រឹងទំនាក់ទំនងអន្តរវិស័យ និងរដ្ឋបាលក្នុងការគ្រប់គ្រងធនធានធម្មជាតិ (van de Linde *et al.* 2001 ដូចមានចុះ German *et al.* 2001) ។ ក្នុងចំណោមអ្នកសង្គមវិទូ វិធីសាស្ត្រគ្រប់គ្រងអាងស្តុង (ឬអាងទន្លេ) ចម្រុះ គឺជារបៀបវារៈនៃការងារសមូហភាពសមភាពនៃការប្រើប្រាស់ និងអភិបាលកិច្ចលើធនធានធម្មជាតិ ដែលការងារនេះមិនអាចដោះស្រាយដោយអាជ្ញាធរមូលដ្ឋាន ។

វិធីសាស្ត្រគ្រប់គ្រងអាងស្តុង ឬអាងទន្លេចម្រុះ ត្រូវមានលក្ខណៈពីរយ៉ាង ។ ទី១ ការកំណត់បញ្ហាគន្លឹះសម្រាប់ដោះស្រាយ ការលើកផែនការ និងការអនុវត្ត ត្រូវតែប្រកបដោយការចូលរួមពីអ្នកពាក់ព័ន្ធ ។ ទី២ ការអភិវឌ្ឍអាងស្តុង ឬអាងទន្លេ ត្រូវបានធ្វើឡើងប្រកបដោយ ពហុជំនាញ (វិស័យ) ដែលបានឆ្លុះបញ្ចាំងលទ្ធភាពបច្ចេកទេស សង្គម និងការរៀបចំស្ថាប័ន (German *et al.* ២០០៦) ។ការអនុវត្តវិធីសាស្ត្រគ្រប់គ្រងអាងស្តុង (ឬអាងទន្លេចម្រុះ) ប្រកបដោយការចូលរួម អាចមានគោលដៅ ដើម្បីអភិរក្សធនធានធម្មជាតិ បង្កើនសន្តិសុខស្បៀង និង/ឬ បង្កើនប្រាក់ចំណូល (German *et al.* 2006) ។

## ៧. វិធីសាស្ត្រសិក្សាស្រាវជ្រាវ

ការសិក្សាប្រកបដោយការចូលរួម និងការស្រាវជ្រាវសកម្ម

ការសិក្សានេះ បានប្រើវិធីសាស្ត្រ *ការសិក្សាប្រកបដោយការចូលរួម និងស្រាវជ្រាវសកម្ម* និងសិក្សាជលសាស្ត្រប្រកបដោយការចូលរួម ដើម្បីអភិវឌ្ឍចំណេះដឹងទាំងឡាយទាក់ទិននឹងជលសាស្ត្រអាងស្ទឹង និងវិភាគរកហេតុផលនៃបញ្ហា សំដៅកំណត់ទិសដៅ និងកាលានុវត្តភាព សម្រាប់ដោះស្រាយបញ្ហា ព្រមទាំងកែលម្អការគ្រប់គ្រងប្រព័ន្ធធារាសាស្ត្រ ក្នុងបរិបទនៃការគ្រប់គ្រងអាងស្ទឹង ឬអាងទន្លេ ។ វិធីសាស្ត្រ ការសិក្សាប្រកបដោយការចូលរួម ជាផ្នែកមួយនៃវិធីសាស្ត្រចង្កោម ដែលរួមមាន ការវាយតម្លៃជនបទប្រកបដោយការចូលរួម (PRA-Participatory Rural Appraisal) ការវាយតម្លៃជនបទរហ័ស (RRA-Rapid Rural Appraisal) ។ល។ ខ្លឹមសាររួមរបស់វិធីសាស្ត្រទាំងអស់នេះ គឺបង្កលក្ខណៈឲ្យអ្នកចូលរួម បានចូលរួមយ៉ាងពេញលេញនៅក្នុងដំណើរការសិក្សាពីសេចក្ដីត្រូវការ កាលានុវត្តភាព ផែនការសកម្មភាព និងសកម្មភាពត្រូវអនុវត្ត ដើម្បីដោះស្រាយបញ្ហា និងបំពេញតម្រូវការចាំបាច់ទាំងអស់នោះ (IIED & CTA 2006) ។

សកម្មភាពក្នុងការអនុវត្តវិធីសាស្ត្រនេះ រួមមាន៖ ការអង្កេតដោយផ្ទាល់នៅទីតាំងជាក់ស្ដែង និងការពិភាក្សាជាក្រុម ដើម្បីជំរុញ ការចូលរួមសិក្សា ការផ្លាស់ប្ដូរបទពិសោធន៍ និងចំណេះដឹង និងវិភាគរចនាសម្ព័ន្ធគ្រប់គ្រង ។ គោលការណ៍សំខាន់ៗ ដើម្បីអនុវត្តវិធីសាស្ត្រ ការសិក្សាប្រកបដោយការចូលរួម មានដូចជា៖

- កំណត់វិធីសាស្ត្រ និងប្រព័ន្ធសិក្សាដោយអ្នកចូលរួម តាមរយៈ ការវិភាគរួមគ្នា និងប្រទាក់ក្រឡាគ្នា
- បង្កើតទស្សនវិស័យចម្រុះ ដែលឆ្លុះបញ្ចាំងដំណោះស្រាយផ្សេងៗដែលមានការពិត និងដំណោះស្រាយត្រូវបានលើកឡើងដោយអ្នកពាក់ព័ន្ធ (ត្រូវឲ្យមានលក្ខណៈចម្រុះ)
- ការពិភាក្សា ត្រូវរៀបចំជាក្រុម ប្រកបដោយការពិភាក្សាសកម្ម
- ប្រធានបទពិភាក្សា ត្រូវស្ថិតក្នុងបរិបទមួយជាក់លាក់ ហើយការរៀបចំដំណើរការពិភាក្សាត្រូវប្រកបដោយការយល់ព្រម និងសមស្របតាមស្ថានភាពមូលដ្ឋាន ។ បើអាចធ្វើបាន ដំណើរការពិភាក្សា ត្រូវរៀបចំដោយម្ចាស់មូលដ្ឋាន ដើម្បីឲ្យពួកគាត់មានភាពជាម្ចាស់លើដំណើរការពិភាក្សានោះ
- អ្នកស្រាវជ្រាវជាអ្នកសម្របសម្រួល ប៉ុន្តែមិនមែនជាអ្នកដឹកនាំទេ ។ អ្នកស្រាវជ្រាវដើរតួជាអ្នកស្ដាប់ និងជាអ្នកវិភាគ ដែលមកពីក្រៅសហគមន៍ ហើយត្រូវប្រើប្រាស់ព័ត៌មាន និងលទ្ធផលវិភាគ ដើម្បីសម្រេចថា តើគួរធ្វើដូចម្ដេចចំពោះទិន្នន័យដែលបានមកពីការពិភាក្សានេះ ។ អ្នកស្រាវជ្រាវ អាចជ្រើសរើសយកព័ត៌មាន ដែលបានមកពីការពិភាក្សា ដើម្បីវិភាគ និងផ្ដល់អនុសាសន៍ដល់ដំណើរការកសាងគោលនយោបាយរបស់រដ្ឋាភិបាល
- ការពិភាក្សារួមគ្នាបែបនេះ អាចកំណត់ទិសដៅ ដើម្បីធ្វើឲ្យមានការផ្លាស់ប្ដូរអ្វីមួយ ដែលបំលាស់ប្ដូរនោះ អាចនាំមកនូវការកែលម្អការគ្រប់គ្រង និងអាចកំណត់ផែនការសកម្មភាពឲ្យសហគមន៍អនុវត្តនូវកំណែទម្រង់នោះ ។

## ៨. ករណីសិក្សា

ការសិក្សានេះបានអនុវត្តករណីសិក្សានៅក្នុងអាងស្ទឹងជ្រៃបាក់ ខេត្តកំពង់ឆ្នាំង ។ ក្បាលស្ទឹងជ្រៃបាក់ ហូរមកពីស្ទឹងជ្រាវ ស្ថិតក្នុងខេត្តកំពង់ស្ពឺ ហើយហូរកាត់ស្រុកទឹកផុស និងស្រុករលៀប្អៀរ រួចហូរចាក់ចូលទៅក្នុងទន្លេសាប ។ ស្ទឹងនេះ ចែកចេញជាបីកំណាត់ ដែលអ្នកស្រុកបានឲ្យឈ្មោះ

ផ្សេងៗគ្នា ពីខ្សែទឹកលើ មកខ្សែទឹកក្រោមថា៖ ស្ទឹងស្រែបាក់ ស្ទឹងគង្ហារ និងស្ទឹងជ្រៃបាក់ ដែលមាន ប្រវែងសរុប ៨០គម និងផ្ទៃក្រឡា ៧៩១គម$^{២}$ ។ មានប្រព័ន្ធធារាសាស្ត្រចំនួនបួនកន្លែង ដែលមាន សំណង់បេតុង សំណង់ដី និងប្រឡាយ ដែលរាប់ពីលើមកក្រោមមានឈ្មោះ ប្រព័ន្ធស្រោចស្រព ប៉ក់ប៉ែន ស្វាយចេក តាំងក្រសាំង និងត្រពាំងត្របែក ។

ក្រាហ្វិក ១៖ អាងស្ទឹងជ្រៃបាក់ ក្នុងខេត្តកំពង់ឆ្នាំង




## ៩ លទ្ធផលសំខាន់ៗ

បរិមាណធារទឹកក្នុងស្ទឹង៖

ការវាស់ធារទឹក និងកម្ពស់ទឹកត្រូវបានធ្វើឡើងជាបន្តបន្ទាប់ ដោយនាយកដ្ឋានជលសាស្ត្រ និង ការងារទន្លេ នៃក្រសួងធនធានទឹក និងឧតុនិយម ក្នុងឆ្នាំ២០០៧ និង ២០០៨ ។ ទិន្នន័យនេះ ត្រូវ បានប្រើដើម្បីបង្កើតរូបមន្តសម្រាប់គណនាធារទឹក នៅជីប្រ៉ង (ក្រាហ្វិក ១) ។ រូបមន្តសមីការខ្សែកោង បានរកឃើញថា៖ $Q = 13.259(H - 0.375)2.029$ ។ ធារទឹកប្រចាំខែ ត្រូវបានកំណត់ថាជាបរិមាណ ទឹក ដែលមានក្នុងស្ទឹងក្នុងខែនោះ ។ ការសិក្សានេះរកឃើញថា ធារទឹកប្រចាំឆ្នាំ គឺ ២៨៤លានម៉ែត្រគូប ដែល ៨៩% នៃបរិមាណនេះមានក្នុងរដូវវស្សា ។ ធារទឹកអតិបរមារបស់ស្ទឹងកើតមានក្នុងចន្លោះ ខែកញ្ញា និង វិច្ឆិកា ដែលមានប្រហែល ៥៨% នៃបរិមាណធារទឹកប្រចាំឆ្នាំ (ក្រាហ្វិក ២) ។

ក្រាហ្វិក ២៖ អ៊ីដ្រូក្រាហ្វធារទឹកមធ្យមប្រចាំខែ នៃឆ្នាំ២០០៧ និង២០០៨




សក្តានុពលទឹកនៃអាងស្ទឹង និងតម្រូវការទឹកស្រូវ៖

ដោយកង្វះខាតទិន្នន័យ តម្រូវការទឹកស្រូវក្នុងអាងស្ទឹងជ្រៃបាក់ តម្រូវការទឹកស្រូវប្រាំង នៅក្នុងតំបន់ស្រូវប្រាំងស្រុកបាធាយ ខេត្តកំពង់ចាម ដែលបានសិក្សាឃើញដោយបណ្ឌិត សុមេធ ប៉ារ៉ាឌី (២០០៧) ត្រូវបានយកមកប្រើប្រាស់ ។ តម្រូវការទឹកស្រូវដែលមានអាយុ ១០៥ថ្ងៃ ប្រែប្រួលពី ៥៦០មីលីម៉ែត្រចំពោះប្រភេទដីឥដ្ឋ និង ៩៩០មីលីម៉ែត្រចំពោះដីល្បាយខ្សាច់ (សុមេធ *et al.* ២០០៧ និង២០០៩) ។ ធារទឹកមធ្យមប្រចាំខែពីខែធ្នូ ដល់ខែមេសា ចំនួន ៦៣លានម³ អាចចាត់ទុកថាជាធារទឹកទាប ដែលត្រូវរក្សាទុកសម្រាប់បរិស្ថាន ។ ទឹកដែលអាចដកយកប្រើប្រាស់ ត្រូវបានគណនាដោយយកបរិមាណធារទឹកសរុប ដកបរិមាណធារទឹកទាបដែលត្រូវរក្សាទុកសម្រាប់បរិស្ថាននោះចេញ ។ ការសិក្សានេះរកឃើញថា ទឹកចំនួន ១៩១លានម៉ែត្រគូប អាចដកយកមកស្រោចស្រពបាន ។ បរិមាណទឹកនេះ អាចបំពេញឲ្យតម្រូវការទឹកស្រូវ ១០៥ថ្ងៃ (ដោយមិនទាន់គិតពីការបាត់បង់តាមប្រឡាយ) បានពី ១៩.០០០ហិកតា ដល់ ៣៤.០០០ហិកតា អាស្រ័យតាមប្រភេទដី ។

រចនាសម្ព័ន្ធគ្រប់គ្រងអាងប្រព័ន្ធធារាសាស្ត្រ ក្នុងកម្រិតអាងស្ទឹង

ក្រសួងធនធានទឹក និងឧតុនិយម ទទួលខុសត្រូវលើការងារអភិវឌ្ឍន៍ និងគ្រប់គ្រងធនធានទឹកនៅទូទាំងប្រទេស ។ បន្ទាប់មក មានមន្ទីរធនធានទឹក និងឧតុនិយម ជាអ្នកទទួលខុសត្រូវការងារដូចគ្នានេះនៅថ្នាក់ក្រោមជាតិ ហើយមន្ទីរនេះទទួលខុសត្រូវដោយផ្ទាល់ចំពោះមុខរដ្ឋមន្ត្រីក្រសួងធនធានទឹក និងឧតុនិយម និងអភិបាលខេត្ត ឬក្រុង ។

គ្រប់ប្រព័ន្ធធារាសាស្ត្រទាំងអស់ (បួន) សុទ្ធតែមានសហគមន៍កសិករប្រើប្រាស់ទឹក ទោះផ្លូវការ ឬមិនផ្លូវការ ជាអ្នកទទួលខុសត្រូវក្នុងការគ្រប់គ្រងនិងដំណើរការប្រព័ន្ធធារាសាស្ត្រក្នុងអាងស្ទឹងជ្រៃបាក់ ។ ខាងក្រោមនេះ គឺជាសេចក្តីសង្ខេបនៃស្ថាប័ន និងការទទួលខុសត្រូវ ដែលពាក់ព័ន្ធនឹងការគ្រប់គ្រងប្រព័ន្ធធារាសាស្ត្រ ក្នុងបរិបទនៃការគ្រប់គ្រង និងអភិវឌ្ឍន៍អាងស្ទឹង ។

តារាង ១៖ ស្ថាប័ន និងការទទួលខុសត្រូវ

| ក្រសួងធនធានទឹក និងឧតុនិយម | មន្ទីរធនធានទឹក និងឧតុនិយម | សហគមន៍កសិករប្រើប្រាស់ទឹក (សកបទ) |
|---|---|---|
| - កសាងច្បាប់ និងគោលនយោបាយទឹក | - មើលការខុសត្រូវរួមក្នុងខេត្តស្តីពីធនធានទឹក និងការងារទំនាក់ទំនង | - រៀបចំផែនការសម្រាប់ សកបទ<br>- រៀបចំលក្ខន្តិកៈសហគមន៍ធ្វើកុងត្រា និងបទបញ្ជាផ្ទៃក្នុងសហគមន៍ |
| - ធ្វើបញ្ជីសារពើភ័ណ្ឌធនធានទឹក និងធ្វើផែនការ | - ផ្តល់យោបល់ដល់គណៈកម្មាធិការអភិវឌ្ឍន៍នានាក្នុងខេត្តទាក់ទងនឹងធនធានទឹក មានដូចជាគម្រោងអភិវឌ្ឍន៍ទឹកស្អាត និងអនាម័យ និងគម្រោងអភិវឌ្ឍន៍ប្រព័ន្ធធារាសាស្ត្រខ្នាតតូចជាដើម | - ថែរក្សាប្រព័ន្ធធារាសាស្ត្រ ដើម្បីផ្តល់ទឹក បម្រើឲ្យការស្រោចស្រពដល់គ្រប់សមាជិកក្នុងសហគមន៍នៃប្រព័ន្ធធារាសាស្ត្រ |
| - ធានាប្រសិទ្ធភាព និងនិរន្តរភាពនៃការគ្រប់គ្រង និងដំណើរការប្រព័ន្ធធារាសាស្ត្រ តាមរយៈការបង្កើតឲ្យមានសហគមន៍កសិករប្រើប្រាស់ទឹក | - ចូលរួមធានាប្រសិទ្ធភាព និងនិរន្តរភាពនៃការគ្រប់គ្រង និងដំណើរការប្រព័ន្ធធារាសាស្ត្រ តាមរយៈការចូលរួមក្នុងការងារបង្កើត និងពង្រឹង សកបទ ក្នុងខេត្ត | - ផ្តល់ទឹកស្រោចស្រពដល់គ្រប់សមាជិកសហគមន៍<br>- ពង្រឹងការប្រើប្រាស់ ការថែទាំប្រព័ន្ធធារាសាស្ត្រ<br>- ដោះស្រាយទំនាស់ដែលកើតចេញពីការស្រោចស្រពក្នុង និងរវាងសហគមន៍<br>- ប្រមូលវិភាគទានទឹកស្រោចស្រពពីសមាជិកសហគមន៍ |
| - គ្រប់គ្រង និងអភិវឌ្ឍធនធានទឹក តាមរយៈយន្តការអាជ្ញាប័ណ្ណទឹក | | |
| - ការពារធនធានទឹក និងទឹកជំនន់ | | |

## ១០. សរុបសេចក្តី និងអនុសាសន៍

### *១០.១. សរុបសេចក្តី*

ជាសេចក្តីសន្និដ្ឋាន ការទទួលបានទឹកស្រោចស្រព គឺនៅមានកម្រិត ដោយមូលហេតុ៖ បរិមាណទឹកក្នុងធម្មជាតិមានកម្រិតកំណត់ ខ្វះហេដ្ឋារចនាសម្ព័ន្ធធារាសាស្ត្ររូបវន្ត សមត្ថភាពបច្ចេកទេស ថវិកា និងអភិបាលកិច្ចនៅមានកម្រិត ។ គ្រប់ប្រព័ន្ធធារាសាស្ត្រក្នុងអាងស្ទឹងជ្រៃបាក់មានអាងស្តុកទឹកតូច ។ ទឹកដែលអាចដកយកមកប្រើប្រាស់បាន ភាគច្រើនមានតែក្នុងរដូវវស្សា ។

ក្រៅពីធនធានទឹកក្នុងធម្មជាតិមានកម្រិត កង្វះខាតហេដ្ឋារចនាសម្ព័ន្ធធារាសាស្ត្រ ក៏ជាចំណោទមួយដែរ ។ កង្វះសំណង់ និងប្រឡាយចែកចាយទឹក បានបង្កបញ្ហាជាច្រើនដល់អ្នកចែកចាយទឹក (អ្នកកាន់ទ្វារទឹក) ដើម្បីផ្តល់ទឹកគ្រប់ចំនួន និងទាន់ពេលវេលា ដល់ម្ចាស់ស្រែដែលត្រូវស្រោចស្រព ។

ការគ្រប់គ្រងប្រព័ន្ធធារាសាស្ត្រមួយ វាទាក់ទងគ្នាជាមួយប្រព័ន្ធធារាសាស្ត្រផ្សេងទៀត ដែលនៅខ្សែទឹកលើ និងនៅខ្សែទឹកក្រោម ។ កង្វះខាតថវិកាបណ្តាលឲ្យពិបាកដល់សហគមន៍ក្នុងការទំនាក់ទំនងគ្នាពីប្រព័ន្ធមួយទៅប្រព័ន្ធមួយទៀត ក្នុងការចែកចាយទឹកស្រោចស្រព ។

កម្ពុជាកំពុងបោះជំហាន ពីការធ្វើស្រែពឹងលើទឹកភ្លៀងទាំងស្រុង ទៅកាន់ប្រព័ន្ធស្រោចស្រព ។ ដូច្នេះ វិធីសាស្ត្រគ្រប់គ្រងធនធានទឹកចម្រុះ ឬការគ្រប់គ្រងអាងស្ទឹងចម្រុះ ប្រកបដោយការចូលរួមគួរត្រូវបានអនុវត្ត ដើម្បីធានាឲ្យការអភិវឌ្ឍវិស័យធនធានទឹកបានប្រកបដោយនិរន្តរភាព ។ ក្នុងគ្រប់កាលៈទេសៈនៃការអភិវឌ្ឍ និងការគ្រប់គ្រងធនធានទឹក ព័ត៌មានជលសាស្ត្រ ដើរតួនាទីសំខាន់ណាស់ក្នុងការរៀបចំគម្រោង កិច្ចដំណើរការ ការជួសជុលប្រព័ន្ធធារាសាស្ត្រ និងការធ្វើផែនការបែងចែកទឹកស្រោចស្រព ក្នុងកម្រិតអាងស្ទឹង ។

## ១០.២. អនុសាសន៍

ដើម្បីពង្រឹងការគ្រប់គ្រងប្រព័ន្ធធារាសាស្ត្រ ឲ្យស្ថិតក្នុងបរិបទនៃអាងស្ទឹងរបស់វា ការពង្រឹងសមត្ថភាពស្ថាប័ន ផ្នែកជលសាស្ត្រ និងអភិបាលកិច្ច ជាការចាំបាច់ណាស់ ។ ការសិក្សានេះ សូមផ្តល់អនុសាសន៍ថា ពង្រឹងសមត្ថភាពមន្ត្រីថ្នាក់មូលដ្ឋាន និងថ្នាក់ក្រោមជាតិ ដូចជា សហគមន៍កសិករប្រើប្រាស់ទឹក ក្រុមប្រឹក្សាឃុំ/សង្កាត់ និងមន្ត្រីមន្ទីរជំនាញ ជាដើម ។ ដើម្បីសម្រេចគោលដៅនេះ កម្មវិធីការរៀនផងធ្វើការផង និងរៀននៅថ្នាក់ឧត្តមសិក្សារៀបរយ គួរត្រូវបានរៀបចំឡើង ។

- អនុវត្តកម្មវិធីអភិវឌ្ឍន៍សមត្ថភាព តាមរយៈការរៀនផងធ្វើការផង ។ កម្មវិធីនេះ អាចអនុវត្តបាន ដោយមានការចូលរួមរបស់អ្នកពាក់ព័ន្ធក្នុងកម្មវិធីស្រាវជ្រាវ ដែលមានលក្ខណៈជាការសិក្សាប្រកបដោយការចូលរួម និងស្រាវជ្រាវសកម្ម ។ មន្ត្រីពាក់ព័ន្ធ រួមមាន៖ មន្ត្រីក្រសួង និងមន្ទីរ ធនធានទឹក និងឧតុនិយម មន្ទីរ ក្រសួងពាក់ព័ន្ធផ្សេងទៀត ក្នុងវិស័យកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ សហគមន៍កសិករប្រើប្រាស់ទឹក (សកបទ) និងអាជ្ញាធរមូលដ្ឋាន ឃុំ ស្រុក ជាដើម ។ ទិសដៅសំខាន់ ក្នុងកម្មវិធីរៀនផងធ្វើការផង គួរផ្តោតលើការផ្លាស់ប្តូរបទពិសោធន៍រវាងអ្នកស្រាវជ្រាវ អ្នកវិទ្យាសាស្ត្រ ជាមួយចំណេះដឹងក្នុងមូលដ្ឋាន ដែលអាចផ្តល់ឲ្យដល់អ្នកអនុវត្តផ្ទាល់នូវចំណេះដឹងផ្នែក ការកំណត់រកបញ្ហាគន្លឹះសម្រាប់ដោះស្រាយ វិធីសាស្ត្រ និងកាលានុវត្តភាពសម្រាប់ដោះស្រាយបញ្ហា និងចំណេះដឹងស្តីពី គោលការណ៍ និងវិធីសាស្ត្រគ្រប់គ្រងធនធានទឹកចម្រុះ ។
- ការកសាងសមត្ថភាព តាមរយៈប្រព័ន្ធអប់រំរៀបរយ អាចអនុវត្តបាន ដោយបង្កើតកម្មវិធីសហប្រតិបត្តិការជាមួយ ស្ថាប័នអប់រំថ្នាក់ជាតិ តំបន់ និងអន្តរជាតិ ។ កម្មវិធីបែបនេះគួរផ្តល់ឱកាសឲ្យបានច្រើនដល់និស្សិតបញ្ញាវន្តវ័យក្មេង ដែលមានសមត្ថភាពគ្រប់គ្រាន់តាមរយៈកម្មវិធីស្រាវជ្រាវ និងកម្មសិក្សា ។

ការសិក្សាជលសាស្ត្រ ទិន្នន័យ និងចំណេះដឹង ស្តីពីបម្រែបម្រួលបរិមាណធារទឹកតាមកាលមានសារៈសំខាន់ណាស់ ក្នុងការធ្វើផែនការអាងស្ទឹង ។ អ្នកធារាសាស្ត្រវិទូ ត្រូវការទិន្នន័យនេះជាចាំបាច់ក្នុងដំណើរការសិក្សារបស់ខ្លួន ។ ដូច្នេះ រាល់កម្មវិធីស្តារ ឬអភិវឌ្ឍប្រព័ន្ធធារាសាស្ត្រត្រូវដាក់បញ្ចូលនូវ៖

- ការអង្កេត (វាស់) កម្ពស់ទឹកក្នុងស្ទឹង (ទន្លេ)
- ការអង្កេតកម្ពស់ទឹកក្នុងទំនប់អាងទឹក
- ប្រមូលទិន្នន័យឧតុនិយម និងជលសាស្ត្រ

- បង្កើត ខ្សែកោងតំណាងធារទឹកក្នុងស្ទឹង ដែលងាយយល់ និងអាចប្រើប្រាស់បានដោយ សកបទ ។ រាល់ចំណេះដឹងទាក់ទងនឹងជលសាស្ត្រ គួរផ្តល់ទៅឲ្យមន្ត្រីមន្ទីរ និងសកបទ

ហេដ្ឋារចនាសម្ព័ន្ធធារាសាស្ត្រប្រវែន្ត មានសារៈសំខាន់ណាស់ក្នុងដំណើរការចែកចាយទឹកស្រោចស្រព របស់ សកបទ ។ ដើម្បីពង្រឹងដំណើរការគ្រប់គ្រងប្រព័ន្ធធារាសាស្ត្រ កម្មវិធីស្តារ ឬអភិវឌ្ឍប្រព័ន្ធធារាសាស្ត្រ ត្រូវផ្តល់លទ្ធភាពបច្ចេកទេស ថវិកា និងរដ្ឋបាល គ្រប់គ្រាន់ដល់មន្ត្រីមូលដ្ឋានក្នុងការអនុវត្តគម្រោង ។

កម្មវិធីអភិវឌ្ឍន៍ក្នុងអាងស្ទឹង ត្រូវមានលក្ខណៈចម្រុះ និងប្រកបដោយការចូលរួម ។ ការធ្វើផែនការ ត្រូវប្រកបដោយការចូលរួមរបស់ សកបទ ក្រុមប្រឹក្សាឃុំសង្កាត់ ក្រុមប្រឹក្សាអភិវឌ្ឍន៍ស្រុក ខេត្ត និងក្រសួង មន្ទីរពាក់ព័ន្ធ ។ មន្ត្រីមន្ទីរ និង សកបទ ដើរតួនាទីសំខាន់ក្នុងការគ្រប់គ្រងប្រព័ន្ធធារាសាស្ត្រថ្នាក់មូលដ្ឋាន ប៉ុន្តែពួកគេខ្វះចំណេះដឹងស្តីពីការគ្រប់គ្រងអាងស្ទឹង ឬអាងទន្លេ និងខ្វះយន្តការរួមក្នុងកម្រិតអាងស្ទឹង ដើម្បីអនុវត្តការងារ ។ ដូច្នេះ វិធីសាស្ត្រការគ្រប់គ្រងអាងស្ទឹងចម្រុះប្រកបដោយការចូលរួម អាចពង្រឹងការគ្រប់គ្រងអាងស្ទឹងបាន ។ ដើម្បីអនុវត្តវិធីសាស្ត្រនេះបានគេត្រូវ៖

- សម្រាប់គ្រប់ប្រព័ន្ធធារាសាស្ត្រទាំងអស់ ត្រូវលើកផែនការបែងចែកទឹកប្រកបដោយការសហការគ្នាល្អ ។ សកបទ ម្នាក់ឯង ពុំមានសមត្ថភាពគ្រប់គ្រាន់ក្នុងការលើកផែនការនេះទេ ។ ពួកគេត្រូវការជំនួយបច្ចេកទេស ពីក្រសួង និងមន្ទីរធនធានទឹក និងអ្នកពាក់ព័ន្ធផ្សេងៗទៀត ។
- គណៈកម្មាធិការគ្រប់គ្រងអាងស្ទឹង គួរតែបង្កើតឡើង និងដឹកនាំដោយកម្រិតសមស្របណាមួយ ។ គណៈកម្មាធិការនេះ ត្រូវរួមបញ្ចូលមន្ទីរពាក់ព័ន្ធ ដោយមានមន្ទីរធនធានទឹក និងឧតុនិយម ដើរតួនាទីនាំមុខ ។
- តំណាង សកបទ គ្រប់ប្រព័ន្ធធារាសាស្ត្រទាំងអស់ ត្រូវមានអាសនៈ និងតួនាទីក្នុងការសម្រេចចិត្តបែងចែកទឹកស្រោចស្រពក្នុងអាងស្ទឹង ។
- ដើម្បីសម្រេចគោលដៅរួមនៃការគ្រប់គ្រងអាងស្ទឹងចម្រុះ ប្រកបដោយការចូលរួម និងការអភិវឌ្ឍប្រព័ន្ធធារាសាស្ត្រប្រកបដោយនិរន្តរភាព ការគាំពារផ្នែកហិរញ្ញវត្ថុ និងបច្ចេកទេស ត្រូវបានរៀបចំសម្រាប់ការអនុវត្តការងាររបស់ សកបទ និងមន្ទីរធនធានទឹក និងឧតុនិយម ។
- ដើម្បីធានានិរន្តរភាពនៃការអភិវឌ្ឍធនធានទឹក កម្មវិធីគ្រប់គ្រងអាងស្ទឹងចម្រុះប្រកបដោយការចូលរួម គួរតែអនុវត្តដោយផ្ទាល់នៅថ្នាក់ខេត្ត ដោយបានទទួលជំនួយយ៉ាងពេញទំហឹងពីក្រសួង និងមន្ទីរធនធានទឹក និងឧតុនិយម ហើយនិងវិទ្យាស្ថានស្រាវជ្រាវ ដូចជាវិទ្យាស្ថានបណ្តុះបណ្តាល និងស្រាវជ្រាវដើម្បីអភិវឌ្ឍន៍កម្ពុជា (CDRI) ជាដើម ។ CDRI អាចដើរតួនាទីជាអ្នកសិក្សាស្រាវជ្រាវ ផ្តល់អនុសាសន៍ និងការបណ្តុះបណ្តាល លើមុខជំនាញគ្រប់គ្រង និងអភិបាលកិច្ចធនធានទឹក ។

ដើម្បីអនុវត្តកម្មវិធីគ្រប់គ្រងអាងស្ទឹងចម្រុះប្រកបដោយការចូលរួមបានជោគជ័យ គួរអនុវត្តជំហានមួយចំនួនដូចខាងក្រោមនេះ៖

- បង្កើតប្រព័ន្ធប្រមូលទិន្នន័យ ប្រកបដោយការចូលរួម ។
- អនុវត្តពហុជំនាញ ដើម្បីដោះស្រាយបញ្ហាដែលបានកំណត់ ។ វិភាគទិន្នន័យ រួចផ្តល់ព័ត៌មានត្រឡប់ទៅអ្នកពាក់ព័ន្ធ និងសហគមន៍វិញ ។
- បណ្តុះបណ្តាលជំនាញបន្ថែមដល់អ្នកស្រាវជ្រាវ មន្ត្រីពាក់ព័ន្ធ និងសហគមន៍ ដើម្បីពង្រឹងប្រសិទ្ធិភាពអនុវត្តការងារ ។
- បង្កើតយន្តការដោះស្រាយទំនាស់ក្នុងការប្រើប្រាស់ទឹកស្រោចស្រព ។

# ឯកសារយោង


CDRI (2008), *Framing Research on Water Resources Management and Governance in Cambodia: A Literature Review*, Working Paper 37 (Phnom Penh: CDRI)

CDRI (2010), *Empirical Evidence of Irrigation Management in the Tonle Sap Basin: Issues and Challenges*, Working Paper 48 (Phnom Penh: CDRI)

Chandler, D. (1993), *Tragedy of Cambodian History: Politics, War and Revolution since 945* (London: Yale University Press)

Chem, P., Someth, P. (2011), *Use of Hydrological Knowledge and Community Participation for Improving Decision-making on Irrigation Water Allocation*, Forthcoming Working Paper (Phnom Penh: Cambodia Development Resource Institute)

Fenemor, A., Davie, T., S. Markham (2003), *Hydrological Information in Water Law and Policy: New Zealand's Devolved Approach to Water Management* (London: IWA Publishing)

German, L., H. Mansoor, G. Alemu, W.Mazengia, T. Amede , A. Strout (2006), *Participatory Integrated Watershed Management: Evolution of Concept and Methods*, Working Paper No. 11 (Kampal: African Highland Initiative)

IIED & CTA (2006), "Mapping for Change: Practice, Technologies and Communication" *Participatory Learning and Action*, Issue 54 (April) pp. 1-14

Kummu M. (2003), *The Natural Environment and Historical Water Management of Angkor, Cambodia* (Washington DC: World Archaeological Congress)

MAFF & MOWRAM (2007), *Strategy for Agriculture and Water 2006-2010* (Phnom Penh: MAFF & MOWRAM)

MAFF & MOWRAM (2010), *Programme Design for Strategy for Agriculture and Water 2010-2013* (Phnom Penh: MAFF & MOWRAM)

MOWRAM (2009), "Action Plan on the Management and Development of Water Resources and Meteorology for Contributing to the Implementation of the Royal Government of Cambodia's Rectangular Strategy Phase II (2009-2013)", *Strategic Action Plan* (Phnom Penh: MOWRAM)

Phalla, C., D. Craig (2008), "Water Resources Management in Cambodia: History and Current Challenges", *Cambodia Development Review*, A Publication of CDRI-Cambodia's leading independent development policy research institute, Vol. 12, No. 1 (January-March) pp. 5-8

Sakhon, V. (2007) "Irrigation Development and Management", *A Presentation on the Occasion of the First Cambodian Development Cooperation Forum at the Council for the Development of Cambodia (CDC) from 19 to 20 June 2007* (Phnom Penh: Ministry of Water Resources and Meteorology)

Shaw, M., E. (1994), *Hydrology in Practice* (London: Chapman & Hall)

Someth, P., Kubo, N., Tanji, H, Ly S. (2009), "Ring Dyke System to Harness Floodwater from the Mekong River for Paddy Rice Cultivation in the Tonle Sap Floodplain in Cambodia", *Agricultural Water Management*, Vol. 96 pp. 100-110

Someth, P., Kubo, N., Tanji, H. (2007), "A Combined Technique of Floodplain Storage and Reservoir for Paddy Rice Cultivation", *Paddy Water Envron*, pp. 101-112

Vickery, M. (1998), *Society, Economics, and Politics in Pre-Angkor Cambodia: The 7th-8th Century* (Tokyo: Centre for East Asian Cultural Studies)

Ward, A. D., W.J. Elliot (1995), *Environmental Hydrology* (Boca Raton, Florida: Lewis Publishers)

# ផ្នែកទី ៤
# អភិបាលកិច្ចបែបប្រជាធិបតេយ្យ និង
# កំណែទម្រង់សាធារណៈ

# -IX-
# គណនេយ្យភាពក្នុងប្រព័ន្ធគ្រប់គ្រងចំណាយសាធារណៈ នៅថ្នាក់ក្រោមជាតិកម្ពុជា

*ដោយលោក ប៉ក់ គឹមជឿន*[១]

វិមជ្ឈការ និងវិសហមជ្ឈការ គឺជាកំណែទម្រង់ធំមួយនៅកម្ពុជា ដោយមានការបោះឆ្នោតជាសកលនៅថ្នាក់ឃុំ/សង្កាត់នៅឆ្នាំ២០០២និង២០០៧និងការបោះឆ្នោតជាអសកលនៅថ្នាក់រាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ កាលពីខែឧសភា ២០០៩ កន្លងមក ។ បន្ទាប់ពីការបង្កើត ក្រុមប្រឹក្សានៅថ្នាក់ក្រោមជាតិ ជំហានបន្ទាប់ត្រូវធ្វើ*ការផ្ទេរមុខងារ* និង*ធនធាន* ដើម្បីឱ្យពួកគេមានលទ្ធភាពឆ្លើយតបចំពោះតម្រូវការក្នុងមូលដ្ឋានរបស់ខ្លួន ។ ទន្ទឹមនឹងការផ្ទេរធនធានទាំងនោះ រាជរដ្ឋាភិបាលត្រូវធ្វើ*ការពង្រឹងគណនេយ្យភាព ក្នុងការគ្រប់គ្រងចំណាយសាធារណៈនៅថ្នាក់ក្រោមជាតិ*[២] ។ អត្ថបទនេះពិភាក្សាអំពីគណនេយ្យភាពក្នុងប្រព័ន្ធគ្រប់គ្រងចំណាយសាធារណៈ នៅថ្នាក់ក្រោមជាតិនៅកម្ពុជា និងអំពីការងារកំណែទម្រង់ដែលរាជរដ្ឋាភិបាល កំពុងអនុវត្ត ដើម្បីពង្រឹងគណនេយ្យភាពនោះ ។

## ១. អត្ថន័យនៃពាក្យគណនេយ្យភាពក្នុងការគ្រប់គ្រងចំណាយសាធារណៈនៅថ្នាក់ក្រោមជាតិ

គណនេយ្យភាព ជាធាតុមួយសំខាន់នៅក្នុងអភិបាលកិច្ចល្អ ។ ពាក្យនេះ ផ្តោតន័យលើ*ទិដ្ឋភាពសំខាន់ ២* ៖ (១) នៅពេលមានការប្រគល់សិទ្ធិនិងធនធានឲ្យជនណាម្នាក់ ឬស្ថាប័នណាមួយ ជននោះ ឬស្ថាប័ននោះ ត្រូវមានគណនេយ្យភាពលើការប្រើប្រាស់សិទ្ធិ និងធនធាន ដែលប្រគល់ឱ្យនោះ និង (២) ប្រព័ន្ធអភិបាលកិច្ច និងគ្រប់គ្រង ត្រូវតែបង្កើតឡើង ដើម្បីតម្រូវឱ្យជននោះ ឬស្ថាប័ននោះមានគណនេយ្យភាព ទោះចង់ ឬមិនចង់ក្តី ។ ដើម្បីសម្រេចបានគណនេយ្យភាព *ត្រូវមានធាតុសំខាន់ៗចំនួន ៥* ៖ (១) ការធ្វើប្រតិភូកម្ម (២) ការប្រគល់ធនធាន (៣) ការអនុវត្តការងារ (៤) ព័ត៌មានអំពីការអនុវត្តការងារ និង (៥) ការផ្តល់រង្វាន់ ឬដាក់ទោសទណ្ឌ ទៅតាមលទ្ធផលការងារ ។

*ការគ្រប់គ្រងចំណាយសាធារណៈ សំដៅទៅលើ (១) ការបែងចែក និង (២) ការប្រើប្រាស់ប្រកបដោយប្រសិទ្ធភាពនូវធនធានសាធារណៈដែលទទួលបានពីគ្រប់ប្រភព* ។ ប្រព័ន្ធគ្រប់គ្រងចំណាយសាធារណៈ រួមមាន រចនាសម្ព័ន្ធគ្រប់គ្រងច្បាប់ និងនីតិវិធីពាក់ព័ន្ធទាំងឡាយ រាប់តាំងពីការធ្វើផែនការ ការកសាងថវិកា ការអនុវត្តថវិកា រហូតដល់ការត្រួតពិនិត្យ និងវាយតម្លៃការធ្វើចំណាយ ។ នៅក្នុងប្រព័ន្ធនេះ ជនណា ឬស្ថាប័នណា ដែលទទួលបានធនធានសាធារណៈ និងសិទ្ធិក្នុងការបែងចែក និងប្រើប្រាស់ធនធានទាំងនោះ គឺត្រូវតែមានគណនេយ្យភាព ។

---

១ លោក ប៉ក់ គឹមជឿន ជាអ្នកស្រាវជ្រាវ នៅវិទ្យាស្ថាន CDRI ។

២ សុន្ទរកថារបស់ឧបនាយករដ្ឋមន្ត្រី គាត ឈន់ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ អនុប្រធានគណៈកម្មាធិការជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ (គ.ជ.អ.ប) ក្នុងឱកាសបើកសិក្ខាសាលាជាតិស្តីពី ការរៀបចំផែនការសកម្មភាព និងថវិកាឆ្នាំ២០១០ របស់គណៈកម្មាធិការជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ (គ.ជ.អ.ប) ភ្នំពេញ ថ្ងៃទី៦-៧ តុលា ២០០៩ ។

គណនេយ្យភាពក្នុងចំណាយសាធារណៈមាន ២ប្រភេទ ៖ (១) គណនេយ្យភាពចំពោះការអនុលោមតាមច្បាប់ និងវិធានជាធរមាន ក្នុងការគ្រប់គ្រងចំណាយសាធារណៈ (ហៅដោយខ្លីថា *គណនេយ្យភាពចំពោះអនុលោមភាព*) និង (២) គណនេយ្យភាពចំពោះលទ្ធផលដែលសម្រេចបានពីការចំណាយធនធាននោះ (ហៅដោយខ្លីថា *គណនេយ្យភាពចំពោះលទ្ធផល*) ។ នៅក្នុងប្រព័ន្ធគ្រប់គ្រងបែបវិមជ្ឈការ រដ្ឋបាលថ្នាក់ក្រោមជាតិត្រូវទទួលបានការផ្ទេរថវិការដ្ឋឲ្យមួយភាគ ។

ក្នុងស្ថានភាពនេះ រដ្ឋបាលថ្នាក់ក្រោមជាតិត្រូវមានទាំង គណនេយ្យភាពចំពោះអនុលោមភាព និង គណនេយ្យភាពចំពោះលទ្ធផល ចំពោះស្ថាប័នទទួលបន្ទុកគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ (ពោលគឺក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និង រតនាគារជាតិ) និងចំពោះរដ្ឋសភាជាតិ ដែលគេហៅថា *គណនេយ្យភាពទៅថ្នាក់លើ* ។ បន្ថែមលើនេះ ពួកគេក៏ត្រូវមាន*គណនេយ្យភាព*ចំពោះប្រជាជននៅមូលដ្ឋានទៅលើការអភិវឌ្ឍសម្រេចបានជាក់ស្តែង និងចំពោះតម្លាភាពក្នុងការបែងចែក និងប្រើប្រាស់ធនធានរបស់រដ្ឋ ដែលគេហៅថា *គណនេយ្យភាពទៅថ្នាក់ក្រោម* ។

ក្រុមប្រឹក្សាមិនអាចធ្វើការងារដោយផ្ទាល់ ដើម្បីបំពេញតម្រូវការរបស់ប្រជាជនបានទេ គឺត្រូវមានប្រព័ន្ធរដ្ឋបាល និងមន្ត្រីប្រតិបត្តិមានសមត្ថភាពគ្រប់គ្រាន់ និងមានការទទួលខុសត្រូវ ក្នុងការអនុវត្តរាល់សេចក្តីសម្រេចរបស់ក្រុមប្រឹក្សា ។ មន្ត្រីប្រតិបត្តិ ត្រូវទទួលបានការផ្ទេរមុខងារពីក្រុមប្រឹក្សារួមជាមួយនឹងធនធាន និងសិទ្ធិដ៏ចាំបាច់ សម្រាប់គ្រប់គ្រង និងចាត់ចែងមុខងារទាំងនោះ ។ ក្នុងន័យនេះ មន្ត្រីប្រតិបត្តិត្រូវមានគណនេយ្យភាពចំពោះក្រុមប្រឹក្សាទៅលើអនុលោមភាព និងលទ្ធផលទាក់ទងនឹងការប្រើប្រាស់សិទ្ធិ និងធនធានទាំងនោះ ដែលគេហៅថា *គណនេយ្យភាពតាមខ្សែទទឹង* ។ ជាគោលនយោបាយ គណនេយ្យភាពដែលរាជរដ្ឋាភិបាលកម្ពុជាចង់បាននៅក្នុងប្រព័ន្ធគ្រប់គ្រងចំណាយសាធារណៈនៅថ្នាក់ក្រោមជាតិ គឺមិនខុសគ្នាអ្វីច្រើនពីក្នុងទ្រឹស្តីដែលទើបបានបកស្រាយនោះទេ ។ ប៉ុន្តែបញ្ហាលំបាក និងត្រូវការពេលវេលាច្រើន គឺការបង្កើត និងពង្រឹងប្រព័ន្ធអភិបាលកិច្ចមួយ ដែលអាចសម្រេចបានគណនេយ្យភាពទាំង ៣ នេះ[៣] ។

## ២. ប្រព័ន្ធគ្រប់គ្រងចំណាយសាធារណៈនៅថ្នាក់ក្រោមជាតិកម្ពុជា

បច្ចុប្បន្នមានប្រព័ន្ធគ្រប់គ្រងចំណាយសាធារណៈយ៉ាងហោចចំនួន ៣ ដែលកំពុងដំណើរការ គឺ (១) ប្រព័ន្ធទូទៅរបស់ជាតិ (២) ប្រព័ន្ធរបស់មូលនិធិឃុំសង្កាត់ និងកម្មវិធីសាកល្បងតាមបែបវិមជ្ឈការ នៅក្នុងក្របខ័ណ្ឌនៃគណៈកម្មាធិការជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ (គ.ជ.អ.ប) និង (៣) ប្រព័ន្ធរបស់ដៃគូអភិវឌ្ឍន៍ ។

### ២.១. ប្រព័ន្ធទូទៅរបស់ជាតិ

ប្រព័ន្ធទូទៅរបស់ជាតិ ផ្អែកតាមច្បាប់គ្រប់គ្រងហិរញ្ញវត្ថុឆ្នាំ ១៩៩៣ និង ២០០៨ ។ នៅថ្នាក់ក្រោមជាតិ ប្រព័ន្ធនេះអនុវត្តលើ (១) ថវិការបស់រដ្ឋបាលថ្នាក់ខេត្ត (ពីមុនហៅថា សាលាខេត្ត ឬសាលាក្រុង) និង (២) ថវិការបស់មន្ទីរជំនាញ ។ បច្ចុប្បន្ន ដោយសារ*ច្បាប់ស្តីពីរបបហិរញ្ញវត្ថុ និងការគ្រប់គ្រងទ្រព្យសម្បត្តិរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ* នៅមិនទាន់បានអនុម័ត ការគ្រប់គ្រងថវិការបស់ខេត្ត ត្រូវបន្តប្រើច្បាប់ឆ្នាំ១៩៩៨ ។ តាមច្បាប់នេះ ខេត្តគឺជា អាណាប័កដើមខ្សែសម្រាប់

---

៣ សុន្ទរកថារបស់ឧបនាយករដ្ឋមន្ត្រី គាត ឈន់ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ អនុប្រធានគណៈកម្មាធិការជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ (គ.ជ.អ.ប) ក្នុងឱកាសបើកសិក្ខាសាលាជាតិស្តីពី ការរៀបចំផែនការសកម្មភាព និងថវិកាឆ្នាំ២០១០ របស់គណៈកម្មាធិការជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ (គ.ជ.អ.ប) ភ្នំពេញ ថ្ងៃទី៦-៧ តុលា ២០០៩ ។

ថវិកាខេត្ត និងជាអាណាប័កផ្ទេរសិទ្ធិសម្រាប់ថវិការបស់មន្ទីរ ។ ចំពោះក្រុមប្រឹក្សាស្រុក/ក្រុង ដែលមិនទាន់មានប្រព័ន្ធគ្រប់គ្រងថវិកា ថ្នាក់នេះនៅតែបន្តទទួលថវិការបស់ខ្លួនតាមរយៈថវិកាខេត្ត ។

នៅក្នុងប្រព័ន្ធទូទៅរបស់ជាតិ ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ (តាមរយៈមន្ទីរសេដ្ឋកិច្ច និងហិរញ្ញវត្ថុ) និងរតនាគារជាតិ (តាមរយៈរតនាគារខេត្ត) ដើរតួនាទីជាអ្នកត្រួតពិនិត្យ និងជាគណនេយ្យករសាធារណៈ ។ ដោយសារប្រព័ន្ធនៅទន់ខ្សោយ រាជរដ្ឋាភិបាលបានយកចិត្តទុកដាក់ជាដំបូងលើគណនេយ្យភាព ចំពោះចំណេះអនុលោមភាព ក្នុងការបែងចែក និងប្រើប្រាស់ចំណាយ ជាជាងលើគណនេយ្យភាពលទ្ធផល ។

ដើម្បីបង្កើនគណនេយ្យភាពចំពោះលទ្ធផល មានការអនុញ្ញាតឲ្យអង្គភាពចំណាយអាចបត់បែនបានច្រើនជាងមុន ក្នុងការបែងចែក និងប្រើប្រាស់ចំណាយ ឱ្យស្របតាមស្ថានភាពជាក់ស្តែង ។ ឧទាហរណ៍ កន្លងមកមានការដាក់ឱ្យប្រើថវិកាកម្មវិធីនៅក្នុង ៨ វិស័យអាទិភាព មានជាអាទិ វិស័យអប់រំ សុខាភិបាល កសិកម្ម អភិវឌ្ឍន៍ជនបទ ។ល។ ថវិកាតាមកម្មវិធី ត្រូវកសាងឡើងដោយភ្ជាប់គម្រោងចំណាយជាមួយនឹងលទ្ធផលរំពឹងទុក និងមានសូចនាករសម្រាប់វាស់វែងជាក់លាក់ ។ ស្ថាប័នចំណាយអាចបត់បែនបានច្រើនក្នុងការចាយថវិកាតាមកម្មវិធី ដូច្នេះ អាចជាជំហានល្អមួយឆ្ពោះទៅរកគណនេយ្យភាពចំពោះលទ្ធផល ។ ប៉ុន្តែនាពេលបច្ចុប្បន្ន ថវិកានេះមានចំនួនតិចតួចនៅឡើយ ។ ក្នុងឆ្នាំ២០១០ ថវិកាតាមកម្មវិធីមានចំនួន ២៥៥,៩៤ពាន់លានរៀល ឬ ៥,១% នៃថវិកាចរន្តសរុបរបស់ជាតិ ។

ទាក់ទិននឹងគណនេយ្យភាពតាមខ្សែទទឹង សព្វថ្ងៃប្រព័ន្ធគ្រប់គ្រងទូទៅនៅថ្នាក់ក្រោមជាតិនៅមានកម្រិតនៅឡើយ ។ អភិបាលខេត្ត មានងារជាអាណាប័កផ្ទេរសិទ្ធិក៏ពិតមែន តែមានសិទ្ធិតិចតួចលើការបែងចែក និងប្រើប្រាស់ចំណាយរបស់មន្ទីរ ដោយសារសិទ្ធិទាំងនេះជាដែនសមត្ថកិច្ចរបស់មន្ទីរហិរញ្ញវត្ថុ និងរតនាគារខេត្ត ។ ម្យ៉ាងទៀត សព្វថ្ងៃស្ទើរតែគ្មានការចូលរួមពីអង្គការមិនមែនរដ្ឋាភិបាល ក្នុងការឃ្លាំមើលការគ្រប់គ្រងថវិការដ្ឋទេ លើកលែងតែក្នុងវិស័យសុខាភិបាល ដែលមានការចូលរួមពីអង្គការជាដៃគូ ក្នុងការពិនិត្យពីដំណើរការអនុវត្តថវិការបស់មន្ទីរសុខាភិបាល ។

## ២.២. ប្រព័ន្ធគ្រប់គ្រងចំណាយក្នុងក្របខ័ណ្ឌរបស់ គ.ជ.អ.ប

គ.ជ.អ.ប ជាយន្តការអន្តរក្រសួងមួយ ដែលត្រូវបានបង្កើតឡើងនៅឆ្នាំ២០០៨ ដើម្បីដឹកនាំ និងសម្របសម្រួលការងារកំណែទម្រង់វិមជ្ឈការ ។ បន្ថែមពីលើការងារផ្នែកគោលនយោបាយ គ.ជ.អ.ប មានតួនាទីរៀបចំ និងអនុវត្តនូវ*គម្រោងផែនការ សកម្មភាព និងថវិកាប្រចាំឆ្នាំ* របស់ខ្លួន ។ សម្រាប់ឆ្នាំ២០១០ ថវិកានេះមានចំនួនសរុប ៣៨១.៣ពាន់លានរៀល ក្នុងនេះប្រហែល ៤០% ទទួលមកពីរដ្ឋាភិបាល ក្រៅពីនោះមកពីដៃគូអភិវឌ្ឍន៍[៤] ។ ថវិកានេះ ត្រូវបែងចែកប្រហែល ២៩១.១ពាន់លានរៀល សម្រាប់ចំណាយនៅថ្នាក់ក្រោមជាតិ ក្នុងនេះ ប្រមាណ ១៩៥ពាន់លានរៀល ត្រូវផ្ទេរទៅឲ្យថ្នាក់ឃុំ/សង្កាត់ ។

នៅក្នុងថវិកាប្រចាំឆ្នាំ មានមូលនិធិវិនិយោគសម្រាប់រាជធានី/ខេត្ត (ហៅកាត់ថា PIF) និងមូលនិធិសម្រាប់ក្រុង ស្រុក/ក្រុង (ហៅកាត់ថា DIF) ។ PIF មួយភាគធំបានប្រើប្រាស់សម្រាប់អនុវត្តគម្រោងដែលមន្ទីរខេត្តលើកឡើង ដើម្បីបម្រើជាប្រយោជន៍នៅថ្នាក់ឃុំ/សង្កាត់ ។ នៅឆ្នាំ២០០៩ PIF

---

៤ សុន្ទរកថារបស់ឧបនាយករដ្ឋមន្ត្រី គាត ឈន់ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ អនុប្រធានគណៈកម្មាធិការជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ (គ.ជ.អ.ប) ក្នុងឱកាសបើកសិក្ខាសាលាជាតិស្តីពីការរៀបចំផែនការសកម្មភាព និងថវិកាឆ្នាំ២០១០ របស់គណៈកម្មាធិការជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ (គ.ជ.អ.ប) ភ្នំពេញ ថ្ងៃទី៦-៧ តុលា ២០០៩ ។

មានចំនួន ២.២៤លានដុល្លារ (ប្រមាណ ៣,២៣ាន់លានរៀល) ។ ក្នុងឆ្នាំដូចគ្នា DIF ត្រូវបានបែងចែកទៅឱ្យ ១០៦ស្រុក/ក្រុង ដោយនីមួយៗទទួលបាន ៣០.០០០ដុល្លារ (ប្រមាណ ១២៣លានរៀល) សម្រាប់អនុវត្តគម្រោងដែលបម្រើតម្រូវការរបស់ឃុំ/សង្កាត់ ។

នៅថ្នាក់ខេត្ត ភ្នាក់ងារទទួលខុសត្រូវលើការគ្រប់គ្រងចំណាយនៃមូលនិធិខាងលើ គឺ*គណៈកម្មាធិការអភិវឌ្ឍន៍ជនបទ និង គណៈកម្មាធិការប្រតិបត្តិរាជធានី និងខេត្ត* (PRDC/ExCom) ដែលគេបានបង្កើតឡើងនៅឆ្នាំ២០០២ នៅក្រោមអតីតកម្មវិធីសិលា និងបន្ទាប់មកផ្ទេរមកក្រោមការគ្រប់គ្រងរបស់ គ.ជ.អ.ប នៅចុងឆ្នាំ២០០៨ ។ ថវិកាប្រចាំនៅក្នុងក្របខ័ណ្ឌនៃ គ.ជ.អ.ប គេគ្រប់គ្រងតាមប្រព័ន្ធមួយផ្សេងទៀត ដូចមានចែងក្នុងសៀវភៅណែនាំសម្រាប់ការកសាងផែនការ និងថវិកាសម្រាប់ឃុំសង្កាត់ និងវិធានផ្សេងៗទៀត ។ ប្រព័ន្ធនេះ ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ បានទទួលស្គាល់ ប៉ុន្តែវាមានខ្លឹមសារ និងការអនុវត្ត ខុសគ្នាច្រើនពីប្រព័ន្ធទូទៅរបស់ជាតិ ។

ទាក់ទងនឹងគណនេយ្យភាព ប្រព័ន្ធនៅក្នុងក្របខ័ណ្ឌនៃ គ.ជ.អ.ប ផ្តោតជាសំខាន់លើការការពារ និងបញ្ចៀស ហានិភ័យ ដែលអាចកើតមានទៅលើថវិកាបានគ្រោងឡើង ។ ប្រព័ន្ធនេះមានលក្ខណៈទំនើប និងការកែលំអជាប្រចាំ ។ ការត្រួតពិនិត្យ វាយតម្លៃ និងសវនកម្មផ្ទៃក្នុង ដែលធ្វើឡើងដោយ PRDC/ExCom និងសវនកម្មមកពីក្រៅ បានដើរតួនាទីយ៉ាងសំខាន់ ។ ប្រព័ន្ធនេះល្អប្រសើរ ព្រោះមិនមែនផ្តោតតែលើគណនេយ្យភាពចំពោះអនុលោមភាពប៉ុណ្ណោះទេ ប៉ុន្តែលើលទ្ធផលសម្រេចបានតាមរយៈគម្រោងអនុវត្តនៅថ្នាក់ឃុំសង្កាត់ ខេត្ត និងស្រុក/ក្រុង ផងដែរ ។

ប្រព័ន្ធគ្រប់គ្រងក្នុងក្របខ័ណ្ឌនៃ គ.ជ.អ.ប ខាងលើនេះ គ្របដណ្តប់តែលើធនធានប្រមាណ ៤.៦% នៃថវិកាសរុបរបស់ជាតិ ដែលមានទំហំធិតដល់ ៨៣០០ពាន់លានរៀល នៅឆ្នាំ២០១០ ។ តួលេខនេះបង្ហាញថា វិមជ្ឈការនៅកម្ពុជានៅមានកម្រិតទាបក្នុងវិស័យហិរញ្ញវត្ថុ ។ ម្យ៉ាងទៀត ប្រព័ន្ធរបស់ គ.ជ.អ.ប នេះ ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ បានទទួលស្គាល់មែន ប៉ុន្តែមិនទាន់បានធ្វើសុខដុមនីយកម្មជាមួយប្រព័ន្ធទូទៅរបស់ជាតិទេ ទោះមានការខិតខំថ្មីៗ ដូចជាការបង្កើតឱ្យមានប្លង់គណនេយ្យថ្មីសម្រាប់ឃុំ/សង្កាត់ ក៏ដោយ ។

គម្រោងរបស់ដៃគូអភិវឌ្ឍន៍ដែលកំពុងដំណើរការក្រោមក្របខ័ណ្ឌរបស់ គ.ជ.អ.ប សព្វថ្ងៃមានប្រហែល ២០ ហើយគម្រោងខ្លះក៏បានចូលរួមចំណែកក្នុងការពង្រឹងគណនេយ្យភាពរវាងមន្ត្រីជាប់ឆ្នោត និងម្ចាស់ឆ្នោត ដោយជួយឱ្យម្ចាស់ឆ្នោតមានលទ្ធភាពខ្លាំងជាងមុន ក្នុងការទាមទារគណនេយ្យភាពនេះ ។ ឧទាហរណ៍ គម្រោងការពារបរិស្ថាន និងលើកកម្ពស់ជីវភាព របស់អង្គការដានីដា បានជម្រុញការផ្តល់អំណាចដល់ប្រជាជន តាមរយៈការកសាងសមត្ថភាពរបស់សង្គមស៊ីវិលនៅមូលដ្ឋាន ។ ឧទាហរណ៍មួយទៀត គឺគម្រោងហៅកាត់ថា SPACE របស់សហភាពអឺរ៉ុប ។

## ២.៣. ប្រព័ន្ធគម្រោងរបស់ដៃគូអភិវឌ្ឍន៍

គម្រោង និងកម្មវិធីរបស់ដៃគូអភិវឌ្ឍន៍ បានលើកមកពិភាក្សានៅពេលនេះ ដោយសារជំនួយបរទេសមួយភាគធំ បានបង្ហូរទៅឲ្យ និងយកទៅចំណាយនៅ ថ្នាក់ក្រោមជាតិ ។ នៅឆ្នាំ២០០៩ ប្រហែល ៦០% នៃថវិកាជំនួយ បានដកទៅចំណាយនៅថ្នាក់ខេត្ត ដោយបានបង្ហូរទៅឲ្យតាមក្រៅប្រព័ន្ធរតនាគារ និងបានអនុវត្តតាមរយៈរាប់រយអង្គភាពគ្រប់គ្រងគម្រោង (RGC 2010) ។

ការពិភាក្សាអំពីជំនួយបរទេសនៅក្នុងអត្ថបទនេះ វាស្មុគស្មាញបន្តិច តែចាំបាច់ ។ បើរាប់ត្រឹមតែគម្រោងដែលជួយដល់កំណែទម្រង់វិមជ្ឈការ សព្វថ្ងៃមាន ២០ គម្រោងដៃគូអភិវឌ្ឍន៍ ដែលប្រើយន្តការសម្របសម្រួលរបស់ គ.ជ.អ.ប ។ ដៃគូអភិវឌ្ឍន៍នានានៅមានគម្រោងជាច្រើនទៀតដែលកំពុងដំណើរការតាមវិស័យជំនាញផ្សេងៗ នឹងដែលត្រូវមានការផ្លាស់ប្តូរនៅពេលរាជរដ្ឋាភិបាលចាប់ផ្តើមគិតគូរពីការផ្ទេរមុខងារ និងបន្ទុកចំណាយទៅឱ្យថ្នាក់ក្រោមជាតិ ។ មកទល់បច្ចុប្បន្ន

គម្រោងទាំងនេះនៅតែផ្តោតលើគណនេយ្យភាពតាមខ្សែបណ្តោយក្នុងវិស័យនីមួយៗ ដោយមិនបានគិតពីគណនេយ្យភាពចំពោះរដ្ឋបាលថ្នាក់ក្រោមជាតិ និង គណនេយ្យភាពរបស់រដ្ឋបាលថ្នាក់ក្រោមជាតិចំពោះប្រជាជន ទេ ។

កន្លងមក វិស័យខ្លះបានចាប់ផ្តើមគិតគូរពីបញ្ហានេះហើយ នៅក្នុងសកម្មភាពផ្តល់សេវារបស់ពួកគេ ។ ឧទាហរណ៍ នៅតាមឃុំ/សង្កាត់ តាមរយៈការប្រជុំប្រចាំខែ ថ្នាក់ដឹកនាំសាលារៀន និងមណ្ឌលសុខភាព បានរាយការណ៍ពីការផ្តល់សេវារបស់អង្គភាពខ្លួន និងទទួលយកយោបល់ពីក្រុមប្រឹក្សា ។ ក្នុងវិស័យសុខាភិបាល ការសម្របសម្រួលក៏មានធ្វើនៅថ្នាក់ខេត្តដែរ ប៉ុន្តែវិស័យផ្សេងទៀតមិនទាន់អនុវត្តបានច្រើននៅឡើយទេ ។

ដើម្បីសម្របតាមផែនការជាតិសម្រាប់រយៈពេល ១០ឆ្នាំ ដៃគូអភិវឌ្ឍន៍សំខាន់ៗ បានចាប់ផ្តើមធ្វើការសម្រួលការអនុវត្តគម្រោងរបស់ខ្លួន សំដៅបង្កើនកិច្ចសហការជាមួយរដ្ឋបាលថ្នាក់ក្រោមជាតិ (គណនេយ្យភាពខ្សែទទឹង) និងក្នុងពេលជាមួយគ្នា ជួយពង្រឹងសមត្ថភាពរបស់រដ្ឋបាលទាំងនោះ ដើម្បីឱ្យពួកគេអាចឆ្លើយតបបានល្អទៅនឹងតម្រូវការរបស់ប្រជាពលរដ្ឋ (គណនេយ្យភាពចុះក្រោម) ។ ឧទហរណ៍ ថ្មីៗនេះ ធនាគារអភិវឌ្ឍន៍អាស៊ី បានធ្វើការសិក្សាលើគម្រោងរបស់ខ្លួន ដើម្បីកំណត់ថាតើសកម្មភាពណាត្រូវបន្តធ្វើសហការដោយផ្ទាល់ជាមួយថ្នាក់ជាតិ និង សកម្មភាពណាត្រូវប្តូរមកសហការជាមួយថ្នាក់ក្រោមជាតិវិញ ។

## ៣. គណនេយ្យភាព និងបរិវារកិច្ច

ការពិភាក្សាខាងលើពាក់ព័ន្ធនឹងគណនេយ្យភាព ដោយគោរពតាមច្បាប់ និងវិធានជា*ផ្លូវការ*របស់រាជរដ្ឋាភិបាល និងរបស់ដៃគូអភិវឌ្ឍន៍ ។ ប៉ុន្តែ គណនេយ្យភាពពុំមែនសុទ្ធតែកំណត់តាមអ្វីដែលមានចែងជាផ្លូវការនោះទេ ។ នៅពេលច្បាប់នៅខ្វះចន្លោះ ឬមិនទាន់បានអនុវត្ត កត្តាមានឥទ្ធិពលខ្លាំង គឺទំនាក់ទំនងរវាងបុគ្គល តាមខ្សែ តាមខ្នង ដែលគេហៅថា *បរិវារកិច្ច* ។

បរិវារកិច្ច បង្កើតឱ្យមានជាគណនេយ្យភាពមួយ រវាងអ្នកដែលជាខ្នង និងអ្នកដែលដើរតាម ។ ក្នុងទំនាក់ទំនងនេះ អ្នកតូចត្រូវមានគណនេយ្យភាពចំពោះអ្នកធំជាងខ្លួន ដោយបង្ហាញពីភាពស្មោះត្រង់ និងការបម្រើ ឬផ្តល់ជាប្រយោជន៍អ្វីមួយ ។ រីឯអ្នកធំវិញ ទោះគ្មាននិយាយ ឬចែងជាលាយលក្ខណ៍អក្សរអ្វី ក៏ត្រូវមានគណនេយ្យភាពចំពោះអ្នកតូចរបស់ខ្លួន ដោយត្រូវផ្តល់ការគាំពារ និងផលប្រយោជន៍មួយចំនួន ដែលភាគីទាំងសងខាងរំពឹងទុក ។ ដោយសារគ្មានអ្វីកំណត់ជាលាយលក្ខណ៍អក្សរ ការរំពឹង និងទំនាក់ទំនង រវាងអ្នកធំ និងអ្នកតូច នៅក្នុងបរិវារកិច្ច ច្រើនអាស្រ័យតាមទម្លាប់ដែលមានពីមុនមក ។

ប្រព័ន្ធគ្រប់គ្រងចំណាយសាធារណៈនៅកម្ពុជា ក៏មានលាយឡំនឹងបរិវារកិច្ចខ្លះដែរ ។ បរិវារកិច្ចនេះ ក្នុងករណីខ្លះបានជួយបំពេញដល់កង្វះខាតនៅក្នុងប្រព័ន្ធផ្លូវការរបស់រដ្ឋ ។ ឧទាហរណ៍ បើទោះជាតាមផ្លូវរដ្ឋ អភិបាលខេត្តមិនសូវមានទំនាក់ទំនងច្រើនជាមួយមន្ទីរ និងការិយាល័យខ្សែបណ្តោយក្តី ប៉ុន្តែតាមខ្សែគណបក្ស និងតាមផ្លូវបុគ្គល មន្ត្រីទាំងនេះមានការប្រាស្រ័យទាក់ទងគ្នាច្រើន ។ ចំណុចមិនល្អនៃការប្រាស្រ័យទាក់ទងបែបនេះ គឺភាគច្រើនវាមិនបានជួយឱ្យមានគណនេយ្យភាពចំពោះអនុលោមភាព និងលទ្ធផល ឬគណនេយ្យភាពចំពោះប្រជាជន ដូចបានរៀបរាប់ខាងលើឡើយ ។ ផ្ទុយទៅវិញ វាបានប៉ះពាល់ដល់គណនេយ្យភាពក្នុងការអនុវត្តច្បាប់គ្រប់គ្រងចំណាយ ព្រោះពេលខ្លះការចរចាថវិកា ការទម្លាក់ថវិកា ការស្នើសុំដកចំណាយ ការចុះត្រួតពិនិត្យ និង សវនកម្ម ។ល។ ត្រូវពឹងផ្អែកលើការយោគយល់រវាងបុគ្គល ឬបក្សពួក ជាជាងតាមការកំណត់ក្នុងច្បាប់ ។

ក្នុងពេលកន្លងមក រាជរដ្ឋាភិបាល និងដៃគូអភិវឌ្ឍន៍ បានខិតខំកែទម្រង់លើប្រព័ន្ធហិរញ្ញវត្ថុសាធារណៈ ដោយរំពឹងថា នៅពេលប្រព័ន្ធផ្លូវការរឹងមាំ ឥទ្ធិពលបុគ្គល និងបរិវារកិច្ច នឹងថយចុះ ។

ការខិតខំនេះ បានចេញជាផ្លែផ្កាមួយចំនួន ដូចជា កំណើនចំណូលក្នុងថវិការដ្ឋចាប់ពីឆ្នាំ២០០៧ កន្លងមក ការផ្ទេរថវិកាបានលឿនជាងមុនទៅឱ្យថ្នាក់មូលដ្ឋាន ។ល។ ប៉ុន្តែ ដោយសារបរិវារកិច្ច នៅកម្ពុជា បានចាក់ឫសជ្រៅនៅក្នុងសង្គម និងប្រទាក់ក្រឡាជាមួយកត្តានយោបាយ និងកត្តាប្រវត្តិសាស្ត្រមួយចំនួន ដូច្នេះ ការអនុវត្តកំណែទម្រង់ចំណាយសាធារណៈ មិនអាចដោះស្រាយបានក្នុងរយៈពេលខ្លីឡើយ ។ ម្យ៉ាងទៀត ការកែប្រែទម្លាប់នេះ ត្រូវមានការចូលរួមមិនត្រឹមពីអ្នកនយោបាយ និងមន្ត្រីរាជការស៊ីវិលប៉ុណ្ណោះទេ ប៉ុន្តែពីសង្គមស៊ីវិល និងមហាជនទូទៅផងដែរ ។

## ៤. សេចក្តីសង្ខេប

ក្នុងការពិភាក្សាអំពីពាក្យគណនេយ្យភាព នៅក្នុងបរិបទនៃការគ្រប់គ្រងចំណាយនៅថ្នាក់ក្រោមជាតិ៖ ទី១ គួរបញ្ជាក់ឱ្យច្បាស់អំពីគណនេយ្យភាពរវាងអ្នកណា? ទៅអ្នកណា? ទៅលើដែនភារកិច្ចអ្វី? និង មានប្រព័ន្ធគ្រប់គ្រងអ្វីខ្លះសម្រាប់ធានាឱ្យមានគណនេយ្យភាព? ការបញ្ជាក់ច្បាស់បែបនេះនឹងជួយកាត់បន្ថយការយល់ច្រលំនៅក្នុងការពិភាក្សា ។ ទី២ គេត្រូវស្វែងយល់ពីប្រព័ន្ធគ្រប់គ្រងចំណាយនានា ដែលកំពុងដំណើរការនៅថ្នាក់ក្រោមជាតិ ។ គួរចោទសួរថា តើប្រព័ន្ធនីមួយៗនាំឱ្យមានគណនេយ្យភាពប្រភេទណា? ជាគណនេយ្យភាពចំពោះអនុលោមភាព? ចំពោះលទ្ធផល? ទៅថ្នាក់លើ? ទៅប្រជាជន? តាមខ្សែទទឹង? និង តើគណនេយ្យភាពទាំងនោះបំពេញឱ្យគ្នា ឬប្រទាំងប្រទើសគ្នាបែបណា?

តាមការរៀបរាប់ខាងលើ គណនេយ្យភាពក្នុងការគ្រប់គ្រងចំណាយនៅថ្នាក់ក្រោមជាតិកម្ពុជាអាចដើរទៅមុខបាន លុះត្រាមានការរីកចម្រើនទៅមុខ និងការសម្របសម្រួលគ្នារវាងកំណែទម្រង់ ៣ គឺ៖ (១) កំណែទម្រង់ប្រព័ន្ធគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ (២) កំណែទម្រង់វិមជ្ឈការ និងវិសហមជ្ឈការ និង (៣) កំណែទម្រង់ក្នុងការសម្របសម្រួលជំនួយអន្តរជាតិ ។ កំណែទម្រង់ទាំងនេះពាក់ព័ន្ធទាំងការងារបច្ចេកទេសផង និងការងារនយោបាយផង ហើយក្នុងនោះ បរិវារកិច្ច គឺជាកត្តាមួយយ៉ាងសំខាន់ដែលគួរស្វែងយល់បន្ថែម និងជម្នះ ។

## ឯកសារយោង


Bahl, R. (1999), *Implementation Rules for Fiscal Decentralisation* (Georgia: Georgia State University)

Danida/Dfid/Nzaid (2010), *A Study of Lessons Learnt from the Civil Society and Pro-poor Markets Component of the Natural Resource Management and Livelihood Programme*

European Commission (2010), *SPACE (Strengthening Performance, Accountability and Civic Engagement) Project Document*

Ministry of Economy and Finance (2007), *Prakas on the use of economic classification of the national budget* (Phnom Penh: RGC)

Ministry of Economy and Finance (2008), *Circular on the Guidance on the Implementation of the Finance Law for 2009*, (Phnom Penh: RGC)

Ministry of Economy and Finance (2009), *Prakas on Allocation of Budget Credit for 2010, 24 December 2009* (Phnom Penh: RGC)

National Committee for Deconcentration and Decentralisation Reform (2008a), *2008 Annual Work Plan and Budget* (Phnom Penh: RGC)

National Committee for Deconcentration and Decentralisation Reform (2008b), *Prakas No. 68, dated 8 September 2008, on the new structure of the PRDC/ExCom* (Phnom Penh: RGC)

National Committee for Deconcentration and Decentralisation Reform (2010a), *Outline of the First Three Years (2011-2013): Implementation Plan of NP-SNDD* (Phnom Penh: NCDD)

National Committee for Deconcentration and Decentralisation Reform (2010b), *An Analysis of the Commune Development Planning Data Base* (Phnom Penh: NCDD)

National Treasury (2010), *Announcement on the meeting from 21-23 October* (Phnom Penh; RGC)

NGO Forum on Cambodia 2007, *Guide to the National Budget*, Phnom Penh

Niazi, T. & J. Lamont (forthcoming), *De-concentration and Decentralisation Reforms in Cambodia: Recommendations for an Institutional Framework* (Manila: ADB)

Pak, K (2009a), Mapping Budget Information in Education, NGO Forum on Cambodia, Phnom Penh

Pak, K (2009b), Mapping Budget Information in Health, NGO forum on Cambodia, Phnom Penh

Pak, K (2010), *Assessment of Actual and Potential Commune and Sangkat Council Functions (unpublished field report)*, (Phnom Penh; National League of the Communes/Sangkats)

Pak, K. & D. Craig (2008), *Accountability and Public Expenditure Management in Decentralised Cambodia*, Working Paper Series (Phnom Penh: CDRI)

Pak, K., V. Horng, N. Eng, S. Ann, S. Kim, J. Knowles & D. Craig (2007), *Accountability and Neo-patrimonialism in Cambodia: A Critical Literature Review*, Working Paper No. 34, (Phnom Penh : CDRI)

PSDD (2009), *2009 Annual Work Plan and Budget*

Public Financial Management Reform Programme Secretariat (2009), *Progress Report on Public Financial Management Reform Program* (Phnom Penh: MEF)

Royal Government of Cambodia (2007), *Public Financial Management Reform Programme: 2007 External Advisory Panel Report* (Phnom Penh: RGC)

Royal Government of Cambodia (2008a), *Public Finance Law* (Phnom Penh: RGC)

Royal Government of Cambodia (2008b), *Royal Decree NS/RKT/1208/1429 on the establishment of the NCDD, dated 31 December 2008* (Phnom Penh: RGC)

Royal Government of Cambodia (2008c), *The Cambodia Aid Effectiveness Report: 2008* (Phnom Penh: RGC)

Royal Government of Cambodia (2009), *Proposed Budget for 2010* (Phnom Penh: RGC)

Royal Government of Cambodia (2010), *Aid Effectiveness Report* (Phnom Penh: RGC)

Schiavo-Campo, S. & D. Tommasi (1999), *Managing Government Expenditure* (Manila: ADB)

Seila Task Force (2002), *Prakas No.292 KDNS, dated 8 December 2002, on the Establishment of PRDC/ExCom*

United Nations Capital Development Fund (2010), *Local Development Outlook: Cambodia*

VBNK and RBMG (2010), *Phase Two Evaluation of the Paris Declaration: Technical volume: Cambodia Country Study Report*

World Bank & Asian Development Bank (2003), *Enhancing Service Delivery through Improved Resource Allocation and Institutional Reform - Integrated Fiduciary Assessment and Public Expenditure Review*

World Bank (2004), *Making Services Work for Poor People,* World Development Report (Washington, DC: World Bank)

World Bank (2005), *East Asia Decentralises: Making Local Government Work* (Washington, DC: World Bank)

# -X-
# ការសិក្សាវាយតម្លៃលើគម្រោងសាកល្បង ការិយាល័យច្រកចេញចូលតែមួយ និងការិយាល័យប្រជាពលរដ្ឋ

*ដោយលោក ហេង សីហា*[១]

ដើម្បីពង្រឹងប្រព័ន្ធរដ្ឋបាល និងរចនាសម្ព័ន្ធរបស់រដ្ឋបាលមូលដ្ឋាន ជាពិសេសនៅថ្នាក់រដ្ឋបាលស្រុក យន្តការថ្មីសម្រាប់ការផ្តល់សេវាសាធារណៈ ដែលមានឈ្មោះថា ការិយាល័យច្រកចេញចូលតែមួយ (OWSO) និង ការិយាល័យប្រជាពលរដ្ឋ (DO) ត្រូវបានបង្កើតឡើងនៅឆ្នាំ២០០៥ ក្នុងស្រុកសាកល្បងចំនួនពីរ គឺស្រុកបាត់ដំបង និង សៀមរាប ។ គម្រោងសាកល្បងនេះមានគោលដៅជួយឲ្យរដ្ឋបាលថ្នាក់ស្រុកមានតួនាទី និងមុខងារ ក្នុងការផ្តល់សេវាមួយចំនួនដល់ប្រជាជនតាមនីតិវិធីងាយស្រួល ក្នុងតម្លៃសេវាថោកសមរម្យ និងមានតម្លាភាព ។ ម្យ៉ាងទៀត គម្រោងសាកល្បងនេះក៏ជាផ្នែកមួយនៃការខិតខំរបស់រាជរដ្ឋាភិបាល ក្នុងការលើកកម្ពស់លទ្ធិប្រជាធិបតេយ្យនៅមូលដ្ឋាន និងពន្លឿនកំណែទម្រង់ វិមជ្ឈការ និងវិសហមជ្ឈការ ដើម្បីកាត់បន្ថយភាពក្រីក្រ ពង្រឹងគណនេយ្យភាពសង្គម និងអភិបាលកិច្ចល្អជារួមផងដែរ ។

អត្ថបទនេះ សិក្សាវាយតម្លៃលើគម្រោងសាកល្បង OWSO និង DO ដោយពិនិត្យពីភាពខុសគ្នារវាងប្រព័ន្ធផ្តល់សេវាសាធារណៈដែលមានស្រាប់ និងសិក្សាពីចំណុចជោគជ័យ និងបញ្ហាប្រឈមនានាក្នុងយន្តការថ្មី ។ ការសិក្សាព្យាយាមឆ្លើយនឹងសំណួរសំខាន់ៗ ៣ ដូចខាងក្រោម៖

១. តើប្រព័ន្ធចាស់នៃការផ្តល់សេវារបស់ថ្នាក់ស្រុក មានដំណើរការយ៉ាងដូចម្តេច?
២. តើយន្តការថ្មីនៃ OWSO-DO ដំណើរការយ៉ាងដូចម្តេច?
៣. ក្នុងដំណើរការនៃកំណែទម្រង់ និងការផ្លាស់ប្តូរពីប្រព័ន្ធចាស់ទៅប្រព័ន្ធថ្មី៖
- តើមានគុណប្រយោជន៍អ្វីខ្លះក្នុងការជ្រើសយកប្រព័ន្ធថ្មី?
- តើអ្នកដែលមិនបានទទួលអត្ថប្រយោជន៍ពីប្រព័ន្ធចាស់គេអាចទទួលបានអត្ថប្រយោជន៍ពីប្រព័ន្ធថ្មីដែរ ឬទេ?

ការសិក្សានេះបានធ្វើឡើងពីខែវិច្ឆិកា ២០០៩ ដល់ មេសា ២០១០ នៅស្រុកសាកល្បងបានជ្រើសរើសចំនួនពីរ គឺបាត់ដំបង និង សៀមរាប ដោយមានការធ្វើសម្ភាសន៍អ្នកប្រើប្រាស់សេវា (ប្រជាជន) មន្ត្រី OWSO-DO និងមន្ត្រីមន្ទីរជំនាញ ដែលបានធ្វើប្រតិភូកម្មមុខងារឲ្យ OWSO ។ ដើម្បីស្វែងយល់ពីប្រព័ន្ធចាស់ ការសិក្សាក៏បានជ្រើសរើសស្រុកដូនកែវ ក្នុងខេត្តតាកែវ មកសិក្សាស្រាវជ្រាវ និងធ្វើការប្រៀបធៀបដែរ ។

## ១. ការផ្តល់សេវានៅមូលដ្ឋានតាមប្រព័ន្ធដែលមានស្រាប់

ប្រព័ន្ធដែលមានស្រាប់ត្រូវបានដាក់អនុវត្តទូទាំងប្រទេស និងស្ថិតក្រោមអំណាចរបស់ក្រសួងជំនាញសាមីនីមួយៗ ។ រាល់ការសម្រេចចិត្តក្នុងការផ្តល់សេវា ត្រូវផ្អែកតាមប្រភេទនៃសេវាដែល

---
[១] លោក ហេង សីហា ជាអ្នកស្រាវជ្រាវ នៅវិទ្យាស្ថាន CDRI ។

ប្រជាជនស្នើសុំ ។ ឧទាហរណ៍៖ បើសេវាមានលក្ខណៈធំដុំ ត្រូវមានការសម្រេចចិត្តពីថ្នាក់ក្រសួងសាម៉ី តែបើសេវាមានលក្ខណៈតូចជាង ឬតូចតាច ការសម្រេចចិត្តអាចធ្វើឡើងត្រឹមមន្ទីរជំនាញថ្នាក់ខេត្ត ។ ប៉ុន្តែពាក្យស្នើសុំ និងសកម្មភាពស្នើសុំនានា ត្រូវតែធ្វើឡើងតាមរយៈមន្ទីរជំនាញសាម៉ី ។

ករណីសិក្សានៅស្រុកដូនកែវបង្ហាញថា ប្រជាពលរដ្ឋដែលចង់ស្នើសុំសេវាត្រូវធ្វើទំនាក់ទំនងដោយផ្ទាល់ជាមួយមន្ត្រីរបស់ការិយាល័យជំនាញក្នុងស្រុកនោះ ។ ការិយាល័យផ្សេងៗ ត្រូវបានបង្កើតឡើងនៅស្រុកនោះសម្រាប់ក្រសួងជំនាញនានា ដូចជា ក្រសួងឧស្សាហកម្មរ៉ែ និងថាមពល ក្រសួងរៀបចំដែនដីនគររូបនីយកម្ម និងសំណង់ ក្រសួងអប់រំ ក្រសួងសាធារណការ និងដឹកជញ្ជូនជាដើម ។

ការស្រាវជ្រាវលើប្រព័ន្ធដែលមានស្រាប់បង្ហាញថា នីតិវិធី និងតម្លៃរបស់សេវានីមួយៗនៅមិនទាន់ច្បាស់លាស់ និងមានលក្ខណៈលាក់លៀម ។ កម្រៃ និងការបង់ប្រាក់ក្រៅផ្លូវការ ត្រូវតែមានបង់ជាចាំបាច់នៅរាល់ដំណាក់កាលនៃការស្នើសុំសេវា ចាប់ពីថ្នាក់ឃុំទៅដល់ថ្នាក់មន្ទីរ ។ តម្លៃរបស់សេវានីមួយៗ គេតែងកំណត់ ឬសម្រេចវា តាមរយៈសាច់ញាតិ ខ្សែស្រឡាយ និងទំនាក់ទំនងរវាងបុគ្គល ។

ជាធម្មតាក្នុងប្រព័ន្ធនេះ ប្រជាពលរដ្ឋមិនមានព័ត៌មានគ្រប់គ្រាន់ទេថា តើគាត់ត្រូវមានឯកសារអ្វីខ្លះ និងតើនរណាទទួលខុសត្រូវលើការផ្តល់សេវាទាំងនោះ ។ ក្នុងល័ក្ខខ័ណ្ឌនេះ ប្រជាពលរដ្ឋតែងតែស្វែងរកឈ្មួញកណ្តាល ឬអ្នករត់ការ ឲ្យជួយទៅសុំសេវាជំនួសខ្លួន ហើយនៅពេលខ្លះប្រជាពលរដ្ឋត្រូវពឹងពាក់មន្ត្រីតាមមន្ទីរជំនាញឲ្យជួយរត់ការជំនួសខ្លួន ដោយគ្រាន់តែផ្តល់ប្រាក់ឈ្នួលបន្ថែមដល់អ្នកទាំងនោះ ។ តាមនេះ អ្នកមានអំណាចតាមតួនាទីរបស់ខ្លួនក្នុងជួររដ្ឋាភិបាលអាចទទួលបានប្រយោជន៍ពីប្រព័ន្ធ ដូចជា ការមិនចាំបាច់បង់កម្រៃសេវា ឬការទទួលបានផលកម្រៃផ្សេងៗទៀត ។ ដូច្នេះ គ្មានអ្វីគួរភ្ញាក់ផ្អើលទេ ដែលប្រជាពលរដ្ឋមានគំនិតអវិជ្ជមាន និងការជឿទុកចិត្តតិចតួចទៅលើប្រព័ន្ធដែលមានស្រាប់ ។

ការសិក្សាអាចសន្និដ្ឋានជារួមបានថា នៅស្រុកគោលដៅក្នុងខេត្តតាកែវ ដែលបានជ្រើសយកមកសិក្សា ប្រព័ន្ធផ្តល់សេវា និងការគ្រប់គ្រងក្នុងប្រព័ន្ធដែលមានស្រាប់ គឺនៅខ្វះតម្លាភាព ខ្វះនីតិវិធីច្បាប់ និងមានការយកកម្រៃក្រៅផ្លូវការ ។ បញ្ហាទាំងនេះ មិនត្រឹមតែប៉ះពាល់ដល់ប្រជាពលរដ្ឋប៉ុណ្ណោះទេ ប៉ុន្តែប៉ះពាល់ដល់ទាំងមន្ត្រី និងបុគ្គលិកជាអ្នកផ្តល់សេវាថែមទៀត ។

## ២. ការិយាល័យច្រកចេញចូលតែមួយ

ការិយាល័យច្រកចេញចូលតែមួយ (OWSO) រួមមាន "ការិយាល័យជួរមុខ" សម្រាប់ទំនាក់ទំនងជាមួយប្រជាពលរដ្ឋ ប្រគល់ពាក្យសុំ និងប្រមូលឯកសារ និង "ការិយាល័យជួរក្រោយ" ដែលជាកន្លែងមន្ត្រីជំនាញទទួលបន្ទុកធ្វើការពិនិត្យឯកសារពាក្យសុំ ដោយផ្តោតលើផ្នែកបច្ចេកទេស ។ មន្ត្រីជួរក្រោយទាំងនេះ សុទ្ធតែបញ្ជូនមកពីមន្ទីរជំនាញសាម៉ីផ្សេងៗ ដែលបានផ្ទេរមុខងារ ឬសេវាទៅឲ្យ OWSO ។

### ក. មុខងារ

គិតតាំងពីឆ្នាំ២០០៥ មក មានក្រសួងជំនាញចំនួន ៦ ហើយដែលបានធ្វើប្រតិភូកម្មមុខងារទៅឲ្យ OWSO គឺមាន (១) ក្រសួងពាណិជ្ជកម្ម (២) ក្រសួងសាធារណការ និងដឹកជញ្ជូន (៣) ក្រសួងទេសចរណ៍ (៤) ក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល (៥) ក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ និង (៦) ក្រសួងរៀបចំដែនដី នគររូបនីយកម្ម និងសំណង់ ។ OWSO នៅក្នុងស្រុកទាំងពីរ គឺបាត់ដំបង និងសៀមរាប មានភាពខុសប្លែកពីប្រព័ន្ធដែលមានស្រាប់តាមរូបភាពពីរយ៉ាង

គឺ (១) តម្លៃសម្រាប់សេវានីមួយៗនៅ OWSO មានភាពច្បាស់លាស់ និងមាន តម្លាភាព (បង្ហាញជាសាធារណៈដល់ប្រជាពលរដ្ឋ) និង (២) សេវាផ្តល់ឲ្យមានតម្លៃថោកសមរម្យ លឿនទាន់ពេលវេលា និងមានសង្គតភាព ។ ម៉្យាងទៀត នីតិវិធី និងពាក្យស្នើសុំសេវា មានលក្ខណៈសាមញ្ញ ច្បាស់លាស់ និងងាយស្រួលសម្រាប់ប្រជាពលរដ្ឋ ។

ក្រៅពីចំណុចល្អដូចរៀបរាប់ខាងលើ ការសិក្សានៅស្រុកទាំងពីរនេះក៏បានរកឃើញថា មុខងារមួយចំនួនដែលបានធ្វើប្រតិភូកម្មឲ្យទៅ OWSO នៅមិនទាន់ច្បាស់លាស់ទេ ដែលបង្កើតឲ្យមានការយល់ខុស និងការមិនសប្បាយចិត្តរវាង OWSO និងស្ថាប័នពាក់ព័ន្ធ ។ បញ្ហានេះធ្វើឲ្យប្រជាពលរដ្ឋមួយចំនួនមានការខកចិត្ត នៅពេលដែល OWSO មិនអាចធ្វើការសម្រេចចិត្ត ឬផ្តល់សេវាដែលពួកគេបានស្នើសុំ ។ ឧទាហរណ៍៖ ប្រកាសលេខ ១១៦ របស់ក្រសួងទេសចរណ៍ បានចែងថា សម្រាប់រាល់ភោជនីយដ្ឋានដែលមានចំនួនកៅអីតិចជាង ៥០ ការិយាល័យ OWSO អាចផ្តល់អាជ្ញាប័ណ្ណជូនប្រជាពលរដ្ឋបាន ប៉ុន្តែបញ្ហាចោទឡើង នៅពេលមន្ទីរជំនាញតម្រូវឲ្យភោជនីយដ្ឋានទំនើប និងមានចំណូលច្រើន (ដូចជា បាបារាំង ក្លឹបរាត្រី) ចុះបញ្ជីសុំអាជ្ញាប័ណ្ណនៅមន្ទីរជំនាញវិញ ទោះបីជាភោជនីយដ្ឋានទាំងនោះមានចំនួនកៅអីតិចជាង ៥០ ក្តី ។

ទាក់ទងនឹងប្រតិភូកម្មមុខងារនេះដែរ កង្វះខាតក្នុងការសម្របសម្រួលតាមខ្សែទទឹង ក៏នៅតែជាបញ្ហាចំបងមួយ ។ ជាក់ស្តែងសម្រាប់អាជីវកម្មដែលត្រូវសុំអាជ្ញាប័ណ្ណច្រើនសម្រាប់សេវាតែមួយ គឺនៅតែជួបការលំបាក ។ ឧទាហរណ៍៖ អ្នកបើកម៉ូតូកង់បី (TUK TUK) ត្រូវទៅសុំស្លាកលេខពី OWSO ផង ប័ណ្ណបើកបរពីក្រសួងសាធារណការ និងដឹកជញ្ជូនផង និង ឯកសណ្ឋានពីនគរបាលចរាចរណ៍ជើងគោកផង ។

ខ. ចំណូល និងថវិកា

*ចំណូល៖* ចំណុចមួយដែលអាចចាត់ទុកជាជោគជ័យរបស់ប្រព័ន្ធថ្មី គឺផ្នែកចំណូល ។ ក្នុងប្រព័ន្ធថ្មីនេះ ចំនួនប្រជាពលរដ្ឋដែលមកសុំសេវានៅ OWSO ឃើញកើនឡើងជាលំដាប់ ដែលធ្វើឲ្យ OWSO រកចំណូលបានច្រើនលើសពីផែនការរដ្ឋទៅទៀត ។ ឧទាហរណ៍៖ ក្នុងឆ្នាំ២០០៩ OWSO នៅស្រុកបាត់ដំបង បានបង្កើនចំណូលរបស់ខ្លួនដល់ទៅ ៨ដង ច្រើនជាងឆ្នាំ២០០៥ ។ ប្រហាក់ប្រហែលគ្នាដែរ ក្នុងឆ្នាំ២០០៥ OWSO នៅស្រុកសៀមរាប រកចំណូលបាន ៤៨លានរៀល ហើយក្នុងឆ្នាំ២០០៩ រកបានដល់ទៅ ២០៥លានរៀល (រាជរដ្ឋាភិបាលបានកំណត់ផែនការត្រឹមតែ ៨៧លានរៀលប៉ុណ្ណោះ សម្រាប់ឆ្នាំ២០០៩)។ តួលេខនេះបង្ហាញថា ប្រជាជនកាន់តែមានជំនឿទុកចិត្តលើប្រព័ន្ធថ្មី ហើយបើតាមការអង្កេត អ្នកដែលមិនបានសុំសេវាក្នុងប្រព័ន្ធមានស្រាប់ ដោយសារខ្វះទំនុកចិត្ត ភ័យខ្លាច ឬមិនមានលទ្ធភាពបង់កម្រៃសេវា បានងាកមកស្នើសុំសេវាផ្សេងៗនៅ OWSO តាមប្រព័ន្ធថ្មីនេះ ។

*ថវិកា៖* ចំណាយប្រតិបត្តិការប្រចាំថ្ងៃរបស់ OWSO បានមកពីកញ្ចប់ថវិការបស់សាលាស្រុក ដែលជាចំណែកតូចមួយនៃកញ្ចប់ថវិការបស់សាលាខេត្ត និងដែលខេត្តបើកផ្តល់ជារៀងរាល់ឆ្នាំដល់ស្រុក/ក្រុងនីមួយៗរបស់ខ្លួន ។ ទោះបីជា OWSO រកបានចំណូលយ៉ាងច្រើនក៏ដោយ ក៏ OWSO មិនមានស្វ័យភាពផ្នែកហិរញ្ញវត្ថុលើចំណូលដែលខ្លួនប្រមូលបានទេ ដូច្នេះ ត្រូវនៅតែពឹងពាក់ទាំងស្រុងលើកញ្ចប់ថវិកាដ៏តិចតួចរបស់សាលាស្រុកដដែល ។ ដូចក្នុងការសិក្សាមុនៗដែរ ការសិក្សានេះបង្ហាញថា OWSO នៅតែបន្តជួបបញ្ហាខ្វះខាតថវិកាប្រតិបត្តិការដែលបង្កជាការព្រួយបារម្ភ និងអាចប៉ះពាល់ដល់ប្រសិទ្ធិភាពនៃយន្តការក្នុងប្រព័ន្ធថ្មី ។

គ. ធនធានមនុស្ស

ដូចបានបញ្ជាក់នៅខាងលើ OWSO មានបុគ្គលិកជួរមុខ (ជាប់កិច្ចសន្យា) និងបុគ្គលិកជួរក្រោយ (បញ្ជូនមកពីមន្ទីរជំនាញសាមីុ) ។ ការសិក្សាបង្ហាញថា កង្វះចំណេះដឹង និងជំនាញ នៅតែជាបញ្ហាចំបងរបស់ OWSO ។ កត្តាមួយដែលនាំឲ្យ OWSO ជួបបញ្ហានេះ គឺសមត្ថភាពនៅមានកម្រិតរបស់បុគ្គលិក ដែលក្រសួងជំនាញសាមីុបញ្ជូនមកឲ្យ OWSO ។ ចំណុចនេះ បង្ហាញពីភាពស្ទាក់ស្ទើររបស់ក្រសួងជំនាញសាមីុ ក្នុងការបញ្ជូនបុគ្គលិកមានសមត្ថភាពទៅឲ្យ OWSO ពីព្រោះពួកគេគ្មានបានអ្វីពីការធ្វើដូច្នោះ ក្រៅតែពីការបាត់បង់ប្រយោជន៍ផ្ទាល់ខ្លួនប៉ុណ្ណោះ ។ ដូចក្នុងការសិក្សាមុនៗដែរ ការសិក្សានេះបង្ហាញថា ក្រសួងជំនាញសាមីុនៅតែមានភាពស្ទាក់ស្ទើរដដែលក្នុងការបញ្ជូនបុគ្គលិកមានសមត្ថភាពទៅឲ្យ OWSO ។ ឧទាហរណ៍ជាក់ស្តែង៖ ក្នុងអំឡុងពេលសិក្សានេះ ក្រុមស្រាវជ្រាវបានសង្កេតឃើញថា ក្នុងចំណោមបុគ្គលិកដែលបានបញ្ជូនទៅឲ្យ OWSO តាំងពីឆ្នាំ២០០៥ គឺមិនទាន់មានការផ្លាស់ប្តូរអ្នកណាម្នាក់នៅឡើយទេ ។

ពាក់ព័ន្ធទៅនឹងប្រាក់បៀវត្សរ៍ និងការលើកទឹកចិត្ត បុគ្គលិកភាគច្រើនរបស់ OWSO បានទទួលប្រាក់លើកទឹកចិត្តបន្ថែម (ប្រាក់កន្សោមអាទិភាព ហៅកាត់ថា PMG) លើប្រាក់បៀវត្សរ៍របស់ខ្លួន ។ បន្ទាប់ពី OWSO ដំណើរការបាន ៥ឆ្នាំមក គេឃើញច្បាស់ថា ប្រាក់លើកទឹកចិត្តបន្ថែមបានដើរតួនាទីសំខាន់ក្នុងការលើកទឹកចិត្តដល់បុគ្គលិក និងសកម្មភាពការងាររបស់ពួកគេឲ្យកាន់តែមានប្រសិទ្ធិភាព ។ កត្តានេះជួយឲ្យប្រព័ន្ធ OWSO ទទួលបានជោគជ័យ និងការជឿទុកចិត្តពីប្រជាពលរដ្ឋ និងបានជួយទប់ស្កាត់ការរកកម្រៃក្រៅផ្លូវការក្នុងចំណោមបុគ្គលិករបស់ OWSO ។ ប៉ុន្តែប្រាក់លើកទឹកចិត្តបន្ថែមនេះ រាជរដ្ឋាភិបាលបានសម្រេចបញ្ឈប់ការអនុវត្តនៅត្រឹមដើមឆ្នាំ២០១០ ដែលជាកត្តាគួរឲ្យព្រួយបារម្ភសម្រាប់និរន្តរភាពរបស់ប្រព័ន្ធ OWSO ពីព្រោះវាបានក្លាយជាយន្តការមួយ ជួយឲ្យបុគ្គលិកអនុវត្តការងារបានល្អ និងមានប្រសិទ្ធិភាព ។ ម្យ៉ាងទៀត ប្រសិនបើបុគ្គលិកត្រូវពឹងផ្អែកតែទៅលើប្រាក់បៀវត្សរ៍ដ៏តិចតួច គឺអាចកើតមានការរាំងស្ទះដល់ទិសដៅចម្បងរបស់ OWSO ក្នុងការលើកកម្ពស់សមត្ថភាពបុគ្គលិក និងបំបាត់អំពើពុករលួយ ។

ឃ. ទស្សនៈរបស់អ្នកពាក់ព័ន្ធ និងប្រជាពលរដ្ឋ

សព្វថ្ងៃ ប្រជាពលរដ្ឋបានយល់ដឹងកាន់តែច្រើនអំពីប្រព័ន្ធ OWSO ។ ដោយសារប្រព័ន្ធមានតម្លាភាព និងភាពគួរទុកចិត្តបានក្នុងការផ្តល់សេវា ប្រជាពលរដ្ឋមានសុទិដ្ឋិនិយម និងឆន្ទៈខ្ពស់ក្នុងការចូលរួម និងប្រើប្រាស់ប្រព័ន្ធនេះ ដើម្បីស្នើសុំសេវា ។ គួរកត់សម្គាល់ថា មិនត្រឹមតែប្រជាពលរដ្ឋប៉ុណ្ណោះទេ ប៉ុន្តែអ្នកពាក់ព័ន្ធដទៃទៀត ដូចជា ប្រធាន OWSO បុគ្គលិក OWSO អភិបាលក្រុង អភិបាលរង និងអាជីវករនៅស្រុកបាត់ដំបង និងសៀមរាប ក៏បានបង្ហាញគំនិតវិជ្ជមានចំពោះប្រព័ន្ធថ្មីដែរ ព្រោះប្រព័ន្ធនេះបានដើរតួនាទីសំខាន់ក្នុងការកាត់បន្ថយអំពើពុករលួយ និងជួយលើកស្ទួយជីវភាពប្រជាជន តាមរយៈការផ្តល់សេវាមានតម្លៃសមរម្យ លឿនទាន់ពេល និងមានប្រសិទ្ធិភាព បើធៀបទៅនឹងប្រព័ន្ធដែលមានស្រាប់ ។ គេក៏សង្កេតឃើញថា យន្តការនេះបានជួយបង្ខិតរាជរដ្ឋាភិបាល ឬរដ្ឋអំណាចឲ្យទៅជិតប្រជាពលរដ្ឋ ដោយផ្លាស់ប្តូរពីអ្នកគ្រប់គ្រង ទៅជាអ្នកផ្តល់សេវាសាធារណៈជូនប្រជាជនវិញ ។

## ៣. ការិយាល័យប្រជាពលរដ្ឋ

នៅក្នុងប្រព័ន្ធ OWSO-DO ការិយាល័យប្រជាពលរដ្ឋ (DO) មានតួនាទីជួយពង្រឹងអាជ្ញាធរស្រុកក្នុងការផ្តល់សេវាសាធារណៈ ជួយទប់ស្កាត់អំពើពុករលួយ និងជួយកសាងទំនុកចិត្តរបស់

ប្រជាពលរដ្ឋលើមន្ត្រីរាជការ តាមរយៈការទទួល និងជួយដោះស្រាយបណ្តឹង និងកង្វល់នានារបស់ប្រជាពលរដ្ឋលើប្រព័ន្ធថ្មី ដោយផ្អែកលើយន្តការសម្រុះសម្រួល ។

យោងតាមការសិក្សានេះ និងតាមការប្រៀបធៀបជាមួយ OWSO ស្នាដៃ និងជោគជ័យរបស់ DO នៅមានកម្រិតនៅឡើយក្នុងការទទួល និងដោះស្រាយបណ្តឹងរបស់ប្រជាពលរដ្ឋ ។ ឧទាហរណ៍៖ នៅក្រុងបាត់ដំបង តាំងពីឆ្នាំ២០០៥ មក DO បានទទួលបណ្តឹងជាលាយលក្ខណ៍អក្សរតែ ២បណ្តឹង ប៉ុណ្ណោះ ។ មូលហេតុនៃបណ្តឹងមានតិចតួច គឺប្រជាពលរដ្ឋអាចមិនហ៊ានប្តឹង ដោយសារកង្វះខាតការផ្សព្វផ្សាយអប់រំ កង្វះជំនឿទុកចិត្តលើប្រព័ន្ធថ្មី និងការភ័យខ្លាចចំពោះមន្ត្រីរដ្ឋអំណាច ហើយពួកគាត់បែរជាមានការរអ៊ូរទាំ ឬធ្វើបណ្តឹងផ្ទាល់មាត់ជំនួសវិញ ដែលបង្កការលំបាកដល់ DO ក្នុងការដោះស្រាយ ។ ដោយសារមិនមានបណ្តឹងច្រើន DO សព្វថ្ងៃកំពុងដើរតួនាទីជាអ្នកផ្តល់ការគាំទ្រ និងផ្តល់ព័ត៌មានអំពី OWSO ជូនដល់ប្រជាជន ទោះបីជាច្បាប់មិនបានចែង ឬប្រគល់មុខងារនេះឲ្យខ្លួនក្តី ។

ក្រៅពីបញ្ហាដូចខាងលើ DO កំពុងជួបបញ្ហាមួយចំនួនទៀត ដូចជា (១) សមត្ថភាពរបស់ប្រធាន DO នៅខ្វះខាតក្នុងការដោះស្រាយបញ្ហា ឬជម្លោះ/បណ្តឹង (២) បុគ្គលិកនៅមានចំនួនតិច ដែលធ្វើឲ្យពិបាកដល់ការបំពេញភារកិច្ច (៣) ប្រាក់បៀវត្សរ៍នៅទាបត្រឹម ១២៣.៤០០រៀល ដែលធ្វើឲ្យមន្ត្រីនានាមិនមានទឹកចិត្តបម្រើការពេញម៉ោង (៤០ម៉ោងក្នុង១សប្តាហ៍) និង (៤) DO មិនទាន់មានចំណាយប្រតិបត្តិការដូចជា OWSO ទេ ដែលប៉ះពាល់យ៉ាងខ្លាំងដល់ដំណើរការ និងប្រសិទ្ធិភាពរបស់ DO ទាំងមូល ដូចជា កង្វះខាតការផ្សព្វផ្សាយអប់រំដល់ប្រជាជននៅមូលដ្ឋានជាដើម ។

ការយល់ដឹងរបស់អ្នកពាក់ព័ន្ធ និងប្រជាពលរដ្ឋអំពី DO នៅមានកម្រិតនៅឡើយ ។ ក្នុងការសិក្សានេះ ជាង ៩០% នៃអ្នកឆ្លើយសម្ភាសន៍បានបញ្ជាក់ថា ពួកគាត់មិនបានដឹងពី DO និងការងាររបស់ DO ទេ ។ ដោយសារការយល់ដឹងនៅមានកម្រិត ប្រជាជនមិនបានប្រើប្រាស់យន្តការនេះទេ នៅពេលពួកគាត់ជួបបញ្ហាពាក់ព័ន្ធនឹងការផ្តល់សេវាសាធារណៈក្នុងស្រុកគាត់ ។ ដូច្នេះទើបមិនសូវមានបណ្តឹងជាផ្លូវការឲ្យ DO ជួយដោះស្រាយ ។

សរុបមក ប្រជាពលរដ្ឋមិនទាន់ពេញចិត្តនឹងការងារ DO នៅឡើយទេ បើប្រៀបធៀបទៅនឹង OWSO ។ តាមការវិភាគ និងអង្កេត DO មិនទាន់ទទួលបានជោគជ័យ ដោយសារមានកត្តារាំងស្ទះជាច្រើន ដូចជា មុខងារនៅមានកំណត់ កង្វះខាតថវិកា កង្វះការផ្សព្វផ្សាយ កង្វះជំនឿទុកចិត្តរបស់ប្រជាជនលើប្រព័ន្ធថ្មី កត្តាវប្បធម៌នយោបាយ ។ល។

## ៤. សេចក្តីសន្និដ្ឋាន និងអនុសាសន៍

ប្រព័ន្ធផ្តល់សេវាបានលើកមកពិភាក្សានេះ អាចចាត់ទុកជាគំរូនៃប្រព័ន្ធផ្តល់សេវាថ្មីមួយនៅប្រទេសកម្ពុជា ដែលខុសប្លែកពីប្រព័ន្ធផ្តល់សេវាមានស្រាប់ ត្រង់ចំណុចសំខាន់ៗមួយចំនួន ដូចជា តម្លៃសេវាថោកសមរម្យ ប្រសិទ្ធិភាពការងារ សង្គតភាព តម្លាភាព និងភាពងាយស្រួលស្នើសុំសេវា ។ ប្រព័ន្ធថ្មីនេះ ក៏មានជោគជ័យល្អដែរក្នុងការជួយកាត់បន្ថយអំពើពុករលួយ និងធ្វើជាស្ពានបង្កើនជំនឿទុកចិត្តរបស់ប្រជាពលរដ្ឋទៅលើរាជរដ្ឋាភិបាល និងរដ្ឋអំណាចមូលដ្ឋាន ។

ក្រៅពីចំណុចវិជ្ជមាន និងលទ្ធផលល្អដូចខាងលើ ការសិក្សាក៏បានរកឃើញបញ្ហាប្រឈមមួយចំនួនដែលអាចប៉ះពាល់ដល់សមត្ថភាពរបស់ប្រព័ន្ធថ្មី ក្នុងការផ្តល់សេវាជូនប្រជាពលរដ្ឋ ដូចជា កង្វះថវិកា កង្វះស្វ័យភាពផ្នែកហិរញ្ញវត្ថុ សមត្ថភាពមានកម្រិតរបស់បុគ្គលិក កង្វះការលើកទឹកចិត្ត កង្វះឆន្ទៈនយោបាយ កង្វះការសម្របសម្រួលខ្សែទទឹង ហើយសេវាមួយចំនួនក៏នៅមានកម្រិត ។

ជាអនុសាសន៍ ដើម្បីឲ្យប្រព័ន្ធ OWSO ដំណើរការបានជោគជ័យ និងមានប្រសិទ្ធិភាពក្នុងការផ្តល់សេវាជូនប្រជាជន រាជរដ្ឋាភិបាល និងស្ថាប័នពាក់ព័ន្ធគួរអនុញ្ញាតឲ្យ OWSO រក្សាទុកចំនួន

ណាមួយនៃចំណូលដែលខ្លួនប្រមូលបានលើសផែនការ និងមានស្វ័យភាពពេញលេញលើធនធានហិរញ្ញវត្ថុដែលខ្លួនមាន ដើម្បីឲ្យ OWSO អាចមានលទ្ធភាពដោះស្រាយបញ្ហាខ្វះខាតចំណាយប្រតិបត្តិការប្រចាំថ្ងៃរបស់ខ្លួន ។ ដើម្បីដោះស្រាយបញ្ហាធនធានមនុស្ស រាល់ក្រសួងជំនាញដែលបានផ្ទេរមុខងារឲ្យ OWSO គួរផ្តល់នូវមន្ត្រីមានសមត្ថភាព ព្រមទាំងថវិកា និងបរិក្ខារផ្សេងៗ ដើម្បីគាំទ្រដល់ប្រព័ន្ធថ្មី ។ ហើយដើម្បីលើកទឹកចិត្តឲ្យបុគ្គលិកបន្តបំពេញការងារកាន់តែមានប្រសិទ្ធិភាព និងកាត់បន្ថយអំពើពុករលួយ យន្តការផ្តល់ប្រាក់បន្ថែមលើប្រាក់បៀវត្សរ៍មួយ គួរតែបង្កើតឡើង និងដាក់អនុវត្ត ។

ដូចគ្នានឹង OWSO ដែរ ដើម្បីធ្វើឲ្យ DO បំពេញការងារបានល្អ គួរយកចិត្តទុក្ខដាក់ និងដោះស្រាយជាបន្តបន្ទាប់ (១) បង្កើនប្រាក់បៀវត្សរ៍ និងផ្តល់ការលើកទឹកចិត្តបន្ថែម ព្រោះតួនាទីនេះមិនអាចរកចំណូលបានដោយមធ្យោបាយណាផ្សេងទេ (២) ផ្តល់វគ្គសិក្សាខ្លីទាក់ទងនឹងការដោះស្រាយជម្លោះ ឬបណ្តឹង និង (៣) បន្ត និងជម្រុញការផ្សព្វផ្សាយពីតួនាទី និងការទទួលខុសត្រូវរបស់ DO ដើម្បីប្រជាជនកាន់តែយល់ដឹង និងអាចប្រើប្រាស់ការិយាល័យនេះ នៅពេលពួកគេមានបញ្ហាក្នុងការស្នើសុំសេវា ។

ការសិក្សាផ្តល់ការសន្និដ្ឋានថា រាជរដ្ឋាភិបាលមានឆន្ទៈរឹងប៉ឹង និងធំទូលាយក្នុងការធ្វើកំណែទម្រង់រដ្ឋបាល ដែលលាតត្រដាងតាមរយៈកំណែទម្រង់វិមជ្ឈការ និងវិសហមជ្ឈការ ជាពិសេសការដាក់អនុវត្តយន្តការផ្តល់សេវាសាធារណៈថ្មី OWSO-DO ។ ទោះបីជា OWSO ទទួលបានជោគជ័យគួរឲ្យកត់សម្គាល់ ប៉ុន្តែលទ្ធផលការងាររបស់ DO នៅមានកំណត់ ។ ប្រព័ន្ធយន្តការ OWSO-DO សំខាន់ណាស់ ព្រោះមិនគ្រាន់តែជាជំហានមួយក្នុងការកាត់បន្ថយអំពើពុករលួយ និងពង្រឹងការផ្តល់សេវាសាធារណៈប៉ុណ្ណោះទេ ប៉ុន្តែក៏ជាមធ្យោបាយសក្តិសិទ្ធិដើម្បីសម្រេចគោលដៅវែងឆ្ងាយរបស់រាជរដ្ឋាភិបាលលើអភិបាលកិច្ចល្អទៀតផង ។ ដូច្នេះ ប្រព័ន្ធយន្តការផ្តល់សេវាថ្មីនេះគួរតែថែរក្សា និងពង្រឹងពង្រីកបន្ថែម ។

## ឯកសារយោង


Chandler, David (1993), *A History of Cambodia*, 2nd ed. (Chiang Mai: Silkworm)

Clasen, Hans & Ruth Gruber (June 2006), *One Window Service Office and the Reform of the District Administrations in Battambang and Siem Reap* (Phnom Penh: Asia Urbs Project)

Council for Administrative Reform (2001), *Governance Action Plan* (Phnom Penh: RGC)

Gottesman, Evan (2004), *Cambodia after the Khmer Rouge: Inside the Politics of Nation Building* (New Haven, CT: Yale University Press)

Hughes, Caroline (2003), *The Political Economy of Cambodia's Transition, 1999-2001* (London, New York: Routledge Curzon)

Hughes, Caroline (2001), *An Investigation of Conflict Management in Cambodia Villages: A Review of the Literature with Suggestions for Future Research* (Phnom Penh: CDRI)

Ministry of Interior (June 2007), *Brief Report on Internal Assessment of OWSO Pilot Projects in Battambang and Siem Reap* (Phnom Penh: RGC)

Ministry of Interior (2007), *One Window Service and Ombudsman: Final Draft on DFGG* (Phnom Penh: MoI)

Pak Kimchoeun, Vuthy Horng, Netra Eng, Sovatha Ann, Sedara Kim, Jenny Knowles & David Craig (2007), "*Accountability and Neo-patrimonialism in Cambodia: A Critical Literature Review*" (Phnom Penh:CDRI)

Royal Government of Cambodia (June 2005), *Strategic Framework for Decentralisation and Deconcentration Reforms* (Phnom Penh: Council of Ministers)

Roberts, David (2008), "Post-conflict State Building and State Legitimacy: From Negative to Positive Peace?" *Development and Change*, 39(4), pp.537-555

Rusten, Caroline, Kim Sedara, Eng Netra, & Pak Kimchoeun (2004), "*The Challenges of Decentralization Design in Cambodia*" Monograph N.1 (Phnom Penh: CDRI)

Scott, James (1985), *Weapons of the Weak, The Everyday Forms of Peasant Resistance* (New Haven: Yale UP)

Simon, Andrea (2008), *New Life - New Town, Asia Urbs project "Strengthening of Pilot City Administrations Battambang and Siem Reap: Revenues and Budget, Transparency and People's Participation", Final Evaluation Report* (Phnom Penh: Asia Urbs)

Un, Kheang (2005), *Patronage Politics and Hybrid Democracy: Political Change in Cambodia, 1993-2003*, (Asian Perspective)

United Nations Economic Commission for Europe (2003), *The Single Window Concept* (Geneva: United Nations)

United Nations (2005), *Case Studies on Implementing a Single Window*, working draft, (Geneva: United Nations)

United Nations (2007), *Good Governance Practices for the Protection of Human Rights* (New-York & Geneva: United Nations)

# ផ្នែកទី ៥
# អភិវឌ្ឍន៍សង្គម

-XI-

# គ្រឿងលើកទឹកចិត្ត និង ការរក្សាបុគ្គលិកសុខាភិបាល នៅតំបន់ជនបទ និងតំបន់ជួបការលំបាកនៅកម្ពុជា

*ដោយលោក សេង ប៊ុនដេត លោក នេត នាថ លោកស្រី Pagaiya Nonglak និង លោកស្រី សុខ សិទ្ធា*[១]

## ១. សេចក្តីផ្តើម

ការរក្សាបុគ្គលិកសុខាភិបាល ឲ្យនៅបម្រើការក្នុងតំបន់ជនបទ និងតំបន់ជួបការលំបាកនៅកម្ពុជា វាស្មុគស្មាញជាខ្លាំងដោយសារមូលហេតុជាច្រើន ដូចជា ប្រាក់ខែទាប ឱកាសធ្វើការឯកជនមានតិច សេវាអប់រំមិនសូវល្អ បញ្ហាផ្ទះសំបែងនិងគ្រឿងសម្រួលការរស់នៅសម្រាប់គ្រួសារ របបគ្រប់គ្រងទន់ខ្សោយ ការគាំទ្រផ្នែកជំនាញនៅមានកម្រិត និងការឃ្លាតឆ្ងាយពីគ្រួសារ ។ ភស្តុតាងបញ្ជាក់រឿងនេះ ភាគច្រើនជាបទពិសោធន៍ផ្ទាល់ខ្លួន ប៉ុន្តែគេក៏ឃើញមានជាទូទៅដែរនៅតាមប្រទេសមានចំណូលទាប ចំណូលមធ្យម និងចំណូលខ្ពស់នានាក្នុងពិភពលោក ។

គ្រឿងលើកទឹកចិត្តបុគ្គលិកសុខាភិបាល មានលក្ខណៈស្មុគស្មាញជាខ្លាំង ដោយមានទាំងគ្រឿងលើកទឹកចិត្តពីខាងក្រៅ និងគ្រឿងលើកទឹកចិត្តផ្ទៃក្នុង ។ រចនាសម្ព័ន្ធ និងកម្លាំង នៃគ្រឿងលើកទឹកចិត្តទាំងនេះ តែងប្រែប្រួលខុសគ្នាទៅតាមបុគ្គល វប្បធម៌ និង ក្រឹត្យក្រមសង្គម ។ ដូច្នេះ លទ្ធផលសំអាងលើបទពិសោធន៍ពីប្រទេសដទៃ ប្រហែលមិនអាចត្រឹមត្រូវទាំងស្រុងសម្រាប់កម្ពុជាទេ ។ ជាពិសេស យើងប្រហែលមិនអាចយកបទពិសោធន៍គ្រឿងលើកទឹកចិត្តនៅប្រទេសដទៃមកដាក់អនុវត្ត ដើម្បីបញ្ចុះបញ្ចូលបុគ្គលិកពេទ្យកម្ពុជាឲ្យទៅធ្វើការនៅទីជនបទដាច់ស្រយាលបានទេ ។

ការសិក្សានេះ ធ្វើឡើងដើម្បីវាយតម្លៃពីឥរិយាបថរបស់និស្សិតពេទ្យនៅឆ្នាំបញ្ចប់ការសិក្សាចំពោះការទៅធ្វើការនៅតំបន់ជនបទ និងវាយតម្លៃពីចំណង់ចំណូលចិត្តរបស់ពួកគេ ចំពោះអន្តរាគមន៍ខាងគោលនយោបាយនានា ដែលអាចយកមកប្រើដើម្បីជ្រើសរើស និងរក្សាទុកបុគ្គលិកសុខាភិបាលជំនាញនៅក្នុងតំបន់ជនបទ ។ ក្នុងការវាយតម្លៃនេះ យើងបានប្រើការពិសោធរកមើលជម្រើសផ្ទាល់ (Discrete Choice Experiment: DCE គឺជាវិធីបែបបរិមាណ សម្រាប់វាយតម្លៃពីសារៈសំខាន់ប្រៀបធៀបនៃចរិតលក្ខណៈផ្សេងៗ ដែលជះឥទ្ធិពលទៅលើជម្រើសរបស់អ្នកប្រើប្រាស់) និងធ្វើអង្កេតបែបបរិមាណមួយក្នុងចំណោម គិលានុបដ្ឋាក ឆ្មប និង និស្សិតវេជ្ជបណ្ឌិត ជាគំរូតាងមួយក្រុម ។

## ២. វិធីសាស្ត្រ

ការសិក្សានេះ ប្រើវិធីចំណូលចិត្តតាមស្ថានភាព (state preference method) ឬហៅម្យ៉ាងទៀតថា វិធីវាយតម្លៃតាមលក្ខខណ្ឌអាចកើតឡើង (contingent valuation method) ។ ក្នុងវិធីនេះ យើងបានស្នើឲ្យអ្នកឆ្លើយសម្ភាសន៍ជ្រើសយកការងារមានចរិតលក្ខណៈខុសៗគ្នា ដែលយើងផ្តល់ឲ្យជាសម្មតិកម្ម ។

---

១ លោក សេង ប៊ុនដេត លោក នេត នាថ និងលោកស្រី សុខ សិទ្ធា ជាអ្នកស្រាវជ្រាវ ហើយលោកស្រី Pagaiya Nonglak ជាទីប្រឹក្សាស្រាវជ្រាវ នៅវិទ្យាស្ថាន CDRI ។

ការពិសោធរកមើលជម្រើសផ្ទាល់

ក្នុងការពិសោធរកមើលជម្រើសផ្ទាល់ (DCE) ជំហានទី១ យើងត្រូវកំណត់នូវចរិតលក្ខណៈផ្សេងៗនៃការងារដែលត្រូវដាក់បញ្ចូលក្នុងការពិសោធ និងកំណត់ពីកម្រិតនៃចរិតលក្ខណៈនីមួយៗ ។ ជំហានទី២ យើងផ្គុំលក្ខណៈទាំងនេះបញ្ចូលគ្នា បង្កើតជាការងារសម្មតិកម្មចំនួន ១៦គូ សម្រាប់ឲ្យអ្នកឆ្លើយសម្ភាសន៍ជ្រើសរើសយកពីក្នុងគូនីមួយៗនូវការងារដែលល្អជាងគេ សម្រាប់តម្រូវការរបស់ខ្លួន ។

ការកំណត់ចរិតលក្ខណៈការងារ និងកម្រិតនៃចរិតលក្ខណៈទាំងនោះ ធ្វើឡើងដោយផ្អែកលើការពិនិត្យឯកសារមានស្រាប់ ការពិនិត្យលើគោលនយោបាយធនធានមនុស្ស សម្ភាសន៍ជាមួយអ្នកផ្តល់ព័ត៌មានគន្លឹះ ការពិភាក្សាតាមក្រុមស្នូល (FGDs) និងសម្ភាសន៍ពាក់កណ្តាលរៀបរយ ។ ចរិតលក្ខណៈការងារ និងកម្រិតរបស់វា ដែលបានជ្រើសរើសសម្រាប់ការសិក្សានេះ មានចុះក្នុងតារាងខាងក្រោម ។

តារាង ១៖ ចរិតលក្ខណៈការងារបានកំណត់សម្រាប់ គិលានុបដ្ឋាក និងឆ្មប

| ចរិតលក្ខណៈការងារ | មូលដ្ឋានសុខាភិបាលនៅជនបទ | មូលដ្ឋានសុខាភិបាល<br>នៅទីប្រជុំជន |
|---|---|---|
| បៀវត្សរ៍ | ដូចគ្នានឹងបៀវត្សរ៍បច្ចុប្បន្ន<br>(៤៥ដុល្លារ)<br>៧០ដុល្លារ<br>៩៥ដុល្លារ<br>១២០ដុល្លារ | ដូចគ្នានឹងបៀវត្សរ៍បច្ចុប្បន្ន<br>(៤៥ដុល្លារ) |
| ឧបករណ៍ និង បរិក្ខារពេទ្យ | មិនគ្រប់គ្រាន់<br>គ្រប់គ្រាន់ | មិនគ្រប់គ្រាន់<br>គ្រប់គ្រាន់ |
| ការផ្តល់ផ្ទះស្នាក់នៅ | គ្មាន<br>មាន | គ្មាន<br>មាន |
| ប្រាក់ឧបត្ថម្ភសម្រាប់ការធ្វើដំណើរ | គ្មាន<br>មាន | គ្មាន |
| រយៈពេលបានឡើងតំណែង | ១ឆ្នាំ<br>២ឆ្នាំ | ១ឆ្នាំ<br>២ឆ្នាំ |
| ឱកាសទទួលបានការបណ្តុះបណ្តាលក្នុង១ឆ្នាំ | ២ សប្តាហ៍<br>៤ សប្តាហ៍ | ០ សប្តាហ៍<br>២ សប្តាហ៍ |
| នៅជិតផ្ទះ | នៅជិត<br>នៅឆ្ងាយ | នៅជិត<br>នៅឆ្ងាយ |

តារាង ២៖ ចរិតលក្ខណៈការងារបានកំណត់សម្រាប់វេជ្ជបណ្ឌិត

| ចរិតលក្ខណៈការងារ | មូលដ្ឋានសុខាភិបាលនៅជនបទ | មូលដ្ឋានសុខាភិបាល នៅទីប្រជុំជន |
|---|---|---|
| បៀវត្សរ៍ | ដូចគ្នានឹងបៀវត្សរ៍បច្ចុប្បន្ន (៥០ដុល្លារ)<br>១០០ដុល្លារ<br>២០០ដុល្លារ<br>៣០០ដុល្លារ | ដូចគ្នានឹងបៀវត្សរ៍បច្ចុប្បន្ន (៥០ដុល្លារ) |
| ឧបករណ៍ និង បរិក្ខារពេទ្យ | មិនគ្រប់គ្រាន់<br>គ្រប់គ្រាន់ | មិនគ្រប់គ្រាន់<br>គ្រប់គ្រាន់ |
| ការផ្តល់ផ្ទះស្នាក់នៅ | គ្មាន<br>មាន | គ្មាន<br>មាន |
| ទីកន្លែងធ្វើការ | ឆ្ងាយពីផ្ទះ<br>ជិតផ្ទះ | ឆ្ងាយផ្ទះ<br>ជិតផ្ទះ |
| រយៈពេលបានឡើងតំណែង | ១ឆ្នាំ<br>២ឆ្នាំ | ១ឆ្នាំ<br>២ឆ្នាំ |
| ឱកាសទទួលបានការបណ្តុះបណ្តាលជំនាញ | មាន<br>គ្មាន | មាន<br>គ្មាន |
| អនុញ្ញាតឲ្យធ្វើការផ្នែកឯកជន | មាន<br>គ្មាន | មាន<br>គ្មាន |

### ការកំណត់គំរូតាង

គំរូតាងសម្រាប់ការសិក្សានេះ ជានិសិត្សពេទ្យនៅឆ្នាំបញ្ចប់ការសិក្សា មកពីសាលាវេជ្ជសាស្ត្រសាធារណៈ ដូចជា សាកលវិទ្យាល័យវិទ្យាសាស្ត្រសុខាភិបាល និង សាលាភូមិភាគសុខាភិបាលចំនួន ៤ ។ យើងបានជ្រើសយកគំរូតាងតាមស្រទាប់ (stratified sample) ពីសាលាវេជ្ជសាស្ត្រនីមួយៗ ។ ទំហំគំរូតាងបានគណនាឡើងដោយផ្អែកលើពិសោធន៍ជាក់ស្តែង ជាជាងការគណនាបែបគណិតវិទ្យា (Louviere *et al.* 2000) ។ យើងបានជ្រើសយកនិស្សិតពេទ្យ ៤៣៦នាក់ ក្នុងនោះ ៨២នាក់ ជ្រើសចេញពីក្រុមនិស្សិតផ្នែកវេជ្ជបណ្ឌិត ១៧០នាក់ ជ្រើសពីក្រុមនិសិត្សផ្នែកគិលានុបដ្ឋាកមធ្យម និង ១៨៤នាក់មកពីក្រុមនិស្សិតផ្នែកឆ្មបបឋម ។

### ការប្រមូលទិន្នន័យ

ទិន្នន័យ ត្រូវបានស្រង់យកពីកម្រងសំណួរដែលបានផ្តល់ទៅឲ្យអ្នកចូលរួមម្នាក់ៗ ដើម្បីប្រមូលយកព័ត៌មានស្តីពី ចរិតលក្ខណៈរបស់និស្សិតផ្ទាល់និងគ្រួសារគេ ការយល់ឃើញពីការរស់នៅ និងធ្វើការនៅតំបន់ជនបទ ទ្រព្យសម្បត្តិរបស់ឪពុកម្តាយ ឬអាណាព្យាបាល និង ហេតុផលនៃការជ្រើសយកអាជីពខាងថែទាំសុខភាព ។ យើងក៏បានស្នើឲ្យនិស្សិតដាក់ពិន្ទុពី ១ ដល់ ៦ (ខ្នាត Likert[២]) តាមការយល់ឃើញរបស់ខ្លួន ចំពោះគ្រឿងលើកទឹកចិត្តផ្ទៃក្នុង និងគោលនយោបាយរដ្ឋាភិបាលជាសក្តានុពល ។

ការវិភាគ

ទិន្នន័យបានទទួលមកពីកម្រងសំណួរ ត្រូវបានកត់បញ្ចូល សំអាត និងចាត់ចែងដោយប្រើកម្មវិធី STATA ។ យើងប្រើ regression techniques ដើម្បីបង្កើតជាម៉ូដែលនៃជម្រើសរបស់អ្នកឆ្លើយសម្ភាសន៍ ឲ្យវាក្លាយជាមុខងារនៃសមាសភាគនានា នៃកញ្ចប់ចរិតលក្ខណៈនីមួយៗ ។ ដើម្បីវិភាគលើកញ្ចប់ចរិតលក្ខណៈជាជម្រើសក្នុងការពិសោធ យើងបានដាក់លេខកូដឲ្យចរិតលក្ខណៈការងារ ហើយបន្ទាប់មកធ្វើឲ្យវាមានទំនាក់ទំនងជាមួយនឹងកញ្ចប់ជម្រើសដែលផ្តល់ឲ្យ ។ ដោយប្រើ conditional logit model អត្រាជ្រើសយកអថេរឯករាជ្យ អាចបកស្រាយបានថាជាឥទ្ធិពលនៃចរិតលក្ខណៈការងារ ទៅលើការជ្រើសយកមុខតំណែងនៅទីជនបទ ឬមុខតំណែងនៅទីប្រជុំជន ។ លើសពីនេះទៀត ការព្យាករណ៍ពីជម្រើសការងារនៅជនបទ ក៏ត្រូវបានគណនាដែរ ដើម្បីបង្ហាញពីចំណែកទីផ្សារ នៃកញ្ចប់ជម្រើសនីមួយៗ ។ ដើម្បីពិពណ៌នា យើងបានវិភាគធៀបបៀវត្សរ៍កម្រិតក្រោមទីផ្សាររបស់អ្នកឆ្លើយសម្ភាសន៍ ទៅនឹងស្ថានភាពសេដ្ឋកិច្ច-សង្គមកិច្ច និងប្រជាសាស្ត្ររបស់គាត់ ។ ឧទាហរណ៍ បៀវត្សរ៍ក្រោមទីផ្សារដែលនិស្សិតទទួលយក អាចខុសគ្នារវាងអ្នកមកពីគ្រួសារធូរធារ និងពីគ្រួសារក្រីក្រ ឬ រវាងអ្នកមកពីជនបទ និងពីទីក្រុង ។ ចំណេះដឹងខាងវេជ្ជសាស្ត្ររបស់អ្នកឆ្លើយសម្ភាសន៍ គ្រឿងលើកទឹកចិត្តផ្ទៃក្នុង និងសេចក្តីប្រាថ្នាខាងការងារ ត្រូវបានវាស់វែង ដើម្បីកំណត់ថា តើកត្តាទាំងនេះ មានឥទ្ធិពលយ៉ាងណាលើជម្រើសបៀវត្សរ៍ក្រោមទីផ្សារ ។ យើងក៏បានប្រើវិធីសាស្ត្រវិភាគពហុអថេរ (multivariate analysis) ដើម្បីពន្យល់ពីអថេរចំណុះគេ (បៀវត្សរ៍ ក្រោមទីផ្សារសម្រាប់ការបម្រើសេវានៅជនបទ) ជាមួយនឹងអថេរឯករាជ្យដែលបានរៀបរាប់ខាងលើ ។

## ៣. លទ្ធផល

### ទំនាក់ទំនងរវាងចំណង់ចំណូលចិត្តកន្លែងធ្វើការ និងចរិតលក្ខណៈសេដ្ឋកិច្ច-សង្គមកិច្ច

ស្ថានភាពការងាររបស់ឪពុក ប្រវត្តិពីកុមារ ទីតាំងវិទ្យាស្ថានសិក្សា (នៅជនបទ ឬទីក្រុង) ទឹកចិត្តគិតគូរពីអ្នកដទៃ និង បំណងចង់រស់នៅនិងធ្វើការនៅជនបទ ជាចរិតលក្ខណៈសេដ្ឋកិច្ច-សង្គមកិច្ចចំបង ដែលជះឥទ្ធិពលទៅលើចំណង់ចំណូលចិត្តការងារ ។ ស្ថានភាពការងាររបស់ឪពុកទំនងមានឥទ្ធិពលទៅលើនិស្សិតផ្នែកគិលានុបដ្ឋាក និងផ្នែកវេជ្ជសាស្ត្រ ដែលជ្រើសយកការងារនៅទីក្រុងជាជាងនៅជនបទ ប៉ុន្តែមិនមែនទៅលើនិស្សិតផ្នែកឆ្មបទេ ។ ប្រវត្តិពីកុមារ ជាសូចនាករដ៏ល្អមួយសម្រាប់ការទស្សទាយពីចំណូលចិត្តលើទីតាំង ។ និស្សិតមានប្រវត្តិធ្លាប់រស់នៅជនបទទំនងមានច្រើននាក់ជាងដែលពេញចិត្តទៅបម្រើការនៅជនបទ ។ លទ្ធផលនេះ មានតួលេខធំគួរកត់សម្គាល់ខាងស្ថិតិ (statistically significant) សម្រាប់និស្សិតផ្នែកឆ្មប និងវេជ្ជសាស្ត្រ និងមានភាពស្របគ្នានឹងលទ្ធផលនៃការសិក្សាក្នុងប្រទេសដទៃ ។ ទំនាក់ទំនង (correlation) រវាងប្រវត្តិធ្លាប់រស់នៅជនបទ និងការជ្រើសយកការងារនៅជនបទ គឺ 0,7043 សម្រាប់និស្សិតផ្នែកវេជ្ជសាស្ត្រ 0,2541 សម្រាប់និស្សិតផ្នែកគិលានុបដ្ឋាក និង 0,4366 សម្រាប់និស្សិតផ្នែកឆ្មប ។ និស្សិតផ្នែកគិលានុបដ្ឋាកដែលសិក្សានៅសាលាភូមិភាគសុខាភិបាល ទំនងមានច្រើននាក់ជាងដែលពេញចិត្តទៅធ្វើការនៅតាមជនបទ បើធៀបនឹងអ្នកដែលសិក្សានៅតាមសាលាក្នុងក្រុងភ្នំពេញ ។ ទឹកចិត្តគិតគូរពីអ្នកដទៃកម្រិតខ្ពស់របស់និស្សិត្យផ្នែកឆ្មប បង្កជាចំណង់ចំណូលចិត្តទៅបម្រើការងារនៅជនបទ ។

---

២ ខ្នាតវាស់វែងផ្នែកចិត្តសាស្ត្រ ដែលតែងមានប្រើក្នុងកម្រងសំណួរ និងជាខ្នាតមានប្រើប្រាស់ជាទូទៅបំផុតនៅក្នុងការស្រាវជ្រាវបែបអង្កេត ។ នៅពេលឆ្លើយនឹងកម្រងសំណួរបែប Likert នេះ អ្នកឆ្លើយត្រូវបញ្ជាក់ពីកម្រិតនៃការយល់ស្របរបស់ខ្លួនចំពោះរឿងនីមួយៗដែលលើកឡើង ។ ខ្នាតនេះ យកឈ្មោះតាមអ្នកបង្កើតវា គឺចិត្តវិទូ Rensis Likert ។

អ្នកឆ្លើយសំណួរដែលមានពិន្ទុជាមធ្យមលើសពី ៤ លើការធ្វើការនិងរស់នៅជនបទ ទំនងជាជ្រើសយកមូលដ្ឋានសុខភាពនៅជនបទ ។

### ឥរិយាបថចំពោះគោលនយោបាយរដ្ឋាភិបាល

រាល់អន្តរាគមន៍ដែលបានលើកឡើង សុទ្ធតែទទួលបានការពេញចិត្ត និងបានពិន្ទុជាមធ្យមលើសពី ៥ លើកលែងតែអន្តរាគមន៍ "លទ្ធភាពជ្រើសយកតំបន់ជនបទជាក់លាក់" ដែលទទួលបានពិន្ទុទាបបំផុត និងដែលបង្ហាញថា បុគ្គលិកសុខាភិបាលយល់ថា តំបន់ជនបទនានាមានលក្ខណៈដូចគ្នាទាំងអស់ តែតាមពិតមិនមែនដូច្នោះទេ ។ និស្សិតផ្នែកគិលានុបដ្ឋាក សម្គាល់កន្លែងធ្វើការមានរបៀបរៀបចំល្អ និងការលូតលាស់ល្អក្នុងអាជីព ជាកត្តាសំខាន់បំផុតដែលទាក់ទាញខ្លួនឲ្យទៅធ្វើការនៅតំបន់ជនបទ ។ ពួកគេក៏មើលឃើញថាសំខាន់ដែរ កន្លែងធ្វើការណាដែលក្រសួងសុខាភិបាល ត្រូវការបុគ្គលិកបំផុតនោះ ។ និស្សិតផ្នែកឆ្មប ក៏មានលទ្ធផលស្រដៀងគ្នានេះដែរ ។ អន្តរាគមន៍សំខាន់បំផុតលំដាប់ទី១ និងទី២ សម្រាប់ពួកគេ គឺដូចគ្នានឹងនិស្សិតផ្នែកគិលានុបដ្ឋាកដែរ ប៉ុន្តែពួកគេជ្រើសយក "ប្រាក់ឧបត្ថម្ភស្ថានភាពលំបាកនៅទីជនបទ" ជាកត្តាសំខាន់លំដាប់ទី៣ ។

ចរិតលក្ខណៈការងារទាំង៧ ដែលបានជ្រើសរើស សម្រាប់បង្កើតការងារសម្មតិកម្មដូចបានបង្ហាញក្នុងតារាងនានាខាងលើ គេរកឃើញថាសុទ្ធតែមានសារៈសំខាន់ខាងស្ថិតិ លើកលែងតែប្រាក់ឧបត្ថម្ភសម្រាប់ការធ្វើដំណើរ និងការបណ្តុះបណ្តាល ដែលមិនសូវសំខាន់សម្រាប់ក្រុមនិស្សិតឆ្មប ។ ខុសពីនិស្សិតផ្នែកវេជ្ជសាស្ត្រ និងផ្នែកគិលានុបដ្ឋាក និស្សិតផ្នែកឆ្មបឲ្យតម្លៃដល់គ្រឿងលើកទឹកចិត្តមិនមែនហិរញ្ញវត្ថុ ( ការងារនៅជិតផ្ទះ និងមានឧបករណ៍គ្រប់គ្រាន់) ជាងគ្រឿងលើកទឹកចិត្តខាងហិរញ្ញវត្ថុ ។ ជម្រើសនេះ ប្រហែលដោយសារនិស្សិតឆ្មបទាំងអស់ជានារី ហើយត្រូវមើលថែទាំគ្រួសារបន្ទាប់ពីបានបញ្ចប់ការសិក្សា ។ ម្យ៉ាងទៀត ការចាត់តាំងឲ្យធ្វើការនៅតាមកន្លែងកំណត់ជាក់លាក់ វាមានលក្ខណៈខានមិនបាន បន្ទាប់ពីនិស្សិតឆ្មបបានបញ្ចប់ការសិក្សា ។ មួយវិញទៀត គេតែងគិតថា បៀវត្សរ៍ខ្ពស់រហូតដល់១២០ដុល្លារ មិនអាចរកបានទេ ដូច្នេះក៏មានការគិតគូរច្រើនជាងអំពីលក្ខណៈវិនិច្ឆ័យដែលមានជាក់ស្តែង ។

### សូចនាករសម្រាប់ការទស្សទាយលើការទទួលយកការងារនៅជនបទ

ក្នុងផ្នែកនេះ យើងប្រើប្រាស់លទ្ធផលពីការវិភាគ DCE ដើម្បីបង្កើតជាសេណារីយ៉ូគោលនយោបាយដែលអាចធ្វើបានមួយចំនួន ។ ផ្អែកតាមកម្លាំងនៃចរិតលក្ខណៈនីមួយៗដែលជម្រុញឲ្យនិស្សិតជ្រើសយកការងារនៅជនបទ ជាជាងនៅទីក្រុង យើងអាចធ្វើពិសោធន៍ត្រាប់ (simulation) រកមើលថា តើមាននិស្សិតប៉ុន្មាននាក់ជ្រើសយក ការងារនៅជនបទជាសម្មតិកម្មនានាដែលមានចរិតលក្ខណៈដ៏ជាក់លាក់ ។ យើងប្រៀបធៀបការងារជាសម្មតិកម្មទាំងនេះ ទៅនឹងសេណារីយ៉ូមូលដ្ឋានមួយ ដែលស្របទៅនឹងទម្រង់ការងារវិស័យសាធារណៈជាមធ្យមនាពេលបច្ចុប្បន្ន ។

លទ្ធផលសម្រាប់និស្សិតផ្នែកគិលានុបដ្ឋាក មានបង្ហាញក្នុងក្រាហ្វិក ១ ។ នៅក្នុងសេណារីយ៉ូមូលដ្ឋាន[៣] ប្រូបាប៊ីលីតេនៃនិស្សិតផ្នែកគិលានុប្បដ្ឋាកទើបបញ្ចប់ការសិក្សា ដែលជ្រើសទៅធ្វើការនៅមូលដ្ឋានសុខាភិបាលនៅជនបទ មាន ២៣,៧% ។ សេណារីយ៉ូទី២ កំណត់ផ្តល់បៀវត្សរ៍ ៧០ដុល្លារ រីឯចរិតលក្ខណៈឯទៀតៗនៃការងារ គឺដូចក្នុងសេណារីយ៉ូមូលដ្ឋាន ហើយជាលទ្ធផលមាននិស្សិតផ្នែកគិលានុប្បដ្ឋាក ៣៣,៦% បានជ្រើសយកការងារនៅជនបទ ។ សេណារីយ៉ូទី៣ កំណត់ផ្តល់បៀវត្សរ៍ ៩៥ដុល្លារ ហើយជាលទ្ធផលមាននិស្សិតផ្នែកគិលានុប្បដ្ឋាក ៤៥,២% ជ្រើសយកការងារនៅជនបទ ។ ប្រសិនបើបៀវត្សរ៍កើនដល់ ១២០ដុល្លារ មាននិស្សិតផ្នែកគិលានុប្បដ្ឋាក ៥៧,៣% ជ្រើសយកការងារនៅជនបទ ។ សេណារីយ៉ូទី៥ ទី៦ និង ទី៧ បូកបញ្ចូលទាំងគ្រឿងលើកទឹកចិត្តខាងហិរញ្ញវត្ថុ និងមិនមែនហិរញ្ញវត្ថុ ដោយផ្តល់បៀវត្សរ៍ ៧០ដុល្លារ ជាមួយនឹង (១) បរិក្ខារគ្រប់គ្រាន់ (២) បរិក្ខារគ្រប់គ្រាន់បូកបន្ថែមផ្ទះស្នាក់នៅ និង (៣) បរិក្ខារគ្រប់គ្រាន់ ផ្ទះស្នាក់នៅ បូកនឹងឱកាសឡើងដំណែងឆាប់ជាងមុន ។ ជាលទ្ធផល សមាមាត្រនិស្សិតខាងគិលានុប្បដ្ឋាក ដែលជ្រើសយកការងារនៅជនបទ កើនដល់ ៦៥,៥% ៦៨,៤% និង ៧៨,៩% រៀងគ្នាសម្រាប់សេណារីយ៉ូទាំងនេះ ។

ក្រាហ្វិក ១៖ ការទស្សទាយពីការជ្រើសយកការងារនៅជនបទដោយគិលានុប្បដ្ឋាក
តាមរយៈការបង្កើតសេណារីយ៉ូពិសោធន៍គ្រាប់ផ្សេងៗ




ក្រាហ្វិក ២ បង្ហាញលទ្ធផលសម្រាប់និស្សិតផ្នែកឆ្មប ។ ក្នុងសេណារីយ៉ូមូលដ្ឋាន មាននិស្សិតឆ្មប ៥១,២% ជ្រើសធ្វើការនៅជនបទ ។ សម្រាប់សេណារីយ៉ូទី១ ដល់ ទី៣ ដែលកំណត់ផ្តល់បៀវត្សរ៍ ៧០ដុល្លារ ៩០ដុល្លារ និង ១២០ដុល្លារ រៀងគ្នានោះ មាននិស្សិតឆ្មប ៥៥,៦% ៦១,៨% និង ៦៦,៧% ជ្រើសធ្វើការនៅជនបទ ។ សេណារីយ៉ូទី៤ ដល់ទី៦ កំណត់ពីឥទ្ធិពលនៃបៀវត្សរ៍គួបផ្សំនឹងចរិតលក្ខណៈមិនមែនហិរញ្ញវត្ថុផ្សេងទៀត ដូចជា (១) បរិក្ខារគ្រប់គ្រាន់ (២) បរិក្ខារ

៣ សេណារីយ៉ូមូលដ្ឋាន វាស្រដៀងនឹងស្ថានភាពបច្ចុប្បន្ន គឺនៅមូលដ្ឋានសុខាភិបាលជនបទមានឧបករណ៍មិនគ្រប់គ្រាន់ រីឯនៅទីក្រុងគេមានគ្រប់គ្រាន់ ។ ចរិតលក្ខណៈដទៃទៀតនៃការងារនៅទីក្រុង និងជនបទមានភាពស្រដៀងគ្នា ដូចជា បៀវត្សរ៍ ៤៥ដុល្លារ/ខែ សម្រាប់គិលានុបដ្ឋាកទើបបញ្ចប់ការសិក្សា គិលានុបដ្ឋាកទទួលបានការបណ្តុះបណ្តាលរយៈពេល ២សប្តាហ៍/ឆ្នាំ និង គ្មានការផ្តល់ប្រាក់ឧបត្ថម្ភលើការស្នាក់នៅ និងការធ្វើដំណើរទេ ។ សេណារីយ៉ូមូលដ្ឋាន កំណត់ថា មូលដ្ឋានសុខាភិបាលនៅទីក្រុង និងនៅជនបទស្ថិតនៅក្បែរផ្ទះ ហើយការធ្វើការបាន ១ឆ្នាំ រាប់ថាមានអតីតភាព ១ឆ្នាំ សម្រាប់ការដំឡើងតំណែង ។

គ្រប់គ្រាន់ បូកបន្ថែមការផ្តល់ផ្ទះស្នាក់នៅ និង (៣) បរិក្ខារគ្រប់គ្រាន់ ការផ្តល់ផ្ទះស្នាក់នៅ និង ការដំឡើងដំណែងឆាប់ជាងមុន ។ កញ្ចប់បន្ថែមលើការងារទាំងនេះ ជម្រុញអត្រាជ្រើសយកការងារនៅជនបទឡើងដល់ ៨៦,១% សម្រាប់សេណារីយ៉ូទី៤ ដល់ ៨៨,១% សម្រាប់សេណារីយ៉ូទី៥ និង ៩២,៦% សម្រាប់សេណារីយ៉ូទី៦ ។

ក្រាហ្វិក ២៖ ការទស្សទាយពីការជ្រើសយកការងារនៅជនបទដោយឆ្លបតាមរយៈការបង្កើតសេណារីយ៉ូពិសោធន៍គ្រាប់ផ្សេងៗ




ការអនុវត្តពិសោធន៍គ្រាប់ស្រដៀងគ្នា ជាមួយនិស្សិតផ្នែកវេជ្ជសាស្ត្រ បានផ្តល់លទ្ធផលដូចតទៅ ។ ក្នុងសេណារីយ៉ូមូលដ្ឋាន[៤] មាននិស្សិតវេជ្ជសាស្ត្រត្រឹម ៩% ប៉ុណ្ណោះ ដែលជ្រើសយកការងារនៅជនបទ ។ ពិសោធន៍គ្រាប់ក្នុងសេណារីយ៉ូទី១ ដល់ទី៣ បង្ហាញថា កំណើនបៀវត្សរ៍ដល់ ១០០ដុល្លារ ២០០ដុល្លារ និង ៣០០ដុល្លារ រៀងគ្នា អាចបង្កើនអត្រាទទួលយកការងារនៅជនបទដល់ ១១,៨% សម្រាប់សេណារីយ៉ូទី១ ១៧,៩% សម្រាប់សេណារីយ៉ូទី២ និង ២៦,១% សម្រាប់សេណារីយ៉ូទី៣ ។ សេណារីយ៉ូទី៤ ដល់ទី៨ មានគួបផ្សំនូវគ្រឿងលើកទឹកចិត្តផ្សេងៗ ទាំងខាងហិរញ្ញវត្ថុ និងមិនមែនហិរញ្ញវត្ថុ ។ សេណារីយ៉ូទាំងនេះ រួមមាន៖ (១) បៀវត្សរ៍ ២០០ដុល្លារ បូកនឹងឱកាសទទួលការបណ្តុះបណ្តាលជំនាញឯកទេស (២) បៀវត្សរ៍ ១០០ដុល្លារ ការបណ្តុះបណ្តាលជំនាញឯកទេស និងបរិក្ខារគ្រប់គ្រាន់ (៣) បៀវត្សរ៍ ១០០ដុល្លារ ការបណ្តុះបណ្តាលជំនាញឯកទេស បរិក្ខារគ្រប់គ្រាន់ បូកឱកាសឡើងតំណែង (៤) បៀវត្សរ៍ ២០០ដុល្លារ ការបណ្តុះបណ្តាលជំនាញឯកទេស បរិក្ខារគ្រប់គ្រាន់ បូកឱកាសឡើងតំណែង និង (៥) បៀវត្សរ៍ ៣០០ដុល្លារ ការបណ្តុះបណ្តាលជំនាញឯកទេស បរិក្ខារគ្រប់គ្រាន់ បូកឱកាសឡើងតំណែង ។ លទ្ធផលបង្ហាញថា អត្រាជ្រើសយកការងារនៅជនបទកើនដល់ ២៤,៩% សម្រាប់សេណារីយ៉ូទី៤

៤ ចរិតលក្ខណៈនៃសេណារីយ៉ូនេះ គឺដូចគ្នាសម្រាប់ការងារនៅទីក្រុង និងជនបទ ប៉ុន្តែការងារនៅទីក្រុងមានបរិក្ខារគ្រប់គ្រាន់ និងផ្តល់ឱកាសសម្រាប់ការបណ្តុះបណ្តាលជំនាញឯកទេស ។ ចរិតលក្ខណៈឯទៀតនៃការងារក្នុងសេណារីយ៉ូមូលដ្ឋាន គឺមាន៖ បៀវត្សរ៍ ៥០ដុល្លារ សម្រាប់វេជ្ជបណ្ឌិតទើបបញ្ចប់ការសិក្សា កន្លែងធ្វើការនៅជិតផ្ទះ ធ្វើការបាន ១ឆ្នាំ រាប់ថា មានអតីតភាព ១ឆ្នាំ សម្រាប់ការឡើងតំណែង ការអនុញ្ញាតឲ្យធ្វើការងារក្នុងវិស័យឯកជន និងគ្មានផ្តល់ផ្ទះស្នាក់នៅទេ ។

ដល់ ៣៣,៩% សម្រាប់សេណារីយ៉ូទី៥ ដល់ ៤៣,២% សម្រាប់សេណារីយ៉ូទី៦ ដល់ ៥៥,៣% សម្រាប់សេណារីយ៉ូទី៧ និង ៦៦,៨% សម្រាប់សេណារីយ៉ូទី៨ ។

ក្រាហ្វិក ៣៖ ការទស្សទាយពីការជ្រើសយកការងារនៅជនបទដោយវេជ្ជបណ្ឌិត តាមរយៈការបង្កើតសេណារីយ៉ូពិសោធន៍គ្រាប់ផ្សេងៗ




## ៥. សេចក្តីសន្និដ្ឋាន

លទ្ធផលនៃការសិក្សាបានបង្ហាញច្បាស់ថា និសិត្សផ្នែកគិលានុបដ្ឋាក ឆ្មប និងវេជ្ជសាស្ត្រ មានចំណង់ចំណូលចិត្តមិនដូចគ្នាទេ នៅពេលសម្រេចចិត្តជ្រើសរើសទៅធ្វើការនៅជនបទ ហើយ ប្រវត្តិធ្លាប់រស់នៅជនបទ និងការសិក្សានៅមជ្ឈមណ្ឌលបណ្តុះបណ្តាលនៅជនបទ ជាសូចនាករ ដ៏ល្អសម្រាប់ទស្សទាយពីចំនួនលើសមធ្យមនៃគិលានុបដ្ឋាក និងឆ្មប ដែលពេញចិត្តទទួលយក ការងារនៅជនបទ ។ ដូច្នេះ ក្រសួងសុខាភិបាលអាចផ្តោតអន្តរាគមន៍ខាងគោលនយោបាយ ដោយផ្ទាល់ ទៅលើនិស្សិតពេទ្យដែលមានប្រវត្តិធ្លាប់រស់នៅជនបទ ឬបានបញ្ចប់ការសិក្សាពី មជ្ឈមណ្ឌលបណ្តុះបណ្តាលនៅជនបទ ។ ដោយការបែងចែកវេជ្ជបណ្ឌិតមានអតុល្យភាពជាខ្លាំង រវាងតំបន់ភូមិសាស្ត្រផ្សេងៗ ដូច្នេះ ក្រសួងសុខាភិបាលគួរពិចារណាបង្កើតសាលាវេជ្ជសាស្ត្រនៅ ក្រៅទីក្រុងភ្នំពេញ ពីព្រោះការបណ្តុះបណ្តាលនៅតំបន់ជនបទជួយបង្កើនចំណូលចិត្តទៅធ្វើការនៅ ជនបទ ។

កម្មវិធីសិក្សារបស់គិលានុបដ្ឋាក ឆ្មប និងវេជ្ជបណ្ឌិត ដើរតួនាទីយ៉ាងសំខាន់ក្នុងការសម្រួល ឥរិយាបថរបស់និស្សិត ចំពោះការរស់នៅ និងធ្វើការនៅតំបន់ជនបទ ។ ការសិក្សាបង្ហាញថា និស្សិត ដែលមានឥរិយាបទវិជ្ជមានចំពោះតំបន់ជនបទ មានទំនោរចិត្តច្រើនជាងក្នុងការជ្រើសយកការងារ នៅជនបទ ។ ដូច្នេះ សាលាពេទ្យ និងស្ថាប័នបណ្តុះបណ្តាលជំនាញថែទាំសុខភាពផ្សេងៗ គួរពង្រីក កម្មវិធីសិក្សា និងការបណ្តុះបណ្តាល ដែលជួយបណ្តុះឥរិយាបទវិជ្ជមានចំពោះតំបន់ជនបទ ។

ការបង្កើតគោលនយោបាយដ៏សក្តិសិទ្ធិ ដើម្បីទាក់ទាញ និងរក្សាបុគ្គលិកសុខាភិបាលនៅ តំបន់ជនបទ ជាបញ្ហាប្រឈមមួយនាពេលបច្ចុប្បន្ន ។ ក្រសួងសុខាភិបាល ទំនងមិនអាចដំឡើង បៀវត្សរ៍បុគ្គលិកសុខាភិបាលឲ្យបានគ្រប់គ្រាន់តាមតម្រូវការរបស់ពួកគេ ដើម្បីជម្រុញទឹកចិត្តជ្រើស យកការងារនៅតំបន់ជនបទនោះទេ ។ ប៉ុន្តែការស្រាវជ្រាវបង្ហាញយ៉ាងច្បាស់ថា ការបូកផ្សំគ្នានូវ គ្រឿងលើកទឹកចិត្តខាងហិរញ្ញវត្ថុ និងមិនមែនហិរញ្ញវត្ថុ អាចមានប្រសិទ្ធភាពជាងគ្រឿងលើកទឹកចិត្ត ខាងហិរញ្ញវត្ថុតែម្យ៉ាង ។ ពិតហើយ គ្រឿងលើកទឹកចិត្តមិនមែនហិរញ្ញវត្ថុ ជួយកាត់បន្ថយតម្រូវការ ប្រាក់ឧបត្ថម្ភ ឬប្រាក់ប៉ះប៉ូវសម្រាប់ការជ្រើសធ្វើការនៅជនបទ ជាពិសេសសម្រាប់ឆ្មប ។ លទ្ធផលនេះ

ផ្តល់នូវទស្សនៈថ្មីៗក្នុងការបង្កើតគោលនយោបាយដែលចំណាយថវិកាមិនច្រើនពេក ដើម្បីទាក់ទាញបុគ្គលិកសុខាភិបាលបានច្រើនជាងមុន ឲ្យទៅបម្រើការងារនៅតំបន់ជនបទ ។

ទាក់ទិននឹងវិធីសាស្ត្រ DCEs ការប្រើប្រាស់វា មានជួបកំហិតមួយចំនួន ។ កំហិតទី១ គឺ វិធីសាស្ត្រនេះ ស្រង់យកចំណង់ចំណូលចិត្តដែលគេប្រកាសប្រាប់ ដោយផ្អែកលើជម្រើសការងារជាលក្ខណៈសម្មតិកម្ម ដូច្នេះជម្រើសជាក់ស្តែងអាចខុសប្លែកពីនេះ ។ លទ្ធផលបានផ្តល់ភស្តុតាងអំពីផលប៉ះពាល់ ដែលទំនងទទួលបានពីអន្តរាគមន៍ខាងគោលនយោបាយផ្សេងៗ ប៉ុន្តែគ្មានផ្តល់ព័ត៌មានអ្វីអំពីចំណាយទៅលើអន្តរាគន៍ទាំងនោះទេ ។ នេះជាចំណុចសំខាន់មួយនៅក្នុងការងារធ្វើគោលនយោបាយជាក់ស្តែង ។ មួយវិញទៀត លទ្ធផលនេះទំនងអាចលំអៀងច្រើនដោយសារឥទ្ធិពលដ៏ខ្លាំងនៃសាលារៀន ដូចជា ផលប៉ះពាល់នៃកម្មវិធីសិក្សា និងវិធីសាស្ត្របណ្តុះបណ្តាលទៅលើជម្រើសរបស់អ្នកឆ្លើយសម្ភាសន៍ ។ ក្នុងការពិតជាក់ស្តែង ឥទ្ធិពលនៃសាលារៀន ប្រហែលថយចុះអស់ (ឬផ្លាស់ប្តូរ) សម្រាប់បុគ្គលិកសុខាភិបាលមានវ័យចំណាស់ គឺបានន័យថា ចំពោះគ្រឿងលើកទឹកចិត្តការងារនៅតំបន់ជនបទ បុគ្គលិកសុខាភិបាលជំនាន់មុនៗ ប្រហែលផ្តល់ចម្លើយតបខុសគ្នាពីពួកនិស្សិតក្នុងការសិក្សានេះ ។ កំហិតមួយទៀត គឺការងារជាសម្មតិកម្មនានា មានចរិតលក្ខណៈត្រឹមតែ ៧យ៉ាង តាមការកំណត់ ដែលទំនងមិនឆ្លុះបញ្ចាំងអស់ទេនូវជម្រើសក្នុងឆាកជីវិតជាក់ស្តែង ហើយអ្នកអនុវត្តការងារថែទាំសុខភាព អាចមានគិតគូរពីកត្តាដទៃទៀតនៅពេលសម្រេចជ្រើសរើស ។ កំហិតទី៣ គឺនិស្សិតពេទ្យជ្រើសរើសមកសិក្សា មានចំនួនតិច (តិចជាង ១០០នាក់) ដែលអាចជះឥទ្ធិពលលើភាពគួរឲ្យជឿជាក់នៃលទ្ធផលសិក្សា ដូច្នេះលទ្ធផលនេះគួរយកមកបកស្រាយដោយប្រយ័ត្នប្រយែង ។

## ឯកសារយោង


Bennett, Sara & Lynne Miller Franco (1999), *Public Sector Health Worker Motivation and Health Sector Reform: A Conceptual Framework*, Major Applied Research 5, Technical Paper No. 1 (Bethesda, MD: ABT Associates)

Burgess, S. & P. Metcalfe (1999), *Incentives in Organisations: A Selective Overview of the Literature with Application to the Public Sector*, Centre for Market and Public Organisation, CMPO Working Paper 99/016 (Bristol: University of Bristol)

Chomitz, K.M., G. Setladi, A. Aswar, N. Ismail & Widyarti (1998), *What do Doctors Want? Developing Incentives for Doctors to Serve in Indonesia's Rural and Remote Areas*, Policy Research Working Paper No 1888 (Washington, DC: World Bank)

Daniels Z.M., B.J. van Leit, B.J. Skipper, M.L. Sanders & R.L. Rhyne (2007), "Factors in Recruiting and Retaining Health Professionals for Rural Practice", *Journal of Rural Health*, 23 (1), pp. 62-71

Dieleman, M., P.V. Cuong, L.V. Anh & T. Martineau (2003), "Identifying Factors for Job Motivation of Rural Health Workers in North Vietnam", *Human Resources for Health*, 1(10)

Dixit, Avinashi K. (2004), *Lawlessness and Economics: Alternative Modes of Governance* (Princeton University Press)

Dixit, Avinashi K. (2002), "Incentives and Organisations in the Public Sector: An Interpretive Review", *Journal of Human Resources*, 37(4), pp. 696-727

Franco, Lynne Miller & Sara Bennett (2000), *Health Worker Motivation in Jordan and Georgia: A Synthesis of Results Framework,* Major Applied Research 5, Technical Paper No. 3 (Bethesda, MD: ABT Associates)

Gosden, T., I. Bowler & M. Sutton (2000), "How do General Practitioners Choose Their Practice? Preferences for Practice and Job Characteristics", J*ournal of Health Services Research and Policy*, 5(4), pp. 208-213

Gunther O.H., B. Koerstein, S.G. Riedel-Heller & H.H. Koenig (2010), "The Role of Monetary and Non-monetary Incentives on the Choice of Practice Establishment: A Stated Preference Study of Young Physicians in Germany", *Health Services Research*, 45:1 (February), pp. 212-229

Hanson, K. & W. Jack (2008), *Health Worker Preferences for Job Attributes in Ethiopia: Results from a Discrete Choice Experiment*, working paper (Washington: Georgetown University) http://www9.georgetown.edu/faculty/wgj/papers/Hanson-Jack-04-23-08.pdf

Hensher, D., J.M. Rose & W.H. Greene (2005), *Applied Choice Analysis: A Primer* (New York: Cambridge University Press)

Jacobson, S.L. (1995), "Monetary Incentives and the Reform of Teacher Compensation: A Persistent Organisational Dilemma", *International Journal of Educational Reform,* 4(1) pp. 29-35

Jolly, G. Jason (2008,) "Contracting Regimes and Third Party Governance: A Theoretical Construct for Exploring the Importance of Public Sector Motivation of Private Sector Contractors", *International Public Management Review*, Volume 9, Issue 2

Karlsson, Martin (2008), *The economics of 'public service motivation': a literature review,* http://www.opi.org.uk/documents/EconomicsofpublicsectormotivationKarlssonApril2008.pdf

Kirton, D. (2001), "Love and Money: Payment, Motivation and the Fostering Task", *Child and Family Social Work*, 6(3) (August), pp. 199-208

Kitange, H. & Hanoi School of Public Health (2001), *A Study on Motivation of Health Staff in Northern Vietnam*, (Amsterdam: Royal Tropical Institute)

Kolstad, J.R. (2010), "How to Make Rural Jobs More Attractive for Health Workers: Findings from a Discrete Choice Experiment in Tanzania", *Health Economics*, Norway: University of Bergen, Pb7802, N-5020 Bergen

Lagarde, Mylene & Duane Blaauw (2009), "A Review of the Application and Contribution of Discrete Choice Experiments to Inform Human Resources Policy Interventions", *Human Resources for Health,* 7:62

Le Grand, Julian (2003), M*otivation, Agency and the Public Sector; Of Knights and Knaves, Pawns and Queens* (Oxford: Oxford University Press)

Louviere, J.J., D.A. Hensher & J.D. Swait (2000), *Stated Choice Methods: Analysis and Applications* (Cambridge: Cambridge University Press)

Mangham, L. (2007), *Addressing the Human Resource Crisis in Malawi's Health Sector: Employment Preferences of Public Sector Registered Nurses* (London: Overseas Development Institute)

Ministry of Health (2006a), *National Guidelines on Complementary Package of Activities for Referral Hospital Development 2006-2010* (Phnom Penh: MoH)

Ministry of Health (2006b), *National Guidelines on Minimum Package of Activities for Health Centre Development 2006-2015* (Phnom Penh: MoH)

Ministry of Health (2006c), *Health Workforce Development Plan 2006-2015* (Phnom Penh: MoH)

Ministry of Health (2008), *Health Strategic Plan 2008-2015* (Phnom Penh: MoH)

Molinari, D.L. & M.A. Monserud (2008), "Rural Nurse Job Satisfaction", *Rural and Remote Health*, 8(4):1055

Myers, Jerrett (2008), "Public Service Motivation and Performance Incentives: A Literature Review", http://www.opi.org.uk/publications/documents/Publicservicemotivationandperformanceincentives_MyersJune2008.pdf

Pagaiya, Nonglak, Thinakorn Noree, Mylene Lagarde, Duane Blaauw, Chotiros Laongbua & Sanya Sriratana (2009), "What Makes Doctors Choose to Work in Rural Area: Discrete Choice Experiment to Elicit Doctors' Job Choices", paper presented at the Fourth AAAH Conference, Getting Committed Health Workers to the Underserved Areas: A Challenge for the Health Systems, 23-25 November 2009, Hanoi

Penn-Kekana L., D. Blaauw, K. San Tint, D. Monareng & J. Chege (2005), *Nursing Staff Dynamics and Implications for Maternal Health Provision in Public Health Facilities in the Context of HIV/AIDS*, (Johannesburg: University of the Witwatersrand)

Richards H.M., J. Farmer & S. Selvaraj (2005), "Sustaining the Rural Primary Healthcare Workforce: Survey of the Health Professionals in the Scottish Highlands", *Rural and Remote Health*, 5(365), pp. 1-14

Rose-Ackerman, S. (1996), "Altruism, Non-profits and Economic Theory", J*ournal of Economic Literature*, Vol 34 (June), pp. 701–7-28

Ryan, M. & S. Farrar (2000), "Using Conjoint Analysis to Elicit Preferences for Healthcare", *British Medical Journal*, 320 (7248), pp. 1530-1533

Ryan, M. (2004), "Discrete Choice Experiments in Healthcare", *British Medical Journal*, 328(7436), pp. 360-361

Scott, A. (2001), "Eliciting GPs' Preferences for Pecuniary and Non-pecuniary Job Characteristics", *Journal of Health Economics*, 20(3), pp. 329-347

Serneels, Pieter, Magnus Lindelow, Jose G. Montalvo & Abigail Barr (2007), "For Public Service or Money: Understanding Geographical Imbalances in the Health Workforce", *Health Policy and Planning*, 22(3) (May), pp. 128-138

Stenger J.M.D., S.B. Cashman & J.A. Savageau (2008), "The Primary Care Physician Workforce in Massachusetts: Implications for the Workforce in Rural, Small Town America", Journal of Rural Health, 24(4) (Fall), pp. 375-383

Stilwell, B. (2001), *Health Worker Motivation in Zimbabwe* (Geneva: World Health Organisation)

Williams, C.C. & J. Windebank (2001), "Beyond Profit-motivated Exchange: Some Lessons from the Study of Paid Informal Work", *European Urban and Regional Studies*, 8(1), pp. 49-61

Williamson, Oliver E. (1998), "Transaction Cost Economics: How it Works; Where it is Headed", *De Economist* 146(1) (April), pp. 23-58

Wordsworth, S., D. Skatun, A. Scott & F. French (2004), "Preferences for General Practice Jobs: A Survey of Principals and Sessional GPs", *British Journal of General Practice*, 54(507), pp. 740-746

Ubach C., A. Scott, F. French, M. Awramenko & G. Needham (2003), "What Do Hospital Consultants Value About Their Jobs? A Discrete Choice Experiment", *British Medical Journal*, 326:1432

# -XII-
# ការធ្វើអន្តេតចំណាយមហន្តរាយលើការថែទាំ សុខភាពគ្រួសារៈ លទ្ធផលពីអង្កេតសេដ្ឋកិច្ច សង្គមកិច្ចកម្ពុជាឆ្នាំ២០០៧

*ដោយលោក នេត នាថ*[១]

## ១. សេចក្តីផ្តើម

នៅមុនឆ្នាំ១៩៩៦ ការថែទាំសុខភាព ឬការព្យាបាល នៅតាមបណ្តាគ្រឹះស្ថានសុខភាពសាធារណៈនានា មិនបានគិតថ្លៃឡើយ ប៉ុន្តែក្រោយមកអ្នកជម្ងឺទាំងអស់ត្រូវតែបង់ថ្លៃ លើកលែងតែអ្នកក្រីក្រខ្លាំងប៉ុណ្ណោះ ។ កំណែទម្រង់ បានបង្កើតជាបញ្ហាខ្លះ ដូចជាគ្រួសារក្រីក្រមួយចំនួនមិនមានលទ្ធភាពក្នុងការប្រើប្រាស់សេវា ។ ដូច្នេះ ដើម្បីជួយឱ្យគ្រួសារក្រីក្រអាចទទួលបានសេវាថែទាំសុខភាពនៅតាមមូលដ្ឋានសុខាភិបាលសាធារណៈនោះ គម្រោងមួយចំនួនត្រូវបានដាក់អនុវត្តដោយមានការជួយឧបត្ថម្ភពីដៃគូអភិវឌ្ឍន៍ ។ គម្រោងទាំងនេះ រួមមាន មូលនិធិសមធម៌សុខភាព ការធានារ៉ាប់រងសុខភាពសហគមន៍ និង ប័ណ្ណធានាសុខភាព ។ គម្រោងផ្តល់ប័ណ្ណធានាសុខភាព ជាចំណែកមួយនៃមូលនិធិសមធម៌សុខភាព និងបានដាក់អនុវត្តសាកល្បងនៅស្រុកប្រតិបត្តិបី នៅចុងឆ្នាំ២០០៧ ហើយការធានារ៉ាប់រងសុខភាពសហគមន៍ និងមូលនិធិសមធម៌ បានដាក់អនុវត្តនៅឆ្នាំ១៩៩៨ និង ២០០០ ។

ដូចនៅបណ្តាប្រទេសក្រីក្រដទៃទៀតដែរ ការថែទាំសុខភាពនៅកម្ពុជាពឹងផ្អែកជាសំខាន់លើការចំណាយប្រាក់ហោប៉ៅផ្ទាល់ ។ នៅឆ្នាំ២០០៥ ចំណាយប្រាក់ហោប៉ៅផ្ទាល់ មាន ៦៨% នៃចំណាយសរុបលើសុខភាព ដែលជាអត្រាមួយខ្ពស់ បើធៀបនឹងប្រទេសជិតខាង ដូចជា ប្រទេសវៀតណាម (៦៣,៩៧%) និង ថៃ (២៧,៦៥%)[២] ។

ប្រសិនបើការបង់ប្រាក់មានកម្រិតខ្ពស់ដល់ចំណុចមួយដែលប្រជាជនមិនអាចបង់បាន វាក្លាយជាឧបសគ្គរារាំងប្រជាជនក្នុងការទទួលបានសេវាថែទាំសុខភាព ហើយអាចរុញច្រានឱ្យប្រជាជនជួបហានិភ័យហិរញ្ញវត្ថុធ្ងន់ធ្ងរ និងធ្លាក់ខ្លួនក្របាន ។ ផ្អែកលើគោលការណ៍សមធម៌ និង ដើម្បីឱ្យមនុស្សគ្រប់គ្នាទទួលបានការថែទាំសុខភាពនោះ ចំណាយមហន្តរាយលើការថែទាំសុខភាព គួរតែបញ្ចៀសឲ្យបាន ។ ចំណាយមហន្តរាយ មិនត្រឹមតែធ្វើឱ្យប្រជាជនដែលមិនមានលទ្ធភាពបង់ចំណាយលើការថែទាំសុខភាព ត្រូវទទួលរងការខាតបង់ផ្ទាល់ខ្លួនយ៉ាងធំធេងប៉ុណ្ណោះទេ ប៉ុន្តែថែមទាំងប៉ះពាល់ដល់ស្ថានភាពសេដ្ឋកិច្ចជាតិផងដែរ ដូចជា អវត្តមានកម្លាំងពលកម្ម ការបាត់បង់ផលិតភាព និងការបាត់បង់ប្រាក់ចំណូល ។ នៅប្រទេសផ្សេងទៀត ដូចជា ឥណ្ឌូនេស៊ី ជាដើម កំហាតបង់សេដ្ឋកិច្ចមានទំហំយ៉ាងធំធេង ដោយសារប្រជាជនមានជម្ងឺធ្ងន់ៗ ។ ដូចនេះ ចំណាយមហន្តរាយ វារាំងស្ទះដល់សុខុមាលភាពគ្រួសារ ជាពិសេសសម្ភារៈចាំបាច់សម្រាប់ជីវភាពរស់នៅប្រចាំថ្ងៃ ។ ប៉ុន្តែវាធ្វើឲ្យរាំងស្ទះដល់សុខុមាលភាព និងរុញច្រានប្រជាជនឱ្យធ្លាក់ខ្លួនក្រធ្ងន់ធ្ងរ

---

១ លោក នេត នាថ ជាអ្នកស្រាវជ្រាវ នៅវិទ្យាស្ថាន CDRI ។

២ ព្យាករណ៍ផ្អែកលើទិន្នន័យបានពីរបាយការណ៍ស្ថិតិសុខភាពពិភពលោកឆ្នាំ២០០៨ របស់អង្គការសុខភាពពិភពលោក ស្តីពី ចំណាយឯកជនលើសុខភាព គិតជាភាគរយនៃចំណាយសរុបលើសុខភាព និង ចំណាយប្រាក់ហោប៉ៅ គិតជាភាគរយនៃចំណាយឯកជន ។

ត្រឹមកម្រិតណានោះ វាអាស្រ័យទៅលើអត្រា (incidence) និងភាពធ្ងន់ធ្ងរ (intensity) នៃការចំណាយ ។ អត្ថបទនេះមានគោលបំណង ៣ ៖ ទី១ វាយតម្លៃអំពីអត្រា និងភាពធ្ងន់ធ្ងរនៃការចំណាយមហន្តរាយលើការថែទាំសុខភាព ។ ទី២ ពិនិត្យពីរបាយ និងភាពធ្ងន់ធ្ងរ នៃចំណាយមហន្តរាយលើការថែទាំសុខភាព និង ទី៣ វាស់វែងពីរបាយនៃកម្រិតបម្រែបម្រួលនៃចំណាយនេះ ។

## ២. ទស្សនទាន

### *២.១. និយមន័យ*

ចំណាយមហន្តរាយ មានន័យថា ការចំណាយប្រាក់ហោប៉ៅរបស់គ្រួសារលើការថែទាំសុខភាពដែលលើសពីកម្រិតសន្មតមួយនៃធនធាន ដែលមានដូចជា ប្រាក់ចំណូល ឬចំណាយប្រចាំឆ្នាំក្នុងគ្រួសារ ។ ជាទូទៅអ្នកស្រាវជ្រាវជាច្រើនបានសន្មតថា ប្រសិនបើចំណាយលើការថែទាំសុខភាពលើស ១០% នៃចំណាយក្នុងគ្រួសារសរុបនោះ គេចាត់ទុកថាជាចំណាយមហន្តរាយ ។ ប៉ុន្តែយើងក៏ធ្វើអង្កេតលើចំណាយប្រាក់ហោប៉ៅរបស់គ្រួសារ ស្មើនឹង ៥% ១០% ១៥% ២៥% ៤០% នៃចំណាយសរុបរបស់គ្រួសារផងដែរ ។

### *២.២. ការវាស់វែងពីអត្រា និងភាពធ្ងន់ធ្ងរនៃការចំណាយមហន្តរាយ*

អត្រានៃចំណាយមហន្តរាយ ជាសមាមាត្រនៃចំនួនអ្នកដែលបានចំណាយលើការថែទាំសុខភាពលើសពី ១០% នៃចំណាយសរុបរបស់គ្រួសារ ធៀបនឹងចំនួនមនុស្សទាំងអស់ដែលបានចំណាយលើការថែទាំសុខភាព (H) ។ កាលណាសមាមាត្រនៃការចំណាយលើការព្យាបាលធៀបនឹងចំណាយសរុប វាលើសពីកម្រិតរបត់នោះ គេហៅថា ចំណាយហួសកម្រិតរបត់ (O) ។ ភាពធ្ងន់ធ្ងរនៃចំណាយមហន្តរាយ ត្រូវវាស់វែងដោយរូបមន្ត ចំណាយហួសកម្រិតរបត់វិជ្ជមានមធ្យម (Mean Positive Overshoot) ៖ MPO = $\frac{O}{H}$ ។

### *២.៣. របាយ - វាស់កម្រិតបម្រែបម្រួល*

ដើម្បីបញ្ជាក់ថា ចំណាយមហន្តរាយធ្វើឡើងជាចំបងដោយអ្នកក្រ ឬអ្នកធូធារ គេក៏បង្កើតសន្ទស្សន៍ប្រមូលផ្តុំ (Concentration Index)[៣] ឡើង សម្រាប់ប្រើជាមួយអត្រានៃអ្នកចំណាយមហន្តរាយ (headcounts) និងចំណាយហួសកម្រិតរបត់ (overshoot) ។ ប៉ុន្តែកម្រិតធ្ងន់ធ្ងរនៃចំណាយមហន្តរាយរបស់អ្នកក្រ ប្រហែលមិនដូចគ្នានឹងអ្នកធូរធារទេ ដូច្នេះ គេត្រូវធ្វើការថ្លឹងថ្លែងឡើងវិញ ដើម្បីកែតម្រូវចំណាយមហន្តរាយ ក្នុងបំណងសិក្សាលើគ្រួសារទាំងអស់ឲ្យស្មើភាពគ្នាដោយមិនគិតថាជាគ្រួសារក្រីក្រ ឬគ្រួសារធូធារទេ ។ Wagstaff និង van Dooslaer (2003) បានស្នើការកែតម្រូវលើការគណនាអត្រានៃអ្នកចំណាយមហន្តរាយ (weighted headcount) និងនៃអ្នកចំណាយហួសកម្រិតរបត់ (weighted overshoot) តាមរយៈរូបមន្ត៖ Hw= H(1- CE) ដែលក្នុងនេះ CE ជាសន្ទស្សន៍ប្រមូលផ្តុំសម្រាប់ចំនួនមនុស្ស និង Ow = O(1- CO) ដែលក្នុងនេះ CO ជាសន្ទស្សន៍ប្រមូលផ្តុំសម្រាប់ចំណាយហួសកម្រិតរបត់ ។ ក្នុងវិធីនេះ គេតែងដាក់ពិន្ទុច្រើនបន្តិចឲ្យអ្នកក្រ និងដាក់ពិន្ទុតិចបន្តិចឲ្យអ្នកធូរធារ ។

---

៣ សន្ទស្សន៍ប្រមូលផ្តុំ (concentration index) វាស់វែងពីទំហំ វិសមភាពនៃអថេរសុខភាព និងមានតម្លៃនៅចន្លោះរវាង -១ និង ១ ។ តម្លៃវិជ្ជមានបង្ហាញថា អថេរសុខភាពប្រមូលផ្តុំច្រើនហួសកម្រិតទៅលើអ្នកធូរធារ ។

## ៣. វិធីសាស្ត្រនៃការសិក្សា

ការសិក្សានេះ ប្រើប្រាស់ទិន្នន័យនៃអង្កេតសេដ្ឋកិច្ច-សង្គមកិច្ចកម្ពុជា (CSES) ឆ្នាំ២០០៧ ដែលសិក្សាអង្កេតលើ ៣៥៩៣គ្រួសារ ក្នុងនោះមានមនុស្សសរុប ១៧.៤៣៩នាក់ និងបានជ្រើសចេញពី ៣៧ទីតាំង នៅ ២តំបន់ (ទីក្រុង និងជនបទ) ក្នុង ២១ខេត្ត នៅកម្ពុជា[៤] ។ ការកំណត់ទម្ងន់ឲ្យគំរូតាង (sampling weight) បានកែតម្រូវ ដោយផ្អែកលើជំរឿនប្រជាសាស្ត្រឆ្នាំ២០០៨ ទៅតាមទំហំ និងសមាសភាព នៃប្រជាជនកម្ពុជា ។ ការចំណាយក្នុងមនុស្សម្នាក់ និងការចំណាយប្រាក់ហោប៉ៅលើការថែទាំសុខភាពក្នុងមនុស្សម្នាក់ គឺជាអថេរពីរនៃការសិក្សានេះ ។ ការប្រើប្រាស់ទំនិញម្ហូបអាហារ និងមិនមែនម្ហូបអាហារ ត្រូវគិតសម្រាប់រយៈពេល១ឆ្នាំ ។ ចំណាយគ្រួសារត្រូវបានកែតម្រូវទៅតាមចំណាយគិតក្នុងមនុស្សពេញវ័យម្នាក់ (expenditure per equivalent adult) ។ ទំហំសមមូលរបស់មនុស្សពេញវ័យ គណនាដោយ eh = (Ah + 0.5Kh )0.75 ដែល Ah គឺជាចំនួនមនុស្សពេញវ័យនៅក្នុងគ្រួសារ h និង Kh គឺជាចំនួនកុមារ (អាយុ 0-14 ឆ្នាំ)[៥] នៅក្នុងគ្រួសារ h ។ កម្រិតរបត់ (threshold) គេកំណត់យក ៥% ១០% ១៥% និង ២៥% នៅពេលចំណាយលើម្ហូបអាហារ មិនបានដកចេញពីចំណាយសរុប និង ៥% ១០% ១៥% ២៥% និង ៤០% នៅពេលចំណាយលើម្ហូបអាហារ បានដកចេញពីចំណាយសរុប ។

ចំនួនមនុស្ស ចំណាយហួសកម្រិតរបត់វិជ្ជមានមធ្យម និង សន្ទស្សន៍ប្រមូលផ្តុំ (concentration index)[៦] អាចគណនាបានតាមវិធីដូចខាងលើ ។

## ៤. លទ្ធផល

ការសិក្សាបង្ហាញថា មានប្រជាជនរស់នៅជនបទច្រើនជាងអ្នកនៅទីក្រុង ដែលមានចំណាយមហន្តរាយលើការថែទាំសុខភាព និងចំណាយមហន្តរាយហួសកម្រិតរបត់ (catastrophic overshoot)[៧] ។ ប៉ុន្តែចំណាយហួសកម្រិតរបត់មធ្យម បង្ហាញថា ប្រជាជនរស់នៅទីក្រុងត្រូវប្រឈមនឹងចំណាយមហន្តរាយលើការថែទាំសុខភាព មានសភាពធ្ងន់ធ្ងរជាង ប្រជាជនរស់នៅជនបទ ។ អត្រានៃចំណាយមហន្តរាយ មានកម្រិតខ្ពស់បំផុតនៅខេត្តស្វាយរៀង និងទាបបំផុតនៅខេត្តកោះកុង ។ ខេត្តកំពត មានចំណាយហួសកម្រិតរបត់ខ្ពស់ជាងគេ ចំណែកឯខេត្តព្រះវិហារមានតិចជាងគេ ។ ចំណាយមហន្តរាយមានសភាពធ្ងន់ធ្ងរជាងគេ នៅខេត្តឧត្តរមានជ័យ និងធូរស្រាលជាងគេនៅខេត្តព្រះវិហារ ។

លទ្ធផលបានបង្ហាញបន្តទៀតថា មធ្យមនៃចំណាយហួសកម្រិតរបត់ និងមធ្យមនៃចំណាយហួសកម្រិតរបត់វិជ្ជមាន រវាងភេទទាំងពីរ មិនមានភាពខុសគ្នាទេ[៨] ប៉ុន្តែអត្រាអ្នកចំណាយហួសកម្រិតរវាងបុរស និង ស្ត្រី មិនដូចគ្នាទេ ។ ស្ត្រីទំនងជាមានចំណាយមហន្តរាយថែទាំសុខភាពច្រើនជាង

---

៤ ខេត្តមណ្ឌលគិរី រតនគិរី និង ប៉ៃលិន មិនស្ថិតនៅក្នុងអង្កេតនេះទេ ។

៥ តម្លៃប៉ារ៉ាម៉ែត្រ ត្រូវបានកំណត់ដោយផ្អែកលើ Deaton (1997, pp. 241-270) ។

៦ សន្ទស្សន៍នេះ គេប៉ាន់ស្មានតាម $ß = (1/r_i)[2\ \sigma^2_r(h_i/\mu)\ -\alpha-\varepsilon_i]$ ដែលក្នុងនោះ $\sigma^2_r$ គឺជាវ៉ារីយ៉ង់នៃចំណាត់ថ្នាក់ប្រភាគ (variance of the fractional rank) $r_i$ ជាចំណាត់ថ្នាក់ប្រភាគ (fractional rank) របស់បុគ្គល *i* ក្នុងរបាយនៃស្តង់ដាររស់នៅ (living standards distribution) $h_i$ ជាអថេរនៃចំណាយមហន្តរាយលើការថែទាំសុខភាព $\mu$ ជាមធ្យម (mean) នៃចំណាយនេះ និង $\varepsilon_i$ ជាលំអៀងចៃដន្យ (random error) នៃអថេរនៃចំណាយនេះ ដោយគេសន្មតថា លំអៀងនេះមានការបែងចែកដូចធម្មតា ។

៧ សមាមាត្រជាមធ្យមនៃចំណាយរបស់គ្រួសារលើការថែទាំសុខភាព គិតជាចំណែកនៃចំណាយសរុបរបស់គ្រួសារ ដែលលើសពីកម្រិតរបត់ (១០% នៃចំណាយសរុបក្នុងការសិក្សានេះ) ។

៨ តេស្តរបស់ Bonferroni បានយកមកប្រើ ដើម្បីបញ្ជាក់លើភាពខុសគ្នានៃមធ្យម(means) ។

បុរស ។ ជាមធ្យម ចំណាយលើការថែទាំសុខភាពរបស់គ្រួសារសម្រាប់នារី គឺ ៥៩.៣២៨,០១រៀល ស្មើនឹង ១៤,៤៤ដុល្លារក្នុងមួយនាក់ក្នុងមួយឆ្នាំ ហើយសម្រាប់បុរស គឺ ៤៣.២២១,៣៤រៀល ស្មើនឹង ១០,៥២ដុល្លារ ។ មធ្យមនៃចំណាយលើការថែទាំសុខភាពសម្រាប់មនុស្សទាំងពីរភេទ មានភាពខុសគ្នា[៩] ។ អត្រា និងភាពធ្ងន់ធ្ងរ នៃការចំណាយមហន្តរាយលើការថែទាំសុខភាព តែងកើនឡើងនៅពេលមនុស្សអាយុកាន់តែចាស់ ជាពិសេសចន្លោះពី ៥៨ឆ្នាំ និង ៦៤ឆ្នាំឡើងទៅ ។

សន្ទស្សន៍ប្រមូលផ្តុំ គណនាសម្រាប់ពិនិត្យ អត្រានៃអ្នកចំណាយមហន្តរាយ ចំណាយហួសកម្រិតរបត់ និង អត្រាអ្នកចំណាយមហន្តរាយកំណែតម្រូវ (rank weighted headcounts) និង ចំណាយហួសកម្រិតរបត់ (overshoots) បានកែតម្រូវសម្រាប់របាយនៃកម្រិតប្រែប្រួល ដោយមាន ឬមិនមានការដកចំណាយម្ហូបអាហារចេញពីចំណាយសរុប និងដោយគណនាសម្រាប់កម្រិតរបត់ ៥% ១០% ១៥% ២៥% និង ៤០% បង្ហាញថា អត្រានៃអ្នកចំណាយមហន្តរាយ និង ចំណាយហួសកម្រិតរបត់ ថយចុះ នៅពេលដែលកម្រិតរបត់ (threshold level) កើនឡើង ។ និន្នាការនេះក៏ឃើញមានដែរ សម្រាប់អត្រាអ្នកចំណាយមហន្តរាយកំណែតម្រូវ និង ចំណាយហួសកម្រិតរបត់កំណែតម្រូវ (adjusted headcount and adjusted overshoot) ។ ការថយចុះនៃអត្រាអ្នកចំណាយមហន្តរាយ មានទំហំធំជាងការកើនឡើងនៃកម្រិតរបត់នៃចំណាយ ។ ចំណុចនេះបង្ហាញថា គ្រួសារភាគច្រើន មិនមានលទ្ធភាពបង់ចំណាយថែទាំសុខភាពទេ នៅពេលតម្លៃសេវាកម្មសុខភាពមានការកើនឡើង ។

## ៥. ការពិភាក្សា

គ្រួសារជាច្រើននៅជនបទ មានធនធានតិចតួច និងបានចំណាយមួយភាគធំទៅលើម្ហូបអាហារ ដែលជាចំណែកដ៏ធំមួយនៃចំណាយសរុប បើធៀបនឹងគ្រួសាររស់នៅទីក្រុង ។ ដោយសារចំណាយប្រើប្រាស់ម្ហូបអាហារ ជាចំណែកមួយធំនៃចំណាយសរុប ដូច្នេះ គ្រួសារក្រីក្រនៅសល់ធនធានតិចណាស់ សម្រាប់ចំណាយលើការថែទាំសុខភាព ។ ករណីនេះ គេសង្កេតឃើញមានចំពោះគ្រួសាររស់នៅខេត្តព្រះវិហារ ផងដែរ ពីព្រោះខេត្តព្រះវិហារ ជាខេត្តមួយក្នុងចំណោមខេត្តមានអត្រាភាពក្រីក្រខ្ពស់ៗបំផុតនៅកម្ពុជា បើផ្អែកទៅតាមរបាយការណ៍របស់ ក្រសួងផែនការឆ្នាំ២០០៦ ។ គ្រួសារបានចំណាយធនធានភាគច្រើនទៅលើម្ហូបអាហារ ហើយរឿងនេះប្រហែលជាមូលហេតុនៃការពិតជាក់ស្តែង ដែលថ្លៃព្យាបាលមួយចំនួនធំ ត្រូវបានទូទាត់ដោយកម្មវិធីហិរញ្ញប្បទានសុខាភិបាល ដូចជា មូលនិធិសមធម៌ ឬគម្រោងផ្តល់ឧបត្ថម្ភធន ដែលមិនកត់ត្រានៅក្នុងអង្កេតសេដ្ឋកិច្ចសង្គមកិច្ចឆ្នាំ២០០៧ ។ គេអាចគិតថា កម្មវិធីហិរញ្ញប្បទានសុខាភិបាល ប្រហែលមានដំណើរការល្អក្នុងការជួយប្រជាជនក្រីក្រនៅខេត្តព្រះវិហារ ។ ចំណាយមហន្តរាយហួសកម្រិតរបត់ដែលគេពិនិត្យឃើញក្នុងខេត្តផ្សេងៗ អាចបង្ហាញថា កម្មវិធីហិរញ្ញប្បទានសុខាភិបាលក្នុងខេត្តទាំងនោះ គួរតែជម្រុញថែមទៀត ។ ខេត្តឧត្តរមានជ័យ មានការបង់ចំណាយមហន្តរាយលើការថែទាំសុខភាព មានភាពធ្ងន់ធ្ងរជាងគេ ទោះបីស្ថិតក្នុងចំណោមខេត្តដែលមានអត្រាភាពក្រីក្រខ្ពស់ៗបំផុតនៅកម្ពុជាក្តី ព្រោះគ្រួសារទាំងអស់ដែលបានជ្រើសរើសសម្រាប់ធ្វើអង្កេតសេដ្ឋកិច្ចសង្គមកិច្ចឆ្នាំ២០០៧ សុទ្ធតែរស់នៅតំបន់ទីក្រុង (ទីរួមខេត្ត) ដូច្នេះ ពួកគេមានលទ្ធភាពច្រើនក្នុងការរកបានប្រភពហិរញ្ញប្បទានផ្សេងៗ ដើម្បីចំណាយលើការព្យាបាល ។

ទោះបីភាពធ្ងន់ធ្ងរនៃការបង់ចំណាយមហន្តរាយលើការថែទាំសុខភាព មិនមានភាពខុសគ្នាជាលក្ខណៈស្ថិតិរវាងបុរស និងស្ត្រី ក្តី ប៉ុន្តែអត្រាចំណាយមហន្តរាយ មានការខុសគ្នាគួរឱ្យកត់សម្គាល់ ។ រឿងនេះ អាស្រ័យលើសភាពនៃការប្រើប្រាស់សេវាថែទាំសុខភាព និង ប្រភេទនៃសេវាសុខភាព

---

៩ មានការជាក់ទម្ងន់លើមនុស្ស ។

ដែលបុរស និងស្ត្រី បានប្រើប្រាស់ ។ ទិន្នន័យបង្ហាញថា ស្ត្រី ៦០% ជាអ្នកជម្ងឺមកព្យាបាលតែមិនបានសម្រាកដេកពេទ្យ ។ ក្នុងចំណោមអ្នកជម្ងឺដែលប្រើប្រាស់សេវាថែទាំសុខភាពឯកជន មាន ៦១% ជាស្ត្រី ហើយក្នុងចំណោមអ្នកជម្ងឺដែលមិនទទួលការព្យាបាលពីពេទ្យ (ប្រើប្រាស់វិស័យមិនមែនវេជ្ជសាស្ត្រ៖ non-medical sector) មាន ៥៩% ជាស្ត្រី ។ ស្ត្រីទំនងស្វែងរកការថែទាំសុខភាពច្រើនជាងបុរស ។ អត្រា និង ភាពធ្ងន់ធ្ងរនៃចំណាយមហន្តរាយលើការថែទាំសុខភាព ហាក់ដូចកើនឡើងនៅពេលមនុស្សមានអាយុកាន់តែច្រើន គឺចាប់ពី ៥៨ឆ្នាំ ឡើងទៅ ។ លទ្ធផលរកឃើញនេះមានលក្ខណៈស្រដៀងគ្នានឹងលទ្ធផលរបស់ Tin Tin Su *et al.* (2006) និង Tewarit and Lagrada (2009) ។ ទិន្នន័យបង្ហាញទៀតថា ក្រុមមនុស្សវ័យចំណាស់ (មានអាយុចន្លោះពី ៥៨ឆ្នាំ ទៅ ៩៦ឆ្នាំ) ទំនងត្រូវប្រឈមនឹងហានិភ័យនៃការឈឺថ្កាត់ខ្ពស់ជាងក្រុមមនុស្សវ័យក្មេងជាង (អាយុក្រោម ៥៨ឆ្នាំ) ជាពិសេស ជម្ងឺរ៉ាំរ៉ៃ ដូចជា ឈឺខ្នង ជម្ងឺត្រចៀក បំពង់កនិងច្រមុះ ទឹកនោមផ្អែម និង លើសឈាម ។ ដូច្នេះ គ្រួសារនៃក្រុមមនុស្សវ័យចំណាស់ ទំនងមានចំណាយលើការថែទាំសុខភាពខ្ពស់ជាងគ្រួសារនៃក្រុមមនុស្សវ័យក្មេង ។

សន្ទស្សន៍នៃការប្រមូលផ្តុំវិជ្ជមាន (positive concentration indices) សម្រាប់ពិនិត្យអត្រាអ្នកចំណាយមហន្តរាយ និងចំណាយហួសកម្រិតរបត់ នៅពេលដែលចំណាយប្រើប្រាស់ម្ហូបអាហារមិនបានដកចេញពីចំណាយសរុប បានបង្ហាញថា គ្រួសារធូរធារមាននិន្នាការទទួលបង់ចំណាយមហន្តរាយលើការថែទាំសុខភាពបានច្រើនជាង ដោយសារប្រាក់ចំណូលរបស់ពួកគេអាចបង្កើន ឬកាត់បន្ថយបានច្រើនក្នុងមុខចំណាយលើម្ហូបអាហារ ។ ប៉ុន្តែនៅពេលចំណាយលើម្ហូបអាហារត្រូវបានដកចេញពីចំណាយសរុប ពេលនោះ សន្ទស្សន៍ប្រមូលផ្តុំសម្រាប់ចំនួនមនុស្សប្រែជាអវិជ្ជមាននៅកម្រិតរបត់ ៥% ១០% ១៥% និង ២៥% ដែលបង្ហាញថា គ្រួសារភាគច្រើនមិនអាចបង់ថ្លៃចំណាយលើការថែទាំសុខភាពទេ ទោះបីជាចំណាយនោះ មានត្រឹម ១០% នៃចំណាយសរុបក្នុងគ្រួសារក្តី គឺបានន័យថា ប្រសិនបើអ្នកក្រចង់ទទួលបានការថែទាំសុខភាព ពួកគេត្រូវតែកាត់បន្ថយការប្រើប្រាស់ម្ហូបអាហារ ។

## ៦. សេចក្តីសន្និដ្ឋាន

កម្មវិធីហិរញ្ញប្បទានសុខាភិបាល ដូចជា មូលនិធិសមធម៌ ប្រព័ន្ធលើកលែងការបង់ថ្លៃប្រើប្រាស់សេវា (user fee exemption) ធានារ៉ាប់រងសុខភាពសហគមន៍ និងគម្រោងផ្តល់ប័ណ្ណធានាសុខភាព មានតួនាទីយ៉ាងសំខាន់ក្នុងការកាត់បន្ថយចំណាយលើការថែទាំសុខភាពរបស់គ្រួសារក្រីក្រនៅជនបទ ។ គ្រួសារទាំងនេះ ភាគច្រើនរស់នៅក្នុងខេត្តស្វាយរៀង កំពង់ឆ្នាំង កំពង់ធំ សៀមរាប កំពង់ចាម និង ព្រះវិហារ ។ គ្រួសារក្រីក្រនៅទីក្រុង និងទីប្រជុំជន ទំនងជួបចំណាយមហន្តរាយលើការថែទាំសុខភាពធ្ងន់ធ្ងរខ្លាំងជាងគ្រួសារក្រីក្រនៅជនបទ ។ គ្រួសារទាំងនេះ ភាគច្រើនរស់នៅខេត្តឧត្តរមានជ័យ កំពង់ស្ពឺ កំពត កោះកុង និង ព្រៃវែង ។ គ្រួសារនៃក្រុមមនុស្សវ័យចំណាស់ និងគ្រួសារមានសមាជិកស្ត្រីភេទ គួរតែទទួលបានការឧបត្ថម្ភច្រើនជាងពីកម្មវិធីផ្សេងៗ ព្រោះពួកគេទំនងត្រូវប្រឈមនឹងហានិភ័យនៃការបង់ចំណាយមហន្តរាយលើការថែទាំសុខភាព ខ្ពស់ជាងក្រុមឯទៀតៗ ។ គ្រួសារធូធារតែងមានចំណាយលើការថែទាំសុខភាពច្រើនជាងគ្រួសារក្រីក្រ ។ ទោះបីជាគ្រួសារធូរធារអាចបង់ចំណាយមហន្តរាយបែបនេះក្តី ក៏គួរតែមានអន្តរាគមន៍ ឬគោលនយោបាយសម្បទានលើការថែទាំសុខភាពខ្លះ ដើម្បីកាត់បន្ថយចំណាយដ៏ខ្ពស់លើសេវាថែទាំសុខភាព ។ បើមិនដូច្នោះទេ គ្រួសារដែលមិនអាចទ្រាំទ្រនឹងចំណាយខ្ពស់ក្នុងរយៈពេលវែងបាន នឹងត្រូវធ្លាក់ខ្លួនក្រជាមិនខាន ។

## ឯកសារយោង


Annear Peter Leslie (2006), Study of Financial Access to Health Services for the Poor in Cambodia, Phase 1: Scope, Design, and Data analysis, *Research Report for the Ministry of Health*, WHO, AusAID and RMIT University

Annear Peter Leslie, Maryam Bigdeli, Ros Chhun Eang & Bart Jacobs (2008), Providing Access to Health Services for the Poor: Health equity in Cambodia, *Health and Social Protection: Experiences from Cambodia, China and Lao PDR,* Studies in Health Services Organisation & Policy (Belgium: ITG Press)

Berki, S. E. (1986), "A Look at Catastrophic Medical Expenses and the Poor", *Health Affairs*, pp. 138-45

Bureau of Health Economics and Financing (2008), *Annual Health Financing Report 2007* (Phnom Penh: Department of Planning and Health Information, Ministry of Health)

Deaton, A. (1997), Analysis of Household Surveys, (Baltimore, Maryland: John Hopkins University Press)

Gertler, P., & J. Gruber (2002), Insuring Consumption against Illness, *American Economic Review 92*(1): 51-70

Ir Por, Dirk Horemans, Narin Souk & Wim Van Damme (2010), Using Targeted Vouchers and Health Equity Funds to Improve Access to Skilled Birth Attendants for Poor Women: A Case Study in Three Rural Districts in Cambodia, *BMC Pregnancy and Childbirth 2010*, 10:1

Limwattananon S., Tangcharoensathien V., and Prakongsai P. (2007), Catastrophic and Poverty Impacts of Health Payments: Results from National Household Surveys in Thailand, *Bulletin of the World Health Organisation* 2007, 85: 600-6

Ministry of Health (2005), *Health Strategic Plan 2008-2015* (Phnom Penh: RGC)

Ministry of Planning (2005), *National Strategic Development Plan 2009-2013*

Ministry of Planning (2006), *A Poverty Profile of Cambodia 2004* (Phnom Penh: RGC)

O'Donnell, Owen, Eddy van Doorslaer, Adam Wagstaff & Magnus Lindelow (2008), Health Care Payment and Poverty, Analysing Health Equity Using Household Survey Data, *A Guide to Techniques and their Implementation,* World Bank Institute, World Bank, pp. 213-219

Pradhan, M.,& N. Prescott (2002), Social Risk Management Options for Medical Care in Indonesia, *Health Economics* 11: 431-46

Ranson, M. K. (2002), Reduction of Catastrophic Health Care Expenditures by a Community-Based Health Insurance Scheme in Gujarat, India: Current Experiences and Challenges, *Bulletin of the World Health Organisation 80*(8): 613-21

Russell, S. (2004), the Economic Burden of Illness for Households in Developing Countries: A Review of Studies Focusing on Malaria, Tuberculosis, and Human Immunodeficiency Virus/Acquired Immunodeficiency Syndrome, *American Journal of Tropical Medicine and Hygiene* 71(Supp. 2): 147-55

Tewarit Somkotra & Leizel P. Lagrada (2009), Which Households Are at Risk of Catastrophic Health Spending: Experience in Thailand after Universal Coverage, *Health Affairs* 28, No. 3 (2009): 467-478

Tin Tin Su,Bocar Kouyate &, Steffen Flessa (2006), Catastrophic Household Expenditure for Health Care in a Low Income Society: A Study from Nouna District, Burkina Faso, *Bulletin of the World Health Organisation* 2006, 84:21-27

van Doorslaer, E., O. O'Donnell, R. P. Rannan-Eliya, A. Somanathan, C. G. Garg, D. Harbianto, A. N. Herrin, M. N. Huq, S. Ibragimova, A. Karan, C.W. Ng, B. R. Pande, R. Racelis, S. Tao, K. Tin, K. Tisayaticom, L. Trisnantoro, C. Vasavid, & Y. Zhao (2006), Effect of Payments for Health Care on Poverty Estimates in 11 Countries in Asia: An Analysis of Household Survey Data, *Lancet* 2006, 368: 1357-64

van Doorslaer, E., O. O'Donnell, R. P. Rannan-Eliya, A. Somanathan, S. R. Adhikari, B. Akkazieva, D. Harbianto, C. G. Garg, P. Hanvoravongchai, A. N. Herrin, M. N. Huq, S. Ibragimova, A. Karan, T.J. Lee, G. M. Leung, J. for the services F.R. Lu, C.W. Ng, B. R. Pande, R. Racelis, S. Tao, K. Tin, L. Trisnantoro, C. Vasavid, B.M. Yang &Y. Zhao (2007), Catastrophic Payments for Health Care in Asia, *Health Economics* (in press)

Wagstaff, A., & E. van Doorslaer (2003), Catastrophe and Impoverishment in Paying for Health Care: Applications to Vietnam 1993-98, *Health Economics* 12: 921-34

World Health Organisation (2000), *World Health Report 2000* (Geneva, Switzerland: WHO)

World Health Organisation (2008), *World Health Statistics 2008* (Washington, DC: WHO)

Wyszewianski, L. (1986), "Financially Catastrophic and High Cost Cases: Definitions, Distinctions and Their Implications for Policy Formulation", *Inquiry* 23(4): 382-94

Xu, K., D. E. Evans, K. Kawabate, R. Zeramdini, J. Klavus,& C. J. L. Murray (2003), "Household Catastrophic Health Expenditure: A Multi-country Analysis", *Lancet* 362: 111-17

# បញ្ជីឯកសារបោះពុម្ពផ្សាយរបស់វិទ្យាស្ថាន CDRI

១. Kannan,K.P. (វិច្ឆិកា ១៩៩៥) *ការកសាងសន្ទស្សន៍ថ្លៃទំនិញប្រើប្រាស់សំរាប់ប្រទេសកម្ពុជា៖ ការពិនិត្យឡើងវិញលើការអនុវត្តន៍នាពេលបច្ចុប្បន្ន និងការលើកមតិកែលំអ* (ឯកសារពិភាក្សាលេខ ១) ។

២. McAndrew, John P. (មករា ១៩៩៦) *ជំនួយហូរចូលជំនួយស្រពិចស្រពិល៖ ជំនួយសង្គ្រោះ និងអភិវឌ្ឍន៍ទ្វេ និងពហុភាគី ១៩៩២-៩៥* (ឯកសារពិភាក្សាលេខ ២) ។

៣. Kannan, K. P. (មករា ១៩៩៧) *កំណែទំរង់សេដ្ឋកិច្ច កំណែតម្រូវរចនាសម្ព័ន្ធនិងការអភិវឌ្ឍន៍កម្ពុជា* (ឯកសារពិភាក្សាលេខ ៣) ។

៤. ជឹម-ចរិយា ស្រ៊ុន-ពិធូ សូ-សុវណ្ណារិទ្ធ ចន-ម៉ាកឃិនឌ្ស ងួន-សុគន្ធា ប៉ុន-ដូរីណា និងរ៉ូប៊ីន-ប៊ិដឹលវ៍ (មិថុនា ១៩៩៨) *ការរៀនសូត្រពីកម្មវិធីអភិវឌ្ឍន៍ជនបទក្នុងប្រទេសកម្ពុជា* (ឯកសារពិភាក្សាលេខ ៤) ជាភាសាខ្មែរ តម្លៃ ៩.០០០រៀល ។

៥. Toshiyasu-Kato ច័ន្ទ-សុផល និង ឡុង-វូ-ពិសិដ្ឋ (កញ្ញា ១៩៩៨) *សមាហរណកម្មសេដ្ឋកិច្ចតំបន់សំរាប់ការ អភិវឌ្ឍន៍ជានិរន្តរ៍ក្នុងប្រទេសកម្ពុជា* (ឯកសារពិភាក្សាលេខ ៥) ជាភាសាខ្មែរ តម្លៃ ៩.០០០រៀល ។

៦. Murshid, K. A. S. (ធ្នូ ១៩៩៨) *សន្តិសុខស្បៀងនៅក្នុងសេដ្ឋកិច្ចអន្តរៈអាស៊ី៖ បទពិសោធន៍កម្ពុជា* (ឯកសារពិភាក្សាលេខ ៦) ជាភាសាខ្មែរ តម្លៃ ៧.៥០០រៀល ។

៧. McAndrew, John P. (ធ្នូ ១៩៩៨) *ការពឹងពាក់គ្នាទៅវិញទៅមកក្នុងយុទ្ធសាស្ត្រចិញ្ចឹមជីវិតគ្រួសារនៅក្នុង ភូមិខ្មែរពីរ* (ឯកសារពិភាក្សាលេខ ៧) ជាភាសាខ្មែរ តម្លៃ ៧.៥០០រៀល ។

៨. ច័ន្ទ-សុផល Martin-Godfrey, Toshiyasu-Kato, ឡុង-វូ-ពិសិដ្ឋ Nina-Orlova, Per-Ronnås ទា-សារ៉ាវ (មករា ១៩៩៩) *ប្រទេសកម្ពុជា៖ បញ្ហាប្រឈមមុខនៃការបង្កើតការងារដែលមានផលិតភាព* (ឯកសារពិភាក្សាលេខ ៨) ជាភាសាខ្មែរ តម្លៃ ៦.០០០រៀល ។

៩. តេង-យូគី ប៉ុន-ដូរីណា សូ-សុវណ្ណារិទ្ធ និង ចន-ម៉ាកឃិនRDU (មេសា ១៩៩៩) *បទពិសោធន៍របស់សកម្មភាព សហគមន៍ដើម្បីអភិវឌ្ឍន៍សង្គមនៃអង្គការយូនីសេហ្វ* (ឯកសារពិភាក្សាលេខ ៩) ជាភាសាខ្មែរ តម្លៃ ៤.៥០០រៀល ។

១០. Gormna, Siobham, ជាមួយ ប៉ុន-ដូរីណា និង សុខ-ខេង (មិថុនា ១៩៩៩) *បញ្ហាតួនាទីបុរស-ស្ត្រី និងការ អភិវឌ្ឍន៍នៅប្រទេសកម្ពុជា៖ ការពិនិត្យមើលជាទូទៅ* (ឯកសារពិភាក្សាលេខ១០) ជាភាសាខ្មែរ តម្លៃ ៤.៥០០រៀល ។

១១. ច័ន្ទ-សុផល និង សូ-សុវណ្ណារិទ្ធ (មិថុនា ១៩៩៩) *ចំណាកពលកម្មកម្ពុជាទៅប្រទេសថៃ៖ ការប៉ាន់ស្មានជំហានដំបូង* (ឯកសារពិគ្រោះលេខ ១១) ជាភាសាខ្មែរ តម្លៃ ៣.០០០រៀល ។

១២. ច័ន្ទ-សុផល Toshiyasu Kato ឡុង-វូពិសិដ្ឋ ទា-សារ៉ាវ សូ-សុវណ្ណារិទ្ធ ហង់-ជួនណារ៉ុន កៅ-គឹមហួន និង ជា-វុធណា (តុលា ១៩៩៩) *ផលប៉ះពាល់នៃវិបត្តិហិរញ្ញវត្ថុអាស៊ីលើសេដ្ឋកិច្ចអន្តរកាលនៅបណ្តាប្រទេស អាស៊ីអគ្នេយ៍៖ ទស្សនៈកម្ពុជា* (ឯកសារពិគ្រោះលេខ ១២) ជាភាសាខ្មែរ តម្លៃ ៤.៥០០រៀល ។

១៣. អ៊ុង-ប៊ុនឡេង (សីហា ២០០០) *ការប្រែប្រួលតាមរដូវកាលនៃសន្ទស្សន៍ថ្លៃទំនិញប្រើប្រាស់នៅក្នុងប្រទេសកម្ពុជា* (ឯកសារពិភាក្សាលេខ ១៣) ជាភាសាខ្មែរ តម្លៃ ៣.០០០រៀល ។

១៤. Toshiyasu-Kato, Jeffrey A. Kaplan, ច័ន្ទ-សុផល និង វៀល-សុភាព (សីហា ២០០០) *ប្រទេសកម្ពុជា៖ លើកកំពស់អភិបាលកិច្ចសំរាប់ការអភិវឌ្ឍន៍មាននិរន្តរភាព* (ឯកសារពិភាក្សា លេខ ១៤) ជាភាសាខ្មែរ តម្លៃ ៣.០០០រៀល ។

១៥. Toshiyasu Kato ច័ន្ទ-សុផល Jeffrey A. Kaplan, (សីហា ២០០០) *ជំនួយបច្ចេកទេស និងការអភិវឌ្ឍន៍ សមត្ថភាពនៅក្នុងសេដ្ឋកិច្ចមួយដែលពឹងផ្អែកលើជំនួយ៖ បទពិសោធន៍កម្ពុជា* (ឯកសារពិភាក្សាលេខ ១៥) ជាភាសាខ្មែរ តម្លៃ ១០.០០០រៀល ។

១៦. ស៊ិក បូរ័ក្ស (ធ្នូ ២០០០) *កម្មសិទ្ធិ ការលក់ដូរ និងការប្រមូលផ្តុំដីធ្លីនៅកម្ពុជា៖ ការពិនិត្យវិភាគដោយគ្រួសៗនូវទិន្នន័យទីពីរ និងទិន្នន័យដើម ដែលបានមកពីអង្កេតថ្មីៗចំនួនបួន* (ឯកសារពិភាក្សាលេខ ១៦) ជាភាសាខ្មែរ តម្លៃ ៨.០០០រៀល ។

១៧. ច័ន្ទ-សុផល សូ-សុវណ្ណារិទ្ធ និងប៊ុន-ដូរីណា (មិថុនា ២០០១) *ជំនួយបច្ចេកទេស និងការអភិវឌ្ឍន៍សមត្ថភាព នៅសាលាកសិកម្មព្រែកលៀប* (ឯកសារពិភាក្សាលេខ ១៧) ជាភាសាខ្មែរ តម្លៃ ៧.០០០រៀល ។

១៨. Martin Godfrey, សូ-សុវណ្ណារិទ្ធ ទេព-សា៉រាវី ប៉ុន-ដូរីណា Claude-Katz, Sarthi-Acharya, ស៊ីសុវត្ថិ-ឌួង-ចាន់តូ និងហ៊ីង ថូរ៉ាក់ស៊ី (តុលា ២០០១) *ការសិក្សាអំពីទីផ្សារពលកម្មនៅកម្ពុជា៖ ការកាត់បន្ថយភាពក្រីក្រ ការលូតលាស់ និងការកែតំរូវចំពោះវិបត្តិ* (ឯកសារពិភាក្សាលេខ១៨) ជាភាសាខ្មែរ តម្លៃ ៨.០០០រៀល ។

១៩. ច័ន្ទ-សុផល ទេព-សា៉រាវី និង Sarthi Acharya, (ធ្នូ ២០០១) *ការកាន់កាប់ដីនៅកម្ពុជា៖ ការវិភាគលើទិន្នន័យចុងក្រោយ* (ឯកសារពិភាក្សាលេខ ១៩) ជាភាសាខ្មែរ តម្លៃ ៨.០០០រៀល ។

២០. សូ-សុវណ្ណារិទ្ធ វៀល-សុភាព អ៊ុច-ឧទេយ្យ ស៊ី-រត្នមុនី, Brett Ballard និង Sarthi Acharya (មីនា ២០០២) *ការវាយតំលៃសង្គមពាក់ព័ន្ធនឹងដីធ្លីនៅកម្ពុជា* (ឯកសារពិភាក្សាលេខ ២០) ជាភាសាខ្មែរ តម្លៃ ៨.០០០រៀល ។

២១. Bhargavi Ramamurthy ស៊ិក-បូរ័ក្ស, Per Ronnås និង សុក-ហាច (មីនា ២០០២) ប្រទេសកម្ពុជាឆ្នាំ១៩៩៩-២០០០៖ *ការផ្តោតលើបញ្ហាដីធ្លី កំលាំងពលកម្ម និងការចិញ្ចឹមជីវិតនៅជនបទ* (ឯកសារពិភាក្សាលេខ ២១)តម្លៃ ៨.០០០រៀល ។

២២. ច័ន្ទ-សុផល និង Sarthi Acharya (កក្កដា ២០០២) *ការលក់ដូរដីធ្លីនៅកម្ពុជា៖ ការវិភាគទិន្នន័យនៃការផ្ទេរ និងការលក់ដូរដីធ្លី* (ឯកសារពិភាក្សាលេខ ២២) ជាភាសាខ្មែរ តម្លៃ ៨.០០០រៀល ។

២៣. Bruce McKenney និង ព្រុំ-តុលា (កញ្ញា ២០០២) *ធនធានធម្មជាតិ និងជីវភាពនៅតាមជនបទក្នុងប្រទេសកម្ពុជា៖ ការវាយតំលៃជាមូលដ្ឋាន* (ឯកសារពិភាក្សាលេខ ២៣) ជាភាសាខ្មែរ តម្លៃ ១០.០០០រៀល ជាអង់គ្លេស ១០.០០ដុល្លារ ។

២៤. ច័ន្ទ-សុផល គឹម-សេតារា និង Sarthi Acharya (ធ្នូ ២០០២) *ដីធ្លី ជីវភាពជនបទ និងសន្តិសុខស្បៀងនៅកម្ពុជា៖ ទស្សនៈបានពីអង្កេតតាមមូលដ្ឋាន* (ឯកសារពិភាក្សាលេខ ២៤) ជាភាសាខ្មែរ តម្លៃ ៦.០០០រៀល ជាអង់គ្លេស តម្លៃ ៧.០០ដុល្លារ ។

២៥. ច័ន្ទ-សុផល និង Sarthi Acharya (ធ្នូ ២០០២) *បញ្ហាប្រឈមចំពោះការចិញ្ចឹមជីវិតនៅជនបទ៖ ការសិក្សា លើភូមិចំនួន ៩ នៅកម្ពុជា* (ឯកសារពិភាក្សា លេខ២៥) ជាភាសាខ្មែរ តម្លៃ ៨.០០០រៀល ជាភាសាអង់គ្លេស តម្លៃ ១០.០០ដុល្លារ ។

២៦. Sarthi Acharya គឹម-សេតារា ចាប-សុថារិទ្ធ និង មាច-យ៉ាឌី (កញ្ញា ២០០៣) *ការងារក្រៅកសិដ្ឋាន និងការងារមិនមែនកសិកម្ម៖ ទស្សនៈស្តីពីការបង្កើតការងារនៅកម្ពុជា* (ឯកសារពិភាក្សាលេខ២៦) ជាភាសាខ្មែរ តម្លៃ ៧.០០០រៀល ជាភាសាអង់គ្លេស តម្លៃ ៥,០០ដុល្លារ ។

២៧. យឹម-ជា និង Bruce McKenney (ធ្នូ ២០០៣) *ការនាំចេញត្រីពីបឹងទន្លេសាបទៅប្រទេសថៃ៖ ការវិភាគលើការរាំងស្ទះពាណិជ្ជកម្ម អភិបាលកិច្ច និងបរិយាកាសសំរាប់ការលូតលាស់* (ឯកសារពិភាក្សាលេខ២៧) ជាភាសា ខ្មែរ តម្លៃ ៧.០០០រៀល ជាភាសាអង់គ្លេស ១០,០០ដុល្លារ ។

២៨. ព្រុំ-តុលា និង Bruce McKenney (ធ្នូ ២០០៣) *ការធ្វើពាណិជ្ជកម្មផលព្រៃឈើនៅកម្ពុជា៖ ការប្រឈម ការគំរាមកំហែង និងឱកាសសំរាប់ពាណិជ្ជកម្មជ័រទឹក* (ឯកសារពិភាក្សាលេខ២៨) ជាភាសាខ្មែរ ៧.០០០រៀល ជាភាសាអង់គ្លេស ១០,០០ដុល្លារ ។

២៩. យឹម-ជា និង Bruce McKenney (វិច្ឆិកា ២០០៣) *ពាណិជ្ជកម្មត្រីក្នុងស្រុក៖ ករណីសិក្សានៃម៉ាឃីទីងត្រីពីបឹង ទន្លេសាបទៅក្រុងភ្នំពេញ* (ឯកសារពិភាក្សាលេខ២៩) ជាភាសាខ្មែរ ៥.០០០រៀល ជាភាសាអង់គ្លេស ៥,០០ដុល្លារ ។

៣០. Caroline Hughes និង គឹម-សេតារា (មិថុនា ២០០៤) *ការវិវត្តន៍នៃដំណើរការប្រជាធិបតេយ្យ និងការគ្រប់គ្រង ទំនាស់នៅកម្ពុជា៖ ការសិក្សាប្រៀបធៀបការបោះឆ្នោតបីលើកនៅកម្ពុជា* (ឯកសារពិភាក្សាលេខ ៣០) ជាភាសាខ្មែរ ១០.០០០រៀល ជាភាសាអង់គ្លេស ១៣,៥០ដុល្លារ ។

៣១. Robert Oberndorf (កក្កដា ២០០៤) *សុខដុមនីយកម្មច្បាប់ទាក់ទងនឹងដំណើរការវិមជ្ឈការនៅកម្ពុជា* (ឯកសារពិភាក្សាលេខ៣១) ជាភាសាខ្មែរ ៥.០០០រៀល ជាភាសាអង់គ្លេស ៦,៥០ដុល្លារ ។

៣២. K. A. S. Murshid និង ទួត-សុខផល្លី (ឧសភា ២០០៥) *សេដ្ឋកិច្ចឆ្លងកាត់ព្រំដែនរបស់ប្រទេសកម្ពុជា៖ ការសិក្សាជំហានដំបូង* (ឯកសារពិភាក្សាលេខ៣២) ជាភាសាខ្មែរ ៨.០០០រៀល ជាភាសាអង់គ្លេស ៥,០០ដុល្លារ ។

៣៣. Hansen, Kasper K. និង តុប-នេត (ធ្នូ ២០០៦) *Natural Forest Benefits and Economic Analysis of Natural Forest Conversion in Cambodia* (Working Paper No. 33)

៣៤. ប៉ក់-គឹមជឿន ហ៊ាង-វុទ្ធី អេង-នេត្រា អាន-សុវត្ថា គឹម-សេតារា, Jenney Knowles និង David Craig (មីនា ២០០៧) *Accountability and Neo-patrimonialism in Cambodia: A Critical Literature Review* (ឯកសារពិភាក្សាលេខ៣៤) ជាភាសាអង់គ្លេស ៦,០០ដុល្លារ ។

៣៥. គឹម-សេតារា និង Joakim Öjendal (ឧសភា ២០០៧) *Where Decentralisation Meets Democracy: Civil Society, Local Government, and Accountability in Cambodia* (ឯកសារពិភាក្សាលេខ៣៥) ជាភាសាអង់គ្លេស ៤,០០ដុល្លារ ។

៣៦. លឹម-សុវណ្ណារា (វិច្ឆិកា ២០០៧) *Youth Migration and Urbanistion in Cambodia* (ឯកសារពិភាក្សាលេខ ៣៦) ជាភាសាខ្មែរ ៦.០០០រៀល ជាភាសាអង់គ្លេស ៣,៥០ដុល្លារ ។

៣៧. Chem Phalla et al. (May 2008), *Framing Research on Water Resources Management and Governance in Cambodia: A Literature Review.*

៣៨. Pak Kimchoeun and David Craig, *Accountability and Public Expenditure Management in Decentralised Cambodia* (Working Paper No. 38)

៣៩. Horng Vuthy and David Craig, *Accountability and Planning in Decentralised Cambodia* (Working Paper No. 39)

៤០. Eng Netra and David Craig (forthcoming), *Accountability and Human Resource Management in Decentralised Cambodia* (Working Paper No. 40)

៤១. ហ៊ីង វុត្ថា និង Hossein Jalilian (មេសា ២០០៩) *ផលប៉ះពាល់នៃកិច្ចព្រមព្រៀងពាណិជ្ជកម្មសេរីអាស៊ាន-ចិន ចំពោះបរិស្ថាន នៅតាមបណ្តាប្រទេសក្នុងមហាអនុតំបន់មេគង្គ (ឯកសារពិភាក្សាលេខ ៤១)* ជាភាសាខ្មែរ តម្លៃ ៨.០០០រៀល ជាភាសាអង់គ្លេស តម្លៃ ៣,០០ដុល្លារ ។

៤២. Thon Vimealea, Ou Sivhuoch, Eng Netra and Ly Tem (October 2009), *Leadership in Local Politics of Cambodia: A Study of Leaders in Three Communes of Three Provinces.*

៤៣. ហ៊ីង វុត្ថា និង បណ្ឌិត ធន់ វឌ្ឍនា (ធ្នូ ២០០៩) *ពាណិជ្ជកម្មកសិកម្មក្នុងមហាអនុតំបន់មេគង្គ៖ ករណីដំឡូងឈើ និងកៅស៊ូ នៅកម្ពុជា* (ឯកសារពិភាក្សាលេខ ៤៣) ជាភាសាខ្មែរ តម្លៃ ៦.០០០រៀល ជាភាសាអង់គ្លេស ៣,០០ដុល្លារ ។

៤៤. ច័ន្ទ សុផល (ធ្នូ ២០០៩) *ផលប្រយោជន៍និងចំណាយនៃទេសន្តរប្រវេសន៍កំលាំងពលកម្មក្នុងមហាអនុតំបន់មេគង្គ៖ ករណីសិក្សានៅប្រទេសកម្ពុជា* ជាភាសាខ្មែរតម្លៃ ៨,០០០រៀល ជាភាសាអង់គ្លេស តម្លៃ ៣.០០ដុល្លារ ។

៤៥. CDRI Publication (December 2009), *Costs and Benefits of Cross-country Labour Migration in the GMS: Synthesis of the Case Studies in Thailand, Cambodia, Laos and Vietnam.*

៤៦. CDRI Publication (December 2009), *Agricultural Trade in the Greater Mekong Sub-region: Synthesis of the Case Studies on Cassava and Rubber Production and Trade in GMS Countries*

៤៧. Chea Chou (August 2010), *The Local Governance of Common Pool Resources: The Case of Irrigation Water in Cambodia*

៤៩. CDRI Publication (August 2010), *Empirical Evidence of Irrigation Management in the Tonle Sap Basin: Issues and Challenges*

៤៩. Chem Phalla and Someth Paradis (March 2011), *Use of Hydrological Knowledge and Community Participation for Improving Decision-making on Irrigation Water Allocation*

សង្ខេបរបាយការណ៍អភិវឌ្ឍន៍ប្រចាំឆ្នាំ២០១០-១១

លេខ ០៦


**វិទ្យាស្ថានបណ្តុះបណ្តាល និង ស្រាវជ្រាវដើម្បីអភិវឌ្ឍន៍កម្ពុជា**

☞ អគារលេខ ៥៦ ផ្លូវ៣១៥ ទួលគោក ភ្នំពេញ កម្ពុជា
✉ ប្រអប់សំបុត្រលេខ៦២២ ភ្នំពេញ កម្ពុជា
☎ (៨៥៥-២៣) ៨៨១-៣៨៤, ៨៨១-៧០១, ៨៨១-៩១៦, ៨៨៣-៦០៣, ០១២ ៨៦៧ ២៧៨
🖷 (៨៥៥-២៣) ៨៨០-៧៣៤
e-mail: cdri@wicam.com.kh
Website: http://www.cdri.org.kh







តំលៃ ៨.០០០ រៀល


9 789995 052416